សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ • ខែ មករា ឆ្នាំ 2015

# លីអាហូណា



## អែសរ៉ា និង ផ្លរ៉ា បែនសឹន ៖ បានរួមដៃគ្នានៅក្នុងកិច្ចការរបស់ព្រះអម្ចាស់ ទំព័រ 32

ការរៀនបង្រៀនដូចជាព្រះអង្គសង្គ្រោះបានបង្រៀន ទំព័រ 24

មនុស្សដ៏សំខាន់បំផុតនៅក្នុងជីវិតរបស់អ្នក ទំព័រ 56

ការលើកដៃជួយតែបន្តិចបន្តួច អាចធ្វើមានភាពខុសប្លែកដ៏ធំ ទំព័រ 64



*« អំបិលជារបស់ល្អ តែបើបាត់ជាតិប្រៃហើយ តើនឹងយកអ្វីធ្វើឲ្យប្រៃឡើងវិញបាន ? »*

លូកា 14:34

ខាងឆ្វេង ៖ ព្រឹកព្រលឹមក្នុងរដូវរងារនៅឆ្នេរសមុទ្រអ៊ីនហ្គេឌីនៃសមុទ្រស្លាប់ដោយមានអំបិលនៅផ្ទៃទឹក ។

# លីអាហូណា ខែ មករា ឆ្នាំ 2015



18

## សារលិខិត


4 **សារលិខិតគណៈប្រធានទីមួយ៖ ធ្វើតាមព្យាការី**
ដោយប្រធាន ថូម៉ាស អេស ម៉នសុន

7 **សារលិខិតបង្រៀនសួរសុខទុក្ខ៖ លក្ខណៈនៃព្រះយេស៊ូវគ្រីស្ទ ៖ បុត្រាដ៏ស្ដាប់បង្គាប់**


## អត្ថបទពិសេស។


18 **តើអ្នកនឹងជ្រើសយកអ្វី ?**
ដោយអែលឌើរ រ៉ាសុល អិម ណិលសុន
*នៅក្នុងជីវិតអ្នក ហ៊ុមព័ទ្ធទៅដោយជម្រើសផ្សេងៗ សូមប្រាកដថា អ្នកនឹងធ្វើការជ្រើសរើសមួយដ៏ត្រឹមត្រូវ ។*

24 **តើយើងគួរធ្វើជាគ្រូបង្រៀនប្រភេទណា ?**
ដោយគណៈប្រធានសាលាថ្ងៃអាទិត្យទូទៅ
*ព្រះអង្គសង្គ្រោះអាចបង្រៀនយើងបានយ៉ាងល្អបំផុត ស្ដីពីរបៀបបង្រៀនដំណឹងល្អទ្រង់ ។*

28 **ជំហូន្មានរបស់ព្យាការី និង ពរជ័យព្រះវិហារបរិសុទ្ធ**
ដោយអែលឌើរ កូអ៊ីឈី អ៊ែយ៉ាហ្គី
*កាលយើងធ្វើតាមព្យាការី ហើយផ្ដល់អាទិភាពដល់ការថ្វាយបង្គំក្នុងព្រះវិហារបរិសុទ្ធ នោះពរជ័យនានានឹងកើតមាននៅក្នុងជីវិតយើង ។*

32 **ផ្លរ៉ា និង ខ្ញុំ ៖ ដៃគូស្មើភាពក្នុងកិច្ចការរបស់ព្រះអម្ចាស់**
ដោយ អើរ៉ុន អិល វ៉ែស
*រៀនពីអាពាហ៍ពិពាហ៍ដែលពោរពេញដោយសេចក្ដីស្រឡាញ់ និង ការគាំទ្រ ដែល អ៊ែសរ៉ា ថាហ្វ ប៉ែនសឹន បានមានជាមួយនឹងភរិយាលោក ផ្លរ៉ា បានជួយដល់ប្រធានទី 13នៃសាសនាចក្រ ។*


## ផ្នែកទាំងឡាយ


8 **សៀវភៅកំណត់ចំណាំសន្និសីទខែ តុលា ឆ្នាំ 2014**

10 **យើងនិយាយអំពីព្រះគ្រីស្ទ៖ រយៈពេលមួយម៉ោងដើម្បីចាំយាមជាមួយនឹងទ្រង់**
ដោយ ម៉ារីស្សា ហ្គន់ស្សាឡេស អេស្តេចូ

12 **គេហដ្ឋាន និង ក្រុមគ្រួសាររបស់យើង៖ មាគ៌ាឆ្ពោះទៅរកគ្រួសារដ៏និរន្តរ**
ដោយ ហ្គាធ និង សេនឌី ហាំប្លីន

14 **ការពិចារណា៖ ហ្វូងសត្វអំពិលអំពែក**
ដោយ ដេវីឌ រ៉ាយ

15 **ការបម្រើនៅក្នុងសាសនាចក្រ៖ ជំឡូងមួយផ្លែសម្រាប់អ្នកគ្រូ**
ដោយ មិននី ឌលស្រាដ់

16 **ព័ត៌មានសាសនាចក្រ**

38 **សំឡេងពួកបរិសុទ្ធថ្ងៃចុងក្រោយ**

80 **លុះត្រាជួបទៀត៖ តើខ្ញុំអាចដឹងថា ព្រះអម្ចាស់បានអត់ទោសឲ្យខ្ញុំតាមរបៀបណា ?**
ដោយប្រធាន ហារ៉ូល ប៊ី លី


**នៅលើគម្រប**
ខាងមុខ ៖ រូបថតទទួលបានសិទ្ធិអនុញ្ញាតជាផ្លូវការពីបណ្ណាល័យប្រវត្តិសាស្ត្រសាសនាចក្រ ។ ខាងក្នុងគម្របខាងមុខ ៖ រូបថតដោយ ហ្គឡាដ ម៉ាស្ស ។

## យុវមជ្ឈិមវ័យ


42


42 **ប្រឹក្សារួមគ្នាជារឿយៗ ៖ ក្រុមប្រឹក្សាគ្រួសារសម្រាប់ភរិយា និងស្វាមី**
ដោយ នីកូល អេក
*របៀបចាប់ផ្ដើមធ្វើក្រុមប្រឹក្សាគ្រួសារប្រកបដោយអត្ថន័យ និង ភាពជោគជ័យ ។*

46 **ភាពក្លាហានដើម្បីរៀបការ**
ដោយ គ្រីស្ទាន ហ័គក្លាន់
*ខ្ញុំបានដឹងថា អាពាហ៍ពិពាហ៍គឺជាជំហានបន្ទាប់សម្រាប់ខ្ញុំ ប៉ុន្តែខ្ញុំចង់រង់ចាំរហូតដល់ព្រះអម្ចាស់មានបន្ទូលប្រាប់ខ្ញុំពីអ្វីដែលត្រូវធ្វើ ។*



50

## យុវវ័យ


48 **បាវចនាម៉្ងូឆលឆ្នាំ 2015**
ដោយគណៈប្រធានយុវនារី និង យុវជនទូទៅ
*បាវចនាម៉្ងូឆលសម្រាប់ឆ្នាំនេះ ជួយយើងឲ្យយល់ពីរបៀបដ៏ល្អបំផុតដើម្បីបម្រើដល់ព្រះវរបិតាសួគ៌ ។*

50 **មួយជំហានម្ដងៗ**
ដោយ ហិល្លរី អុលសិន
*យុវវ័យក្នុងប្រទេសអ៊ីតាលី បានចែកចាយពីរបៀបដែលពួកគេបម្រើព្រះដោយអស់ពីចិត្ត គំនិត កម្លាំង និង ពលំរបស់ពួកគេ ។*

53 **សូមបម្រើព្រះឲ្យអស់ពីចិត្ត គំនិត កម្លាំង និង ពលំរបស់អ្នក**
*តើអ្នកអនុវត្តបាវចនាម៉្ងូឆលសម្រាប់ឆ្នាំនេះតាមរបៀបណា ? នេះគឺជាគំនិតមួយចំនួន ។*

55 **ប័ណ្ណប្រកាស៖ ចាប់ផ្ដើម**

56 **ហេតុអ្វីបានជាព្រះយេស៊ូវគ្រីស្ទមានសារៈសំខាន់ចំពោះជីវិតខ្ញុំ ?**
*នេះជាហេតុផលទាំងប្រាំយ៉ាង ដែលព្រះអង្គសង្គ្រោះអាចជាអង្គដ៏សំខាន់បំផុតនៅក្នុងជីវិតរបស់អ្នក ។*

60 **របៀបសម្រេចគោលដៅអស់កល្បជានិច្ច**
ដោយ អែលឌើរ រ៉ូប៊ឺត ឌី ហែល
*គោលដៅទាំងបួននេះ នឹងនាំសេចក្ដីអំណរដល់អ្នក កាលអ្នកបំពេញបេសកកម្មរបស់អ្នកនៅលើផែនដីនេះ ។*

61 **របៀបដែលខ្ញុំដឹង: គ្រឹះនៃជីវិតខ្ញុំ**
ដោយ រ៉ូបើរតូ ប៉ាឆេកូ ព្រេតេល
*តើព្រះគ្រីស្ទនៅទ្វីបអាមេរិកមែនឬ ? ពួកអ្នកផ្សព្វផ្សាយសាសនាប្រហែលជាយល់ខុសហើយ ។*

62 **ទៅកាន់គោលដៅ**

63 **ការផ្ដល់អំណោយដ៏ល្អបំផុត**
ដោយ ម៉ារីឡា រ៉ូឌ្រីហ្គេស្ស
*តាមរយៈការធ្វើតាមដំបូន្មានរបស់ព្យាការី ខ្ញុំអាចផ្ដល់អំណោយមួយដ៏ល្អបំផុត ។*




***ចាំមើលថា តើអ្នកអាចរកឃើញរូបលីអាហូណា ដែលលាក់នៅក្នុងលេខនេះដែរឬទេ ។ តម្រុយ ៖ ស្វែងរកកៅអីមួយនៅលើរថយន្តក្រុង ។***

## កុមារ


72


64 **សូមហុចដៃជួយយើងផង !**
*ដូចគ្នានឹងកុមារទាំងនេះដែរ អ្នកអាចបង្ហាញថា អ្នកខ្វល់ខ្វាយដោយការស្វែងរកវិធីជួយដល់អ្នកដទៃ ។*

66 **ការសាកល្បងតម្រិះព្រះគម្ពីរក្នុងព្រះគម្ពីរសញ្ញាថ្មី**
*សកម្មភាពនេះនឹងជួយអ្នកឲ្យអានបទគម្ពីរមួយចំនួនក្នុងព្រះគម្ពីរសញ្ញាថ្មីនៅរាល់សប្ដាហ៍សម្រាប់ឆ្នាំនេះ ។*

69 **ការធ្វើអ្វីមួយដែលល្អសក្ដិសមនឹងពេលវេលាខ្ញុំ**
ដោយ ក្លេតុន ដមុលយូ
*ខ្ញុំមិនអាចទៅលេងនៅខាងក្រៅបានទេ ពីព្រោះអាកាសធាតុត្រជាក់ណាស់ តើមានអ្វីផ្សេងទៀតដែលខ្ញុំអាចធ្វើបាន ?*

70 **ទំព័ររបស់យើង**

71 **សាក្សីពិសេស៖ តើព្រះគម្ពីរអាចជួយខ្ញុំបានតាមរបៀបណា ?**
ដោយប្រធាន ប៊ិយដ៏ ឃេ ផាកកឺ

72 **គ្រឿងសឹកសម្ងាត់**
ដោយ ជេស្ស៊ីកា ឡាសិន
*អាយវី គឺជាក្មេងតូចជាងគេក្នុងថ្នាក់យើង — តើនាងអាចជួយយើងឲ្យឈ្នះបានយ៉ាងដូចម្ដេចទៅ ?*

74 **ពេលវេលាសម្រាប់ព្រះគម្ពីរ៖ ការធ្វើដំណើរមួយដើម្បីរៀនពីព្រះយេស៊ូវគ្រីស្ទ**

76 **រឿងដ៏សំខាន់បំផុតទាំង 10 យ៉ាងរបស់ អាប់ប៊ី**
ដោយ រ៉ូសម៉ារី អិម វិកស្សម
*តើគោលដៅដ៏សំខាន់បំផុតទាំង 10 នៅក្នុងជីវិតអ្នកគឺជាអ្វីទៅ ?*

77 **រូបភាពបទគម្ពីរក្នុងព្រះគម្ពីរសញ្ញាថ្មី៖ ព្រះយេស៊ូវកំពុងបង្រៀននៅក្នុងព្រះវិហារបរិសុទ្ធ**

78 **ការអធិស្ឋាននៅលើរថយន្តក្រុង**
ដោយ មិតស្សឺ ជីមេណេស្ស រ៉ាមិរេស្ស

**ខែ មករា ឆ្នាំ 2015 វ៉ុល 14 លេខ 1**
**លីអាហូណា 12561 258**
ទស្សនាវដ្ដីអន្តរជាតិរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

**គណៈប្រធានទីមួយ ៖** ថូម៉ាស អេស. ម៉នសុន, ហិនរី ប៊ី. អាវរិង, ឌៀថើរ អេហ្វ. អុជដូហ្វ

**កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖** បយដ៍ ខេ. ផាកកឺ, អិល. ថម ភែរី, រ័សុល អិម. ណិលសុន, ដាល្លិន អេក. អូក, អិម. រ័សុល បាឡឺដ, រីឆាដ ជី. ស្កត, រ៉ូបឺត ឌី. ហែល, ជែហ្វ្រី អ័រ. ហូឡិន, ដេវីឌ អេ. បែដណា, ឃ្វីនថិន អិល. ឃុក, ឌី ថត. គ្រីស្តូហ្វឺសិន, នែល អិល. អាន់ឌើរសិន

**អ្នកកែសម្រួល ៖** ក្រេក អេ. ខារដុន
**អ្នកប្រឹក្សា ៖** សមើរវីន ប៊ី អាណុល, ឡារី អ័រ ឡរ៉ារិន, ជេមស៍ ប៊ី ម៉ាទីណូ, យ៉ូសែប ដបុលយូ ស៊ីតាទី គ្រីស្តូហ្វែល ហ្គូលឌិន

**នាយកគ្រប់គ្រង ៖** ដេវីឌ ធី. វ៉ នើរ
**នាយកគាំទ្រគ្រួសារ និង សមាជិក ៖** វីនសេនត៍ អេ. វ៉ាញ
**នាយកទស្សនាវដ្ដីសាសនាចក្រ ៖** អាលែន អ័រ. ឡយប៊ិច
**អ្នកគ្រប់គ្រងពាណិជ្ជកម្ម ៖** ហ្គាស្វ ខាណុន

**អ្នកគ្រប់គ្រងផ្នែកកែសម្រួល ៖** អ័រ. វ៉ាល ចនសុន
**ជំនួយការអ្នកគ្រប់គ្រងផ្នែកកែសម្រួល ៖** រ៉ៃអិន ខារ
**ជំនួយការផ្នែកបោះពុម្ព ៖** លីស្សា ស៊ី ឡប៉េស្ស
**និពន្ធ និងកែសម្រួល ៖** ប្រ៊ីតថានី ប៊ីតធី, ដេវីដ ឌិកសុន, ដេវីដ អេ. អែដវ៉ដ, ម៉ាថាយ ឌី. ហ្វលិតតុន, ឡារី ហ្វលទ្បើរ ហ្គេរី អេច. ហ្គាហ្វ, ឡារិនេ ផតធើរ ហ្គូន, មីនឌី អាន់ ឡេវិត ម៉ៃឃើល អ័រ. ម៉ូរីស, សាលី ចនសុន អូឌេឃឺក, យ៉ូស្វេ ជេ ភឺគី, ជេន ភីនប៊ូរ៉ាហ្វ, រីឆាដ អិម. រ៉មនី, ប៉ុល វ៉ែនដិនប៊ើជ, ម៉ារីស្សា វីឌីសុន

**នាយកគ្រប់គ្រងផ្នែកសិល្បៈ ៖** ជេ. ស្កត នូដសិន
**នាយកផ្នែកសិល្បៈ ៖** ថាត អ័រ. ភីធើរសុន
**រចនាម៉ូត ៖** ជីនិត អាន់ទ្រូ, ហ្វេ ភី. អាន់ត្រូស, មែនឌី អឹម. ប៊ែនលី, ស៊ី. ឃីមបឺល បុត, ថូម៉ាស ឆាល, ណាត ហ្គីនេស, ខូលីន ហ៊ីងគ្លី, អេរិក ភី. ចនសិន, ស៊ូសាន ឡហ្វ្រីន, ស្កត អិម. ម៉ូយ, ម៉ាក ដបុលយូ. រ៉ូប៊ីសុន, ប្រាត ធៀរ, ឃេ. នីកូល វ៉កឃិនហ្វ៊ូស

**អ្នកសម្របសម្រួលកម្មសិទ្ធបញ្ញា ៖** ខូលែត នែបឃើ អាន
**អ្នកគ្រប់គ្រងផ្នែកផលិតកម្ម ៖** ជេន អាន ភិធើរស៍
**ផលិតកម្ម ៖** ខេវិន ស៊ី បេងស៍, ខននី ប៊ូស្រូប ប្រ៊ីជ, ជូលី បើដេត, ប្រាយអែន ដបុលយូ. ជីគី, ដេនីស តើបៃ, ជិន្នីស ឌីប៊ី, ជីន្នី ហ្គីននី ជេ. នីលសុន, ហ្គេលី ថេត វ៉ាហ្វើធី
**អ្នកពិនិត្យមុនការបោះពុម្ព ៖** ជេហ្វ អិល. ម៉ាទីន

**នាយកផ្នែកបោះពុម្ព ៖** ក្រេហ្គ ឌេ. សែតវីត
**នាយកផ្នែកចែកចាយ ៖** ស្តេហ្វិន អ័រ គ្រីស្ទិនសិន

ចំពោះការជាវ និង តម្លៃនៅខាងក្រៅសហរដ្ឋ និង កាណាដា សូមចូលទៅកាន់គេហទំព័រ store.lds.org ឬ សូមទាក់ទងមជ្ឈមណ្ឌលចែកចាយរបស់សាសនាចក្រក្នុងមូលដ្ឋានរបស់អ្នក ឬ ទាក់ទងអ្នកដឹកនាំវួដ ឬ សាខារបស់អ្នក ។

**សូមផ្ញើអត្ថបទ និងសំណួរទាំងឡាយ** តាមអ៊ិនធើរណិតនៅគេហទំព័រ liahona.lds.org តាមអ៊ីម៉ែលទៅកាន់ liahona@ldschurch.org ឬ តាមសំបុត្រទៅកាន់ Liahona, Rm. 2420, 50 E. North Temple St., Salt Lake City, UT 84150-0024, USA ។

*លីអាហូណា* ( ពាក្យក្នុងព្រះគម្ពីរមរមនមានន័យថា « ត្រីវិស័យ » ឬ « វត្ថុនាំផ្លូវ » ) ត្រូវបានបោះពុម្ពជាភាសា អាល់បានី, អាមេនី, ប៊ីស្លាមា, ប៊ុលហ្គារី, ខ្មែរ, សេប៊ូអាណូ, ចិន, ចិន ( ងាយស្រួល ), ក្រូអាត, ឆែក, ដាណាម៉ាក, ហូឡង់, អង់គ្លេស, អេស្តូអានី, ហ៊្វីជី, ហ្វាំងឡង់, បារាំង, អាល្លឺម៉ង់, ក្រិច, ហុងគ្រី, អាយឡែនឌិក, ឥណ្ឌូនេស៊ី, អ៊ីតាលី, ជប៉ុន, គីរីបាទី, កូរ៉េ, ឡាវៀន, លីទុយអានី, ម៉ាឡាហ្គាស៊ី, ម៉ាស្សែល, ម៉ុងហ្គោលី,នរវេ, ប៉ូឡូញ, ព័រទុយហ្គាល់, រ៉ូម៉ានី, រុស្ស៊ី, សាម័រ, ស្លូវ៉ានី, អេស្ប៉ាញ, ស្វាហ៊ីលី, ស៊ុយអែត, តាហ្គាឡុក, តាហ៊ីទី, ថៃ, តុងហ្គា, អ៊ុយក្រែន, អ៊ឺឌូ និង វៀតណាម ។ ( ការចេញញឹកញាប់ប៉ុន្មាន គឺប្រែប្រួលទៅតាមភាសា ) ។

© 2015 ដោយ Intellectual Reserve, Inc ។ រក្សាសិទ្ធិគ្រប់យ៉ាង ។ បោះពុម្ពនៅសហរដ្ឋអាមេរិក ។

អត្ថបទ និង សម្ភារដែលមើលឃើញ ដែលមាននៅក្នុង *លីអាហូណា* អាចថតចម្លងយកទៅប្រើប្រាស់ជាបន្ទាប់បន្សំ ដែលមិនមែនជាការធ្វើពាណិជ្ជកម្មតាមសាសនាចក្រ ឬ តាមគេហដ្ឋានឡើយ ។ សម្ភារដែលមើលឃើញ មិនអាចថតចម្លងបានឡើយ ប្រសិនបើមានដាក់បម្រាម ដែលបានចង្អុលបង្ហាញត្រង់បន្ទាត់សម្គាល់ ដែលនៅជាមួយនឹងរូបសិល្បៈ ។ សំណួរទាក់ទងនឹងការរក្សាសិទ្ធិ គួរតែសាកសួរទៅកាន់ Intellectual Property Office, 50 E. North Temple St., Salt Lake City, UT 84150, USA អ៊ីម៉ែល ៖ cor-intellectualproperty@ldschurch.org ។

**For Readers in the United States and Canada:**
January 2015 Vol. 14 No. 1. LIAHONA (USPS 311-480) Cambodian (ISSN 1538-4535) is published six times a year (January, April, June, July, October, and December) by The Church of Jesus Christ of Latter-day Saints, 50 E. North Temple St., Salt Lake City, UT 84150. USA subscription price is $5.00 per year; Canada, $6.00 plus applicable taxes. Periodicals Postage Paid at Salt Lake City, Utah. Sixty days' notice required for change of address. Include address label from a recent issue; old and new address must be included. Send USA and Canadian subscriptions to Salt Lake Distribution Center at address below. Subscription help line: 1-800-537-5971. Credit card orders (American Express, Discover, MasterCard, Visa) may be taken by phone or at store.lds.org. (Canada Post Information: Publication Agreement #40017431)

POSTMASTER: Send all UAA to CFS (see DMM 707.4.12.5). NONPOSTAL AND MILITARY FACILITIES: Send address changes to Distribution Services, Church Magazines, P.O. Box 26368, Salt Lake City, UT 84126-0368, USA.

# យោបល់ទាំងឡាយសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ

*ច្បាប់នេះមាននូវអត្ថបទ និង សកម្មភាពទាំងឡាយដែលអាចប្រើប្រាស់ សម្រាប់ធ្វើរាត្រីជួបជុំក្រុមគ្រួសារ ។ ខាងក្រោមនេះគឺជាឧទាហរណ៍ចំនួនពីរ ។*



« **របៀបសម្រេចគោលដៅអស់កល្បជានិច្ច** » ទំព័រ 60 និង « **រឿងដ៏សំខាន់បំផុតទាំង 10 យ៉ាងរបស់ អាប់ប៊ី** » ទំព័រ 76 ៖ ជាមួយនឹងការចាប់ផ្ដើមឆ្នាំថ្មី អ្នក និងគ្រួសារអ្នកអាចគិតពីគោលដៅជាក់លាក់នានា ដែលអ្នកចង់សម្រេចដោយខ្លួនឯង និង ជាគ្រួសារ ។ សូមពិចារណាអានអត្ថបទរបស់ស៊ិស្ទើរ រ៉ូសម៉ារី អិម វិកស្សុម ស្ដីពីគោលដៅដ៏សំខាន់បំផុតកំពូលទាំង 10 នៅក្នុងជីវិតរបស់យុវនារីម្នាក់ ហើយអញ្ជើញកូនចៅរបស់អ្នកគិតពីគោលដៅផ្ទាល់ខ្លួនរបស់ពួកគេ ។ កូនចៅធំៗរបស់អ្នកក៏អាចទទួលបានអត្ថប្រយោជន៍ពីការពិភាក្សាមួយនៅក្នុងអត្ថបទរបស់អែលឌើរ រ៉ូប៊ឺត ឌី ហែល ស្ដីពីគោលដៅអស់កល្បជានិច្ច និង សារៈសំខាន់នៃការដាក់ផែនការដើម្បីសម្រេចគោលដៅទាំងនោះផងដែរ ។ សូមលើកទឹកចិត្តសមាជិកគ្រួសារឲ្យសរសេរពីគោលដៅរបស់ពួកគេ ហើយបិទវានៅក្នុងផ្ទះរបស់អ្នកត្រង់កន្លែងដែលងាយមើលឃើញ ។

« **ការសាកល្បងក្នុងព្រះគម្ពីរសម្រាប់ព្រះគម្ពីរសញ្ញាថ្មី** » ទំព័រ 66 ៖ សូមពិចារណាចាប់ផ្ដើមការសាកល្បងការអានក្នុងព្រះគម្ពីរសញ្ញាថ្មីជាគ្រួសារ ។ អ្នកអាចចាប់ផ្ដើមដោយសុំឲ្យសមាជិកគ្រួសារម្នាក់ៗចែកចាយដំណើររឿងដែលពួកគេចូលចិត្តស្ដីពីឆាកជីវិតព្រះយេស៊ូវគ្រីស្ទ ។ រួចជាគ្រួសារ សូមចូលទៅ gospelart.lds.org ឬ scripturestories.lds.org ដើម្បីរកមើលវីដេអូ និង គំនូរដែលទាក់ទងនឹងកាលវិភាគនៃការអានរបស់អ្នក ។ ឬសូមពិចារណាធ្វើការសម្ដែងពីទិដ្ឋភាពក្នុងព្រះគម្ពីរសញ្ញាថ្មីកាលអ្នកកំពុងអាន ។

## ជាភាសារបស់អ្នក

*លីអាហូណា* និង ឯកសារផ្សេងទៀតរបស់សាសនាចក្រមានជាច្រើនភាសា សូមចូលទៅកាន់ **languages.lds.org ។**

**ប្រធានបទទាំងឡាយក្នុងច្បាប់នេះ**
*លេខទាំងឡាយគឺតំណាងឲ្យទំព័រទីមួយនៃអត្ថបទ ។*

*ការគោរព* 72
*ការគោរពប្រតិបត្តិ* 7
*ការទាស់ទែងគ្នា* 62
*ការបង្រៀន* 24
*ការបម្រើ* 15, 38, 41, 48, 50, 53, 55, 64
*ការប្រែចិត្ត* 12, 39, 80
*ការប្រែចិត្តជឿ* 12
*ការល្បួង* 14
*ការសម្រេចចិត្ត* 4, 6, 18
*ការអធិស្ឋាន* 78
*ការអប់រំ* 18
*ការអភ័យទោស* 80
*កិច្ចការផ្សព្វផ្សាយសាសនា* 40, 48, 53, 55, 63
*កិច្ចការព្រះវិហារបរិសុទ្ធ* 12, 28
*ក្រុមគ្រួសារ* 12 28, 32, 42, 46
*គោលដៅ* 60, 76
*ចិត្តសប្បុរស* 72
*ជីវិតដ៏នៅអស់កល្បជានិច្ច* 14, 60, 76
*ជីវិតមុនផែនដី* 18
*ដង្វាយធួន* 10
*ពិធីសាក្រាម៉ង់* 10
*ព្យាការីទាំងឡាយ* 28, 32
*ព្រះគម្ពីរ* 66, 71
*ព្រះគម្ពីរសញ្ញាថ្មី* 66, 68, 74, 77
*ព្រះយេស៊ូវគ្រីស្ទ* 7, 10, 24, 56, 61, 74
*មាត្រានៃសេចក្ដីជំនឿ* 69
*សន្និសីទទូទៅ* 8
*សិទ្ធិជ្រើសរើស* 18
*សេចក្ដីស្រឡាញ់* 15
*អាពាហ៍ពិពាហ៍* 28, 32, 42, 46
*អែសរ៉ា ថាហ្វ បែនសឹន* 32



ដោយប្រធាន
ថូម៉ាស អេស ម៉នសុន

# ធ្វើតាម ព្យាការី

ខ្ញុំបានបម្រើក្នុងទ័ពជើងទឹករបស់អាមេរិករហូតដល់សង្គ្រាមលោកលើកទី 2 បានបញ្ចប់ ។ ខ្ញុំគឺជាទាហានកងនាវាមួយរូប មានឋានៈតូចបំផុតក្នុងកងទ័ពនាវា ។ រួចខ្ញុំមានគុណសម្បត្តិធ្វើជាទាហានកងនាវាថ្នាក់ទីមួយ ក្រោយមកខ្ញុំបានក្លាយជាទាហានជើងទឹកថ្នាក់ទីបី ។

សង្គ្រាមលោកលើកទី 2 បានបញ្ចប់ ហើយក្រោយមកខ្ញុំបានឈប់ពីជួរកងទ័ពនោះ ។ ប៉ុន្តែខ្ញុំបានធ្វើការសម្រេចចិត្តមួយថា ប្រសិនបើខ្ញុំត្រឡប់ចូលបម្រើកងទ័ពវិញ ខ្ញុំចង់ធ្វើជាមេបញ្ជាការម្នាក់ ។ ខ្ញុំបានគិតថា « ខ្ញុំមិនចង់សំអាតនាវាដ៏កខ្វក់ ដាំស្លក្នុងផ្ទះបាយ ប្រសិនបើអាចចៀសវាបាន » ។

ក្រោយពីខ្ញុំបានឈប់ ខ្ញុំចូលជាកងទ័ពជើងទឹកបម្រុងរបស់អាមេរិក ។ ខ្ញុំបានទៅហ្វឹកហាត់រៀងរាល់យប់ថ្ងៃចន្ទ ។ ខ្ញុំខំសិក្សាយ៉ាងខ្លាំងរហូតដល់ខ្ញុំមានលក្ខណៈសម្បត្តិសម្រាប់ការអប់រំ ។ ខ្ញុំបានប្រឡងរាល់មុខវិជ្ជាដែលអាចធ្វើបានដូចជា ៖ ផ្នែកផ្លូវចិត្ត ផ្លូវកាយ និង ផ្លូវអារម្មណ៍ ។ នៅទីបំផុត ដំណឹងដ៏រីករាយបានកើតឡើង ៖ « អ្នកត្រូវបានទទួលយកឲ្យធ្វើជាមេបញ្ជាការជើងទឹកក្នុងកងទ័ពជើងទឹកបម្រុងរបស់អាមេរិក »។

ខ្ញុំបានបង្ហាញលិខិតនោះដល់ភរិយាខ្ញុំ ហ្វ្រេនសេស ហើយពោលដោយក្ដីរីករាយថា « បងធ្វើបានសម្រេចហើយ ! បងធ្វើបានសម្រេចហើយ ! » គាត់បានឱបខ្ញុំ ហើយពោលថា « បងបានខំល្មមគ្រប់គ្រាន់ហើយដើម្បីទទួលបានវា » ។

ប៉ុន្តែក្រោយមកមានអ្វីមួយបានកើតឡើង ។ ខ្ញុំត្រូវបានហៅឲ្យធ្វើជាទីប្រឹក្សាទីមួយក្នុងគណៈប៊ីស្សពវួដរបស់ខ្ញុំ ។ ការប្រជុំក្រុមប្រឹក្សារបស់ប៊ីស្សពធ្វើនៅចំពេលល្ងាចនៃការប្រជុំហ្វឹកហាត់ទាហានជើងទឹករបស់ខ្ញុំ ។ ខ្ញុំបានដឹងថា វាគឺជាបញ្ហាមួយដ៏ធំ ។ ខ្ញុំបានដឹងថា ខ្ញុំគ្មានពេលដើម្បីចាប់យកការធ្វើជាទ័ពជើងទឹកបម្រុងនិងកាតព្វជាគណៈប៊ីស្សពរបស់ខ្ញុំបានឡើយ ។ តើខ្ញុំត្រូវធ្វើដូចម្ដេចទៅ ? ការសម្រេចចិត្តមួយត្រូវតែធ្វើឡើង ។

ខ្ញុំបានអធិស្ឋានពីរឿងនេះ ។ រួចខ្ញុំបានចេញទៅជួបនឹងបុរសម្នាក់ដែលជាប្រធានស្តេករបស់ខ្ញុំ កាលខ្ញុំនៅក្មេងគឺ អែលឌើរ ហារ៉ូល ប៊ី លី ( 1899–1973 ) ដែលក្រោយមកលោកបម្រើក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ ខ្ញុំបានអង្គុយចុះនៅពីមុខលោក ។ ខ្ញុំបានប្រាប់លោកថា ខ្ញុំចង់បានការងារនោះខ្លាំងណាស់ ។ ពិតណាស់ ខ្ញុំបានបង្ហាញលោកពីលិខិតតែងតាំងដែលខ្ញុំបានទទួល ។

បន្ទាប់ពីសញ្ជឹងគិតពីបញ្ហានោះមួយសន្ទុះមក លោកបានថ្លែងមកកាន់ខ្ញុំថា « នេះជាអ្វីដែលអ្នកគួរធ្វើ ប្អូនប្រុស ម៉នសុន ។ អ្នកសរសេរសំបុត្រមួយទៅការិយាល័យផ្នែកទ័ពជើងទឹក ហើយប្រាប់ពួកគេថា ដោយសារការហៅបម្រើរបស់អ្នកជាសមាជិកមួយរូបក្នុងគណៈប៊ីស្សព អ្នកមិនអាចទទួលយកការតែងតាំងនោះក្នុងកងទ័ពជើងទឹកបម្រុងរបស់អាមេរិកបានទេ » ។

ខ្ញុំមានចិត្តសោកស្ដាយជាខ្លាំង ។ លោកបានបន្ថែមទៀតថា « រួចសរសេរទៅមេបញ្ជាការនៃមណ្ឌលទ័ពជើងទឹកទីដប់ពីរក្នុងរដ្ឋសាន់ ហ្វ្រានស៊ីស្កូ ហើយប្រាប់ពួកគេថា អ្នកចង់ឈប់ពីការបម្រុងនោះ » ។

ខ្ញុំបានតបថា « អែលឌើរ លី លោកមិនយល់ពីរឿងយោធានោះទេ ។ ពិតណាស់ ពួកគេនឹងមិនផ្ដល់ឋានៈនោះដល់ខ្ញុំទេ ប្រសិនបើខ្ញុំបដិសេធមិនទទួលវា ប៉ុន្តែមណ្ឌលទ័ពជើងទឹកទីដប់ពីរនោះមិនយល់ព្រមនឹងខ្ញុំនោះទេ ។ ដោយមានការចាប់ផ្ដើមសង្គ្រាមមួយក្នុងប្រទេសកូរ៉េ មេបញ្ជាការម្នាក់ដែលមិនបានចាត់តាំងនឹងត្រូវបានហៅជាប្រាកដ ។ ប្រសិនបើខ្ញុំត្រូវបានហៅឲ្យត្រឡប់ទៅវិញ ខ្ញុំចង់ធ្វើជាមេបញ្ជាការម្នាក់ ប៉ុន្តែខ្ញុំនឹងមិនអាចឡើយ ប្រសិនបើខ្ញុំបដិសេធការតែងតាំងនេះ ។ តើអ្នកប្រាកដហើយមែនទេ ថានេះគឺជាដំបូន្មានដែលលោកចង់ឲ្យខ្ញុំទទួល ? »

អែលឌើរ លី បានដាក់ដៃលើស្មាខ្ញុំ ហើយថ្លែងដោយសេចក្ដីស្រឡាញ់ថា « ប្អូនប្រុស ម៉នសុន ចូរមានសេចក្ដីជំនឿឲ្យបានច្រើន ។ ការងារយោធាមិនមែនសម្រាប់ប្អូនទេ » ។

ខ្ញុំបានត្រឡប់ទៅផ្ទះវិញ ។ ខ្ញុំបានស៊កលិខិតតែងតាំងនោះចូលក្នុងស្រោមសំបុត្រវិញទាំងទឹកភ្នែក ដោយភ្ជាប់នូវលិខិតមួយសរសេរបដិសេធមិនទទួលយកវា ។ រួចខ្ញុំបានសរសេរលិខិតមួយទៅមណ្ឌលជើងទឹកទីដប់ពីរ ហើយបានសុំឈប់ពីការធ្វើទ័ពជើងទឹកបម្រុង ។

ការលាលែងរបស់ខ្ញុំពីទ័ពជើងទឹកបម្រុង គឺស្ថិតនៅក្នុងក្រុមចុងក្រោយដែលបានដំណើរការពីមុនសង្គ្រាមនៅប្រទេសកូរ៉េបានផ្ទុះឡើង ។ សំលៀក



*ខ្ញុំនឹងមិនបានកាន់តួនាទីក្នុងសាសនាចក្រដូចសព្វថ្ងៃនេះឡើយ ប្រសិនបើខ្ញុំមិនបានធ្វើតាមដំបូន្មានរបស់អែលឌើរ ហារ៉ូល ប៊ី លី ។*

បំពាក់ទាហាននៅទីស្នាក់ការកណ្ដាលរបស់ខ្ញុំត្រូវបានរៀបចំខ្លួនរួចហើយ ។ ប្រាំមួយសប្ដាហ៍ក្រោយពីខ្ញុំត្រូវបានហៅឲ្យធ្វើជាទីប្រឹក្សាក្នុងគណៈប៊ីស្សព ខ្ញុំត្រូវបានហៅឲ្យធ្វើជាប៊ីស្សពក្នុងវួដរបស់ខ្ញុំ ។

ខ្ញុំនឹងមិនបានកាន់តួនាទីក្នុងសាសនាចក្រដូចសព្វថ្ងៃនេះឡើយ ប្រសិនបើខ្ញុំមិនបានធ្វើតាមដំបូន្មានរបស់ព្យាការី ប្រសិនបើខ្ញុំមិនបានអធិស្ឋានពីការសម្រេចចិត្តនោះ បើខ្ញុំមិនបានមានអំណរគុណចំពោះសេចក្ដីពិតដ៏សំខាន់មួយថា ៖ ជារឿយៗព្រះប្រាជ្ញាញាណរបស់ព្រះប្រាកដឡើងហាក់ដូចជារឿងឆ្កួតលីលាសម្រាប់មនុស្ស ។[1] ប៉ុន្តែមេរៀនដ៏អស្ចារ្យបំផុតតែមួយគត់ដែលយើងអាចរៀនក្នុងជីវិតរមែងស្លាប់នេះគឺថា នៅពេលព្រះមានបន្ទូលហើយកូនចៅទ្រង់គោរពប្រតិបត្តិតាម ពួកគេនឹងធ្វើរឿងដ៏ត្រឹមត្រូវជានិច្ច ។

មានពាក្យមួយឃ្លាបានលើកឡើងថា ប្រវត្តិសាស្ត្រពឹងផ្អែកទៅលើការសម្រេចចិត្តតូចៗ រីឯជីវិតរបស់យើងក៏ដូចគ្នាដែរ ។ ការសម្រេចចិត្តកំណត់ដល់ជោគវាសនា ។ ប៉ុន្តែយើងមិនត្រូវបានទុកចោលដោយគ្មានជំនួយនៅក្នុងការសម្រេចចិត្តរបស់យើងនោះឡើយ ។

ប្រសិនបើអ្នកចង់ឃើញពន្លឺស្ថានសួគ៌ ប្រសិនបើអ្នកចង់មានអារម្មណ៍នៃការបំផុសគំនិតពីព្រះដ៏មានមហិទ្ធិឫទ្ធិ ប្រសិនបើអ្នកចង់មានអារម្មណ៍ដែលដក់នៅក្នុងចិត្តរបស់អ្នកថា ព្រះវរបិតាសួគ៌របស់អ្នកកំពុងដឹកនាំអ្នក សូមធ្វើតាមពួកព្យាការីរបស់ព្រះ ។ កាលអ្នកធ្វើតាមពួកព្យាការី អ្នកនឹងស្ថិតនៅក្នុងតំបន់ដ៏មានសុវត្ថិភាព ។ ■

**កំណត់ចំណាំ**

1. សូមមើល កូរិនថូសទី 1 2:14។

**ការបង្រៀនចេញពីសារលិខិតនេះ**

ពុំមានសមាជិកសាសនាចក្រច្រើនទេ ដែលនឹងបានទទួលដំបូន្មានដោយផ្ទាល់ពីសាវក ដូចជាប្រធាន ម៉នសុន ឡើយ ។ ប៉ុន្តែយើងនៅតែអាចទទួលបានពរជ័យ កាលយើងធ្វើតាមការបង្រៀនរបស់ពួកព្យាការី និង ពួកសាវក ។ សូមពិចារណាអានសុន្ទរកថារបស់ប្រធាន ម៉នសុន ក្នុងសន្និសីទទូទៅទើបតែកន្លងផុតមកនេះ ( សូមចងចាំពីសុន្ទរកថាបិទបើករបស់លោកផងដែរ ) ។ សូមរកមើលទិសដៅជាក់លាក់ ឬធ្វើសកម្មភាព ។ អ្នកអាចពិភាក្សាពីអ្វីដែលអ្នករៀនជាមួយសមាជិកដែលអ្នកទៅសួរសុខទុក្ខ ហើយពិចារណាពីរបៀបអនុវត្តដំបូន្មានរបស់ប្រធាន ម៉នសុន ។

សម្រាប់យោបល់នានាស្ដីពីការបង្រៀនសារលិខិតនេះសម្រាប់យុវវ័យ និង កុមារ សូមមើលទំព័រទី 6 ។

រូបគំនូរដោយ ម៉ាក់ ម៉ាន

## ដំបូន្មានសម្រាប់ជម្រើសដ៏ពិបាក

ប្រធាន ហិនរី ប៊ី អាវរិង ជាប្រឹក្សាទីមួយក្នុងគណៈប្រធានទីមួយ បានប្រាប់ពីគ្រាមួយដែលលោកបានធ្វើតាមដំបូន្មានរបស់ព្យាការី ។ អំឡុងពេលមួយ ក្នុងសន្និសីទទូទៅ ប្រធាន ដេវីដ អូ ម៉ាកខេ ( 1873–1970 ) បានលើកទឹកចិត្តសមាជិកឲ្យចៀសចេញពីបំណុល — ជាពិសេសបំណុលនៃការទិញផ្ទះ ។

ប្រធាន អាវរិង បានថ្លែងថា ៖ « ខ្ញុំងាករកភរិយាខ្ញុំបន្ទាប់ពីការប្រជុំនោះ ហើយបានសួរថា ‹ តើអូនគិតថាមានវិធីណាមួយដែលយើងអាចធ្វើបែបនោះបានទេ ? › ដំបូង យើងមិនអាចធ្វើបានទ្បើយ » ។ ប៉ុន្តែ លុះនៅល្ងាចនោះ លោកបានគិតពីផ្ទះមួយដែលពួកលោកបានលក់វាជាច្រើនឆ្នាំ ប៉ុន្តែលក់មិនដាច់សោះ ។ « យើងបានទុកចិត្តលើព្រះ និង . . . សារលិខិតរបស់អ្នកបម្រើទ្រង់ [ដូច្នេះ] យើងបានធ្វើការហៅទូរសព្ទមួយ ។ . . . ខ្ញុំបានឮចម្លើយមួយដែលបានពង្រឹងការទុកចិត្តរបស់ខ្ញុំលើព្រះ និង ពួកអ្នកបម្រើទ្រង់រហូតមកដល់សព្វថ្ងៃនេះ » ។ នៅថ្ងៃដដែលនោះ មានបុរសម្នាក់បានឲ្យថ្លៃផ្ទះរបស់គ្រួសារអាវរិងនៅក្នុងចំនួនមួយដែលលើសពីតម្លៃផ្ទះរបស់ពួកលោក ។ មិនយូរប៉ុន្មានគ្រួសារអាវរិងបានរួចផុតពីបំណុល ( សូមមើល « Trust in God, Then Go and Do » *Liahona* ខែ វិច្ឆិកា ឆ្នាំ 2010 ទំព័រ 72–73 ) ។

អ្នកប្រហែលជាគ្មានផ្ទះដែលត្រូវបង់រំលោះនោះទេ ប៉ុន្តែការប្រឹក្សារបស់ព្យាការីអាចដឹកនាំអ្នកនៅពេលនេះដោយឆ្លងកាត់នូវការសម្រេចចិត្តដ៏ពិបាក។ទាក់ទងនឹងការងារ ការអប់រំ បេសកកម្ម និង ការការដើរលេងជាគូ ។ សូមពិភាក្សាជាមួយនឹងគ្រួសារ ឬ មិត្តភក្តិរបស់អ្នកពីរបៀបដែលអ្នកអាចធ្វើតាមព្យាការី កាលអ្នកត្រូវធ្វើការសម្រេចចិត្តនានានោះ ។



## ស្វែងរកផ្លូវរបស់អ្នក

យើងត្រូវតែធ្វើការជ្រើសរើសជាច្រើនដើម្បីត្រឡប់ទៅព្រះវរបិតាសួគ៌យើងវិញ ។ យើងអាចធ្វើការជ្រើសរើសដ៏ល្អបំផុត កាលយើងធ្វើតាមព្យាការី ។

សូមស្វែងរកផ្លូវរបស់អ្នកដោយឆ្លងកាត់ផ្លូវដែលខ្វាត់ខ្វែងនេះ ។ កាលអ្នកធ្វើការសម្រេចចិត្តរួចហើយ សូមមើលទៅដំបូន្មានរបស់ព្យាការី !


**អានគម្ពីរ**
ទៅខាងស្ដាំ


**អធិស្ឋាន**
ចុះក្រោម រួចទៅខាងស្ដាំ


**ចែកចាយទីបន្ទាល់របស់អ្នក**
ទៅខាងស្ដាំ


**ជួយអ្នកដទៃ**
ចុះក្រោម រួចទៅខាងឆ្វេង


**ទៅព្រះវិហារ**
ឡើងលើ



*សូមសិក្សាឯកសារនេះ ហើយស្វែងយល់នូវអ្វីដែលត្រូវចែកចាយប្រកបដោយការអធិស្ឋាន ។ តើការយល់ដឹងពីឆាកជីវិត និង បេសកកម្មរបស់ព្រះអង្គសង្គ្រោះ នឹងពង្រឹងសេចក្ដីជំនឿរបស់អ្នកលើទ្រង់ ហើយប្រទានពរដល់អ្នកទាំងឡាយដែលអ្នកមើលថែ តាមការបង្រៀនសួរសុខទុក្ខបានដោយរបៀបណា ? ចំពោះព័ត៌មានបន្ថែម សូមចូលទៅ reliefsociety.lds.org ។*

# លក្ខណៈនៃព្រះយេស៊ូវគ្រីស្ទ ៖ បុត្រាដ៏ស្ដាប់បង្គាប់

*នេះជាផ្នែកនៃគំរូមួយអំពីសារលិខិតបង្រៀនសួរសុខទុក្ខ ដែលឆ្លុះបញ្ចាំងពីលក្ខណៈរបស់ព្រះអង្គសង្គ្រោះ ។*



ការធ្វើតាមគំរូរបស់ព្រះយេស៊ូវគ្រីស្ទស្ដីពីការគោរពប្រតិបត្តិ បង្កើនសេចក្ដីជំនឿយើងលើទ្រង់ ។ អែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានថ្លែងថា « តើមាននរណាម្នាក់ងឿងឆ្ងល់ ថាហេតុអ្វីបានជាព្រះគ្រីស្ទជ្រើសបង្ហាញថាទ្រង់មានទំនាក់ទំនងនឹងព្រះវរបិតាទ្រង់ — ថាទ្រង់ស្រឡាញ់ ហើយគោរពតាមព្រះវរបិតាទ្រង់ ហើយធ្វើតាមទ្រង់ជាបុត្រាមួយអង្គដ៏ស្មោះត្រង់ដែរឬទេ ? . . . ការគោរពប្រត្តិបត្តិ *គឺជា*ក្រិត្យវិន័យទីមួយនៃស្ថានសួគ៌ » ។[1]

ហើយកាលណាយើងបានព្រះពរណាមួយពីព្រះ នោះគឺដោយសារការគោរពដល់ក្រិត្យវិន័យនោះដែលព្រះពរនោះផ្អែកទៅលើ » ( គ. និង ស. 130:21 ) ។ ការរីកចម្រើនខាងវិញ្ញាណរបស់យើងកើតឡើង កាលណាយើងខិតទៅជិតព្រះតាមរយៈការគោរពប្រតិបត្តិ ហើយអញ្ជើញព្រះចេស្ដានៃដង្វាយធួនរបស់ព្រះអង្គសង្គ្រោះឲ្យចូលមកក្នុងជីវិតយើង ។

អែលឌើរ ឌី ថត គ្រីស្ដូហ្វឺសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានថ្លែងថា « នៅពេលយើងដើរនៅក្នុងការគោរពប្រតិបត្តិចំពោះគោលការណ៍ និងព្រះបញ្ញត្តិនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ យើងរីករាយនឹងការចាក់ព្រះពរជាបន្តបន្ទាប់ដែលព្រះបានសន្យានៅក្នុងសេចក្ដីសញ្ញារបស់ទ្រង់ជាមួយនឹងយើង ។ ពរជ័យទាំងនោះបានផ្ដល់ជាធនធានដែលយើងត្រូវការដើម្បីធ្វើសកម្មភាពជាជាងទទួលសកម្មភាពនៅពេលយើងបន្តដំណើរនៅក្នុងជីវិតនេះ ។ . . . ការគោរពប្រតិបត្តិ ផ្ដល់ឲ្យយើងនូវការគ្រប់គ្រងកាន់តែច្រើនលើជីវិតយើង ឲ្យយើងមានសមត្ថភាពកាន់តែច្រើនដើម្បីផ្លាស់ប្ដូរ ធ្វើការ និងបង្កើត »។[2]

### *ព្រះគម្ពីរបន្ថែម*

លូកា 22:41–46, គោលលទ្ធិ និង សេចក្ដីសញ្ញា 82:10, 93:28

### *សូមពិចារណាចំណុចនេះ*

តើគំរូមួយចំនួននៅក្នុងព្រះគម្ពីរស្ដីពីការគោរពប្រតិបត្តិមានអ្វីខ្លះ ?

**កំណត់ចំណាំ**

1. ជែហ្វ្រី អ័រ ហូឡិន « The Will of the Father in All Things » ( Brigham Young University devotional ថ្ងៃទី 17 ខែ មករា ឆ្នាំ 1989 ) ទំព័រ 4, speeches.byu.edu។
2. ឌី ថត គ្រីស្ដូហ្វឺសិន « The Power of Covenants » *Liahona* ខែ ឧសភា ឆ្នាំ 2009 ទំព័រ 21 ។
3. ដេវីឌ អេ បែដណា « Converted unto the Lord » *Liahona* ខែ វិច្ឆិកា ឆ្នាំ 2012 ទំព័រ 109 ។

**សេចក្ដីជំនឿ ក្រុមគ្រួសារ ការសង្គ្រោះ**

### *ដកស្រង់ចេញពីព្រះគម្ពីរ*

« តើកម្លាំងខាងវិញ្ញាណដែលកើតចេញពីការគោរពប្រតិបត្តិជាទៀងទាត់ចំពោះព្រះបញ្ញត្តិអាចផ្ដល់ ឲ្យ ទៅឲ្យមនុស្សម្នាក់ទៀតបានដែរឬទេ ? » អែលឌើរ ដេវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានសួរ ។ « ចម្លើយដ៏ជាក់ច្បាស់ . . . គឺថា ទេ » ។[3]

រឿងប្រៀបប្រដូចស្ដីពីស្ត្រីព្រហ្មចារីទាំងដប់ គឺជាឧទាហរណ៍មួយនៃគោលការណ៍នេះ ។ កាលដែលស្ត្រីព្រហ្មចារីគ្រប់រូបបានយកចង្កៀងរបស់ខ្លួនទៅ « ជួបនឹងកូនកម្លោះ » មានតែប្រាំនាក់ប៉ុណ្ណោះ ដែលឈ្លាសវៃដាក់ប្រេងក្នុងចង្កៀងខ្លួន ។ រីឯប្រាំនាក់ទៀតគឺជាមនុស្សល្ងង់ខ្លៅ ដោយសារពួកគេ « មិនបានយកប្រេងមកជាមួយនោះទេ » ។

លុះដល់កណ្ដាលអធ្រាត្រ ស្រាប់តែឮសំឡេងស្រែកឡើងថា ៖ « នែ ប្ដីមកហើយ ចូរចេញទៅទទួលចុះ » ។ ស្ត្រីព្រហ្មចារីទាំងអស់រៀបចំចង្កៀងខ្លួន ប៉ុន្តែពួកស្ត្រីព្រហ្មចារីដែលល្ងង់គ្មានប្រេងទេ ។ ពួកគេបាននិយាយទៅកាន់ពួកស្ត្រីព្រហ្មចារី ដែលមានគំនិតថា « សូមចែកប្រេងមកឲ្យយើងផង ព្រោះចង្កៀងយើងចង់រលត់ហើយ » ។

ពួកនាងដែលមានគំនិតបានតបថា « ទេ ក្រែងគ្មានល្មមដល់យើង ហើយនឹងនាងរាល់គ្នាផង ៖ ស៊ូទៅ . . . ទិញសម្រាប់ខ្លួនវិញទៅ » ។ រួចកាលពួកនាងដែលល្ងង់ចេញទៅ កូនកម្លោះក៏មកដល់ ហើយពួកនាងដែលមានគំនិតបានចូលទៅជាមួយគាត់ រួច « បិទទ្វារ » ( ម៉ាថាយ 25:1–13 ) ។

# សៀវភៅកំណត់ចំណាំសន្និសីទខែ តុលា ឆ្នាំ 2014

*« អ្វីដែលយើងជាព្រះអម្ចាស់បានមានបន្ទូល នោះយើងបានមានបន្ទូលហើយ . . . ទោះជាដោយសំឡេងរបស់យើងផ្ទាល់ ឬ ក៏ដោយសំឡេងនៃពួកអ្នកបម្រើរបស់យើងក្ដី គឺដូចតែគ្នា » ( គ. និង ស.1:38 ) ។*

*នៅពេលអ្នកមើលសន្និសីទទូទៅខែ តុលា ឆ្នាំ 2014 ឡើងវិញ នោះអ្នកអាចប្រើប្រាស់ទំព័រទាំងនេះ ( និង សៀវភៅកំណត់ចំណាំសន្និសីទនៅច្បាប់ចេញផ្សាយនាពេលខាងមុខទៀត ) ដើម្បីជួយអ្នកសិក្សា និង អនុវត្តការបង្រៀនថ្មីៗរបស់ព្យាការី និង សាវកដែលរស់នៅ និង អ្នកដឹកនាំសាសនាចក្រដទៃផ្សេងទៀត ។*

**ការដកស្រង់គោលលទ្ធិ**



## យើងត្រូវបានដឹកនាំដោយពួកព្យាការីដែលនៅរស់ ។

« ឆ្នាំមុន ពេលប្រធាន ម៉នសុន បានឈានដល់រយៈពេលប្រាំឆ្នាំ នៃការបម្រើជាប្រធានសាសនាចក្រ នោះលោកបានគិតពីការបម្រើជាសាវករយៈពេល 50 ឆ្នាំរបស់លោក ហើយបានថ្លែងដូចនេះថា ៖ . . . ‹ ខ្ញុំសូមអះអាងបងប្អូនថា សាសនាចក្រគឺស្ថិតនៅក្នុងការមើលថែយ៉ាងល្អ ។ ប្រព័ន្ធដែលបង្កើតឡើងសម្រាប់ក្រុមប្រឹក្សានៃគណៈប្រធានទីមួយ និងកូរ៉ុមនៃពួកដប់ពីរនាក់ បញ្ជាក់ដល់ [ យើង ] ថា វានឹងស្ថិតនៅក្នុងការមើលថែយ៉ាងល្អជានិច្ច មិនថាអ្វីកើតឡើងទេ យើងពុំចាំបាច់ព្រួយបារម្ភ ឬខ្លាចឡើយ ។ ព្រះអង្គសង្គ្រោះរបស់យើង គឺព្រះយេស៊ូវគ្រីស្ទ ដែលយើងដើរតាម ដែលយើងថ្វាយបង្គំ ហើយដែលយើងបម្រើ គឺកំពុងដឹកនាំសាសនាចក្រទ្រង់ › ។[1]

« ប្រធាន ម៉នសុន យើងសូមអរគុណសម្រាប់ការពិតទាំងនោះណាស់ ! ហើយយើងអរគុណលោកចំពោះភាពជាគំរូ និងការបម្រើដ៏លះបង់ពេញមួយជីវិតរបស់លោកប្រធាន ។ . . . ពួកយើងគាំទ្រលោកប្រធាន ពុំគ្រាន់តែដោយការលើកដៃទេ ប៉ុន្តែដោយអស់ពីដួងចិត្ត និងកិច្ចខិតខំក្នុងការថ្វាយខ្លួនរបស់យើង » ។

**អែលឌើរ រ័សុល អិម ណិលសុន « ការគាំទ្រពួកព្យាការី » *Liahona,* ខែ វិច្ឆិកា ឆ្នាំ 2014 ទំព័រ 76 ។**

**កំណត់ចំណាំ**

1. « សារលិខិតពីប្រធាន ថូម៉ាស អេស ម៉នសុន » *Church News,* ថ្ងៃទី 3 ខែ កុម្ភៈ ឆ្នាំ 2013 ទំព័រ 9 ។

**ការសន្យានៃការព្យាករណ៍**



## មាគ៌ារបស់ព្រះគ្រីស្ទ

« ពេលយើងព្យាយាមដាក់ព្រះគ្រីស្ទជាចំបងក្នុងជីវិតរបស់យើង តាមការរៀនសូត្រពីព្រះបន្ទូលទ្រង់ តាមការធ្វើតាមការបង្រៀនរបស់ទ្រង់ និងតាមការដើរតាមផ្លូវរបស់ទ្រង់ នោះទ្រង់បានសន្យាថានឹងប្រទានជីវិតអស់កល្បជានិច្ចដល់យើង ដែលទ្រង់បានសុគតដើម្បីឲ្យយើងអាចទទួលបាន ។ គ្មានការបញ្ចប់ណាល្អជាងនេះទេ ថាយើងគួរតែជ្រើសរើសដើម្បីទទួលយកការលត់ដំរបស់ទ្រង់ ហើយក្លាយជាសិស្សទ្រង់ និងធ្វើកិច្ចការរបស់ទ្រង់នៅពេញមួយជីវិតយើង ។ គ្មានអ្វីផ្សេងទៀត គ្មានការជ្រើសរើសណាផ្សេងទៀតដែលយើងធ្វើ អាចធ្វើឲ្យយើងក្លាយដូចជាទ្រង់ទេ » ។

**ប្រធាន ថូម៉ាស អេស ម៉នសុន « ពិចារណាពីផ្លូវដែលយើងឯងដើរ » *Liahona,* ខែ វិច្ឆិកា ឆ្នាំ 2014 ទំព័រ 88 ។**



### មនុស្សទាំងអស់មានពរដោយសារការតមអាហារ

« ខ្ញុំសូមថ្លែងជាសាក្សីអំពីអព្ភូតហេតុទាំងនេះ ទាំងខាងវិញ្ញាណ និង ខាងសាច់ឈាម ដែលកើតមានចំពោះជនដែលរស់នៅតាមច្បាប់តមអាហារ ។ . . . សូមឲ្យតម្លៃដល់ឯកសិទ្ធិដ៏ពិសិដ្ឋនោះយ៉ាងហោចណាស់មួយខែម្ដង ហើយមានចិត្តសប្បុរសធមទៅតាមលទ្ធភាពនៅក្នុងដង្វាយតមអាហាររបស់អ្នក និងដង្វាយសម្រាប់មនុស្សធម៌ ការអប់រំ និងអ្នកផ្សាយសាសនាផ្សេងទៀត ។ ខ្ញុំសូមសន្យាថា ព្រះនឹងមានព្រះទ័យសប្បុរសចំពោះអ្នក ហើយជនដែលទទួលបានជំនួយពីអ្នកនឹងហៅឈ្មោះអ្នកថាមានពរជារៀងរហូត » ។

**អែលឌើរ ជែហ្វ្រី អ័រ ហូឡិន « តើយើងទាំងអស់គ្នានេះ ពុំមែនជាអ្នកសុំទានទេឬ ? »** ***Liahona,*** **ខែ វិច្ឆិកា ឆ្នាំ 2014 ទំព័រ 42 ។**



ព្រះគ្រីស្ទ និង អ្នកមានវ័យក្មេង ដោយ ហៃនរិច ហូហ្វម៉ែន ទទួលបានសិទ្ធិអនុញ្ញាតពីការពីC. HARRISON CONROY CO.

## ចម្លើយសម្រាប់អ្នក

សន្និសីទនិមួយៗ ពួកព្យាការី និងសាវក ផ្ដល់ចម្លើយដ៏បំផុសគំនិតចំពោះសំណួរ ដែលសមាជិកសាសនាចក្រអាចមាន ។ សូមប្រើប្រាស់ច្បាប់ខែ វិច្ឆិកា ឆ្នាំ 2014 ឬ ចូលទៅកាន់គេហទំព័រ conference.lds.org ដើម្បីស្វែងរកចម្លើយចំពោះសំណួរទាំងនេះ ៖

- តើព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទជាអង្គតែមួយតាមរបៀបណា ? ។ សូមមើល រ៉ូប៊ឺត ឌី ហែល « ជីវិតអស់កល្ប — ដើម្បីស្គាល់ព្រះវរបិតាសួគ៌យើង និងព្រះរាជបុត្រាទ្រង់ ព្រះយេស៊ូវគ្រីស្ទ » ទំព័រ 80 ។
- តើទីបន្ទាល់ជាអ្វីទៅ ហើយតើខ្ញុំទទួលបានវាតាមរបៀបណា ? សូមមើល គ្រេហ្គ សី គ្រីស្ទីនសិន « ខ្ញុំដឹងរឿងទាំងនេះដោយខ្លួនឯង » ទំព័រ 50 ។
- តើខ្ញុំត្រូវធ្វើអ្វីខ្លះ ខណៈដែលកំពុងស្វែងរកចម្លើយចំពោះសំណួរនានារបស់ខ្ញុំនោះ ? សូមមើល អិម រ័សុល បាឡឺដ « ចូរនៅលើទូក ហើយតោងឲ្យជាប់ ! » 89 ។



**ការបង្រៀនដែលស្របគ្នា**

## ព្រះវិហារបរិសុទ្ធ

មានពេលខ្លះមានអ្នកឡើងនិយាយជាច្រើនបានលើកឡើងនូវប្រធាននៃដំណឹងល្អដូចគ្នា ។ នេះជាអ្វីដែលអ្នកឡើងនិយាយបីរូបបានថ្លែងពីព្រះវិហារបរិសុទ្ធ ៖

- « យើងអាចទទួលបានការបំផុសគំនិត និងវិវរណៈនៅក្នុងព្រះវិហារបរិសុទ្ធ — និងព្រះចេស្ដាដើម្បីប្រឈមនឹងការលំបាកក្នុងជីវិត » ។ — សិស្ទើរ លីនដា ខេ បើតុន « បានប្រុងប្រៀបខ្លួនតាមរបៀបមួយដែលមិនដែលបានស្គាល់ » ទំព័រ 111 ។
- « តាមរយៈការចិញ្ចឹមបីបាច់អារម្មណ៍អំពីព្រះវិហារបរិសុទ្ធ នោះយើងអាចរៀនពីភាពពិត អំណាច និងសេចក្ដីសង្ឃឹមលើដង្វាយធួនរបស់ព្រះអង្គសង្គ្រោះនៅក្នុងជីវិតរបស់យើងផ្ទាល់ » ។ — សិស្ទើរ នីល អែហ្វ ម៉ារ៉ត « ការចែកចាយពន្លឺរបស់អ្នក » ទំព័រ 117 ។
- « បើយើងចង់ទទួលបាននូវរាល់ពរជ័យដែលព្រះផ្ដល់ឲ្យដោយក្ដីសប្បុរសបំផុត នោះផ្លូវក្នុងជីវិតលើផែនដីរបស់យើង ត្រូវតែដឹកនាំទៅរកព្រះវិហារបរិសុទ្ធ ។ ព្រះវិហារបរិសុទ្ធ គឺជាការបង្ហាញមួយអំពីក្ដីស្រឡាញ់របស់ព្រះ » ។ — សិស្ទើរ ជីន អេ ស្ទីវិនស៍ « បុត្រីនៃសេចក្ដីសញ្ញារបស់ព្រះ » ទំព័រ 114 ។

ដើម្បីអាន ទស្សនា ឬ ស្ដាប់សុន្ទរកថាសន្និសីទទូទៅ សូមចូលទៅកាន់គេហទំព័រ conference.lds.org ។

# រយៈពេលមួយម៉ោងដើម្បីចាំយាមជាមួយនឹងទ្រង់

ដោយ ម៉ារីស្សា ហ្គន់ស្សាឡេស អេស្ពេចូ

មានថ្ងៃមួយខ្ញុំកំពុងតែរៀបចំខ្លួនឡើងនិយាយនៅក្នុងការប្រជុំសាក្រាម៉ង់ ។ ខ្ញុំបានសិក្សាពីអត្ថបទមួយដែលមានចំណងជើងថា « The Atonement of Jesus Christ » ដោយអែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ក្នុង*លីអាហូណា ខែ មីនា ឆ្នាំ 2008* ។ ក្នុងអត្ថបទរបស់លោក អែលឌើរ ហូឡិន បានលើកឡើងពីសុបិនមួយ ដែលអែលឌើរ អ័រសិន អេហ្វ វីតនី ( 1855–1931 ) មាន ដោយលោកបានឃើញព្រះអង្គសង្គ្រោះគង់ក្នុងសួនច្បារគេតសេម៉ានី ។ អែលឌើរ វីតនី បានរៀបរាប់ពីការឈឺចាប់ និង ការរងទុក្ខដែលលោកបានឃើញព្រះអង្គសង្គ្រោះបានទ្រាំទ្រ ។ រួចលោកបានសរសេរថា ៖

« មិនយូរប៉ុន្មាន ទ្រង់បានក្រោកឡើង ហើយយាងទៅកន្លែងដែលពួកសាវកកំពុង — ដេកលក់យ៉ាងស្កប់ស្កល់ ! ទ្រង់បានយកព្រះហស្តអង្រួនពួកគេថ្នមៗ ដាស់ពួកគេឲ្យភ្ញាក់ ហើយនៅក្នុងការស្ដីបន្ទោសដោយពាក្យស្រទន់ ដោយមិនបង្ហាញពីការក្រោធខឹង នោះទ្រង់បានសួរថា តើពួកគេនៅចាំយាមជាមួយនឹងទ្រង់មួយម៉ោងមិនបានទេឬអី ។ . . .

« ដោយវិលត្រឡប់ទៅកន្លែងទ្រង់វិញ ទ្រង់បានអធិស្ឋានម្ដងទៀត រួចបានត្រឡប់ទៅវិញ ហើយបានឃើញពួកគេដេកលក់ម្ដងទៀត ។ ទ្រង់បានដាស់ពួកគេឲ្យភ្ញាក់ម្ដងទៀត បានទូន្មានពួកគេ ហើយបានត្រឡប់ទៅអធិស្ឋានវិញ ។ រឿងនេះបានកើតឡើងបីដង » ។[1]

កាលខ្ញុំអានរឿងនេះ វិញ្ញាណនៃវិវរណៈបានចូលមកក្នុងគំនិតខ្ញុំ ។ ភ្លាមៗនោះ ខ្ញុំបានដឹងថា វិធីដែលខ្ញុំអាច « ចាំយាមនឹងទ្រង់មួយម៉ោង » គឺនៅក្នុងរបៀបដែលខ្ញុំចាប់ផ្ដើមចូលរួមការប្រជុំសាក្រាម៉ង់រៀងរាល់ថ្ងៃអាទិត្យ ។ ចាប់ពីពេលនោះមក ខ្ញុំបានរៀនថា នេះគឺជារយៈពេលមួយម៉ោងដែលយើងអាចអធិស្ឋានទៅព្រះវរបិតាសួគ៌យើងតាមរបៀបដ៏កាន់តែមានអត្ថន័យបន្ថែមទៀត ។ ការអធិស្ឋានគឺជារឿងដ៏សំខាន់នៅគ្រប់ពេល ប៉ុន្តែព្រះវិញ្ញាណដែលមានវត្តមាននៅក្នុងម៉ោងសាក្រាម៉ង់នោះគឺជាឱកាសមួយដើម្បីលើកកម្ពស់ខ្លួនយើងឲ្យខិតទៅជិតព្រះវរបិតាសួគ៌ និង ព្រះអង្គសង្គ្រោះយើង ព្រះយេស៊ូវគ្រីស្ទ ។ កាលយើងផ្ដោតគំនិតយើងទៅលើព្រះអម្ចាស់ ដោយនៅជាមួយទ្រង់ក្នុងគ្រានៃការឈឺចាប់ដែលទ្រង់បានស៊ូទ្រាំ កាលទ្រង់លើកដាក់អំពើបាបយើងមកលើអង្គទ្រង់ ។ វាគឺជាពេលមួយដើម្បីទទួលស្គាល់ពីការឈឺចាប់ដែលទ្រង់បានរងទុក្ខសម្រាប់យើង ។

ការប្រជុំសាក្រាម៉ង់មានន័យខ្លាំងណាស់ចំពោះខ្ញុំ ។ ចំពោះខ្ញុំវាគឺជាពេលវេលាមួយនៃសេចក្ដីសង្គ្រោះដ៏គ្មានទីបញ្ចប់ ។ វាបានក្លាយជាពេលវេលាមួយដ៏ពិសិដ្ឋដែលខ្ញុំនឹកចាំ ហើយតាំងចិត្តក្នុងការអធិស្ឋាន និង ក្នុងអារម្មណ៍ដើម្បី



**គ្រាដែលសញ្ជឹងគិត ហើយមានគារវភាព**

« [ពិធីសាក្រាម៉ង់] គួរតែជាគ្រាមួយដ៏មានឥទ្ធិពល មានគារវភាព មានការសញ្ជឹងគិតបំផុត ។ វាគួរធ្វើឲ្យមានអារម្មណ៍ និង ការបំផុសខាងវិញ្ញាណ ។ ដោយហេតុផលនេះ វាមិនគួរមានភាព ប្រញាប់ប្រញាល់ទេ ។ វាមិនមែនជាពិធីមួយដែល ‹ ត្រូវបញ្ចប់ឲ្យបានលឿន › ដើម្បីឲ្យគោលបំណងដ៏ពិតនៃការប្រជុំសាក្រាម៉ង់អាចត្រូវបានធ្វើតាមនោះទេ ។ នេះ*គឺជា*គោលបំណងពិតនៃការប្រជុំនេះ ។ ហើយអ្វីៗទាំងអស់ដែលបានលើកឡើង ឬច្រៀង ឬអធិស្ឋានក្នុងការប្រជុំទាំងនោះ គប្បីមានស្ថិរភាពពិតទៅនឹងពិធីបរិសុទ្ធដ៏ពិសិដ្ឋនេះជាទៀងទាត់ » ។

**អែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « This Do in Remembrance of Me » *Ensign* ខែ វិច្ឆិកា ឆ្នាំ 1995 ទំព័រ 68 ។**



គោរពដល់សេចក្ដីសញ្ញាខ្ញុំ ហើយធ្វើតាមគំរូដ៏ល្អឥតខ្ចោះរបស់ព្រះអង្គសង្គ្រោះ ។ ខ្ញុំដឹងថា ទ្រង់មានព្រះជន្មរស់ ហើយទ្រង់ស្រឡាញ់ខ្ញុំ ។ ខ្ញុំដឹងថា មានតែតាមរយៈពលិកម្មរបស់ទ្រង់ និង ព្រះលោហិតដ៏មានតម្លៃដែលទ្រង់បង្ហូរប៉ុណ្ណោះ ទើបយើងទាំងអស់គ្នាអាចបានសង្គ្រោះ ។ ខ្ញុំដឹងថារឿងនេះជាការពិត ដោយសារកាលខ្ញុំខំប្រឹងប្រែងក្នុង « ការចាំយាមជាមួយនឹងទ្រង់ » ការយល់ដឹងរបស់ខ្ញុំត្រូវបានបំភ្លឺ ជីវិតខ្ញុំត្រូវបានប្រទានពរឲ្យ ហើយទស្សនៈរបស់ខ្ញុំពីជីវិតដ៏នៅអស់កល្បជានិច្ចក្នុងវត្តមានរបស់ទ្រង់បានចាក់ឫសយ៉ាងជ្រៅ ។ ■

*អ្នកនិពន្ធរស់នៅទីក្រុង អ៊ីកា ប្រទេសប៉េរូ ។*

**កំណត់ចំណាំ**

1. អ័រសិន អេហ្វ វីតនី បានដកស្រង់ក្នុង ជែហ្វ្រី អ័រ ហូឡិន « The Atonement of Jesus Christ » *Liahona* ខែ មីនា ឆ្នាំ 2008 ទំព័រ 33 ។

**តើការទទួលទានសាក្រាម៉ង់អាចផ្លាស់ប្ដូរជីវិតខ្ញុំតាមរបៀបណាខ្លះ ?**

នៅក្នុងសន្និសីទទូទៅខែ តុលា ឆ្នាំ 2012 អែលឌើរ ដុន អរ ក្លាក នៃពួកចិតសិបនាក់ បានបង្រៀនថា « ប្រសិនបើយើងរៀបចំខ្លួនឲ្យបានត្រឹមត្រូវសម្រាប់ពិធីសាក្រាម៉ង់ យើងអាចផ្លាស់ប្ដូរជីវិតយើង »។ រួចលោកបានណែនាំថា « គោលការណ៍ប្រាំយ៉ាងដែលអាចប្រទានពរដល់ជីវិតយើង កាលយើងទទួលទានសាក្រាម៉ង់ដោយសក្ដិសម » គឺ ៖

1. មានអារម្មណ៍ដឹងគុណចំពោះដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។
2. សូមចងចាំថា យើងកំពុងតែរំឭកអំពីសេចក្ដីសញ្ញាបុណ្យជ្រមុជទឹក ។
3. ស្វែងរកអារម្មណ៍អភ័យទោសពីអំពើបាបយើង ។
4. ស្វែងរកការបំផុសគំនិតជាដំណោះស្រាយចំពោះបញ្ហាទាំងឡាយរបស់យើង ។
5. ទទួលទានសាក្រាម៉ង់ដោយសក្ដិសម ដើម្បីយើងអាចពោរពេញដោយព្រះវិញ្ញាណបរិសុទ្ធ ។

អែលឌើរ ក្លាក បានសន្យាថា ៖ « វានឹងជាការប្រជុំសាក្រាម៉ង់ដ៏អស្ចារ្យមួយ បើពិធីសាក្រាម៉ង់នោះ ផ្ដោតសំខាន់លើការថ្វាយបង្គំរបស់យើង » ។[1]

**កំណត់ចំណាំ**

1. សូមមើល ដុន អ័រ ក្លាក « Blessings of the Sacrament » *Liahona* ខែ វិច្ឆិកា ឆ្នាំ 2012 ទំព័រ 104–06 ។



# មាគ៌ាឆ្ពោះទៅរកគ្រួសារដ៏និរន្តរ

ដោយ ហ្គាធ និង សេនឌី ហាំប្លីន

*កាលពួកគេបានប្រែចិត្តជឿរួចហើយនោះ គ្រួសារ អាកៅអូឡាស បានតាំងចិត្តទៅព្រះវិហារបរិសុទ្ធ ។*

នៅព្រឹកថ្ងៃអាទិត្យមួយ បន្ទាប់ពីផឹកស្រាជាមួយមិត្តភក្តិជិតពេញមួយយប់ ស៊ីអូប៉េ អាកៅអូឡា នៅប្រទេសតុងហ្គា បានត្រឡប់មកផ្ទះវិញ គាត់បានឃើញគ្រួសារមួយក្រុម ស្លៀកសម្លៀកបំពាក់យ៉ាងស្អាតបាតសម្រាប់ថ្ងៃអាទិត្យ ។ ពួកគេបានដើរទាំងនិយាយ និងសើចយ៉ាងក្អាកក្អាយជាមួយគ្នា ។ ស៊ីអូប៉េ បានងឿងឆ្ងល់ថា តើអ្វីទៅដែលធ្វើឲ្យពួកគេរីករាយយ៉ាងនេះ ដូច្នេះគាត់ក៏បានដើរតាមពួកគេដើម្បីដឹងថាតើពួកគេទៅណា ។

ស៊ីអូប៉េ បានឃើញគ្រួសារនោះចូលក្នុងអគារមួយរបស់សាសនាចក្រពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ គាត់បានមើលតាមបង្អួច កាលអ្នកដទៃទៀតបានមកដល់ ។ សុភមង្គលបានបង្ហាញនៅលើផ្ទៃមុខរបស់ពួកគេ កាលក្រុមគ្រួសារបានអង្គុយជុំគ្នា ហើយច្រៀងចម្រៀងថ្វាយបង្គំ ។

គំនិតរបស់ ស៊ីអូប៉េ បានគិតទៅដល់ភរិយាគាត់ឈ្មោះ លីអ៊ូ ។ សេចក្តីស្រឡាញ់ដែលពួកគេធ្លាប់មានកាលពីរៀបការថ្មីថ្មោងបានរលាយសាបសូន្យអស់ ។ ស៊ីអូប៉េ ចង់បានសេចក្តីស្រឡាញ់នោះមកវិញ ។ គាត់បានប្រញាប់ប្រញាល់ទៅផ្ទះ ហើយប្រាប់ភរិយាគាត់ថា គាត់បានរកឃើញវិធីដើម្បីជួយគ្រួសារពួកគេឲ្យទទួលបានជោគជ័យ ៖ ពួកគេត្រូវតែចូលរួមនឹងសាសនាចក្រ ។

នៅថ្ងៃដដែលនោះ ស៊ីអូប៉េ បានទៅផ្ទះរបស់ប៊ីស្សពក្នុងភូមិរបស់គាត់ ។ ប៊ីស្សពបានស្គាល់ស៊ីអូប៉េ ដោយធ្លាប់ឃើញគាត់ស្រវឹងស្រាដើរតាមផ្លូវ ។ កាលពួកគេបាននិយាយគ្នា ស៊ីអូប៉េ អាចមើលឃើញភាពសង្ស័យនៅលើទឹកមុខប៊ីស្សព ប៉ុន្តែគាត់ជឿជាក់ គាត់បានប្រាប់ដល់ប៊ីស្សពដោយភាពអង់អាចថា គាត់ចង់ទទួលបុណ្យជ្រមុជទឹក ។ ប៊ីស្សព បានផ្អាកនិយាយ រួចបានអញ្ជើញ ស៊ីអូប៉េ ឲ្យចូលមកក្នុង ហើយចាប់ផ្តើមបង្រៀនគាត់ពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។

លីអ៊ូ ដំបូងមានការស្ទាក់ស្ទើរ ប៉ុន្តែនៅចាំមើលកាលស្វាមីនាងបានផ្លាស់ប្តូរទៅរកភាពប្រសើរបន្តិចម្តងៗ ។ ស៊ីអូប៉េ បានចំណាយពេលច្រើនជាងមុនជាមួយនឹងកូនចៅពួកគេ ហើយបង្ហាញសេចក្តីស្រឡាញ់កាន់តែច្រើនដល់ភរិយាគាត់ និង គ្រួសារតាមរយៈទង្វើរបស់គាត់ ។ ដូច្នេះ លីអ៊ូ ក៏បានចាប់ផ្តើមរៀនពីមេរៀនអ្នកផ្សព្វផ្សាយសាសនាដែរ ហើយមិនយូរប៉ុន្មានពួកគេទាំងពីរបានជ្រមុជទឹក ។

កាលគម្រប់ខួបមួយឆ្នាំនៃពិធីបុណ្យជ្រមុជទឹករបស់ពួកគេបានខិតចូលមកដល់ គ្រួសារ អាកៅអូឡា បានសម្លឹងឆ្ពោះទៅពរជ័យដ៏អស្ចារ្យនៃព្រះវិហារបរិសុទ្ធ ។ ស៊ីអូប៉េ បានពោលថា « ប្រសិនបើពរជ័យទាំងឡាយនៃព្រះវិហារបរិសុទ្ធមានភាពអស្ចារ្យលើសពីពរជ័យដែលយើងបានទទួលក្នុងពិធីបុណ្យជ្រមុជទឹក សូមនឹកស្រមៃទៅមើល ថាតើពរជ័យនៃព្រះវិហារបរិសុទ្ធមានភាពអស្ចារ្យយ៉ាងណាទៅ » ។ ទោះជាពួកគេមានបំណងធ្វើការផ្សារភ្ជាប់ក្តី ក៏ព្រះវិហារបរិសុទ្ធក្នុងប្រទេសតុងហ្គា កំពុងធ្វើការជួសជុលដែរ ដូច្នេះពួកគេត្រូវរង់ចាំមួយឆ្នាំទៀត ឬធ្វើដំណើរទៅកាន់ព្រះវិហារបរិសុទ្ធ ដែលត្រូវចំណាយប្រាក់ច្រើនក្នុងការធ្វើដំណើរគឺ ប្រទេសនូវែលសេឡង់ ឬប្រទេសហ្វីជី ។

គ្រួសារនេះបានគិត ហើយបានខំអធិស្ឋានពីអ្វីដែលត្រូវធ្វើ ។ នៅទីបំផុត ពួកគេបានសម្រេចចិត្តយកប្រាក់កម្ចីមួយចំនួនតូច ។ កាលកំពុងរង់ចាំការអនុមតិ ធនាគារដែលឲ្យពួកគេខ្ចីប្រាក់នោះ ត្រូវភ្លើងឆេះបំផ្លិចបំផ្លាញអស់ ។ ប្រាក់កម្ចីទាំងអស់ត្រូវពន្យារពេលរហូតដល់ឆ្នាំក្រោយ ។

ស៊ីអូប៉េ និង លីអ៊ូ បានមានអារម្មណ៍បាក់ទឹកចិត្ត ។ ពួកគេបានអង្គុយជុំគ្នាក្នុងបន្ទប់ទទួលភ្ញៀវតូចមួយរបស់ពួកគេ ហើយបានអធិស្ឋានសូមឲ្យមានអព្ភូតហេតុមួយកើតឡើង ។ កាលពួកគេបានអធិស្ឋាន ហើយបានប្រឹក្សារួមគ្នា ចម្លើយមួយបានកើតមាន ៖ ស៊ីអូប៉េ បានពោលថា « ខ្ញុំបានឃើញនៅក្នុងគំនិតរបស់ខ្ញុំថា រថយន្តសម្រាប់គ្រួសារកំពុងតែញញឹមដាក់យើង ហើយខ្ញុំដឹងថា នេះជាចម្លើយចំពោះការអធិស្ឋានរបស់យើង » ។ លុះស្អែកឡើងពួកគេបានលក់រថយន្តនោះ ហើយបានទិញសំបុត្រយន្តហោះទៅប្រទេសហ្វីជីសម្រាប់គ្រួសារពួកគេប្រាំនាក់ ។

ពួកគេបានទៅដល់ទីក្រុងណាឌី ប្រទេសហ្វីជីទាំងយប់ជ្រៅ ដោយមានកូនបីនាក់កំពុងដេកលក់ ហើយផ្លូវក៏វែងឆ្ងាយដែលពួកគេត្រូវធ្វើដំណើរដើម្បីទៅកាន់ព្រះវិហារបរិសុទ្ធ នៅទីក្រុងស៊ូវ៉ា ។ លីអ៊ូ បានពោលថា « ខ្ញុំបានរៀនថា កាលណាយើងព្យាយាមខិតទៅជិតដំណាក់របស់ព្រះអម្ចាស់កាន់តែខ្លាំង នោះសាតាំងក៏ខំធ្វើឲ្យយើងចុះចាញ់ពីមុនយើងទទួលបានពរជ័យនោះដែរ » ។

កាលកំពុងអង្គុយក្នុងអាកាសយានដ្ឋានខំគិតពីអ្វីដែលពួកគេត្រូវធ្វើបន្ទាប់ទៀត មានស្ត្រីម្នាក់បានជួយពួកគេរៀបចំវ៉ាលី និងរថយន្តទៅទីក្រុងស៊ូវ៉ានៅថ្ងៃស្អែកក្នុងតម្លៃធម្មតា ។ ពួកគេបានមានអារម្មណ៍ថា ព្រះបានបញ្ជូនទេវតាមកជួយពួកគេ ។



លុះស្អែកឡើង ពួកគេបានទៅដល់ព្រះវិហារបរិសុទ្ធនោះ ។ លីអ៊ូ បានពោលថា « កាលយើងចូលទៅក្នុងព្រះវិហារបរិសុទ្ធ ខ្ញុំមានអារម្មណ៍សុខសាន្ត ហើយស្ងប់នៅក្នុងចិត្ត » ។ « ក្នុងមួយជីវិតខ្ញុំ ខ្ញុំមិនធ្លាប់ឃើញកន្លែងស ហើយស្អាត ដូចជានៅក្នុងព្រះវិហារបរិសុទ្ធពីមុនមកឡើយ ។ មានគំនិតមួយបានផុសចេញមក ៖ ប្រសិនបើព្រះវិហារបរិសុទ្ធគឺជាដំណាក់មួយដែលធ្វើឡើងដោយមនុស្ស ហើយវាស្រស់ស្អាតយ៉ាងនេះ ចុះបើដំណាក់ដែលព្រះវរបិតាសួគ៌បានសន្យាប្រទានឲ្យយើងវិញនឹងមានភាពអស្ចារ្យយ៉ាងណាទៅ ! »

បទពិសោធន៍របស់ពួកគេឮនៅក្នុងព្រះវិហារបរិសុទ្ធគឺជាការផ្លាស់ប្តូរមួយដ៏ធំសម្រាប់គ្រួសារនេះ ។ លីអ៊ូ បានពោលថា « ក្នុងអំឡុងពេលដែលយើងនៅប្រទេសហ្វីជី ខ្ញុំទទួលអារម្មណ៍នូវសេចក្តីស្រឡាញ់របស់ព្រះវរបិតាសួគ៌ចំពោះយើង ។ កាលយើងជ្រើសធ្វើតាមទ្រង់ ទ្រង់ពិតជាថែទាំយើង » ។

ពរជ័យដ៏អស្ចារ្យចេះតែបន្តកើតមានសម្រាប់គ្រួសារអាកៅអូឡា បន្ទាប់ពីពួកគេបានត្រឡប់មកផ្ទះវិញ ។ ទាំង ស៊ីអូប៉េ និង លីអ៊ូ បានទទួលអាហារូបករណ៍សម្រាប់មហាវិទ្យាល័យ ទទួលបានសញ្ញាបត្រផ្នែកបង្រៀន ហើយបានធ្វើការនៅវិទ្យាល័យលីអាហូណា ។

កាលកំពុងបង្រៀន ពួកគេយកចិត្តទុកដាក់ចំពោះកុមារដែលត្រូវការកន្លែងស្នាក់នៅ ។ ពេលខ្លះមានក្មេងម្នាក់ ពេលខ្លះទៀត ពីរទៅបីនាក់ កុមារបានចាប់ផ្តើមគោះទ្វាររបស់ស៊ីអូប៉េ និង លីអ៊ូ ។ ហើយស៊ីអូប៉េ និង លីអ៊ូ បានឲ្យពួកគេចូលមកក្នុង ។ ឥឡូវនេះ ផ្ទះដ៏តូចរបស់ពួកគេមានមនុស្សដល់ទៅ 20 នាក់ ។ ពួកគេមានកូន « ចិញ្ចឹម » ប្រាំនាក់ផ្សេងទៀតដែលបានចេញទៅរៀននៅមហាវិទ្យាល័យ ឬទៅបម្រើបេសកកម្ម ។

ស៊ីអូប៉េ និង លីអ៊ូ ដឹងថា កុមារទាំងនេះនឹងធំ ហើយរីកចម្រើន កាលពួកគេទទួលបានសេចក្តីស្រឡាញ់ និងការលត់ដំនៅក្នុងជីវិតពួកគេ ។ អ្នកដែលមិនមែនជាសមាជិកសាសនាចក្របានឱបក្រសោបយកដំណឹងល្អ ហើយឥឡូវនេះមានបំណងប្រាថ្នាចង់បម្រើបេសកកម្ម ។ ស៊ីអូប៉េ និងលីអ៊ូ ហៅកុមារទាំងអស់ដែលស្ថិតក្រោមការមើលថែពួកគេថា ជាកូន *របស់ពួកគេ* ហើយក្មេងទាំងនោះក៏ហៅ លីអ៊ូ និង ស៊ីអូប៉េ ថាជាឪពុក និង ម្តាយផងដែរ ។ គ្រួសារអាកៅអូឡាដឹងថាពួកគេមានពរជ័យយ៉ាងច្រើន ហើយពួកគេរីករាយដើម្បីចែកចាយពរជ័យទាំងនេះជាមួយអ្នកដទៃ ។ ■

*អ្នកនិពន្ធមកពីរដ្ឋអាឡាស្កា ស.រ.អា. ហើយកំពុងបម្រើបេសកកម្មនៅប្រទេសតុងហ្គា ។*



រចនារូបភាពដោយ ជេមស៍ អិល ចនសិន រូបថតទទួលបានសិទ្ធិអនុញ្ញាតជាផ្លូវការមកពីអ្នកនិពន្ធ

# ហ្វូងសត្វអំពិលអំពែក

ដោយ ដេវីឌ រ៉ាយ

*តើយើងកំពុងផ្ដោតលើរង្វាន់ដ៏នៅអស់កល្បជានិច្ច — ឬអ្វីមួយផ្សេងទៀតដែរឬទេ ?*

ប៉ុន្មានឆ្នាំមុន ខ្ញុំបានធ្វើការនៅតំបន់បុរាណវត្ថុវិទ្យាមួយ ដែលមានឈ្មោះថា អាគូអាតេកា ដែលមានទីតាំងនៅក្នុងតំបន់ដាច់ស្រយាលដ៏ស្រស់ស្អាតមួយរបស់ប្រទេសក្វាតេម៉ាឡា ដោយត្រូវធ្វើដំណើរតាមទូកឆ្លងកាត់ទន្លេប៉េតិចបាទុនដែលបត់បែន ។

មានល្ងាចមួយ ខ្ញុំបានត្រឡប់ទៅអាគូអាតេកាវិញជាមួយនឹងពួកបុរាណវិទូមួយចំនួន បន្ទាប់ពីចំណាយពេលពេញមួយថ្ងៃនៅតំបន់ក្បែរនោះ ។ កាលយើងធ្វើដំណើរតាមទូកឆ្ពោះទៅកាន់ទន្លេនោះ ដោយមានឮតែសំឡេងម៉ាស៊ីន និង សំឡេងសត្វល្អិតយំ ខ្ញុំបានទម្រេតខ្លួនទៅលើទូក ដោយរីករាយនឹងការធ្វើដំណើរដ៏សុខសាន្ត ហើយគ្មានពន្លឺព្រះចន្ទជាយប់ដែលមានផ្ទៃមេឃស្រឡះខុសពីធម្មតា ។ កាលទូកធ្វើដំណើរតាមទន្លេនោះដែលមានផ្លូវបត់បែន ខ្ញុំបានព្យាយាមផ្ដោតអារម្មណ៍ខ្ញុំមើលតាមទិសផ្កាយរះនៅភាគខាងជើង ។ ពេលខ្លះ ផ្កាយរះនៅភាគខាងជើងនោះ ត្រូវបានបិទបាំងដោយស្រមោលដ៏ខ្មៅងងឹតរបស់ដើមឈើដែលដុះតម្រៀបតាមមាត់ទន្លេ ប៉ុន្តែវាតែងលេចមកវិញជានិច្ច ។

នៅត្រង់ផ្លូវបត់មួយក្នុងទន្លេនោះ ផ្កាយរះនៅភាគខាងជើងនោះបានបាំងដោយចុងឈើជាថ្មីម្ដងទៀត ។ កាលទូកបានបត់ទៅភាគខាងត្បូងភ្លាមនោះខ្ញុំបានឃើញវាម្ដងទៀត ដោយមានអារម្មណ៍ដូចជាទាហានជើងទឹកកាលពីសម័យមុន ហើយមានមោទនភាពពីសមត្ថភាពខ្ញុំក្នុងការផ្ដោតអារម្មណ៍ ។ ប៉ុន្តែបន្ទាប់ពីមើលវាបានមួយនាទី ខ្ញុំបានដឹងថា ខ្ញុំបានមើលច្រឡំ ៖ ខ្ញុំមិនបានមើលឃើញផ្កាយរះនៅភាគខាងជើង ឬផ្កាយណាមួយនោះទេ ។ ខ្ញុំកំពុងមើលសត្វអំពិលអំពែក ។

នៅពេលនោះទើបខ្ញុំបានដឹងថា « ផ្កាយ » ជាច្រើនដែលនៅខាងលើខ្ញុំនោះគឺជាហ្វូងសត្វអំពិលអំពែក ដែលកំពុងហោះហើរសំកាំងនៅលើវេហានាយប់ដ៏សែនមនោរម្យ ។ រឿងដ៏អស្ចារ្យគឺថា ពន្លឺភ្លឺចិញ្ចែងនៃហ្វូងសត្វអំពិលអំពែកជាច្រើនស្ទើរតែដូចគ្នានឹងពន្លឺផ្កាយ និងកញ្ចុំផ្កាយដែលមានចម្ងាយដ៏វែងឆ្ងាយដែរ ហើយការជិះទូកបត់បែនតាមទន្លេនោះងាយនឹងធ្វើឲ្យវត្ថុទាំងពីរនេះច្រឡំគ្នាណាស់ ។

« តើខ្ញុំអាចមើលច្រឡំសត្វអំពិលអំពែកដ៏តូចមួយក្បាលថា ជាផ្កាយមួយដ៏ធំបានយ៉ាងដូចម្ដេចទៅ ? » ខ្ញុំមានការងឿងឆ្ងល់ ។ ចម្លើយគឺច្បាស់ថា ៖ គឺវាអាស្រ័យទៅលើទស្សនៈ ។ ពន្លឺព្រិចៗនៃហ្វូងសត្វអំពិលអំពែកស្រដៀងគ្នាទៅនឹងពន្លឺផ្កាយដរាបណាហ្វូងសត្វអំពិលអំពែកហើរពីលើក្បាលខ្ញុំពីរទៅបីម៉ែត្រ រីឯផ្កាយវិញមានចម្ងាយដ៏ឆ្ងាយ ។ ចំពោះទស្សនៈខ្ញុំ វត្ថុទាំងពីរនេះស្ទើរតែស្រដៀងគ្នាបេះបិទ ។

ដូចជាហ្វូងសត្វអំពិលអំពែកដែរ ការល្បួង និង ការសាកល្បងហាក់ដូចជាធំក្រៃ លែងដោយសារវាស្ថិតនៅជិតបង្កើយ ។ ដូចគ្នានេះដែរ ពរជ័យដែលបានសន្យាប្រៀបបានទៅនឹងផ្កាយអាចត្រូវបានគេមើលឃើញថានៅដ៏សែនឆ្ងាយអនេក ។



រចនារូបភាព ដោយ ស៊ូហ៊ានណា ម៉ែរ៉ៈណាយ

ការខ្វះនូវការមើលឃើញវែងឆ្ងាយខាងវិញ្ញាណរបស់យើង អាចទទួលបាននូវលទ្ធផលជាច្រើន ។ កាលណារង្វាន់មើលទៅកាន់តែឆ្ងាយ យើងក៏ត្រូវបានល្បួងកាន់តែច្រើនឲ្យគិតថាយើងអាចពន្យារពេលនៃការប្រែចិត្តរបស់យើង ហើយនៅតែបានត្រឡប់ទៅព្រះវរបិតាសួគ៌ដើម្បីទទួលកេរមរតកដ៏អស់កល្បរបស់យើង ( សូមមើល អាលម៉ា 34:33–34 ) ។ យើងប្រហែលជាចាប់ផ្ដើមសង្ស័យពីរង្វាន់អស់កល្បជានិច្ចនោះ ឬសម្រេចចិត្តថា ការប្រព្រឹត្តតាមមនុស្សខាងសាច់ឈាមនៅពេលនេះពិតជាសប្បាយជាងការរង់ចាំពរជ័យដែលនឹងកើតមាននៅពេលក្រោយដ៏យូរនោះ ។ យើងប្រហែលជាភ័យខ្លាចចំពោះភាពស្មុគស្មាញឥតឈប់ឈរដ៏យូរទាស់នឹងអំពើបាប ឬខ្វះនូវសេចក្ដីជំនឿថា ព្រះអង្គសង្គ្រោះនឹងជួយយើងឲ្យទប់ទល់ការវាយប្រហាររបស់សាតាំង ។

ម្ដងម្កាល យើងទាំងអស់គ្នាបាត់បង់នូវទស្សនៈអស់កល្បជានិច្ចរបស់យើង រឿងដ៏សំខាន់គឺត្រូវពង្រឹងវាជាថ្មី ឲ្យបានកាន់តែឆាប់កាន់តែល្អ ។ ទោះជាពិភពលោកនេះអាចនឹងផ្ដល់នូវរង្វាន់ដែលគួរឲ្យរំជើបរំជួល ក្លែងក្លាយយ៉ាងណាក្ដី យើងអាចមើលទៅព្រះយេស៊ូវគ្រីស្ទ កាលយើងដើរលើផ្លូវបត់បែននៃជីវិត ហើយទុកចិត្តថា ទ្រង់ពិតជា « ប្រទានរង្វាន់ដល់អស់អ្នកដែលស្វែងរកទ្រង់ » ( ហេព្រើរ 11:6 ) ។

វាកន្លងទៅជាច្រើនឆ្នាំ ហើយ ចាប់តាំងពីខ្ញុំបានជិះទូកនៅតាមដងទន្លេនោះ ប៉ុន្តែរហូតមកដល់សព្វថ្ងៃនេះ កាលខ្ញុំប្រឈមមុខនឹងការល្បួង ខ្ញុំបានរំឭកខ្លួនឯងថា « វាគ្រាន់តែជាសត្វអំពិលអំពែកមួយក្បាលប៉ុណ្ណោះ » ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ ផ្លរីដា ស.រ.អា. ។*

# ដំឡូងមួយផ្លែសម្រាប់អ្នកគ្រូ

ដោយ ប៊ិននី ឌលស្រាដ់

*ខ្ញុំបានដឹងថា ខ្ញុំមិនចាំបាច់ធ្វើការបម្រើធំៗនៅគ្រប់ពេលនោះទេ ។ សកម្មភាពដ៏តូចតាចមួយនៃសេចក្ដីស្រឡាញ់ក៏ជារឿងដ៏ល្អដែរ ។*

ក្នុងនាមជាគ្រូបង្រៀនថ្នាក់មត្តេយ្យអស់ជាង 25 ឆ្នាំ ខ្ញុំបានទទួលរបស់ដ៏គួរឲ្យចាប់អារម្មណ៍ជាច្រើនពីសិស្សតូចៗរបស់ខ្ញុំ ។ សារខ្លី រូបគំនូរ និងវត្ថុតាមការស្រមើស្រមៃគឺជាអំណោយភាគច្រើនដែលខ្ញុំបានទទួល ។ ប៉ុន្តែកាលពីឆ្នាំមុន គឺជាលើកទីមួយហើយដែលខ្ញុំបានដំឡូងមួយផ្លែ ។

មានកុមារីម្នាក់ឈ្មោះ អិមម៉ា នាងបានដើរមកតុខ្ញុំ ហើយបាននិយាយដោយអង់អាចថា « ដំឡូងមួយផ្លែសម្រាប់អ្នកគ្រូ ដោយសារខ្ញុំគ្មានផ្លែប៉ោមជូនអ្នកគ្រូទេ » ។ វាគឺជាផ្លែដំឡូងធំល្មមហើយជូតយ៉ាងស្អាតលើសដំឡូងឯទៀតៗ ។ ខ្ញុំបានអរគុណនាង ហើយដាក់វានៅលើតុ ។ ខ្ញុំបានឃើញភ្នែកធំៗពណ៌ខៀវរបស់អិមម៉ា ជះពន្លឺដោយមោទនភាព កាលនាងបានសម្លឹងមើលដំឡូងនោះពេញមួយថ្ងៃ ។

ក្រោយពីថ្នាក់រៀនបានបញ្ចប់ កាលខ្ញុំដើរទៅតុរបស់ខ្ញុំ ខ្ញុំបានឃើញផ្លែដំឡូងនោះមានទឹកមុខញញឹមដ៏ទន់ភ្លន់ ។ កុមារមើលឃើញរឿងនានាថាជារឿងយ៉ាងសាមញ្ញ ហើយជាមួយនឹងផ្លែដំឡូងនោះ អិមម៉ា បានបង្រៀនខ្ញុំពីរឿងមួយដ៏សំខាន់ ។ ខ្ញុំបានទុកវានៅលើតុខ្ញុំអស់រយៈពេលមួយសប្ដាហ៍ ដោយព្រោះតែវាជួយរំឭកដល់ខ្ញុំ ។

ក្នុងនាមជាគ្រូបង្រៀនសួរសុខទុក្ខ និង ជាបងប្អូនស្ត្រីម្នាក់ក្នុងវួដខ្ញុំ ខ្ញុំចង់បម្រើដល់អ្នកដទៃ ប៉ុន្តែខ្ញុំតែងរង់ចាំ « ឱកាសបម្រើធំៗ » ពីមុនខ្ញុំចំណាយពេលជួយ ។ ប្រសិនបើខ្ញុំរវល់ ហើយមិនអាចធ្វើម្ហូបបន្ថែម ឬប្រសិនបើខ្ញុំចង់ជូនផ្កាជាអំណោយពិសេសមួយ ប៉ុន្តែមិនអាចទៅហាងផ្កាបាន នោះខ្ញុំបានបដិសេធនឹងសំឡេងតូចរហៀងនៃព្រះវិញ្ញាណខ្សឹបប្រាប់ថាមានមនុស្សម្នាក់ដែលត្រូវការការបម្រើរបស់ខ្ញុំ ។

ខ្ញុំបានតាំងចិត្តថា « ខ្ញុំនឹងធ្វើរឿងមួយនៅសប្ដាហ៍នេះ ពេលខ្ញុំទំនេរ » ។ « ថ្ងៃនេះគ្មាននរណាត្រូវការខ្ញុំទេ » ។

ចុះប្រសិនបើមាននរណាម្នាក់ពិតជាត្រូវការខ្ញុំវិញនោះ ? ចុះប្រសិនបើខ្ញុំមិនបានបដិសេធការបំផុសគំនិតឲ្យទៅលេងនឹងអ្នកជិតខាងដែលមានវ័យចំណាស់ម្នាក់ ឬស្ត្រីមេម៉ាយវ័យក្មេងដែលទើបតែ បាត់បង់ស្វាមីថ្មីៗវិញនោះ ? តើខ្ញុំអាចជួយឬបម្រើបានដែរឬទេ បើទោះជាខ្ញុំអាចផ្ដល់ឲ្យបានតែ — « ដំឡូងតូចមួយ » ក្នុងពេលនោះក្ដី ?

ខ្ញុំបានរៀននូវមេរៀនដ៏អស្ចារ្យមួយពី អិមម៉ា ថាខ្ញុំកំពុងតែខិតខំទាំងលំបាកដើម្បីនឹងអនុវត្តទង្វើនោះ ។ ប្រសិនបើខ្ញុំគ្មានផ្លែប៉ោមទេនោះ ខ្ញុំអាចឲ្យជាដំឡូងវិញ ហើយខ្ញុំត្រូវធ្វើវាឥឡូវនេះ ។ ខ្ញុំមិនត្រូវចាំទាល់តែធ្វើម្ហូប ឬធ្វើនំក្រែមក្រូចឆ្មា ដែលមានរសជាតិក្រូចដ៏ពិសេសរបស់ខ្ញុំនោះទេ ខ្ញុំអាចទិញនំឃុកគីមួយប្រអប់ជំនួសវិញក៏បាន ។ ខ្ញុំមិនចាំបាច់ទៅហាងទិញផ្កាជាញឹកញាប់នោះទេ ប៉ុន្តែខ្ញុំអាចជួបនិយាយគ្នាក្នុងពេលខ្លីមួយដោយគ្មានផ្កាបាន ។ ការធ្វើប័ណ្ណជូនពរដោយខ្លួនឯងជាការល្អ ប៉ុន្តែការទូរសព្ទទៅលេងក៏ជាការល្អផងដែរ ។ ខ្ញុំមិនចាំបាច់មានកាយវិការនៃការបម្រើធំៗគ្រប់ពេលវេលានោះទេ ។ កាយវិការដ៏តូចតាចមួយនៃសេចក្ដីស្រឡាញ់ក៏ជារឿងដ៏ប្រពៃដែរ ។

ឥឡូវនេះ ខ្ញុំយកផ្លែដំឡូងនោះមកផ្ទះហើយ ប៉ុន្តែខ្ញុំគិតថា ខ្ញុំនឹងមិនហូបវាឡើយ ។ វាជួយរំឭកខ្ញុំគ្រប់ពេលឲ្យបម្រើ កាលខ្ញុំបានទទួលការបំផុសគំនិត ។



ឥឡូវនេះ ខ្ញុំផ្ដល់នូវអ្វីដែលខ្ញុំអាចធ្វើបានជំនួសឲ្យការរង់ចាំដល់ពេលក្រោយ ។ ដំឡូងមួយផ្លែសម្រាប់អ្នកគ្រូ ពិតជាអំណោយដ៏វិសេសវិសាលមែន ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋយូថាហ៍ ស.រ.អា. ។*

រូបថតដោយ FENG YU/ISTOCK/THINKSTOCK

# ព័ត៌មាននៃសាសនាចក្រ

*សូមចូលទៅកាន់គេហទំព័រ news.lds.org សម្រាប់ព័ត៌មាន និងព្រឹត្តិការណ៍នានាបន្ថែមទៀត*

## តម្រូវការនានាដើម្បីលើកទឹកចិត្តសិស្សថ្នាក់សិក្ខាសាលាឲ្យលើកកម្ពស់ដល់ការសិក្សា

តម្រូវការថ្មីមួយសម្រាប់ការបញ្ចប់ថ្នាក់សិក្ខាសាលាដែលនឹងជួយសិស្ស « លើកកម្ពស់ដល់ការសិក្សា » ត្រូវបានដាក់ឲ្យអនុវត្តទូទាំងសាសនាចក្រ។ តម្រូវការនានាដែលដាក់ឲ្យអនុវត្តក្នុងការសិក្សានៅដើមឆ្នាំនេះពីគោលលទ្ធិ និង សេចក្តីសញ្ញា និង ប្រវត្តិសាសនាចក្រ មានរួមចំណុចពីរសំខាន់៖

1. សិស្សថ្នាក់សិក្ខាសាលានឹងតម្រូវឲ្យអានព្រះគម្ពីរដែលពួកគេកំពុងសិក្សាពេញមួយឆ្នាំ បន្ថែមពីលើការទទួលបានពិន្ទុដោយផ្អែកទៅលើវត្តមាន និង ឯកសារគាំទ្រពីប៊ីស្សព ឬប្រធានសាខា ។ ការអានព្រះគម្ពីរត្រូវបានគូសបញ្ជាក់តាំងពីមុនមកហើយ ប៉ុន្តែឥឡូវនេះ តម្រូវឲ្យធ្វើសម្រាប់ការបញ្ចប់ការសិក្សា ។
2. សិស្សនឹងតម្រូវឲ្យឆ្លងកាត់ការប្រឡងវគ្គសិក្សាចំនួនពីរអំឡុងពេលមួយឆ្នាំ ដោយទទួលបានពិន្ទុយ៉ាងហោចណាស់ 75 ភាគរយ ។ ការប្រឡងលើកទីមួយនឹងត្រូវធ្វើឡើងនៅពាក់កណ្តាលឆ្នាំ ហើយការប្រឡងលើកទីពីរនឹងមាននៅចុងឆ្នាំនៃការសិក្សានោះ ។ ការប្រឡងទាំងឡាយនឹងទាក់ទងជាទូទៅលើការយល់ដឹងពីគោលលទ្ធិ និង ការអនុវត្តន៍គោលការណ៍ទាំងឡាយក្នុងជីវិតរស់នៅប្រចាំថ្ងៃ ។

*សិស្សថ្នាក់សិក្ខាសាលានៅហ្គុយយ៉ាណា អាមេរិចខាងត្បូងកំពុងសិក្សាព្រះគម្ពីររួមគ្នា ។*



តម្រូវការនានាសម្រាប់ថ្នាក់សិក្ខាសាលាថ្មីគឺ-សិក្សារួមជាមួយនឹងសៀវភៅ *ប្រកាសដំណឹងល្អទ្រង់៖ មគ្គុទេសសម្រាប់ការបម្រើជាអ្នកផ្សព្វផ្សាយសាសនា* និងកម្មវិធីសិក្សាសម្រាប់យុវវ័យនៅថ្ងៃអាទិត្យ *ចូរមកតាមខ្ញុំ* — នឹងផ្តល់ដល់យុវវ័យនូវឱកាសដើម្បីប្រែក្លាយខ្លួនកាន់តែនឹងមាំក្នុងទីបន្ទាល់ មានការយល់ដឹងកាន់ជ្រៅជ្រះពីដំណឹងល្អ ហើយបង្កើនសមត្ថភាពដើម្បីចែកចាយចំណេះដឹងរបស់ពួកគេនៅពេលពួកគេរៀបចំជីវិតសម្រាប់ការបម្រើ និងភាពជាសិស្ស ។

នៅរាល់ចុងឆ្នាំ សិក្សានុសិស្សនឹងទទួលសញ្ញាប័ត្រដែលបញ្ជាក់ថា ពួកគេបានបញ្ចប់តម្រូវការចាំបាច់នានា ( រួមទាំងការអាននិងការវាយតម្លៃនានា ) ឬក៏ទទួលបានសញ្ញាប័ត្រទទួលស្គាល់មួយដែលបញ្ជាក់ថាពួកគេបំពេញតម្រូវការវត្តមាន ។ ■

## ការអញ្ជើញអោយធ្វើលិបិក្រមបានផ្តល់នូវកំណត់ត្រាថ្មី

អ្នកចូលរួមជាច្រើនក្នុងកម្មវិធីការអញ្ជើញអោយធ្វើលិបិក្រមជាអន្តរជាតិ បានបង្កើតកំណត់ត្រាថ្មីមួយសម្រាប់អ្នកចូលរួមធ្វើលិបិក្រមភាគច្រើនបំផុតតាមអិនធើណិតក្នុងរយៈពេលតែមួយថ្ងៃប៉ុណ្ណោះ ។ នៅថ្ងៃទៅ 22 ខែ កក្កដា ឆ្នាំ 2014 មានអ្នកស្ម័គ្រចិត្តចំនួន 66511 នាក់បានប្រើអិនធើណិត ដើម្បីមើលរូបភាពនៃបញ្ជីពង្សប្រវត្តិ ហើយវាយបញ្ចូលព័ត៌មានក្នុងទិន្នន័យស្រាវជ្រាវនៅលើគេហទំព័រ familysearch.org។ តាមកំណត់ត្រាកាលពីលើកមុនក្នុងតែមួយថ្ងៃ មានអ្នកស្ម័គ្រចិត្តចំនួន 49,025 នាក់ ដែលបានចូលរួមនៅខែកក្កដា ឆ្នាំ 2012 ក្នុងកិច្ចប្រឹងប្រែងដ៏ខ្លាំងបំផុតនៃការស្រង់ធ្វើលិបិក្រមប្រជាជនអាមេរិចកាំងចាប់ពីឆ្នាំ 1940 ។

ការអញ្ជើញក៏បានបង្កើតឲ្យមានចំនួនរួមគ្នាសរុបខ្ពស់បំផុតទីពីរ ( លិបិក្រម ឬវិនិច្ឆ័យ ) នៃកំណត់ត្រាដែលបានបញ្ជូន ដែលកើនទៅដល់ 5.7 លាននាក់ ។ ( រាល់បញ្ជីនិមួយៗត្រូវបានធ្វើលិបិក្រមដោយអ្នកស្ម័គ្រចិត្តពីរនាក់ ហើយបន្ទាប់មក ពិនិត្យដោយអ្នកស្ម័គ្រចិត្តទីបីម្នាក់ដែលគេហៅគាត់ថាជា អាជ្ញាកណ្តាល ដើម្បីបញ្ជាក់ពីគុណភាព និង ភាពច្បាស់លាស់ ) ។

ប៊ីស្សព ខ្រូអេត៍ ពីទីក្រុងត្រូឡូស ប្រទេសបារាំង បានមានប្រសាសន៍ថា « សមាជិកទាំងឡាយរបស់យើងទាំងក្មេង និង ចាស់បានចូលរួមដោយចិត្តសប្បាយរីករាយ » ។ « ជាបទពិសោធន៍ដ៏ល្អអ្វីម៉្លេះ »។

ខ្រិសតូហ្វើ ចនស៍ មកពីវេលស៍ បានមាននិយាយថា « យើងបានរៀបចំធ្វើរាត្រីជួបជុំក្រុមគ្រួសារដើម្បីយើងទាំងអស់គ្នាអាចធ្វើលិបិក្រម — ឪពុកម្តាយ និងកូនប្រាំពីរនាក់អាយុពី 18 ឆ្នាំ ទៅ 5ឆ្នាំ។ ពួកគេទាំងអស់គ្នាបានប្រាប់ថា គ្រាន់តែមួយគ្រួសារ យើងបានធ្វើលិបិក្រមជាង 900 កំណត់ត្រា! »។

ណាតាលី ផៃរី ពី ក្រុងបាំងកក ប្រទេស ថៃ បានមាននិយាយថា នាងពេញចិត្តនឹងការចូលរួមថ្ងៃធ្វើលិបិក្រមទូទាំងពិភពលោកជាមួយកូនស្រីរបស់នាងដែលមានអាយុ 13 ឆ្នាំ។ ហើយគ្រីស ស្មីត ពីខលី ប្រទេសអង់គ្លេស បានមាននិយាយថា គាត់អាចស្វែងរកឈ្មោះគ្រួសារថ្មីប្រហែលជា30ឈ្មោះ ដោយមានរួមទាំង «ក្មេងស្រីម្នាក់ដែលបានស្លាប់បន្ទាប់ពីបុណ្យជ្រមុជទឹក ហើយបានប្រទះឃើញនៅចន្លោះបញ្ជីការស្រង់ស្ថិតិប្រជាជន » ។ ■







*អែលឌើរ ដេវិឌ អេ.បែដណា មានប្រសាសន៍ថា ប្រព័ន្ធផ្សព្វផ្សាយសង្គមផ្ដល់ឱកាសតែមួយគត់គឺដើម្បីចែកចាយដំណឹងល្អ ។*

# សាវកផ្ដល់ពាក្យទូន្មានអំពីប្រព័ន្ធផ្សព្វផ្សាយសង្គម

អែលឌើរ ដេវិឌ អេ.បែដណា នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានមានប្រសាសន៍ក្នុងសន្និសីទមួយនៃកម្មវិធីអប់រំជាសប្ដាហ៍នៅសកលវិទ្យាល័យព្រិកហាំង យ៉ាំង នៅថ្ងៃទី 19 ខែ សីហា ឆ្នាំ 2014 ថា « ចាប់ផ្ដើមនៅទីនេះ និងនៅពេលនេះ ខ្ញុំទូន្មានអ្នកឲ្យបោសសំអាតផែនដីនេះជាមួយនឹងសារលិខិតដែលពោពេញដោយសេចក្ដីសុចរិត និងសេចក្ដីពិត សារលិខិតទាំងឡាយដែលជាការពិតស្អាងឡើង និង គួរឲ្យសរសើរ ហើយត្រូវតែពិតដូចជាការបោសសំអាតផែនដីដោយទឹកជំនន់មែន ។

« ខ្ញុំអធិស្ឋានថា យើងនឹងមិនគ្រាន់តែចូលរួមក្នុងទឹកជំនន់ដែលឡើងយ៉ាងឆាប់រហ័ស ហើយបន្ទាប់មកស្រកយ៉ាងរហ័សនោះទេ » លោកបានមានប្រសាសន៍ក្នុងសារមួយដែលគូសបញ្ជាក់ពីអំណាចនៃប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីទំនាក់ទំនងសេចក្ដីពិត ។ អែលឌើរ បែដណា បានហៅជំនាន់យើងថាជា « រដូវកាលដែលមានតែមួយគត់ក្នុងប្រវត្តិសាស្ត្រពិភពលោក » ដែលយើងមានពរជ័យនៃភាពរុងរឿងខាងគំនិត និងសម្ភារឆ្នៃប្រឌិតថ្មីៗដែលផ្ដល់ឲ្យនូវលទ្ធភាព និង ពន្លឿនកិច្ចការនៃសេចក្ដីសង្គ្រោះ ។

លោកបានមានប្រសាសន៍ថា « ប្រមាណជា 40 ភាគរយនៃកម្លាំងអ្នកផ្សព្វផ្សាយសាសនារបស់យើងទូទាំងពិភពលោកនឹងប្រើប្រាស់សម្ភារឌីជីថលដែលជាឧបករណ៍ក្នុងកិច្ចការនៃការផ្លាស់ប្រែចិត្តជឿ ការថែរក្សា ហើយនិងការធ្វើឲ្យសកម្មឡើងវិញ »។ ខ្ញុំមានទំនុកចិត្តថា យើងទាំងអស់គ្នាក៏ទទួលស្គាល់ពីរបៀបដែលបច្ចេកវិជ្ជាបានបង្កើនល្បឿនកិច្ចការពង្សប្រវត្តិ និង កិច្ចការព្រះវិហារបរិសុទ្ធ ការសិក្សាដំណឹងល្អស្ដារឡើងវិញផ្ទាល់ខ្លួន និង ជាគ្រួសារ ហើយដែលធ្វើឲ្យយើងអាចរៀនបាន មើលឃើញ និងទទួលបានបទពិសោធ៍ពីពិភពលោកនេះយ៉ាងងាយតាមរបៀបដ៏អស្ចារ្យ » ។

លោកបានលើកឡើងពីប្រព័ន្ធផ្សព្វផ្សាយសង្គមនាពេលថ្មីៗនេះដោយមានរួមទាំងវិដេអូសម្រាប់បុណ្យអ៊ីស្ទើរដែលផលិតដោយសាសនាចក្រដែលមានចំណងជើងថា *ដោយសារទ្រង់*, ដែលមានគេចូលទស្សនាចំនួនជាងប្រាំលានដងក្នុងប្រទេស 191 និងស្លាកមួយដែលសរសេរថា #តើបានអធិស្ឋានឬ ដែលនាំឲ្យមានការសន្ទនាច្រើនជាង 4000 ដងអំពីភាពចាំបាច់នៃការអធិស្ឋាន ។

ការណ៍ទាំងអស់នេះ និង កិច្ចប្រឹងប្រែងផ្សេងៗទៀតគឺ « គ្រាន់តែជាខ្សែទឹកដ៏តូចមួយប៉ុណ្ណោះ » លោកមានប្រសាសន៍ដោយការអំពាវនាវទៅកាន់ពួកបរិសុទ្ធថ្ងៃចុងក្រោយ « ឲ្យជួយផ្លាស់ប្ដូរខ្សែទឹកនេះទៅជាទឹកជំនន់ » ។ លោកក៏បានមានប្រសាសន៍ថា នៅពេលប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ៖

- « យើងគប្បីមិននិយាយបំផ្លើស បញ្ឆេញបញ្ឆូល ឬធ្វើពុតជានរណាម្នាក់ ឬក៏អ្វីមួយដែលពុំមែនជាខ្លួនយើងនោះទេ ។ មាតិការបស់យើងគួរតែទុកចិត្តបាន និង ស្ថាបនាឲ្យរឹងមាំ » ។
- « សារលិខិតរបស់យើងគួរតែព្យាយាមស្អាងឡើង និង លើកតម្កើងជាជាងជម្លោះ ប្រកែកគ្នា ថ្កោលទោស ឬ បន្ថោកគ្នា » ។
- « ចូរក្លាហាន ហើយមោះមុត ប៉ុន្តែកុំធ្វើហួសហេតុក្នុងការគាំទ្រ និង ការពារដល់ជំនឿរបស់យើង ហើយចៀសវាងពីជម្លោះ ។ ក្នុងនាមជាសិស្ស គោលបំណងរបស់យើងគួរតែប្រើប្រាស់ប៉ុស្ដ៍ប្រព័ន្ធផ្សព្វផ្សាយសង្គមជាមធ្យោបាយសម្រាប់បញ្ចាំងពន្លឺ និង សេចក្ដីពិតនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដែលបានស្ដារឡើងវិញ » ។
- « ការចំណាយពេលច្រើនពេកអាចជាការខ្ជះខ្ជាយ ការទំនាក់ទំនងច្រើនពេកអាចត្រូវបានខូចប្រយោជន៍ ឬ បំផ្លាញ ហើយបទដ្ឋានដ៏មានតម្លៃនៃសេចក្ដីសុចរិតអាចត្រូវបានបង្អាក់នៅពេលបច្ចេកវិជ្ជាត្រូវបានប្រើប្រាស់មិនត្រឹមត្រូវ ។ យើងគប្បីកុំអនុញ្ញាតសូម្បីតែការអុវត្តន៍ល្អនៃប្រព័ន្ធផ្សព្វផ្សាយសង្គមដើម្បីច្រានចោលការប្រើប្រាស់ពេលវេលាថាមពល និង ធនធានទាំងឡាយរបស់យើងឲ្យកាន់តែប្រសើរ និងប្រសើរបំផុត » ។
- « យើងមិនចាំបាច់ប្រែក្លាយខ្លួនជាអ្នកជំនាញ ឬអ្នកនិយមជ្រុលខាងប្រព័ន្ធផ្សព្វផ្សាយសង្គមនោះទេ ។ ហើយយើងមិនចាំបាច់ចំណាយពេលច្រើនពេកក្នុងការបង្កើត និងចែកចាយនូវសារលិខិតដ៏ល្អិតល្អន់នោះដែរ » ។ ■



សូមឲ្យអ្នកជ្រើសធ្វើជាពន្លឺដល់ពិភពលោកនេះ ដើម្បីជួយសង្គ្រោះដល់កូនចៅរបស់ព្រះ ដើម្បីមាន សេចក្ដីអំណរ ហើយទីបំផុតគឺដើម្បីទទួលបាន ពរជ័យនៃជីវិតដ៏នៅអស់កល្បជានិច្ច ។



**ដោយអែលឌើរ**
**រ័សុល អិម ណិលសុន**
ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់

# តើអ្នកនឹង ជ្រើសយកអ្វី ?

*អ្នករាល់គ្នាត្រូវបានចាត់ដោយព្រះវរបិតាសួគ៌របស់អ្នក ដើម្បីស្ថាបនានគរព្រះនៅលើផែនដីឥឡូវនេះ ហើយរៀបចំប្រជាជនដើម្បីទទួលព្រះអង្គសង្គ្រោះ ។*

ក្នុងនាមជា « យុវវ័យនៃសិទ្ធិពីកំណើតដ៏ថ្លៃថ្នូរ »[1] អ្នកគឺជាបុត្រាបុត្រីពិតរបស់ព្រះ បានកើតមកក្នុងពេលពិសេសនេះនៃប្រវត្តិសាស្រ្តពិភពលោកសម្រាប់គោលបំណងពិសិដ្ឋបំផុតមួយ ។ ទោះជាតម្លៃសីលធម៌ និងសាសនាក្នុងសង្គមហាក់ដូចជាចុះអន់ថយនៅទូទាំងសាកលលោកក្តី ក៏យុវវ័យនៃសាសនាចក្រនេះគឺជាអ្នកកាន់តាមបទដ្ឋាននៃព្រះអម្ចាស់ ហើយជាប្រភពពន្លឺដើម្បីទាញចិត្តអ្នកដទៃមករកទ្រង់ដែរ ។ អត្តសញ្ញាណ និងគោលបំណងរបស់អ្នកគឺពិសេស ។

តើអត្តសញ្ញាណរបស់អ្នកជាអ្វីទៅ ? អ្នកគឺជាកូនចៅនៃសេចក្តីសញ្ញាដែលព្រះបានចុះជាមួយនឹងលោកឪពុកអ័ប្រាហាំ ពេលលោកអ័ប្រាហាំត្រូវបានសន្យាថា « អស់ទាំងគ្រួសារនៅផែនដីនឹងបានពរដោយសារពូជឯង » ( កិច្ចការ 3:25 សូមមើលផងដែរ នីហ្វៃទី 1 15:18, នីហ្វៃទី 3 20:25 ) ។ អ្នកក៏ជា « កូនចៅនៃជំនាន់ដែលបានសន្យានោះផងដែរ »[2] ជារយៈកាលនេះនៃប្រវត្តិសាស្រ្តពិភពលោក ពេលដែលដំណឹងល្អនឹងត្រូវប្រកាសយ៉ាងទូលំទូលាយពេញពិភពលោក ។

តើគោលបំណងអ្នកជាអ្វីទៅ ? បងប្អូនប្រុស អ្នកត្រូវបានតែងតាំងពីមុននៅក្នុងពិភពជីវិតមុនជីវិតនេះដើម្បីកាន់បព្វជិតភាព ( សូមមើល អាលម៉ា 13:2–3 ) ។ ហើយបងប្អូនស្រី អ្នកត្រូវបានជ្រើសរើសតាំងពីមុនបង្កើតពិភពលោក ដើម្បីបង្កើត ហើយមើលថែកូនចៅព្រះ ហើយពេលធ្វើដូច្នោះ អ្នកផ្តល់សិរីល្អដល់ព្រះ ( សូមមើល គ. និង ស. 132:63 ) ។ បងប្អូនស្រី តើអ្នកមានបានគិតពិនិត្យពីអត្ថន័យពិតនៃការធ្វើជាអ្នកបង្កបង្កើតជាមួយព្រះដែរឬទេ ?

យុវជន និង យុវនារី អ្នករាល់គ្នាម្នាក់ៗ គឺត្រូវបានចាត់ដោយព្រះវរបិតាសួគ៌ ដើម្បីស្ថាបនានគរព្រះនៅលើផែនដីឥឡូវនេះ ហើយរៀបចំប្រជាជនឲ្យទទួលព្រះអង្គសង្គ្រោះ ពេលទ្រង់នឹងគ្រងរាជ្យជាព្រះមែស៊ីក្នុងសហសវត្ស ។ សិទ្ធិពីកំណើតដ៏ថ្លៃថ្នូរ អត្តសញ្ញាណ គោលបំណង និងការចាត់តាំងដ៏ទេវភាពរបស់អ្នកបានញែកអ្នកចេញពីអ្នកដទៃទៀតទាំងអស់ ។

ប៉ុន្តែសិទ្ធិពីកំណើត ការតែងតាំងពីជីវិតមុន និងការចាត់តាំងរបស់អ្នក ពុំអាចសង្គ្រោះ ឬលើកតម្កើងអ្នកបានទេ ។ អ្នកនឹងធ្វើកិច្ចការនោះតាមរយៈការសម្រេចចិត្តផ្ទាល់ខ្លួនរបស់អ្នក និងនៅពេលអ្នកជ្រើសរើសទទួលយក

រូបថតដោយ ក្រេក ឌីម៉ុន

ព្រះចេស្ដានៃដង្វាយធួនរបស់ព្រះអម្ចាស់មកក្នុងជីវិតអ្នក ។ គោលការណ៍នៃសិទ្ធិជ្រើសរើសដ៏អស់កល្បមហិមានោះមានតម្លៃចំពោះផែនការនៃព្រះវរបិតាយើង ។ ដូច្នេះ យុវវ័យនៃសិទ្ធិពីកំណើតដ៏ថ្លៃថ្នូរ ៖ តើអ្នកនឹងជ្រើសរើសយកអ្វី ?

**តើអ្នកនឹងជ្រើសរើសឲ្យមានចំណេះចម្រើនឡើងមែនទេ ?**

ការអប់រំគឺជាអ្វីដែលអ្នកត្រូវទទួល ។ គ្មាននរណាផ្សេងអាចទទួលវាជំនួសអ្នកបានទេ ។ មិនថាអ្នកនៅកន្លែងណាទេ សូមបង្កើតនូវបំណងប្រាថ្នាដ៏ខ្លាំងក្លាមួយដើម្បីរៀនសូត្រ ។ ចំពោះយើង ដែលជាពួកបរិសុទ្ធថ្ងៃចុងក្រោយ ការទទួលបានការអប់រំពុំមែនគ្រាន់តែជាឯកសិទ្ធិមួយប៉ុណ្ណោះទេ តែវាជាការទទួលខុសត្រូវខាងសាសនាមួយផងដែរ ។ « សិរីល្អនៃព្រះគឺជាបញ្ញា » ( គ. និង ស. 93:36 ) ។ ប្រាកដណាស់ ការអប់រំរបស់យើងនឹងនៅយូរអង្វែងដល់អស់កល្បជានិច្ច ។

« គោលការណ៍នៃបញ្ញាណាក៏ដោយដែលយើងបានទទួលនៅក្នុងជីវិតនេះ នោះនឹងនៅជាប់នឹងយើងក្នុងដំណើររស់ឡើងវិញ ។

« ហើយបើសិនជាអ្នកណាមួយបានចំណេះវិជ្ជា និងបញ្ញាច្រើនជាងអ្នកផ្សេងនៅក្នុងជីវិតនេះ . . . គាត់ [ ឬនាង ] នឹងបានប្រៀបច្រើននៅពិភពខាងមុខ » ( គ. និង ស. 130:18–19 ) ។

ទស្សនៈរយៈពេលយូរដូច្នោះនឹងជួយអ្នកធ្វើការជ្រើសរើសល្អពីការរៀនសូត្រ ។

ចូរកុំខ្លាចក្នុងការតោងចាប់គោលដៅអ្នកឡើយ — ទោះជាសុបិនអ្នកក្ដី ! ប៉ុន្តែសូមដឹងថា គ្មានផ្លូវកាត់ណាដើម្បីបានឧត្តមភាព និងមានសមត្ថភាពនោះទេ ។ ការអប់រំគឺជាការខុសប្លែកគ្នារវាង*ការប៉ងប្រាថ្នា* ថាអ្នកអាចជួយអ្នកដទៃ និង *ការមានលទ្ធភាពអាច* ជួយដល់ពួកគេ ។

**តើអ្នកនឹងជ្រើសរើសយកការរស់នៅបែបណា ?**

អ្នកត្រូវបានរំពឹងទុកឲ្យរស់នៅខុសពីអ្នកដទៃ ។ អ្នកដឹងនូវអ្វីដែល ប៉ុលបានមានប្រសាសន៍ទៅកាន់យុវជន ធីម៉ូថេ ថា ៖ « ធ្វើជាគំរូដល់ពួកអ្នកជឿដោយពាក្យសម្ដី កិរិយាប្រព្រឹត្ត សេចក្ដីស្រឡាញ់ សេចក្ដីជំនឿ និង សេចក្ដីសប្បុរស » ( ធីម៉ូថេទី 1 4:12 ) ។[3] សូមជ្រើសរើសយកការគិត និងទង្វើរខុសប្លែកពីមនុស្សក្នុងពិភពលោកនេះ ។ សូមជ្រើសរើសយកឲ្យមានភាពខុសប្លែក ហើយមើលឃើញពីឥទ្ធិពលល្អដែលអ្នកនឹងអាចទទួលបាន ។ ដូចស៊ីស្ទើរ អាឌីស ជី ខាប មានគ្រាមួយបានថ្លែងថា « អ្នកមិនអាចក្លាយជាអ្នកសង្គ្រោះជីវិតបានឡើយ បើអ្នកមានរូបរាងដូចនឹងពួកអ្នកហែលទឹកផ្សេងទៀតដែលនៅលើឆ្នេរសមុទ្រនោះ » ។[4]

ក្នុងនាមជាយុវវ័យដែលមានសិទ្ធិពីកំណើតថ្លៃថ្នូរ នោះអ្នកមានការចាប់ផ្ដើមដ៏អស្ចារ្យនៅក្នុងជីវិត ប៉ុន្តែអ្នកក៏មាននូវទំនួលខុសត្រូវបន្ថែមទៀតផងដែរ ។ « ត្បិតដល់អ្នកណាដែលត្រូវបានប្រទានឲ្យច្រើន នោះក៏មានតម្រូវការជាច្រើនវិញ » ( គ. និង ស. 82:3 សូមមើលផងដែរ លូកា 12:48 ) ។ ផ្នែកនៃតម្រូវការនោះគឺការក្លាយជាទំពថ្មីម្នាក់ ។ ពេលអ្នកជ្រមុជទឹក អ្នកចុះឈ្មោះជាថ្មីនៅក្នុងកងទ័ពរបស់ព្រះអម្ចាស់ ។[5] ពីមុនជីវិតនេះ អ្នកបានឈរក្បែរព្រះយេស៊ូវគ្រីស្ទក្នុងចម្បាំងនៅស្ថានសួគ៌ ។ ហើយឥឡូវនេះ ចម្បាំងរវាងកម្លាំងនៃអំពើល្អ និងអំពើអាក្រក់បានបន្តនៅលើផែនដី ។ វាពិត ! ( សូមមើល វិវរណៈ 12:7–9, គ. និង ស. 29:40–41 ) ។ នៅខាងព្រះគឺព្រះយេស៊ូវគ្រីស្ទ ដែលត្រូវបានតែងតាំងទុកជាមុនជាព្រះអង្គសង្គ្រោះនៃពិភពលោក ( សូមមើល នីហ្វៃទី 1 10:4 ) ។ រីឯបក្សម្ខាងទៀតគឺសាតាំង — ដែលជាអ្នកបះបោរ ជាអ្នកបំផ្លាញសិទ្ធិជ្រើសរើស ( សូមមើល ម៉ូសេ 4:3 ) ។[6]

ផែនការរបស់ព្រះ អនុញ្ញាតឲ្យមារសត្រូវល្បួងអ្នក ដើម្បីឲ្យអ្នកអាចអនុវត្តសិទ្ធិជ្រើសរើសអ្នក ជ្រើសល្អជំនួសអាក្រក់ ជ្រើសប្រែចិត្ត ជ្រើសមករកព្រះយេស៊ូវគ្រីស្ទ ហើយជឿលើការបង្រៀនទ្រង់ ព្រមទាំងធ្វើតាមគំរូទ្រង់ ។ ឱ ! នេះជាការទទួលខុសត្រូវ និងជាទំនុកចិត្តដ៏ធំធេងណាស់ !

សេរីភាពអ្នកដើម្បីប្រព្រឹត្តដោយខ្លួនឯង គឺសំខាន់ចំពោះការរីកចម្រើន និងសុភមង្គលអស់កល្បរបស់អ្នក ដែលមារសត្រូវបានខិតខំយ៉ាងខ្លាំង ដើម្បីធ្វើឲ្យវាចុះខ្សោយ ( សូមមើល នីហ្វៃទី 2 2:27, 10:23 ) ។

**តើអ្នកនឹងបង្កើតអាទិភាព ដើម្បីជួយអ្នកឲ្យធ្វើការជ្រើសរើសក្នុងជីវិតដែរឬទេ ?**

ការជ្រើសរើសអ្នកនឹងពុំមែនរវាងអំពើល្អ និងអំពើអាក្រក់ទាំងអស់នោះទេ ។ មនុស្សជាច្រើននឹងជ្រើសរើសរវាងជម្រើសល្អពីរ ។ សេចក្ដីពិតពុំត្រូវបានបង្កើតឡើងដូចគ្នានោះទេ ដូច្នេះអ្នកត្រូវដាក់អាទិភាព ។ ក្នុងការស្វែងរកចំណេះដឹងរបស់អ្នក សូមដឹងថា សេចក្ដីពិតដ៏សំខាន់បំផុតដែលអ្នកអាចរៀនបានមកពីព្រះអម្ចាស់ ។ ក្នុងការអធិស្ឋានទៅព្រះវរបិតាសម្រាប់ពួកសិស្សទ្រង់ ព្រះអម្ចាស់ផ្ទាល់បានបញ្ជាក់ពីការណ៍នេះ ។ ទ្រង់បានមានបន្ទូលថា « នេះគឺជាជីវិតដ៏នៅអស់កល្បជានិច្ច គឺឲ្យគេបានស្គាល់ដល់ទ្រង់ដ៏ជាព្រះពិតតែមួយ និងព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់បានចាត់ឲ្យមកផង » ( យ៉ូហាន 17:3 ) ។ ក្រៅពីការព្យាយាមរៀនសូត្រ ចូរព្យាយាមស្គាល់ព្រះ ជាព្រះវរបិតាសួគ៌អ្នក និងព្រះរាជបុត្រាទ្រង់ ព្រះយេស៊ូវគ្រីស្ទ ។ សូមមកស្គាល់ទ្រង់ ហើយស្រឡាញ់ទ្រង់ដូចជាខ្ញុំ ។

បទគម្ពីរមួយទៀតស្ដីពីអាទិភាពបានជួយខ្ញុំក្នុងជីវិតខ្ញុំ គឺបទគម្ពីរមួយនេះ ៖ « ចូរស្វែងរកនគរ និង សេចក្ដីសុចរិតនៃព្រះជាមុនសិន ទើបគ្រប់របស់ទាំងនោះនឹងបានប្រទានមកអ្នករាល់គ្នាថែមទៀតផង » ( ម៉ាថាយ 6:33 ) ។

លើសពីអ្វីផ្សេងទៀតក្នុងពិភពលោកនេះ អ្នកគួរតែធ្វើការជ្រើសរើសអ្វីដែលដឹកនាំទៅកាន់ជោគវាសនានៃជីវិតអស់កល្បរុងរឿងដ៏ខ្ពស់បំផុត ។ នោះជាសិរីល្អធំជាងគេរបស់ព្រះសម្រាប់អ្នក ( សូមមើល គ. និង ស. 14:7, ម៉ូសេ 1:39 ) ។ សូមជ្រើសយកជីវិតអស់កល្បជាអាទិភាពខ្ពស់បំផុតរបស់អ្នក ! សូមសិក្សាព្រះគម្ពីរ ដូចជាកណ្ឌ 76 និង 88 ក្នុងគោលលទ្ធិ និងសេចក្ដីសញ្ញា ដើម្បីយល់បន្ថែមពីពរជ័យផ្សេងៗគ្នា ដែលកំពុងរង់ចាំអ្នកដែលជ្រើសយកជីវិតអស់កល្បនិងអ្នកដែលបដិសេធ ។ សូមជ្រើសយកជីវិតអស់កល្បជាអាទិភាពខ្ពស់បំផុតរបស់អ្នក ហើយកត់សម្គាល់ពីរបៀបដែលការជ្រើសរើសផ្សេងទៀតបានកើតឡើងយ៉ាងងាយ ។



*មនុស្សជាច្រើនពុំទាន់បានរកឃើញសេចក្ដីពិតពីព្រះនៅឡើយទេ ហើយមិនដឹងពីទីកន្លែងនឹងរកវា ។ ប៉ុន្តែ អ្នករាល់គ្នាដែលជាយុវវ័យដែលមានសិទ្ធិពីកំណើតថ្លៃថ្នូរនឹងជួយសង្គ្រោះដល់ពួកគេ ។*

**តើអ្នកនឹងជ្រើសរើសសេពគប់មនុស្សបែបណា ?**

អ្នកនឹងសេពគប់មនុស្សល្អជាច្រើនដែលជឿលើព្រះដែរ ។ មិនថាពួកគេជាសាសនាយូដា កាតូលីក ប្រូតេស្តង់ ឬម៉ូស្លីមទេ ពួកអ្នកជឿដឹងថាមានសេចក្ដីពិត ។ ពួកអ្នកជឿលើព្រះក៏មានសតិសម្បជញ្ញៈមួយដែរ ។ ពួកអ្នកជឿគោរពតាមច្បាប់សង្គម និងច្បាប់ព្រះដោយស្ម័គ្រចិត្ត ទោះជាច្បាប់នោះមិនអាចប្រតិបត្តិតាមបានក្ដី ។

ជាមួយការតាំងចិត្តរបស់អ្នកដើម្បីគោរពច្បាប់សង្គម និងច្បាប់ព្រះ នោះអ្នកនឹងឈប់នៅត្រង់ភ្លើងពណ៌ក្រហម ទោះជាគ្មានចរាចរដែលអាចមើលឃើញនឹងភ្នែកក្ដី ។ ក្នុងនាមជាកូនចៅនៃព្រះ ទោះជានគរបាលមិនបានចាប់អ្នក ទោះជាអ្នកបានលួច ធ្វើឃាត ឬធ្វើអំពើកំផិតក្ដី អ្នកដឹងថា ទង្វើទាំងនេះខុស ហើយថានៅទីបំផុត ព្រះនឹងតម្រូវឲ្យអ្នកទទួលខុសត្រូវ ។ អ្នកដឹងថា លទ្ធផលចំពោះការមិនប្រតិបត្តិតាមគឺមានដល់ភាពអស់កល្ប ពុំមែនត្រឹមតែខាងសាច់ឈាមនោះទេ ។

នៅពេលអ្នកធ្វើដំណើរក្នុងជីវិត អ្នកក៏នឹងជួបមនុស្សដែលមិនជឿព្រះផងដែរ ។ ពួកគេភាគច្រើនពុំទាន់ស្វែងរកឃើញសេចក្ដីពិតពីព្រះនៅឡើយ ហើយមិនដឹងពីទីកន្លែងនឹងរកវា ។ ប៉ុន្តែ អ្នករាល់គ្នាដែលជាយុវវ័យដែលមានសិទ្ធិពីកំណើតថ្លៃថ្នូរនឹងជួយសង្គ្រោះដល់ពួកគេ ។ ក្នុងចំនួនដ៏ធំ អ្នកកំពុងប្រមូលផ្ដុំគ្នាតាមសំណើររបស់ព្យាការីនៃព្រះ ដើម្បីមានពួកអ្នកផ្សព្វផ្សាយសាសនាកាន់តែច្រើន ។ យើងមានអំណរជាខ្លាំងចំពោះពួកគេម្នាក់ៗ !

នៅពេលអ្នកសេពគប់នឹងពួកអ្នកមិនជឿព្រះ ចូរប្រុងប្រយ័ត្នថា ពួកគេមួយចំនួនអាចនឹងមិនខ្វល់ពីចំណាប់អារម្មណ៍ក្នុងចិត្តអ្នកឡើយ ( សូមមើល គ. និង ស. 1:16, 89:4 ) ។ រំពេចណាអ្នកដឹងពីការណ៍នោះ សូមចាកចេញពីពួកគេភ្លាម ហើយជារៀងរហូត ( សូមមើល ធីម៉ូថេទី 1 6:5–6, 11 ) ។

ជាអកុសល អ្នកនឹងជួបមនុស្សដែលការស្វែងរកសុភមង្គលរបស់ពួកគេហាក់ដូចជាកំពុងនាំពួកគេចុះទៅចំណោតរអិលនៃអំពើបាប ។ សូមប្រុងប្រយ័ត្នចំពោះចំណោតរអិលនោះ ! រាល់ភាពរីករាយក្នុងអំពើបាបគឺមានរយៈពេលខ្លី ហើយការចងចាំដ៏អាក្រក់ របស់វានឹងអន្ទងតាមរយៈការព្រួយ និងកំហុស ។ ទង្វើរខុសឆ្គងនៃភាពស្និទ្ធស្នាល ធ្វើឲ្យខូចអ្វីៗដែលបានរៀបចំឡើងដោយព្រះដើម្បីរួបរួមប្ដី និងប្រពន្ធ វាគឺជាតម្រាប់ក្លែងក្លាយ ។ បទពិសោធន៍មិនស្របច្បាប់នីមួយៗ គឺបានដកយកចេញនូវអត្ថន័យជ្រាលជ្រៅ និងអនុស្សាវរីយដ៏ផ្អែមល្ហែម ។

**តើអ្នកនឹងជ្រើសយកសេរីភាព ឬការជាប់ឃុំឃាំង ?**

កងកម្លាំងសត្រូវនៅព័ទ្ធជុំវិញ ។ អ្នកកំពុងរស់នៅក្នុង ដែនដីដែលសត្រូវកាន់កាប់ ។[7] ជំងឺនៃរូបអាសគ្រាមដ៏អាក្រក់កើតមានពាសពេញ ។

វាដាក់អន្ទាក់ដល់អស់ជនដែលងាកទៅរកឥទ្ធិពលអាក្រក់របស់វា ។

ការណ៍នេះត្រូវបានទតឃើញជាមុនដោយព្រះអម្ចាស់ ដោយទ្រង់មានបន្ទូលថា « ហើយឥឡូវនេះ យើងបង្ហាញដល់អ្នកនូវសេចក្ដីអាថ៌កំបាំងមួយ ជាការណ៍ដែលមាននៅក្នុងបន្ទប់សម្ងាត់ ដើម្បីនាំឲ្យកើតមានសេចក្ដីបំផ្លិចបំផ្លាញដល់អ្នកកន្លងពេលក្រោយមក ហើយអ្នករាល់គ្នាពុំបានដឹងសោះ » ( គ. និង ស. 38:13 សូមមើលផងដែរ ខ 28 ) ។

សូមពិចារណាពីរបៀបដែលមនុស្សជាច្រើន ក្នុងបន្ទប់សម្ងាត់ជាច្រើនកំពុងស្វែងរកបំផ្លាញជីវិត និងសុភមង្គលអ្នកនៅពេលនេះ ! ការល្បួងខាងរូបកាយពុំមែនជារឿងថ្មីនោះទេ ។ សាវកពេត្រុសបានព្រមានពីអន្ទាក់ដូចគ្នានេះ កាលលោកបានសរសេរថា ៖

« គេ . . . បិទនុយប្រកបដោយសេចក្ដីសម្រើបខាងសាច់ឈាម . . . ដើម្បីចាប់ពួកអស់អ្នកដែលទើបតែនឹងរួចចេញពីពួកវង្វេង ។ . . .

« ទាំងសន្យាឲ្យអ្នកទាំងនោះបានសេរីភាពផង តែខ្លួនគេក៏នៅជាប់ជាបាវបម្រើរបស់ពួកពុករលួយវិញ ៖ ត្បិតបើអ្នកណាត្រូវគេបង្ក្រាបខ្លួន នោះត្រូវនៅជាប់ជាបាវរបស់អ្នកនោះហើយ » ( ពេត្រុសទី 2 2:18–19 ) ។

សូមជៀសពីការជាប់ឃុំឃាំងនោះ ឱ បងប្អូនប្រុសស្រីជាទីស្រឡាញ់របស់ខ្ញុំអើយ ។ បើអ្នកកំពុងមើលរូបអាសគ្រាមនៅពេលនេះ សូមបញ្ឈប់វា ! សូមស្វែងរកជំនួយពីប៊ីស្សពអ្នក ។ គ្មាននរណាម្នាក់ឆ្លាតគ្រប់គ្រាន់ ដើម្បីយកឈ្នះលើសត្រូវតែម្នាក់ឯងបានឡើយ នៅពេលពួកគេត្រូវបានបំពុលដោយរូបអាសគ្រាមនោះ ។ វាអាក្រក់ដូចជាជំងឺឆ្លង ញៀនដូចជាថ្នាំ ហើយកាត់ដូចជាទឹកអាស៊ីត ។

### តើអ្នកនឹងជ្រើសរើសដើរតាមព្រះអម្ចាស់ ឬគំនិតរបស់មនុស្ស ?

សូមសិក្សាដោយយកចិត្តទុកដាក់នូវ « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » ។[8] គ្រួសារស្ថិតនៅក្រោមការវាយប្រហារនៅជុំវិញពិភពលោក ប៉ុន្តែសេចក្ដីពិតនៃការប្រកាសពីគ្រួសារនឹងពង្រឹងដល់អ្នក ។

អ្នកត្រូវយល់ដឹងពីផលវិបាកដ៏នៃចម្បាំងបច្ចុប្បន្នរបស់សង្គមទៅលើនិយមន័យជាច្រើននៃអាពាហ៍ពិពាហ៍ ។ ការជជែកវែកញែកសព្វថ្ងៃនេះជាប់ទាក់ទងនឹងសំណួរថា តើមនុស្សពីរនាក់មានភេទដូចគ្នាអាចរៀបការបានដែរឬទេ ។ ប្រសិនបើអ្នកមានសំណួរពីគោលជំហររបស់សាសនាចក្រចំពោះបញ្ហានេះ ឬបញ្ហាដ៏សំខាន់ណាមួយផ្សេងទៀត សូមសញ្ជឹងគិតវាប្រកបដោយការអធិស្ឋាន បន្ទាប់មកសូមស្ដាប់តាមសារលិខិតរបស់ព្យាការីដែលកំពុងរស់នៅ ។ ប្រសាសន៍ដ៏បំផុសគំនិតរបស់ពួកលោក រួមជាមួយនឹងការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នឹងផ្ដល់ការយល់ដឹងពេញលេញដ៏ពិតដល់គំនិតអ្នក ។[9]

ការជជែកគ្នាពីអាពាហ៍ពិពាហ៍គឺគ្រាន់តែជាការវែកញែកគ្នាមួយ ដែលនឹងសាកល្បងអ្នកនាពេលអនាគត ។ ដើម្បីប្រឆាំងនឹងសំឡេងរំខាននៃមារសត្រូវ អ្នករាល់គ្នា ជាយុវវ័យដែលមានសិទ្ធិពីកំណើតដ៏ថ្លៃថ្នូរ នឹងជ្រើសរើសដើម្បីឈរការពារព្រះអម្ចាស់ និង សេចក្ដីពិតរបស់ទ្រង់ ។

សាវកប៉ុលបានព្យាករពីស្ថានភាពអាក្រក់នៃជំនាន់យើង ( សូមមើល ធីម៉ូថេទី 2 3:1–5 ) ។ ទស្សនៈដ៏ត្រឹមត្រូវរបស់លោកអំពីការបំផ្លិចបំផ្លាញខាងវិញ្ញាណនៅជំនាន់យើងត្រូវបានអមដោយការសន្និដ្ឋានបញ្ជាក់សារជាថ្មីរបស់លោក ដោយប្រាប់យើងពីរបៀបរស់នៅឲ្យមានសុវត្ថិភាពថា ៖ « តាំងពីក្មេងតូចមក អ្នកបានស្គាល់បទគម្ពីរទាំងប៉ុន្មានដែលអាចនឹងនាំឲ្យអ្នកមានប្រាជ្ញាដល់ទីសង្គ្រោះ ដែលបានដោយសារសេចក្ដីជំនឿជឿដល់ព្រះយេស៊ូវគ្រីស្ទផង » ( ធីម៉ូថេទី 2 3:15 ) ។

ខ្ញុំសូមបន្ថែមការណែនាំផ្ទាល់របស់ខ្ញុំពីលើការណែនាំរបស់លោកថា ៖ សូមបន្តសិក្សាព្រះគម្ពីរ ។ សូមបន្តធ្វើរឿងដែលស្ថាបនាសេចក្ដីជំនឿអ្នកលើព្រះយេស៊ូវគ្រីស្ទ ។ រួចហើយកត់សម្គាល់ពីការជ្រើសរើសដ៏ឈ្លាសវៃ ដែលអ្នកបានលើកទឹកចិត្តឲ្យតាមដោយឯកឯង ។

សេចក្ដីជំនឿរបស់អ្នកលើព្រះយេស៊ូវគ្រីស្ទ និង លើដំណឹងល្អទ្រង់នឹងផ្ដល់នូវភាពក្លាហានដល់អ្នក ដើម្បីរៀបអាពាហ៍ពិពាហ៍ ហើយនាំកូនចៅមកក្នុងគ្រួសារអ្នក ខណៈដែលអ្នកនៅក្មេង ហើយមានលទ្ធភាពមានពួកគេ ។ នៅពេលអ្នកមានវ័យដូចខ្ញុំ អ្នកនឹងឲ្យតម្លៃដល់កូនចៅអ្នក និង កូនរបស់ពួកគេលើសពីកេរ្តិ៍ឈ្មោះ ឬទ្រព្យដែលនឹងអាចកើតមានឡើងទាំងអស់ ។

### តើអ្នកនឹងរៀបចំខ្លួនសម្រាប់ការសម្ភាសផ្ទាល់របស់អ្នកជាមួយនឹងព្រះអង្គសង្គ្រោះដោយរបៀបណា ?

អ្នករាល់គ្នា ដែលជាយុវវ័យដែលមានសិទ្ធិពីកំណើតដ៏ថ្លៃថ្នូរ គឺមិនទាន់ល្អឥតខ្ចោះនៅឡើយទេ ។ គឺយើងគ្រប់គ្នា ។ ដូច្នេះ រួមនឹងពួកយើងផ្សេងទៀត មានអំណរគុណជាខ្លាំងចំពោះដង្វាយធួននៃព្រះអង្គសង្គ្រោះ ដែលផ្ដល់ការអភ័យទោសពេញលេញ នៅពេលប្រែចិត្តដោយពិតប្រាកដ ។ អ្នកក៏ដឹងដែរថា ជីវិតរមែងស្លាប់នេះខ្លីណាស់ ។ នៅពេលកំណត់មួយ អ្នករាល់គ្នានឹងបញ្ចប់ពីជីវិតរមែងស្លាប់នេះ ហើយផ្លាស់ទៅភពមួយទៀត ។

ថ្ងៃជំនុំជម្រះរង់ចាំយើងម្នាក់ៗ ។ ខ្ញុំដឹងថា « អ្នកឆ្មាំទ្វារគឺជាព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល ហើយទ្រង់មិនជួលបាវបម្រើនៅឡើយ » ( នីហ្វៃទី 2 9:41 ) ។ ពិតណាស់ យើងម្នាក់ៗនឹងមានការសម្ភាសផ្ទាល់ខ្លួនមួយជាមួយនឹងព្រះយេស៊ូវគ្រីស្ទ ។

ជីវិតរាល់ថ្ងៃលើផែនដីផ្ដល់ពេល និង ឱកាសដល់អ្នកឲ្យរៀបចំខ្លួនសម្រាប់ការសម្ភាសនោះ ។ សូមដឹងពីការណ៍នេះថា ៖ ពេលអ្នកជ្រើសរស់នៅខាងព្រះអម្ចាស់ នោះអ្នកនឹងមិនឯកោឡើយ ។ ព្រះបានប្រទានសិទ្ធិដល់អ្នកដើម្បីទទួលបានជំនួយរបស់ទ្រង់ ខណៈដែលអ្នកធ្វើដំណើរលើផ្លូវដ៏គ្រោះថ្នាក់ក្នុងជីវិតរមែងស្លាប់នេះ ។ ពេលអ្នកបង្វែរចិត្តអ្នកទៅរកទ្រង់ ដោយព្យាយាមយ៉ាងស្មោះក្នុងការអធិស្ឋានប្រចាំថ្ងៃ ទ្រង់នឹងបញ្ជូនពួកទេវតាទ្រង់មកជួយអ្នក ( សូមមើល គ. និង ស. 84:88 ) ។ ទ្រង់ប្រទានព្រះវិញ្ញាណបរិសុទ្ធឲ្យគង់នៅក្បែរអ្នកពេលអ្នករស់នៅដោយសក្ដិសម ។ ទ្រង់ប្រទានព្រះគម្ពីរដល់អ្នក ដើម្បីអ្នកអាចត្រូវបានចិញ្ចឹមបីបាច់យ៉ាងពេញលេញដោយព្រះបន្ទូលនៃព្រះយេស៊ូវគ្រីស្ទ



*សូមជ្រើសយកការគិត និង ទង្វើខុសប្លែកពីមនុស្ស ក្នុងពិភពលោកនេះ ។ សូមជ្រើសយកឲ្យមាន ភាពខុសប្លែក ហើយមើល ឃើញពីឥទ្ធិពលល្អដែលអ្នក នឹងទទួលបាន ។*

( សូមមើល នីហ្វៃទី 2 9:51, 32:3 ) ។ ទ្រង់ប្រទានប្រសាសន៍នៃព្យាការីកំពុងរស់នៅឲ្យអ្នកស្ដាប់ ។

**តើអ្នកនឹងដាក់ការទុកចិត្តអ្នកទៅលើនរណា ?**

អ្នកដឹងថា ព្រះគឺជាព្រះវរបិតារបស់អ្នក ។ ទ្រង់ស្រឡាញ់អ្នក ។ ទ្រង់សព្វព្រះទ័យឲ្យអ្នករីករាយ ។ សូមដាក់ការទុកចិត្តអ្នកលើទ្រង់ ( សូមមើល នីហ្វៃទី 2 4:34, 28:31 ) ។ សូមរក្សាការផ្ដោតអារម្មណ៍អ្នកលើព្រះវិហារបរិសុទ្ធរបស់ទ្រង់ ។ ចូរមានភាពសក្ដិសមដើម្បីទទួលបានពិធីបរិសុទ្ធនៃអំណោយទានពិសិដ្ឋ និង ការផ្សារភ្ជាប់របស់អ្នក ។ ចូរបន្តស្មោះត្រង់ចំពោះសេចក្ដីសញ្ញានោះ ហើយត្រឡប់ទៅព្រះវិហារបរិសុទ្ធជាញឹកញាប់ ។ សូមចងចាំថា គោលដៅដ៏ខ្ពស់បំផុតរបស់អ្នកគឺដើម្បីទទួលពរជ័យដ៏ធំជាងគេរបស់ព្រះ នោះគឺជាជីវិតដ៏នៅអស់កល្បជានិច្ច ( សូមមើល គ. និង ស. 14:7 ) ។ ពិធីបរិសុទ្ធនៅក្នុងព្រះវិហារបរិសុទ្ធគឺចាំបាច់ចំពោះពរជ័យនោះ ( សូមមើល គ. និង ស. 131:1–3 ) ។

ខ្ញុំសូមអញ្ជើញអ្នកឲ្យសិក្សាបទគម្ពីរអំពីអត្តសញ្ញាណ គោលបំណង និង ពរជ័យរបស់អ្នកប្រកបដោយការអធិស្ឋាន ( សូមមើល គ. និង ស. 86:8–11 ) ។ មែនហើយ អ្នកពិតជាយុវវ័យដែលមានសិទ្ធិពីកំណើតដ៏ថ្លៃថ្នូរ ដែលបានបង្កើតតាមរូបភាពនៃព្រះ ។ អ្នកគឺជាកូនចៅពេញច្បាប់របស់ទ្រង់ នៅទីនេះដើម្បីព្យាយាម ហើយសាកល្បង។ សូមឲ្យអ្នកជ្រើសធ្វើជាពន្លឺដល់ពិភពលោកនេះ ដើម្បីជួយសង្គ្រោះដល់កូនចៅរបស់ព្រះ ដើម្បីមានសេចក្ដីអំណរ ហើយសំខាន់បំផុតគឺដើម្បីទទួលបានពរជ័យនៃជីវិតដ៏នៅអស់កល្បជានិច្ច ។ ■

*ដកស្រង់ចេញពីសុន្ទរកថានៅការប្រជុំធម្មនិដ្ឋាននៃប្រពន្ធ័អប់រំសាសនាចក្រ « យុវវ័យនៃសិទ្ធិពីកំណើតដ៏ថ្លៃថ្នូរ ៖ តើអ្នកនឹងជ្រើសយកអ្វី ? » ធ្វើឡើងនៅសាកលវិទ្យាល័យព្រិកហាំ យ៉ង់ — ហាវ៉ៃ នៅថ្ងៃទី 6 ខែកញ្ញា ឆ្នាំ 2013 ។ សម្រាប់សុន្ទរកថាទាំងស្រុង សូមចូលទៅ cesdevotionals.lds.org ។*

**កំណត់ចំណាំ**

1. « Carry On » *Hymns,* ល.រ 255 ។
2. « Hope of Israel » *Hymns,* ល.រ. 259 ។
3. ពាក្យក្រិក *anastrophe* ប្រែ*ការសន្ទនា* ត្រូវបានបកប្រែ មានន័យថា ការរស់នៅក្នុងរបៀបលើកតម្កើង ។
4. អាឌីស ហ្វ្រីន ខាប *I Walk by Faith* ( ឆ្នាំ 1987 ) ទំព័រ 97 ។
5. សូមមើល «We Are All Enlisted» *Hymns,* ល.រ. 250 ។
6. មនុស្សមួយចំនួនពិពណ៌នាពីសិទ្ធិជ្រើសរើសជា *សេរីភាពក្នុងការជ្រើសរើស* ប៉ុន្តែនោះពុំមែននៅក្នុងព្រះគម្ពីរឡើយ ។ ព្រះគម្ពីរបានចែងថាជា *សិទ្ធិជ្រើសរើសខាងក្រមសីលធម៌* ( សូមមើល គ. និង ស. 101:78 ) ។
7. សូមមើល ប៊ិយដ៍ ឃេ ផាកកឺ « Counsel to Youth » *Liahona,* ខែ វិច្ឆិកា ឆ្នាំ 2011 ទំព័រ 16, 18 ។
8. សូមមើល « The Family: A Proclamation to the World » *Liahona,* ខែ វិច្ឆិកា ឆ្នាំ 2010 ទំព័រ 129 ។
9. ការប្រកាសដ៏បំផុសគំនិតរបស់សាសនាចក្រអំពីក្រុមគ្រួសារបានចែងថា ៖ « ក្រុមគ្រួសារត្រូវបានតែងតាំងឡើងដោយព្រះ ។ អាពាហ៍ពិពាហ៍រវាងបុរស និង ស្ត្រី គឺជាផ្នែកមួយដ៏សំខាន់ក្នុងផែនការដ៏នៅអស់កល្បជានិច្ចរបស់ទ្រង់ ។ កូនចៅមានសិទ្ធិនឹងកើតមកក្នុងចំណងអាពាហ៍ពិពាហ៍ ហើយនឹងត្រូវបានចិញ្ចឹមបីបាច់ដោយឪពុកម្ដាយ » ( « The Family: A Proclamation to the World » *Liahona,* ខែ វិច្ឆិកា ឆ្នាំ 2010 ទំព័រ 129 ) ។

# តើយើងគួរធ្វើជា គ្រូបង្រៀន ប្រភេទណា ?

*ប្រសិនបើយើងពិតជាចង់ប្រែក្លាយដូចជាព្រះអង្គសង្គ្រោះ យើងត្រូវតែរៀនបង្រៀនតាមរបៀបដែលទ្រង់បានបង្រៀន ។*

**ដោយគណៈប្រធានសាលាថ្ងៃអាទិត្យទូទៅ**



*ថាត អរ ខាលីស្ទើរ ជាប្រធាន (កណ្ដាល) ចន អេស ធេនណើរ ជាទីប្រឹក្សាទីមួយ (ខាងឆ្វេង) និង ដេវិន ជី ឌើរ៉ាង់ ជាទីប្រឹក្សាទីពីរ (ខាងស្ដាំ)*

ព្រះអម្ចាស់ដែលបានរស់ឡើងវិញ រៀបនឹងបញ្ចប់ការបម្រើរបស់ទ្រង់នៅក្នុងទ្វីបអាមេរិក ។ មិនយូរប៉ុន្មាន ទ្រង់បានយាងចុះមកពីស្ថានសួគ៌ ដោយនាំយកពន្លឺទៅបំភ្លឺដល់ភាពងងឹតដែលបានគ្របដណ្ដប់លើដែនដីពួកសាសន៍នីហ្វៃ និង ពួកសាសន៍លេមិនបន្ទាប់ពីការសុគតរបស់ទ្រង់ ។ ទ្រង់បានបង្រៀន ថ្លែងទីបន្ទាល់ ហើយបានអធិស្ឋាន ។ ទ្រង់បានប្រសិទ្ធពរ ឆ្លើយតបនឹងសំណួរ ហើយស្ថាបនាសាសនាចក្រទ្រង់ឡើង ។ ឥឡូវនេះ កាលទ្រង់រៀបចំចាកចេញពីពួកសិស្សរបស់ទ្រង់ ទ្រង់បានបង្ហាញពីទំនួលខុសត្រូវមួយ ដែលបានធ្វើឲ្យពួកគេមាននូវភាពជឿជាក់ថា ៖

« អ្នករាល់គ្នាស្គាល់ការណ៍ទាំងឡាយដែលអ្នករាល់គ្នាត្រូវធ្វើនៅក្នុងសាសនាចក្ររបស់យើង ត្បិតកិច្ចការទាំងឡាយដែលអ្នករាល់គ្នាបានឃើញយើងធ្វើយ៉ាងណា នោះអ្នករាល់គ្នាត្រូវធ្វើយ៉ាងនោះដែរ . . .

«. . . ដូច្នេះ តើអ្នករាល់គ្នាគួរធ្វើជាមនុស្សបែបណាទៅ ? យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា ត្រូវឲ្យបានដូចជាយើង » ( នីហ្វៃទី 3 27:27 ) ។

ព្រះយេស៊ូវបានអញ្ជើញយើងឲ្យប្រែក្លាយដូចជាទ្រង់ ហើយលក្ខណៈដ៏អស្ចារ្យមួយរបស់ទ្រង់ គឺជាសមត្ថភាពរបស់ទ្រង់ក្នុងការបង្រៀន ។ ទ្រង់គឺជាគ្រូបង្រៀនដ៏ឆ្នើមប្រពៃ ។ ដើម្បីប្រែក្លាយដូចជាទ្រង់ យើងក៏ត្រូវធ្វើជាគ្រូបង្រៀនដែលគួរឲ្យស្រឡាញ់ ហើយជួយផ្លាស់ប្ដូរជីវិតដែរ ទាំងនៅឯព្រះវិហារ និងនៅក្នុងផ្ទះ ។ ដើម្បីប្រែក្លាយដូចជាទ្រង់ យើងគួរមានបំណងប្រាថ្នាដ៏ឆាបឆួលក្នុងចិត្តយើងដើម្បីបង្រៀនដូចដែលទ្រង់បានបង្រៀន ។

## សំណួរ និង ការអញ្ជើញ

ជារឿយៗ ព្រះយេស៊ូវបានបង្រៀនតាមរយៈសំណួរ និង ការអញ្ជើញ ។ សូមពិចារណាពីគំរូមួយនៅក្នុងគ្រាដែលទ្រង់បានចំណាយពេលជាមួយនឹងពួកសិស្សនៅទ្វីបអាមេរិក ។ កាលពួកគេកំពុងអធិស្ឋាន ព្រះអង្គសង្គ្រោះបានបង្ហាញព្រះកាយដល់ពួកគេ ហើយបានសួរនូវសំណួរត្រង់ៗមួយថា ៖ « តើអ្នករាល់គ្នាចង់ឲ្យយើងប្រទានអ្វីដល់អ្នក? » ( នីហ្វៃទី 3 27:2 ) ។ តើអ្នកនឹងឆ្លើយបែបណា ប្រសិនបើព្រះអង្គសង្គ្រោះសួរសំណួរនេះដល់អ្នកវិញ ?

ពួកសិស្សបានតបថា ៖ « ឱព្រះអម្ចាស់អើយ យើងខ្ញុំសូមឲ្យព្រះអង្គប្រាប់យើងខ្ញុំនូវឈ្មោះដែលយើងខ្ញុំនឹងហៅសាសសនាចក្រនេះ ត្បិតមានការប្រកែកគ្នានៅក្នុងចំណោមប្រជាជនអំពីរឿងនេះ » ( នីហ្វៃ 3 27:3 ) ។

ព្រះគ្រីស្ទបានឆ្លើយនឹងសំណួរពួកគេថា ៖ « តើពួកគេពុំបានអានបទគម្ពីរទាំងឡាយដែលបានចែងថា អ្នករាល់គ្នាត្រូវយកព្រះនាមព្រះគ្រីស្ទដាក់លើខ្លួនដែលជានាមយើងទេឬ ? » ( នីហ្វៃទី 3 27:5 ) ។



សាសន៍នីហ្វៃទាំងដប់ពីរដោយ ហ្គារី អិល ខាប

សំណួរនេះបានក្រើនរំឭកយើងដល់ពួកអ្នករៀនរបស់ទ្រង់ថា ពួកគេគួរដាក់ការខិតខំមួយចំនួនទៅក្នុងការឆ្លើយសំណួរពួកគេផ្ទាល់ ហើយថាចម្លើយចំពោះសំណួរជាច្រើនអាចមាននៅក្នុងព្រះគម្ពីរ ។

រួចទ្រង់បានបញ្ចប់ដោយរំឭកពួកសិស្សពីផ្នែកសំខាន់នៃព្រះនាមរបស់ទ្រង់ ។ បន្ទូលរបស់ទ្រង់បានអញ្ជើញពួកគេឲ្យធ្វើសកម្មភាព ហើយបានសន្យាពីពរជ័យមួយដល់ពួកគេ ៖ « ហើយអស់អ្នកណាដែលដាក់នាមយើងលើខ្លួន ហើយកាន់ខ្ជាប់ដរាបដល់ចុងបំផុត អ្នកនោះហើយនឹងបានសង្គ្រោះនៅថ្ងៃចុងក្រោយបង្អស់ » ( នីហ្វៃទី 3 27:6 ) ។

## គំរូនៃការបង្រៀន

នៅក្នុងបទគម្ពីរខ្លីៗទាំងនេះ ព្រះយេស៊ូវគ្រីស្ទបានប្រទានដល់យើង នូវគំរូនៃការបង្រៀនមួយដ៏ទេវភាព ។ ទ្រង់បានចាប់ផ្ដើមដោយសំណួរមួយដែលបំផុសគំនិតដែលបានរៀបចំឡើង ដើម្បីញាណដឹងពីសេចក្ដីត្រូវការរបស់ពួកសិស្សទ្រង់ ។ រួចទ្រង់បានរង់ចាំ ហើយស្ដាប់ពីចម្លើយរបស់ពួកគេ ។

បន្ទាប់ពីពួកសិស្សរបស់ទ្រង់បានឆ្លើយរួច ទ្រង់បានជួយពួកគេស្វែងរកអ្វីដែលពួកគេកំពុងស្វែងរកតាមរយៈការដឹកនាំពួកគេឲ្យទៅរកព្រះគម្ពីរ ។

ទីបំផុត ទ្រង់បានធ្វើការអញ្ជើញចំនួនពីរ ហើយបានសន្យានូវពរជ័យមួយដ៏អស្ចារ្យដល់ជនដែលព្រមធ្វើតាមការអញ្ជើញរបស់ទ្រង់ ។ វិធីសាស្ត្រនៃការបង្រៀនរបស់ព្រះគ្រីស្ទនៅក្នុងគ្រានេះ អាចត្រូវបានសង្ខេបជាគោលការណ៍ប្រាំយ៉ាង ៖

***1. សួរសំណួរដែលមានប្រសិទ្ធភាព ។***

ព្រះអង្គសង្គ្រោះបានសួរថា « តើអ្នករាល់គ្នាចង់ឲ្យយើងប្រទានអ្វីដល់អ្នក ? » សំណួរនេះអញ្ជើញឲ្យមានចម្លើយផ្សេងៗគ្នា ។ កាលយើងសួរសំណួរបែបនេះ យើងជួយសិស្សឲ្យបង្ហាញប្រាប់នូវអ្វីដែលពួកគេចង់រៀន ហើយយើងជួយពួកគេឲ្យផ្ដោតលើរឿង ដែលសំខាន់បំផុតទាំងនោះ យើងធ្វើឲ្យពួកគេចូលរួមយ៉ាងសកម្មក្នុងការរៀនសូត្រ ។

***2. ស្ដាប់សិស្សរបស់អ្នក ។***

ព្រះយេស៊ូវគ្រីស្ទស្ដាប់ កាលពួកគេបានពោលថា « ឱព្រះអម្ចាស់អើយ យើងខ្ញុំសូមឲ្យព្រះអង្គប្រាប់

យើងខ្ញុំនូវឈ្មោះដែលយើងខ្ញុំនឹងហៅសាសនាចក្រនេះ » ។ តាមរយៈការស្ដាប់ យើងអាចរៀបចំខ្លួនបានយ៉ាងប្រសើរដើម្បីផ្ដោតអារម្មណ៍លើសេចក្ដីត្រូវការរបស់សិស្សយើង ។

***3. ប្រើព្រះគម្ពីរ ។***

ព្រះគ្រីស្ទបានរំឭកដល់ពួកសិស្សទ្រង់ថា « តើពួកគេពុំបានអានបទគម្ពីរទាំងឡាយដែលបានចែងថា អ្នករាល់គ្នាត្រូវយកព្រះនាមព្រះគ្រីស្ទដាក់លើខ្លួន ដែលជានាមយើងទេឬ ? » ទាំងគ្រូបង្រៀន និង សិស្សគួរចំណាយពេលមើលព្រះគម្ពីរដើម្បីរៀបចំខ្លួនសម្រាប់មេរៀន ។ ការសិក្សាព្រះគម្ពីរគឺជាផ្នែកមួយដ៏សំខាន់នៃការរៀបចំខ្លួនខាងវិញ្ញាណសម្រាប់គ្រូបង្រៀន និង សិស្ស ។

***4. អញ្ជើញសិស្សអ្នកឲ្យធ្វើសកម្មភាព ។***

ព្រះអម្ចាស់បានអញ្ជើញពួកសិស្សរបស់ទ្រង់ឲ្យ (1) លើកដាក់ព្រះនាមទ្រង់លើខ្លួនពួកគេ (2) កាន់ខ្ជាប់ដរាបដល់ចុងបំផុត ។ *ប្រកាសដំណឹងល្អរបស់យើង*ចែងថា « តែទោះជាមាន ក៏វាកម្រណាស់ដែលអ្នកគួរតែនិយាយទៅកាន់មនុស្ស ឬបង្រៀនពួកគេដោយគ្មានការអញ្ជើញឲ្យតាំងចិត្តដើម្បីធ្វើអ្វីមួយនោះ ដែលនឹងពង្រឹងសេចក្ដីជំនឿរបស់ពួកគេនៅក្នុងព្រះគ្រីស្ទ » ។[1] នេះគឺជាការប្រឹក្សាដ៏ល្អ ពុំមែនសម្រាប់តែពួកអ្នកផ្សព្វផ្សាយសាសនាប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់គ្រូបង្រៀនដំណឹងល្អទាំងអស់ ។

***5. រំឭកសិស្សអ្នកពីពរជ័យនៃការគោរពប្រតិបត្តិដែលបានសន្យា ។***

ជាចុងក្រោយ ព្រះយេស៊ូវគ្រីស្ទបានសន្យាដល់ពួកសិស្សទ្រង់ថា ជនដែលធ្វើតាមការអញ្ជើញរបស់ទ្រង់ « នឹងត្រូវបានសង្គ្រោះនៅថ្ងៃចុងក្រោយបង្អស់ » ។ ព្រះគ្រីស្ទបានសន្យាចំពោះយើងជាញឹកញាប់អំពីពរជ័យដ៏ជម្រើសបំផុតរបស់ទ្រង់សម្រាប់ការគោរពប្រតិបត្តិរបស់យើង ( សូមមើល គ. និង ស. 14:7 ) ។ យើងអាចធ្វើដូចគ្នាដែរ ក្នុងនាមជាគ្រូបង្រៀនពីដំណឹងល្អរបស់ទ្រង់ ។

គំរូខាងលើបានឆ្លុះបញ្ចាំងពីវិធីសាស្ត្របង្រៀនដ៏សំខាន់មួយចំនួន ដែលព្រះអង្គសង្គ្រោះបានប្រើ ។ ជាងនេះទៀត ពេលខ្លះទ្រង់បានបង្រៀនដោយរឿងប្រៀបប្រដូច ។ ម្ដងម្កាល ទ្រង់បានសាកល្បង ហើយថែមទាំងវាយផ្ចាលដល់ពួកអ្នករិះគន់ដល់ទ្រង់ផងដែរ ។ ប៉ុន្តែទ្រង់តែងតែបង្រៀនដោយសេចក្ដីស្រឡាញ់ សូម្បីតែជនដែលទ្រង់បានស្ដីបន្ទោសដែរ ( សូមមើល វិវរណៈ 3:19 ) ។

**ស្រឡាញ់សិស្សរបស់អ្នក**

យើងក៏ត្រូវបង្រៀនដោយសេចក្ដីស្រឡាញ់ និង សេចក្ដីសប្បុរសផងដែរ ប្រសិនបើយើងចង់បង្រៀនតាមរបៀបរបស់ព្រះអង្គសង្គ្រោះ ។ សេចក្ដីស្រឡាញ់បើកដួងចិត្តទាំងគ្រូបង្រៀន និង សិស្សដូច្នេះ « ទាំងពីរនាក់ [ អាចត្រូវបាន ] ស្អាងឡើងហើយត្រេកអរជាមួយគ្នា » ( គ. និង ស. 50:22 ) ។

គំរូមួយដ៏អស្ចារ្យពីសេចក្ដីស្រឡាញ់របស់ព្រះអង្គសង្គ្រោះចំពោះពួកសិស្សទ្រង់អាចរកឃើញនៅក្នុងនីហ្វៃទី 3 ត្រង់កន្លែងដែលទ្រង់អធិស្ឋាន ទ្រង់ព្រះកន្សែង ហើយបានប្រសិទ្ធពរដល់ប្រជាជននោះ ។ កាលទ្រង់បានអធិស្ឋានទៅព្រះវរបិតាទ្រង់ឲ្យប្រទានពរដល់ពួកគេ នោះពួកសាសន៍នីហ្វៃទទួលបាននូវសេចក្ដីស្រឡាញ់របស់ទ្រង់ ៖ « គ្មានអ្នកណាមួយអាចយល់នូវសេចក្ដីអំណរដែលពោរពេញនៅក្នុងព្រលឹងនៃយើង នៅពេលយើងបានឮទ្រង់អធិស្ឋានដល់ព្រះវរបិតាសម្រាប់យើងនោះទេ » ( នីហ្វៃទី 3 17:17 ) ។

ទ្រង់បានព្រះកន្សែងដោយសេចក្ដីអំណរសម្រាប់ពួកគេ ហើយបានប្រទានពរដល់ពួកគេសម្រាប់សេចក្ដីជំនឿរបស់ពួកគេ ហើយសេចក្ដីស្រឡាញ់របស់ទ្រង់ក៏អស្ចារ្យដែរ ៖

« មានពរហើយ អ្នករាល់គ្នា មកពីសេចក្ដីជំនឿរបស់អ្នក ។ ហើយ ឥឡូវនេះ មើលចុះ សេចក្ដីអំណររបស់យើងបានពោរពេញ ។

« ហើយកាលទ្រង់បានធ្វើការនេះចប់ហើយ នោះទ្រង់ក៏ ព្រះកន្សែងទៀត » ( នីហ្វៃទី 3 17:20–21 ) ។

សេចក្ដីស្រឡាញ់ដ៏អស្ចារ្យអាចបង្កើតឲ្យមានការរៀនសូត្រដ៏អស្ចារ្យ ។ ព្រះគម្ពីរកត់ត្រាថា « ព្រះភក្ត្ររបស់ទ្រង់បានញញឹមទៅរកពួកគេ » ហើយ « ចិត្តគេបានបើក បណ្ដាលឲ្យគេយល់នៅក្នុងចិត្តគេ » ( នីហ្វៃទី 3 19:25, 33) ។

**លើកទឹកចិត្តសិស្សរបស់អ្នកឲ្យថ្លែងទីបន្ទាល់**

ព្រះអង្គសង្គ្រោះក៏ប្រទានឱកាសដល់ពួកអ្នករៀនទ្រង់ឲ្យចែកចាយទីបន្ទាល់របស់ពួកគេផងដែរ ។ ឧទាហរណ៍ « កាលព្រះយេស៊ូវបានយាងមកដល់ក្រវល់ក្រុងសេសារា ភីលីព នោះទ្រង់មានព្រះបន្ទូល សាកសួរពួកសិស្សថា តើមនុស្សទាំងឡាយ គេថាកូនមនុស្សជានរណា ?

« ពួកសិស្សទូលឆ្លើយថា ខ្លះ ថាជា យ៉ូហាន បាទីស្ទ ខ្លះទៀតថាជាអេលីយ៉ា ហើយខ្លះទៀតថាជាយេរេមា ឬហោរាណាមួយ ។



« ទ្រង់មានបន្ទូលសួរថា ចុះ អ្នករាល់គ្នា វិញ តើថាខ្ញុំជាអ្នកណា ?

« ហើយស៊ីម៉ូន ពេត្រុសទូលឆ្លើយថា ទ្រង់ ជា ព្រះគ្រីស្ទ ជាព្រះរាជបុត្រា នៃ ព្រះដ៏មាន ព្រះជន្មរស់ » ( ម៉ាថាយ 16:13–16 ) ។

បន្ទាប់ពីពេត្រុសបានចែកចាយទីបន្ទាល់ខ្លួន ហើយ ព្រះគ្រីស្ទបានប្រកាសនូវពរជ័យដ៏អស្ចារ្យ មកលើគាត់ថា ៖

« អ្នកស៊ីម៉ូន កូនយ៉ូណាសអើយ ត្បិតមិនមែន សាច់ឈាមដែល បានសម្ដែង ឲ្យ អ្នកស្គាល់ទេ គឺព្រះវរបិតានៃខ្ញុំដែលគង់នៅស្ថានសួគ៌វិញ ។

« ខ្ញុំប្រាប់អ្នកថា អ្នកឈ្មោះពេត្រុស ខ្ញុំនឹង តាំង ពួកជំនុំខ្ញុំនៅលើថ្មដានេះ ហើយទ្វារ ស្ថានឃុំ ព្រលឹងមនុស្សស្លាប់ នឹង មិនដែលឈ្នះពួកជំនុំ ឡើយ ។

« ខ្ញុំនឹងឲ្យកូនសោនៃនគរស្ថានសួគ៌ដល់អ្នក បើ អ្នកនឹងចងទុកអ្វីៗនៅផែនដី នោះនឹងត្រូវចងទុក នៅលើស្ថានសួគ៌ដែរ ហើយបើអ្នកនឹងស្រាយអ្វីៗ នៅផែនដី នោះនឹងត្រូវស្រាយនៅស្ថានសួគ៌ដែរ » ( ម៉ាថាយ 16:17–19 ) ។

នៅក្នុងការព្យាយាមក្លាយជាគ្រូដ៏ឆ្នើមប្រពៃ យើងក៏ត្រូវសួរសំណួរ ដែលបំផុសគំនិតដល់សិស្ស ឲ្យចែកចាយទីបន្ទាល់ពួកគេ ទាំងពាក្យសម្ដី និង នៅក្នុងចិត្តរបស់ពួកគេជានិច្ចផងដែរ ។ យើងត្រូវ អញ្ជើញសិស្សយើងឲ្យស្វែងរកបទពិសោធន៍ ដែល បង្កើតនូវទីបន្ទាល់ផ្ទាល់ខ្លួននៅក្នុងជីវិតប្រចាំថ្ងៃ របស់ពួកគេ ។ រួចប្រសិនបើបរិយាកាសក្នុងថ្នាក់ រៀន ឬផ្ទះល្អដើម្បីអញ្ជើញព្រះវិញ្ញាណ សិស្សយើង នឹងមានចិត្តកក់ក្ដៅដើម្បីចែកចាយបទពិសោធន៍ ខាងវិញ្ញាណ និងទីបន្ទាល់ជាមួយនឹងគ្នាទៅវិញ ទៅមក ។

## រស់តាមអ្វីដែលអ្នកបង្រៀន

ព្រះយេស៊ូវគ្រីស្ទបានទូន្មានដល់មនុស្សដទៃ ឲ្យធ្វើរឿងដែលទ្រង់បានធ្វើ ( សូមមើលនីហ្វៃទី 3 27:21 ) — ដើម្បីធ្វើតាមទ្រង់ ( សូមមើលម៉ាថាយ 4:19 ) ។ ទ្រង់បានរស់នៅតាមអ្វីដែលទ្រង់បាន បង្រៀន ហេតុដូច្នេះហើយ ទ្រង់បានបង្រៀន តាមរយៈគំរូ ។

ទ្រង់បានបង្រៀនពីការបម្រើតាមរយៈការធ្វើ ការបម្រើ ។ ពិតជាមេរៀនមួយដ៏អស្ចារ្យណាស់អ្វី ម្លេះ សម្រាប់ពួកសិស្សរបស់ទ្រង់ កាលដែលទ្រង់ បានលាងជើងដល់ពួកគេនោះ ! « ដូច្នេះបើខ្ញុំដែល ជាព្រះអម្ចាស់ ហើយជាគ្រូបានលាងជើងឲ្យអ្នករាល់ គ្នា នោះគួរតែឲ្យអ្នករាល់គ្នាលាងជើងដល់គ្នានឹងគ្នា ដែរ ។

« ដ្បិតខ្ញុំបានធ្វើតម្រាប់ទុកឲ្យអ្នករាល់គ្នា ហើយ ដើម្បីឲ្យអ្នករាល់គ្នាត្រាប់តាមការដែលខ្ញុំបានធ្វើឲ្យ នោះ » ( យ៉ូហាន 13:14–15 ) ។

ទ្រង់បានបង្រៀនពីសេចក្ដីស្រឡាញ់ដោយ បង្ហាញសេចក្ដីស្រឡាញ់ ។ « ខ្ញុំឲ្យសេចក្ដីប ញ្ញត្តិថ្មីមួយដល់អ្នករាល់គ្នាគឺឲ្យអ្នករាល់គ្នា ស្រឡាញ់គ្នាទៅវិញទៅមក ត្រូវឲ្យស្រឡាញ់ គ្នាដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ » ( យ៉ូហាន 13:34 ) ។

ទ្រង់បានបង្រៀនពីការអធិស្ឋានដោយការធ្វើ ការអធិស្ឋាន ។ បន្ទាប់ពីធ្វើការអធិស្ឋានដ៏ ស្និទ្ធស្នាល ហើយវិសេសវិសាលបំផុតរហូតដល់ ពួកគេមិនអាចកត់ត្រាទុកបាន ទ្រង់មានបន្ទូល ថា « ហើយដូចដែលយើងបានអធិស្ឋាននៅក្នុង ចំណោមអ្នករាល់គ្នា នោះអ្នករាល់គ្នាក៏ត្រូវអធិស្ឋាន នៅក្នុងសាសនាចក្ររបស់យើងយ៉ាងនោះដែរ ។ . . . មើលចុះ យើងជាពន្លឺ យើងបានធ្វើជាគំរូដល់ អ្នករាល់គ្នា » ( នីហ្វៃទី 3 18:16 ) ។

ព្រះយេស៊ូវគ្រីស្ទបានប្រទានជាគំរូមួយសម្រាប់ គ្រូបង្រៀនដំណឹងល្អទាំងអស់ដែលចង់បង្រៀនតាម របៀបរបស់ទ្រង់ ។ ថ្វីកាលដែលយើងមិនទាន់ល្អ ឥតខ្ចោះដូចជាទ្រង់ទេនោះ យើងអាចខិតខំដោយ ឧស្សាហ៍ដើម្បីរស់នៅតាមអ្វីដែលយើងបង្រៀន ។ នៅក្នុងទំនុកច្រៀងនៃចម្រៀងមួយបទរបស់កុមារ គ្រូបង្រៀនអាចមានលទ្ធភាពនិយាយនូវឃ្លាថា « ធ្វើតាមដូចខ្ញុំធ្វើ ធ្វើតាមធ្វើតាមខ្ញុំ ! »[2]

## ការបង្រៀនតាមរបៀបរបស់ព្រះអង្គសង្គ្រោះ

គ្រូបង្រៀនដំណឹងល្អទាំងអស់ត្រូវបានអញ្ជើញ ឲ្យសម្របខ្លួនតាមគោលការណ៍សំខាន់ទាំងប្រាំមួយ ដូចខាងក្រោមនេះ ដែលឆ្លុះបញ្ចាំងពីរបៀបដែល ព្រះអង្គសង្គ្រោះបានបង្រៀន ៖

1. **ស្រឡាញ់មនុស្សដែលអ្នកបង្រៀន ។**
   - ស្វែងយល់ពីបុគ្គលម្នាក់ៗ ។
   - ផ្ដោតលើសេចក្ដីត្រូវការរបស់សិស្សអ្នក ។
2. **រៀបចំខ្លួនខាងវិញ្ញាណ ។**
   - រស់តាមអ្វីដែលអ្នកបង្រៀន ។
   - ដឹងពីធនធានដែលមាន ។
3. **បង្រៀនដោយព្រះវិញ្ញាណ ។**
   - ជួយសិស្សអ្នកឲ្យស្គាល់ព្រះវិញ្ញាណ ។
   - ធ្វើជាគ្រូបង្រៀនម្នាក់ដែលងាយបង្រៀន ។
   - បង្កើតបរិយាកាសរៀនសូត្រ
4. **ស្វែងរកដំណឹងល្អរួមគ្នា ។**
   - ដាក់ការរំពឹងទុកឲ្យខ្ពស់ ។
   - លើកទឹកចិត្តសិស្សរបស់អ្នកឲ្យថ្លែង ទីបន្ទាល់ ។
   - សួរសំណួរដែលមានប្រសិទ្ធភាព ។
   - ស្ដាប់សិស្សរបស់អ្នក ។
5. **បង្រៀនគោលលទ្ធិ ។**
   - ប្រើព្រះគម្ពីរ ។
   - ប្រើដំណើររឿង និង ឧទាហរណ៍ ។
   - សន្យាពរជ័យ ហើយថ្លែងទីបន្ទាល់ ។
6. **អញ្ជើញសិស្សអ្នកឲ្យធ្វើសកម្មភាព ។**
   - ជួយសិស្សអ្នកឲ្យអនុវត្ត ។
   - តាមដានលើការអញ្ជើញ

កាលណាយើងអនុវត្តគោលការណ៍ទាំងនេះ យើងនឹងក្លាយជាគ្រូបង្រៀនដ៏ប្រពៃ សិស្សដ៏ប្រពៃ ឪពុកម្ដាយដ៏ប្រពៃ និង ជាសិស្សដ៏ប្រពៃរបស់ ព្រះយេស៊ូវគ្រីស្ទ ។ ត្បិតទ្រង់បានបង្គាប់យើងឲ្យ « បង្រៀនគ្នាទៅវិញទៅមក » « ដោយឧស្សាហ៍ » តាមរបៀបដែល « ឲ្យទាំងអស់បានស្អាងឡើង ទាំងអស់គ្នា » ( គ. និង ស. 88:77, 78, 122 ) ។ សូមឲ្យអ្នកដែលយើងបង្រៀនឃើញពីលក្ខណៈ នៃគ្រូបង្រៀនដ៏ឆ្នើមប្រពៃនៅក្នុងខ្លួនយើង ហើយ ទទួលបានបទពិសោធន៍មួយដែលពុំមែនគ្រាន់តែ ផ្ដល់ឲ្យពួកគេនូវចំណេះដឹងប៉ុណ្ណោះទេ ប៉ុន្តែក៏ ផ្លាស់ប្ដូរជីវិតពួកគេផងដែរ ។ ■

**កំណត់ចំណាំ**

1. *ប្រកាសដំណឹងល្អរបស់យើង ៖ សៀវភៅណែនាំសម្រាប់ការបម្រើជាអ្នកផ្សព្វផ្សាយសាសនា* ( ឆ្នាំ 2004 ) ទំព័រ 200 ។
2. « Do As I'm Doing » *Children's Songbook,* ទំព័រ 276 ។

*តើអ្នកស្រឡាញ់ខ្ញុំជាជាងរបស់ទាំងនេះឬអី ?* ដោយ ដេវីឌ លីនស្លី



ដោយអែលឌើរ កូអ៊ីឈិ
អ័រយ៉ាហ្គិ
នៃពួកចិតសិបនាក់



# ជំរុំដំបូន្មានរបស់ព្យាការី និង ពរជ័យព្រះវិហារបរិសុទ្ធ

កាលខ្ញុំមានវ័យជំទង់ អែលឌើរ ស្ពែនស៊ើរ ដបុលយូ឵ យឹមបឹល ( 1895–1985 ) នៅពេលនោះជាសមាជិកក្នុងកូរ៉ុមនៃពួកសាវក ដប់ពីរនាក់ បានទៅទស្សនកិច្ចនៅប្រទេសជប៉ុន ហើយបានថ្លែងសុន្ទរកថានៅក្នុងសន្និសីទមួយដែលខ្ញុំបានចូលរួម ។ ខ្ញុំនៅចាំពីការប្រឹក្សារបស់លោកថា ៖ « យុវវ័យត្រូវចេញបេសកកម្ម ហើយពួកគេត្រូវតែរៀបអាពាហ៍ពិពាហ៍នៅក្នុងព្រះវិហារបរិសុទ្ធ » ។

ខ្ញុំទទួលបានការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ ហើយបានតាំងចិត្តថា ខ្ញុំនឹងបម្រើបេសកកម្ម ហើយរៀបអាពាហ៍ពិពាហ៍ក្នុងព្រះវិហារបរិសុទ្ធ ទោះជាប្រទេសជប៉ុនពុំទាន់មានព្រះវិហារបរិសុទ្ធនៅឡើយក្តី ។

នៅពេលនោះ ខ្ញុំមានអាយុ 19 ឆ្នាំ ហើយខ្ញុំរៀននៅសាកលវិទ្យាល័យឆ្នាំទីពីរ ។ ឪពុកម្តាយខ្ញុំដែលពុំមែនជាពួកបរិសុទ្ធថ្ងៃចុងក្រោយបានជំទាស់យ៉ាងដាច់ខាតទៅនឹងការសម្រេចចិត្តរបស់ខ្ញុំក្នុងការបម្រើបេសកកម្ម ។ ខ្ញុំបានអធិស្ឋានរាល់ថ្ងៃសូមឲ្យពួកគាត់អនុញ្ញាតឲ្យខ្ញុំ ហើយឲ្យពរដល់ខ្ញុំ ។ ប្រាំមួយខែក្រោយមក ព្រះអម្ចាស់បានឆ្លើយតបនឹងការអធិស្ឋានខ្ញុំ ។

ឪពុកម្តាយខ្ញុំបានប្រាប់ខ្ញុំថា « ប៉ាម៉ាក់កំពុងមានវិបត្តិផ្នែកហិរញ្ញវត្ថុ ហើយប៉ាម៉ាក់មិនអាចមិនបង់ថ្លៃសាលាឲ្យកូន និងថ្លៃចំណាយផ្សេងៗបានទៀតឡើយ » ។ « ចាប់ពីពេលនេះទៅកូនត្រូវរៀនរស់នៅដោយខ្លួនឯងហើយ ។ ប៉ាម៉ាក់ក៏មិនខ្វល់ខ្វាយទៀតដែរ ប្រសិនបើកូនចង់ចេញបេសកកម្មនោះ ! »

ខ្ញុំទទួលបានពរពីឪពុកម្តាយខ្ញុំ ដូច្នេះខ្ញុំបានឈប់រៀន ហើយបានត្រៀមខ្លួនបម្រើបេសកកម្មក្នុងសាសនាចក្រ រួចបានចាប់ផ្តើមស្វែងរកការងារមួយដើម្បីសន្សំប្រាក់សម្រាប់ការចេញបេសកកម្ម ។ ដោយមានជំនួយពីព្រះអម្ចាស់ ខ្ញុំរកបានការងារបី ! ជារៀងរាល់ថ្ងៃ លើកលែងតែថ្ងៃអាទិត្យ អស់រយៈពេលមួយឆ្នាំ

*ខ្ញុំសូមថ្លែងទីបន្ទាល់ថា នៅពេលយើងអធិស្ឋានសូមការដឹកនាំ ធ្វើតាមព្យាការីដែលកំពុងរស់នៅ ហើយដាក់ព្រះវិហារបរិសុទ្ធជាអាទិភាពក្នុងជីវិតរបស់យើង នោះព្រះវរបិតាសួគ៌នឹងដឹកនាំយើង ហើយប្រទានពរដល់យើង ។*

ក្រោយមក ខ្ញុំបានធ្វើជាអ្នករត់កាសែតពីម៉ោង 3:00 រហូតដល់ ម៉ោង 7:00 ព្រឹក សម្អាតអគារពីម៉ោង 9:00 ព្រឹក រហូតដល់ម៉ោង 4 រសៀល ហើយធ្វើជាចុងភៅពីម៉ោង 5:00 ល្ងាច រហូតដល់ ម៉ោង 7:30 យប់ ។ រួចខ្ញុំផ្លាស់សំលៀកបំពាក់ ហើយទៅធ្វើការនៅពេលយប់ជាអ្នកផ្សព្វផ្សាយសាសនាប្រចាំមណ្ឌល ។

កាលខ្ញុំអាយុ 22 ឆ្នាំ ខ្ញុំត្រូវបានហៅឲ្យបម្រើនៅបេសកកម្ម ន័រធើន ហ្វាអ៊ីស្ទ ។ តាមរយៈការបម្រើក្នុងបេសកកម្មរបស់ខ្ញុំ ខ្ញុំមាននូវសេចក្តីអំណរដ៏ធំធេងបំផុតដែលខ្ញុំពុំធ្លាប់មាន ខ្ញុំមានឱកាសជាច្រើនដើម្បីស្គាល់ពីសេចក្តីស្រឡាញ់របស់ព្រះ ហើយទទួលបាននូវពរជ័យជាច្រើន ។ គ្រួសារខ្ញុំក៏បានទទួលពរជ័យក្នុងពេលខ្ញុំកំពុងបម្រើផងដែរ ដោយឪពុកម្តាយខ្ញុំបានដោះស្រាយវិបត្តិផ្នែកហិរញ្ញវត្ថុរបស់ពួកគាត់ ។

**ការធ្វើតាមព្យាការី**

កាលខ្ញុំបញ្ចប់បេសកកម្ម ព្រះវិញ្ញាណបានបំផុសគំនិតខ្ញុំឲ្យធ្វើតាមចំណុចទីពីរនៃការប្រឹក្សារបស់ប្រធានឃឹមបឹល ហើយកុំឲ្យពន្យារការរៀបអាពាហ៍ពិពាហ៍នៅក្នុងព្រះវិហារបរិសុទ្ធ ។ មួយឆ្នាំមុន សមាជិកសាសនាចក្រនៅប្រទេសជប៉ុនបានចាប់ផ្តើមដាក់ផែនការធ្វើដំណើរទៅព្រះវិហារបរិសុទ្ធសលត៍ លេក ។

ដោយសារពួកគេនឹងត្រូវចេញដំណើរទៅក្នុងរយៈពេលបីខែទៀត ខ្ញុំបានអធិស្ឋាន ហើយបានតមអាហារដើម្បីបានដឹកនាំទៅរកយុវនារីដ៏សក្ដិសមម្នាក់ដែលខ្ញុំអាចនាំនាងទៅព្រះវិហារបរិសុទ្ធ ។

មិនយូរប៉ុន្មានក្រោយមក ខ្ញុំបានចូលរួមសកម្មភាពសាសនាចក្រមួយនៅស្រុកកំណើតខ្ញុំគឺទីក្រុង ម៉ាស្សឹម៉ូតូ ។ កាលខ្ញុំនៅទីនោះខ្ញុំបានជួបនឹង ហ្ស៊ីរ៉ូកូ ម៉ូម៉ូសេ ដែលធ្លាប់រៀននៅវិទ្យាល័យជាមួយគ្នា ទន្ទឹមនឹងពេលខ្ញុំបានចូលរួមសាសនាចក្រ ។ ភ្លាមនោះ ព្រះវិញ្ញាណបានបញ្ជាក់ថា នាងគឺជានារីដែលបានរៀបចំសម្រាប់ខ្ញុំ ។

ក្រោយពីយើងបានចាប់ផ្ដើមដើរលេងជាមួយគ្នាបានមិនយូរប៉ុន្មាន ខ្ញុំបានសូម ហ្ស៊ីរ៉ូកូ រៀបការ ។ នាងបានធ្វើឲ្យខ្ញុំរីករាយ កាលនាងបានយល់ព្រម ប៉ុន្តែនាងបានធ្វើឲ្យខ្ញុំផ្ញាក់ផ្អើលជាមួយនឹងពាក្យសម្ដីដែលនាងប្រាប់បន្ទាប់មកទៀត ។

នាងពោលថា « អូនរីករាយជាខ្លាំងដោយដឹងថា ព្រះអម្ចាស់របស់បងគឺជាព្រះអម្ចាស់របស់អូនដែរ » ។ « កាលគេបានប្រកាសពីដំណើរទៅព្រះវិហារបរិសុទ្ធសលត៍ លេក អូនចង់ទៅជាខ្លាំង ។ អូនបានអធិស្ឋានជាច្រើនដងសូមឲ្យព្រះអម្ចាស់ជួយអូនឲ្យរកឃើញបុរសម្នាក់ដែលអូនអាចរៀបការជាមួយនៅទីនោះ ។ ប្រហែលជាមួយឆ្នាំមុន អូនបានដឹងតាមរយៈព្រះវិញ្ញាណបរិសុទ្ធកាលកំពុងអធិស្ឋានថា អូនគួររង់ចាំបង ហើយថាបងនឹងសូមអូនរៀបការពេលបងត្រឡប់មកពីបេសកកម្មវិញ » ។

ការណ៍នោះគឺជាបទពិសោធន៍ខាងវិញ្ញាណដ៏អស្ចារ្យមួយសម្រាប់យើង ហើយវាបានពង្រឹងដល់ដំណោះស្រាយរបស់យើងដើម្បីរៀបអាពាហ៍ពិពាហ៍នៅក្នុងព្រះវិហារបរិសុទ្ធសលត៍ លេក ។ យើងមានប្រាក់បន្តិចបន្តួចដើម្បីធ្វើដំណើរនោះ ប៉ុន្តែយើងមិនបានបណ្ដោយឲ្យរឿងនោះធ្វើឲ្យយើងបាក់ទឹកចិត្តឡើយ ។ លុះដល់ពេលនោះ យើងបានដឹងថា កាលយើងពឹងផ្អែកលើព្រះអម្ចាស់ ហើយគោរពព្រះបញ្ញត្តិទ្រង់ នោះទ្រង់ជួយយើងឲ្យសម្រេចនូវរឿងទាំងឡាយដែលយើងមិនអាចសម្រេចវាដោយខ្លួនឯងបាន ។

យើងបានទូលអង្វរដល់ព្រះវរបិតាសួគ៌យើងនៅក្នុងការអធិស្ឋាន ហើយបានខិតខំអស់ពីលទ្ធភាពរបស់យើងដើម្បីសន្សំប្រាក់ដែលត្រូវការចាំបាច់ ។



**ការគោរពប្រតិបត្តិ — ការដឹកនាំដ៏ជាក់លាក់**

« ព្រះវរបិតាសួគ៌ជាទីស្រឡាញ់ បានរៀបចំទិសដៅឲ្យយើង ហើយផ្ដល់នូវការដឹកនាំដោយឥតបរាជ័យ — គឺជា *ការគោរពប្រតិបត្តិ* ។ ចំណេះដឹងមួយអំពីសេចក្ដីពិត និងចម្លើយចំពោះសំណួរដ៏ធំរបស់យើង កើតមាននៅពេលយើងគោរពប្រតិបត្តិតាមព្រះបញ្ញត្តិរបស់ព្រះ » ។

**ប្រធាន ថូម៉ាស អេស ម៉នសុន « Preparation Brings Blessings » *Liahona* ខែ ឧសភា ឆ្នាំ 2013 ទំព័រ 89 ។**

ការខិតខំទាំងនោះ រួមទាំងជំនួយផ្នែកហិរញ្ញវត្ថុពីមិត្តម្នាក់របស់ ហ្ស៊ីរ៉ូកូ បានជួយយើងឲ្យចូលរួមនឹងពួកបរិសុទ្ធជប៉ុន ដែលបានទៅព្រះវិហារបរិសុទ្ធសលត៍ លេក ។

យើងមិនអាចសម្ដែងនូវសេចក្ដីអំណរ ដែលយើងមាន ពេលបានផ្សារភ្ជាប់នៅទីនោះជាស្វាមីភរិយាអស់កល្បជានិច្ចបានឡើយ ។ យើងមិនអាចបំភ្លេចបទពិសោធន៍នោះបានទេ ។ អ្វីដែលបានបន្ថែមទៅលើសេចក្ដីអំណររបស់យើងគឺថា យើងបានស្រាវជ្រាវឃើញដូនតាយើងប្រាំជំនាន់ ហើយបានរៀបចំឈ្មោះពួកគាត់សម្រាប់កិច្ចការព្រះវិហារបរិសុទ្ធ ។ កាលនៅ ទីក្រុង សលត៍ លេក យើងបានធ្វើពិធីបរិសុទ្ធជំនួសឲ្យដូនតាទាំងនោះ ។ ការធ្វើពិធីបរិសុទ្ធទាំងនោះបានជួយយើងឲ្យមានអារម្មណ៍ជិតស្និទ្ធនឹងពួកគាត់ ។ យើងបានដឹងថា ពួកគាត់បានពោរពេញដោយសេចក្ដីអំណរ ដោយសារការខិតខំរបស់យើង ។

យើងគឺជាស្វាមីភរិយាទើបរៀបការថ្មោងថ្មីដែលក្រីក្រ ប៉ុន្តែយើងបានដាក់ការចូលរួមក្នុងព្រះវិហារបរិសុទ្ធជាអាទិភាព ក្រោយមកទៀតយើងបានទៅព្រះវិហារបរិសុទ្ធឡាអ៊ីអេ ហាវ៉ៃ ជារឿយៗ តាមលទ្ធភាពដែលយើងអាចធ្វើទៅបាន ។

**មានពរតាមរយៈព្រះវិហារបរិសុទ្ធ**

ព្យាការី យ៉ូសែប ស្ម៊ីធ បានថ្លែងថា « យើងត្រូវការព្រះវិហារបរិសុទ្ធលើសពីអ្វីៗផ្សេងទៀត »[1]

នៅក្នុងផែនការសង្គ្រោះរបស់ព្រះ ព្រះវិហារបរិសុទ្ធគឺជាកត្តាដ៏ចាំបាច់ចំពោះសុភមង្គលអស់កល្បជានិច្ចរបស់យើង ដោយសារយើងធ្វើពិធីការ និងពិធីបរិសុទ្ធដ៏ពិសិដ្ឋនៃសេចក្ដីសង្គ្រោះនៅទីនោះ ។ Bible Dictionary ( វចនានុក្រមព្រះគម្ពីរប៊ីប ) ប្រាប់យើងថា ព្រះវិហារបរិសុទ្ធគឺជាកន្លែងដ៏បរិសុទ្ធបំផុតនៃការថ្វាយបង្គំនៅលើផែនដី និង ជា « កន្លែងមួយដែលព្រះអម្ចាស់អាចនឹងយាងមក » ។[2]

ប្រសិនបើយើងគោរពដល់សេចក្ដីសញ្ញានៃព្រះវិហារបរិសុទ្ធរបស់យើង ហើយទៅព្រះវិហារបរិសុទ្ធ « ដោយចិត្តរាបសា ស្អាតស្អំ ហើយដោយកិត្តិយស និងសេចក្ដីទៀងត្រង់ »[3] នោះយើងនឹងទទួលអារម្មណ៍ពីព្រះវិញ្ញាបរិសុទ្ធ ហើយទទួលបានពន្លឺ និង ចំណេះដឹងបន្ថែមទៀត ។ កាលយើងចាកចេញពីព្រះវិហារបរិសុទ្ធ យើងនឹងចេញទៅដោយមាននូវព្រះចេស្ដារបស់ព្រះអម្ចាស់ និងដោយមានព្រះនាមទ្រង់ដាក់មកលើយើង សិរីល្អទ្រង់ព័ទ្ធជុំវិញយើង ហើយពួកទេវតាទ្រង់ឃុំគ្រងយើង ( សូមមើល គ. និង ស. 109:13, 22 ) ។

កាលយើងត្រឡប់មកប្រទេសជប៉ុនវិញបន្ទាប់ពីអាពាហ៍ពិពាហ៍របស់យើង ការសន្យារបស់ព្រះអម្ចាស់បានកើតឡើងនៅក្នុងជីវិតខ្ញុំ កាលខ្ញុំខំស្វែងរកការងារពេញម៉ោង ។

**ព្រះអម្ចាស់បំពេញតាមការសន្យារបស់ទ្រង់**

ខ្ញុំបានធ្វើការក្រៅម៉ោងនៅឡើយ កាលកូនដំបូងរបស់យើងបានកើត ។ យើងមានក្ដីរីករាយ ប៉ុន្តែខ្ញុំបានដឹងថា ខ្ញុំមិនអាចផ្គត់ផ្គង់គ្រួសារយើងដែលកំពុងតែ



វីកធំឡើងនេះដោយគ្មានការងារពេញម៉ោងបានឡើយ ។ យើងបានចាប់ផ្ដើមអធិស្ឋានដោយស្មោះទូលសូមជំនួយពីស្ថានសួគ៌ ។

ពីមុនខ្ញុំបម្រើបេសកកម្មខ្ញុំ ខ្ញុំចង់ធ្វើការផ្នែកពាណិជ្ជកម្មបរទេស ។ ប៉ុន្តែដើម្បីបានធ្វើការនៅក្នុងក្រុមហ៊ុនពាណិជ្ជកម្មមួយ ជាទូទៅ បេក្ខជនម្នាក់ត្រូវមានសញ្ញាបត្រជាក់លាក់ថាបានបញ្ចប់សាកលវិទ្យាល័យ ។ ខ្ញុំមិនបានបញ្ចប់មហាវិទ្យាល័យទេ ហើយគ្មានសញ្ញាបត្រ ប៉ុន្តែកាលយើងអធិស្ឋាន យើងទទួលអារម្មណ៍ថា ព្រះអម្ចាស់នឹងប្រទានពរយើង ហើយរៀបចំការងារមួយសម្រាប់ខ្ញុំ ។

ខ្ញុំបានសម្រេចចិត្តធ្វើការប្រឡងចូលក្រុមហ៊ុនពាណិជ្ជកម្មជាច្រើន ទោះជាខ្ញុំខ្វះខាងការអប់រំក្ដី ។ ក្រុមហ៊ុនពីរដំបូងបានបដិសេធខ្ញុំ ប៉ុន្តែខ្ញុំមានបទពិសោធន៍យ៉ាងចំឡែកមួយ កាលខ្ញុំដាក់ពាក្យនៅក្រុមហ៊ុនទីបី ។

នៅសម័យនោះ មានសមាជិកសាសនាចក្រជនជាតិជប៉ុនតែពីរបីនាក់ប៉ុណ្ណោះ ហើយមានមនុស្សជាច្រើនបានប្រឆាំងទាស់នឹងសាសនាចក្រ ។ កាលអ្នកតំណាងបីរូបមកពីក្រុមហ៊ុនពាណិជ្ជកម្មទីបីបានមកសម្ភាសខ្ញុំ ពួកគេបានមើលប្រវត្តិរូបខ្ញុំ ហើយបានដឹងថា ខ្ញុំជាពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ ពួកគេបានសួរសំណួរខ្ញុំអំពីសាសនាចក្រ ដោយស្នើសុំឲ្យខ្ញុំឆ្លើយយ៉ាងលម្អិត ។ ដោយទើបត្រឡប់មកពីបេសកកម្មវិញថ្មីៗ ខ្ញុំគ្មានបញ្ហាអ្វីនឹងនិយាយពីសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទដែលបានស្ដារឡើងវិញនោះទេ ។

ប្រហែលជា 40 នាទី ខ្ញុំបាននិយាយពីដំណឹងល្អ ហើយបានថ្លែងទីបន្ទាល់ខ្ញុំពីជីវិតរបស់ព្រះយេស៊ូវគ្រីស្ទ ការក្បត់សាសនា ទស្សនៈនិមិត្តដំបូងរបស់យ៉ូសែបស្ម៊ីធ ព្រះគម្ពីរមរមន ការស្ដារឡើងវិញនៃសាសនាចក្រដ៏ពិតនៃព្រះយេស៊ូវគ្រីស្ទ និងការបង្រៀនទាំងឡាយរបស់សាសនាចក្រ ។

គ្មានអ្នកសម្ភាសណាម្នាក់បានបញ្ឈប់ខ្ញុំ កាលខ្ញុំកំពុងនិយាយឡើយ ។ ពីរបីថ្ងៃក្រោយមក ក្រុមហ៊ុនពាណិជ្ជកម្មនោះបានផ្ដល់ការងារមួយ ដែលឲ្យប្រាក់ខែដ៏ខ្ពស់ ។ ក្រោយមកទៀត កាលខ្ញុំសួរដល់ប្រធានរបស់ខ្ញុំថា ហេតុអ្វីបានជាពួកគេជួលខ្ញុំ គាត់បានតបថា « ក្នុងការសម្ភាសរបស់លោក ខ្ញុំបានទទួលការអះអាងមួយថា លោកជាមនុស្សឧស្សាហ៍ ស្មោះត្រង់ ហើយទៀងត្រង់ ហើយថាលោកនឹងជាមនុស្សម្នាក់ដែលធ្វើការសម្រាប់ក្រុមហ៊ុនយើងតាមរបៀបដូច្នេះដែរ » ។

ខ្ញុំសូមថ្លែងទីបន្ទាល់ថា ព្រះអម្ចាស់បំពេញការសន្យារបស់ទ្រង់ ។ ក្នុងការសម្ភាសន៍របស់ខ្ញុំ ខ្ញុំមានអារម្មណ៍ពីព្រះចេស្ដា និង ព្រះវិញ្ញាណនៃព្រះអម្ចាស់មកលើខ្ញុំ ដូចជាទ្រង់សន្យាដល់ជនដែលចូលទៅក្នុងព្រះវិហារបរិសុទ្ធ ហើយគោរពដល់សេចក្ដីសញ្ញានៃព្រះវិហារបរិសុទ្ធរបស់ពួកគេ ។ ខ្ញុំក៏ទទួលអារម្មណ៍ថា ព្រះវិញ្ញាណគង់ជាមួយនឹងខ្ញុំ កាលខ្ញុំធ្វើការឲ្យក្រុមហ៊ុននោះ ជាកន្លែងដែលខ្ញុំមានពរដើម្បីធ្វើការបរិច្ចាគដ៏មានតម្លៃជាច្រើន ។

## ព្រះវិហារបរិសុទ្ធកើតមាននៅប្រទេសជប៉ុន

នៅឯសន្និសីទភូមិភាគមួយនៅទីក្រុងតូក្យូ ឆ្នាំ 1975 ប្រធាន឵ ឃីមបឹល បានប្រកាសពីការសាងសង់ព្រះវិហារបរិសុទ្ធតូក្យូជប៉ុន ។ រំពេចនោះ ពួកបរិសុទ្ធជប៉ុនពុំអាចទប់ចិត្តរំភើបបានឡើយ ហើយបានទះដៃព្រមគ្នា ដើម្បីបង្ហាញសេចក្ដីអំណរ និង អំណរគុណរបស់ពួកគេ ។

ព្រះវិហារបរិសុទ្ធតូក្យូជប៉ុន បានសង់ចប់សព្វគ្រប់នៅឆ្នាំ 1980 ។ ក្នុងពិធីបើកសម្ពោធ និង ឧទ្ទិសឆ្លង ពួកបរិសុទ្ធត្រូវបានប្រទានពរជាមួយនឹងបទពិសោធន៍ខាងវិញ្ញាណ និង សេចក្ដីអំណរដ៏មហាអស្ចារ្យ ។ បទពិសោធន៍ទាំងនោះបានបន្តបន្ទាប់ការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធនោះ កាលពួកបរិសុទ្ធបានចាប់ផ្ដើមទទួលពិធីបរិសុទ្ធនៅក្នុងព្រះវិហារបរិសុទ្ធរបស់ពួកគេ ហើយធ្វើពិធីបរិសុទ្ធជំនួសឲ្យដូនតារបស់ពួកគេដែលបានចែកឋានទៅ ។

នៅថ្ងៃនេះ ហ្សឺរ៉ូកូ និង ខ្ញុំបានរៀបការជិត 45 ឆ្នាំហើយ ការសម្រេចចិត្តរបស់ខ្ញុំដើម្បីធ្វើតាមការប្រឹក្សារបស់ព្យាការីបានបន្តប្រទានពរដល់ជីវិតយើង និង ជីវិតកូនចៅរបស់យើង ។ យើងបានស្ថាបនាគ្រួសារមួយដ៏អស្ចារ្យតាមរបៀបរបស់ព្រះអម្ចាស់ — បានចាក់គ្រឹះនៅលើដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ រួមបញ្ចូលទាំងសេចក្ដីសញ្ញានៃព្រះវិហារបរិសុទ្ធ ។

ខ្ញុំសូមថ្លែងទីបន្ទាល់ថា នៅពេលយើងអធិស្ឋានសូមការដឹកនាំ ធ្វើតាមព្យាការីដែលកំពុងរស់នៅ ហើយដាក់ព្រះវិហារបរិសុទ្ធជាអាទិភាពក្នុងជីវិតរបស់យើង នោះព្រះវរបិតាសួគ៌នឹងដឹកនាំយើង ហើយប្រទានពរដល់យើង ។ ■

**កំណត់ចំណាំ**

1. *Teachings of Presidents of the Church: Joseph Smith* ( ឆ្នាំ 2007 ) ទំព័រ 416 ។
2. Bible Dictionary « Temple »។
3. ស្ពែនស៊ើរ ដបុលយូ ឃីមបឹល ដកស្រង់ចេញពីការអធិស្ឋានឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធតូក្យូជប៉ុន ក្នុង *2013 Church Almanac* ( ឆ្នាំ 2013 ) ទំព័រ 297 ។

# ផ្ល័រ៉ា និង ខ្ញុំ ៖
## ដៃគូស្មើភាពក្នុងកិច្ចការរបស់ព្រះអម្ចាស់







*ខាងឆ្វេង ៖ ផ្ល័រ៉ា អាំម៉ូសឹន និង អែសរ៉ា ថាហ្វ បិនសិន កាលពីវ័យជំទង់ ។ ខាងស្ដាំ ៖ ផ្ល័រ៉ា និង អែសរ៉ា កំពុងរីករាយជាមួយនឹងកូនទាំងប្រាំមួយនាក់របស់ពួកគាត់ ។*





*កាលយើងរៀនពីភាពជាដៃគូដែលចេះជួយគ្នា និងចេះស្រឡាញ់គ្នា ដែលប្រធាន អែសរ៉ា ថាហ្វ ប៊ែនសឹន បានរីករាយជាមួយនឹងភរិយាលោក ផ្លរ៉ា នោះយើងទទួលបានការយល់ដឹងដ៏ស៊ីជម្រៅមួយពីការបម្រើរបស់លោក ។*

**ដោយ អើរ៉ុន អិល វ៉ែស**
ផ្នែកសេវាកម្មបោះពុម្ពរបស់សាសនាចក្រ

ពេលខ្លះ ប្រសិនបើយើងស្ដាប់ដោយយកចិត្តទុកដាក់ នោះឃ្លាដ៏ខ្លីមួយអាចមានឥទ្ធិពលដូចជាទេសនកថាមួយដែរ ។ ដូចជាករណីថ្ងៃទី 11 ខែ វិច្ឆិកា ឆ្នាំ 1985 ។ ឃ្លានោះគឺ « ផ្លរ៉ា និង ខ្ញុំ » ។

ប្រធាន អែសរ៉ា ថាហ្វ ប៊ែនសឹន ( 1899–1994 ) បានអានពាក្យពេចន៍ទាំងនោះជាផ្នែកនៃសេចក្ដីថ្លែងការណ៍មួយ ដែលបានរៀបចំសម្រាប់ពួកអ្នកសារព័ត៌មាន នៅថ្ងៃក្រោយពីលោកត្រូវបានធ្វើពិធីញែកចេញជាប្រធាននៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ ប្រធាន ស្ពែនសើរ ដបុលយូ ឃឹមបឹល ( 1895–1985 ) បានទទួលមរណភាពកាលពីប្រាំមួយថ្ងៃមុន ដោយបន្សល់ទុកឲ្យប្រធាន ប៊ែនសឹន ជាសាវករៀមច្បង ។

ប្រធាន ប៊ែនសឹន និង ភរិយាលោក ផ្លរ៉ា បាននៅជាមួយគ្នា កាលពួកលោកបានទទួលដំណឹងពីមរណភាពរបស់ប្រធាន ឃឹមបឹល ហើយពួកលោក « បានលុតជង្គង់ចុះភ្លាម » ដើម្បីអធិស្ឋាន ។[1] ឥឡូវនេះ នៅក្នុងឃ្លាទីមួយនៃសេចក្ដីថ្លែងការណ៍ដែលនឹងត្រូវបានបោះពុម្ពផ្សាយពាសពេញពិភពលោក ប្រធាន ប៊ែនសឹន បានបន្ទាបខ្លួនលោកនៅក្បែរ ផ្លរ៉ា ជាថ្មីម្ដងទៀត ។ លោកបានថ្លែងថា ៖ « នេះគឺជាថ្ងៃមួយដែលខ្ញុំមិនបានរំពឹងទុកជាមុន ។ ភរិយាខ្ញុំ ផ្លរ៉ា និង ខ្ញុំបានអធិស្ឋានជានិច្ចសូមឲ្យប្រធាន ឃឹមបឹល មានអាយុវែងរស់នៅលើផែនដីនេះ ហើយសូមឲ្យអព្ភូតហេតុមួយទៀតបានកើតឡើងដើម្បីជាប្រយោជន៍ដល់លោក ។ ឥឡូវនេះ ដោយសារព្រះអម្ចាស់បានមានបន្ទូល យើងនឹងធ្វើឲ្យអស់ពីលទ្ធភាព ដោយស្ថិតនៅក្រោមការដឹកនាំរបស់ទ្រង់ ដើម្បីជម្រុញកិច្ចការនេះឲ្យឆ្ពោះទៅមុខនៅលើផែនដី » ។[2]

បន្ទាប់ពីរៀបការបាន 59 ឆ្នាំ ប្រយោគថា « ផ្លរ៉ា និង ខ្ញុំ » បានកើតមានដោយឯកឯងចំពោះប្រធាន ប៊ែនសឹន ។ ហើយកាលលោកថ្លែងថា « យើងនឹងធ្វើឲ្យអស់ពីលទ្ធភាពដោយស្ថិតនៅក្រោមការដឹកនាំរបស់ទ្រង់



*ដើម្បីអានពីរបៀបដែលជីវិតរស់នៅក្នុងកសិដ្ឋានបានពង្រឹងដល់បុគ្គលិកលក្ខណៈរបស់អែសរ៉ា ថាហ្វ បែនសឹន សូមមើល* Teachings of Presidents of the Church: Ezra Taft Benson *ទំព័រ 2–5 ។*







*ពីស្ដាំទៅឆ្វេងចាប់ពីផ្នែកខាងលើមក ៖ អែសរ៉ា ថាហ្វ បែនសឹន ជាមួយនឹងកសិករដទៃទៀត អែសរ៉ា នៅទីពីររាប់ពីឆ្វេង ជាមួយនឹងម្ដាយ រួមទាំងបងប្អូនលោក ឪពុកម្ដាយរបស់អែសរ៉ា ចច ធី បែនសឹន និង សារ៉ា ដាំងលី បែនសឹន ។*

ដើម្បីជម្រុញកិច្ចការនេះឲ្យឆ្ពោះទៅមុខនៅលើផែនដី » លោកមិនបានប្រើពាក្យថា *យើងដើម្បីសំដៅទៅលើខ្លួនលោក* និងពួកអ្នកមានសិទ្ធិអំណាចទូទៅផ្សេងទៀតនោះទេ ប៉ុន្តែទោះជាយ៉ាងណា លោកប្រាកដជានឹងរួបរួមជាមួយនឹងពួកគាត់ ។ នៅក្នុងសេចក្ដីថ្លែងការណ៍នេះ ព្យាការី អ្នកមើលឆុត និង អ្នកទទួលវិវរណៈរបស់សាសនាចក្របានលើកឡើងពីការរួបរួមនឹងភរិយាលោកក្នុងកិច្ចការរបស់ព្រះអម្ចាស់ ។

ហេតុអ្វីលោកធ្វើដូច្នេះ ? លោក និង ផ្លរ៉ា បានរួបរួមគ្នាក្នុងកិច្ចការរបស់ព្រះអម្ចាស់ជិតប្រាំមួយទសវត្សរ៍មកហើយ ។ ខណៈដែលផ្នែកជាច្រើននៅក្នុងជីវិតពួកលោកបានផ្លាស់ប្ដូរជាច្រើនឆ្នាំក្ដី ភាពជាដៃគូរបស់ពួកលោកបានក្លាយជាប្រភពនៃកម្លាំងដ៏ខ្ជាប់ខ្ជួនសម្រាប់ពួកលោកទាំងពីរនាក់ ។

នៅឆ្នាំនេះវគ្គសិក្សាសម្រាប់បងប្អូនស្រីថ្នាក់សមាគមសង្គ្រោះ និង ពួកអ្នកកាន់បព្វជិតភាពមិលគីស្សាដែកជាក់បញ្ចូលនូវឱកាសមួយដើម្បីរៀនពីប្រធាន អែសរ៉ា ថាហ្វ បែនសឹន ។ នៅពេលអ្នកសិក្សាការបង្រៀនរបស់លោក អ្នកអាចនឹងទទួលអារម្មណ៍លើកទឹកចិត្តដើម្បីរៀនពីបុគ្គលិកលក្ខណៈរបស់លោក ។ អត្ថបទនេះផ្ដល់នូវការសំដែងឲ្យឃើញមួយចំនួននៅក្នុងឆាកជីវិត និង កិច្ចការបម្រើរបស់លោក តាមរយៈទស្សនៈរបស់ភរិយាលោក ផ្លរ៉ា អាំម៉ូសិន បែនសឹន ។ រាល់ជំពូក និង លេខទំព័រក្នុងអត្ថបទនេះយោងទៅលើ *Teachings of Presidents of the Church: Ezra Taft Benson* ។

**« ខ្ញុំចង់រៀបការនឹងបុរសកសិករម្នាក់ »**

នារដូវស្លឹកឈើជ្រុះក្នុងឆ្នាំ 1920 អែសរ៉ា ថាហ្វ បែនសឹន ដែលមានវ័យ 21 ឆ្នាំ បានធ្វើដំណើរពីកសិដ្ឋានគ្រួសារគាត់នៅទីក្រុង វីតនី រដ្ឋអៃដាហូ ស.រ.អា. ទៅកាន់ទីក្រុងឡូហ្គិន រដ្ឋយូថាហ៍ ជាកន្លែងដែលគាត់ចូលរៀននៅមហាវិទ្យាល័យកសិកម្មយូថាហ៍ ( សព្វថ្ងៃនេះជា សាកលវិទ្យាល័យរដ្ឋយូថាហ៍ ) ។ មានថ្ងៃមួយ កាលគាត់នៅជាមួយមិត្តមួយចំនួនក្នុងបរិវេណសាលា គាត់បានចាប់ចិត្តនឹងយុវនារីម្នាក់ ។ ក្រោយមក គាត់បាននៅចាំថា ៖

« យើងបាននៅក្បែរកន្លែងលក់ទឹកដោះគោមួយ កាលយុវនារីម្នាក់ — ដែលមានរូបឆោមស្រស់ស្អាត — បានបើកឡានតូចមួយសំដៅមកកន្លែងលក់នោះដើម្បីទិញទឹកដោះគោ ។ កាលពួកប្រុសៗបានគ្រវីដៃដាក់នាង នាងបានគ្រវីដៃតបវិញ ។ ខ្ញុំបានសួរថា ‹ តើនាងជានរណាទៅ ? › ពួកគេតបថា ‹ នាងឈ្មោះ ផ្លរ៉ា អាំម៉ូសិន › ។

« ខ្ញុំបានប្រាប់ពួកគេថា ‹ ពួកឯងដឹងទេ គ្នាមានអារម្មណ៍ថា គ្នានឹងរៀបការជាមួយនឹងនាង ›» ។

មិត្តរបស់អែសរ៉ាបាននាំគ្នាសើចចំពោះការនិយាយបែបនេះ ។ ពួកគេបានតបថា « នាងស្អាតពេកហើយសម្រាប់ប្រុសដែលជាកសិករ » ។ តើគាត់ឆ្លើយតបយ៉ាងដូចម្ដេចដែរ ? « វាធ្វើឲ្យអ្វីៗទាំងអស់កាន់តែមានភាពចាប់អារម្មណ៍ » ។[3]

មិត្តរបស់អែសរ៉ាមិនគួរវិនិច្ឆ័យខុសទៅលើ ផ្លរ៉ា អាំម៉ូសិន ឡើយ ។ ចាប់តាំងពីនាងមានវ័យជំទង់ នាងបានឃើញនូវបុគ្គលលក្ខណៈពិសេសមួយរបស់បុរសដែលធ្វើការនៅតាមវាលស្រែ ។ មានថ្ងៃមួយកាលម្ដាយនាងឈ្មោះ បាបារ៉ា បានប្រាប់នាងថា « នាងមិនអាចទទួលបានកម្រិតដ៏ខ្ពស់បំផុតនៃសិរីល្អដោយគ្មានអាពាហ៍ពិពាហ៍សេឡេស្ទាលបានទេនោះ ផ្លរ៉ា បានតបទៅវិញដោយមានការគិតគូរមួយចំនួនថា ‹ ដូច្នេះកូនសុខចិត្តរៀបការនឹងបុរសដែលក្រខាងទ្រព្យសម្បត្តិ ប៉ុន្តែបរិបូរណ៍ផ្នែកវិញ្ញាណ ដើម្បីយើងអាចបានអ្វីដែលយើងចង់បានរួមគ្នា › ។ នាងបានឈប់មួយសន្ទុះ រួចបានបន្ថែមទៀតថា ‹ កូនចង់រៀបការនឹងបុរសកសិករម្នាក់ ›» ។[4]

ក្រោយមក ផ្លរ៉ា និង អែសរ៉ា បានជួបគ្នាក្នុងឆ្នាំ 1920 ហើយមិនយូរប៉ុន្មាន មិត្តភាពរបស់ពួកគេបានក្លាយទៅជាសេចក្ដីស្នេហា ។ ផ្លរ៉ា បានដឹងថា អែសរ៉ា ថាហ្វ បែនសឹន គឺជាយុវជនម្នាក់ដែលបានចាប់ផ្ដើមប្រមូលនូវភាពបរិបូរណ៍ខាងវិញ្ញាណដែលនាងឲ្យតម្លៃយ៉ាងខ្លាំងបំផុត ។ ហើយដូចដែលនាងបានរំពឹងទុក ឫសគល់នៃកម្លាំងខាងវិញ្ញាណរបស់គាត់បានចាក់ឫសយ៉ាងជ្រៅទៅក្នុងដីនៃកសិដ្ឋានគ្រួសាររបស់គាត់ ។



*ដើម្បីអានពីដំណើររឿងនៃការបម្រើជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងរបស់ អែសរ៉ា ថាហ្វ ប៊ែនសឹន សូមមើលទំព័រ 9–10 និង 103–4 នៅក្នុងសៀវភៅសិក្សានេះ ។ ដើម្បីអានពីការបម្រើរបស់លោកនៅក្នុង – សង្គ្រាមលោកលើកទី 2 ប៉ែកអឺរ៉ុប អំឡុងពេលលោកជាសាវក សូមមើលទំព័រ 17–21, 54–55, 69–70, 264 និង 268 ។*

### ការធ្វើការរួមគ្នាដើម្បីដាក់ព្រះមុនគេបង្អស់

កាលផ្លរ៉ា និង អែសរ៉ា កំពុងចាប់ផ្ដើមរៀនយល់ចិត្ត គ្នាទៅវិញទៅមក ពួកគេបានដឹងថា ពួកគេត្រូវបែកចេញពីគ្នារយៈពេលពីរឆ្នាំ ។ អែសរ៉ា បានទទួលការហៅមួយឲ្យបម្រើនៅបេសកកម្មអង់គ្លេស ។ គាត់ និង ផ្លរ៉ា មានចិត្តរំភើបរីករាយចំពោះឱកាសដើម្បីបម្រើ ហើយពួកគេ « បានពិភាក្សាគ្នាពីទំនាក់ទំនងរបស់ពួកគេ ។ ពួកគេចង់ឲ្យមិត្តភាពរបស់ពួកគេបន្តទៅមុខទៀត ប៉ុន្តែពួកគេក៏ដឹងពីសេចក្ដីត្រូវការសម្រាប់អែសរ៉ា ដើម្បីធ្វើជាអ្នកផ្សព្វផ្សាយសាសនាម្នាក់ដែលមានការលះបង់ខ្ពស់ផងដែរ ។ លោកបានថ្លែងថា ‹ ពីមុនខ្ញុំឃ្លាតទៅ ផ្លរ៉ា និង ខ្ញុំបានសម្រេចចិត្តសរសេរ [ សំបុត្រ ] តែមួយខែម្ដងប៉ុណ្ណោះ › ។ ‹ យើងក៏បានសម្រេចចិត្តថា សំបុត្ររបស់យើងនឹងជាការលើកទឹកចិត្ត ទំនុកចិត្ត និង ដំណឹងផ្សេងៗ ។ យើងបានធ្វើដូច្នេះមែន › » ។[5]

ដោយចាប់ផ្ដើមជាមួយនឹងការហៅឲ្យបម្រើបេសកកម្មតាមរបៀបនេះ ពួកគេបានធ្វើជាគំរូពីសេចក្ដីពិតមួយដែលអែសរ៉ាបានបង្រៀនដល់ពួកបរិសុទ្ធនៅច្រើនឆ្នាំក្រោយមកថា ៖ « កាលយើងដាក់ព្រះមុនគេបង្អស់ យើងនឹងដឹងពីអ្វីដែលសំខាន់ ឬអ្វីដែលមិនសំខាន់នៅក្នុងជីវិតរបស់យើង ។ សេចក្ដីស្រឡាញ់របស់យើងចំពោះព្រះអម្ចាស់ត្រូវបានបង្ហាញដោយមនោសញ្ចេតនារបស់យើង ដោយរបៀបដែលយើងចំណាយពេលវេលារបស់យើង ចំណូលចិត្តដែលយើងខំប្រឹងស្វែងរក និង លំដាប់លំដោយនៃអាទិភាពរបស់យើង » ។[6]

កាលអែសរ៉ាជិតបញ្ចប់បេសកកម្មរបស់គាត់ គាត់ និង ផ្លរ៉ា បានទន្ទឹងរង់ចាំការឃើញមុខគ្នាជាថ្មីវិញ ។ ប៉ុន្តែ ផ្លរ៉ា « បានធ្វើលើសពីការទន្ទឹងរង់ចាំការចំណាយពេលនៅជាមួយនឹងគាត់ទៅទៀត ។ នាងពិតជាបានទន្ទឹងរង់ចាំ — ចំពោះអនាគត និង សក្ដានុពលរបស់លោកមែន ។ . . . នាងមានចិត្តរីករាយនឹងបំណងប្រាថ្នារបស់អែសរ៉ា ដើម្បីរស់នៅឯកសិដ្ឋានគ្រួសារនៅទីក្រុងវីតនី រដ្ឋអៃដាហូ ។ ប៉ុន្តែ នាងមានអារម្មណ៍ថា លោកត្រូវបញ្ចប់ការសិក្សារបស់លោកជាមុនសិន » ។[7] ក្នុងការខិតខំរបស់នាងដើម្បីជួយគាត់ធ្វើដូច្នេះ នាងបានចូលរួមនឹងលោកដើម្បីដាក់ព្រះមុនគេបង្អស់ ។ ក្រោយពីលោកបានត្រឡប់មកពីបេសកកម្មវិញមិនបានមួយឆ្នាំផង នាងបានធ្វើឲ្យលោកភ្ញាក់ផ្អើលដោយប្រាប់លោកថា នាងនឹងចេញទៅបម្រើបេសកកម្ម ។ ដើម្បីរៀនបន្ថែមទៀតពីការសម្រេចចិត្តរបស់នាង សូមមើលទំព័រ 10–11 ។

### ពេជ្រមិនទាន់ច្នៃ

ផ្លរ៉ា និង អែសរ៉ា ត្រូវបានផ្សារភ្ជាប់នៅព្រះវិហារបរិសុទ្ធសលត៍ លេក នៅថ្ងៃទី 10 ខែ កញ្ញា ឆ្នាំ 1926 ។





*ផ្នែកខាងលើ ៖ អែសរ៉ា ថាហ្វ ប៊ែនសឹន វ័យក្មេង ពីមុនទទួលបានការហៅឲ្យបម្រើបេសកកម្ម ។ ខាងលើ និង ខាងស្ដាំ ៖ ក្នុងនាមជាសាវក លោកបានជួយបម្រើដល់ប្រជាជននៅ — សង្គ្រាមលោកលើកទី 2 ប៉ែកអឺរ៉ុប ។*

ថ្វីបើ អែសរ៉ា មានអត្តចរិកល្អពីកំណើត និង ភាពជោគជ័យក្នុងសាលាក្ដី « មានមនុស្សមួយចំនួនបានបន្តងឿងឆ្ងល់ចំពោះការគិតរបស់ផ្លរ៉ា ។ ពួកគេមិនយល់សោះថា ហេតុអ្វីបានជានារីម្នាក់ដែលមានទ្រព្យសម្បត្តិស្ដុកស្ដម្ភ ហើយមានមុខមាត់ល្បីល្បាញម្នាក់ សុខចិត្តរួមរស់នឹងបុរសម្នាក់ដែលជាកសិករទៅវិញដូច្នេះ ។ ប៉ុន្តែនាងបានបន្តប្រាប់ថា នាង ‹ តែងតែចង់រៀបការនឹងបុរសកសិករម្នាក់ › ។ នាងពោលថា អែសរ៉ា ‹ គឺជាមនុស្សមិនសាំញ៉ាំ មានសុភវិនិច្ឆ័យ ហើយរឹងមាំ › ។ ហើយនាងបានសង្កេតឃើញថា ‹ គាត់មានសម្ដីផ្អែមល្ហែមចំពោះឪពុកម្ដាយគាត់ ហើយខ្ញុំបានដឹងថា បើគាត់ចេះគោរពដល់ឪពុកម្ដាយគាត់ នោះគាត់ក៏ចេះគោរពដល់ខ្ញុំដែរ › ។ នាងបានដឹងថា គាត់គឺជា ‹ ពេជ្រមិនទាន់ច្នៃ › ហើយនាងបានថ្លែងថា ‹ ខ្ញុំនឹងធ្វើឲ្យអស់ពីលទ្ធភាពដើម្បីជួយគាត់ត្រូវបានគេស្គាល់ក្នុងសេចក្ដីល្អ មិនមែនតែក្នុងសហគមន៍ដ៏តូចនេះប៉ុណ្ណោះទេ ប៉ុន្តែពិភពលោកទាំងមូលនឹងបានស្គាល់គាត់ › » ។[8]

ដោយមានទស្សនៈនេះចំពោះសក្ដានុពលរបស់ស្វាមីនាង ផ្លរ៉ា បានចេញទៅដោយរីករាយនៅគ្រប់ទីកន្លែងដែលពួកគេត្រូវការទៅដើម្បីផ្គត់ផ្គង់ដល់កូនៗរបស់ពួកគាត់ និង បម្រើដល់សាសនាចក្រ សហគមន៍ និង ប្រទេសរបស់ពួកគាត់ ។

*អែលឌើរ អ៊ែសរ៉ា ថាហ្វ បែនសឹន បានបម្រើជាលេខាផ្នែកកសិកម្មរបស់សហរដ្ឋអាមេរិក អស់រយៈពេលប្រាំបីឆ្នាំ ទន្ទឹមនឹងពេលដែលលោកបម្រើជាសាវកដែរ ។ ដើម្បីអានពីរបៀបដែលគាត់បានបំពេញទំនួលខុសត្រូវទាំងនេះ សូមមើលទំព័រ 21–25 និង 47–48 ។*







*ផ្នែកខាងលើ ៖ ប្រធាន បែនសឹន នៅក្នុងចំណោមពួកបរិសុទ្ធ ។ ខាងឆ្វេង និង ខាងលើ ៖ ការបម្រើជាលេខាផ្នែកកសិកម្មរបស់ប្រធានាធិបតីអាមេរិក ។*

ពេលខ្លះ ការណ៍នេះតម្រូវឲ្យនាងរស់នៅក្នុងជីវិតមួយសាមញ្ញជាងដែលនាងធ្លាប់មានមក ប៉ុន្តែនាងបានឱបក្រសោបយកឱកាសនោះ ។

ឧទាហរណ៍ នៅថ្ងៃរៀបការពួកគាត់ « ពិធីនោះមានតែ . . . អាហារពេលព្រឹកសម្រាប់គ្រួសារ និង មិត្តភក្តិប៉ុណ្ណោះ ។ បន្ទាប់ពីអាហារពេលព្រឹករួច ស្វាមីភរិយាថ្មោងថ្មីនេះបានបើកឡានមួយបាំងកន្លះរបស់ពួកគាត់ម៉ាក T Ford ចេញទៅទីក្រុង អេមស៍ រដ្ឋ អៃអូវ៉ា ភ្លាម « ជាកន្លែងដែល អ៊ែសរ៉ា បន្តយកថ្នាក់អនុបណ្ឌិតផ្នែកសេដ្ឋកិច្ចកសិកម្ម ។ « នៅតាមផ្លូវ ពួកគាត់បានស្នាក់នៅរយៈពេលប្រាំបីយប់នៅក្នុងត្រសាលមួយដែលធ្លុះធ្លាយ ។ កាលពួកគាត់បានមកដល់ទីក្រុង អេមស៍ ពួកគាត់បានជួលបន្ទប់មួយនៅក្បែរបរិវេណមហាវិទ្យាល័យ ។ បន្ទប់ជួលនោះមានទំហំតូច ហើយគ្រួសារបែនសឹនរស់នៅក្នុងបន្ទប់ដែលមានសត្វកន្លាតជាច្រើន ប៉ុន្តែ អ៊ែសរ៉ា បានថ្លែងថា ‹ មិនយូរប៉ុន្មាន វាហាក់ដូចជាផ្ទះដ៏តូចមួយដែលមានភាពស្រណុកចិត្តបំផុត » ។[9]

កាល អ៊ែសរ៉ា ក្លាយកាន់តែមានភាពរឹងមាំនៅក្នុងបុគ្គលិកលក្ខណៈរបស់គាត់ គាត់បានប្រឡូកកាន់តែច្រើនឡើងនៅក្នុងការបម្រើនៅខាងក្រៅផ្ទះ ។ ការណ៍នេះបានដឹកនាំទៅរកដំណើរបន្សុទ្ធសម្រាប់ ផ្លូរ៉ា ផងដែរ ។ ពេលខ្លះ កាលគាត់នៅឃ្លាតឆ្ងាយ នាងមានការលំបាកដោយភាពឯកោ និង ការបាក់ទឹកចិត្ត ។ ប៉ុន្តែនាងមានចិត្តសោមនស្សធ្វើជាភរិយា និង ជាម្ដាយ ហើយនាងបានបង្ហាញអំណរគុណចំពោះសេចក្ដីល្អរបស់ស្វាមីនាង និងចំពោះការលះបង់របស់គាត់ចំពោះគ្រួសារ ។ ដើម្បីរៀនបន្ថែមទៀតពីអាពាហ៍ពិពាហ៍ ព្រមទាំងភាពជាឪពុកម្ដាយថ្មីថ្មោងរបស់ផ្លូរ៉ា និង អ៊ែសរ៉ា សូមមើលទំព័រ 12–15 ។

## ការទទួលទូរសព្ទចំនួនពីរលើកដែលបានផ្លាស់ប្ដូរជីវិត

នៅថ្ងៃទី 27 ខែ កក្កដា ឆ្នាំ 1943 ផ្លូរ៉ា បានទទួលទូរសព្ទមួយមកពីស្វាមីនាង ។ គាត់នៅទីក្រុង សលត៍ លេក រដ្ឋ យូថាហ៍ ដោយរៀបចំខ្លួនត្រឡប់មកពីដំណើរពាណិជ្ជកម្មជាមួយនឹងកូនប្រុសពួកគាត់ រីដ វិញ ។ នាងស្នាក់នៅឯផ្ទះក្បែរវ៉ាស៊ីតោន ឌី.ស៊ី. ដែលមានចម្ងាយប្រមាណជា 3,200 គ.ម. ពីគ្នា ។ បន្ទាប់ពីការសម្រាកមិនលក់ពេញមួយយប់ពេញទៅដោយការអធិស្ឋាន និង ទឹកភ្នែក គាត់បានទូរសព្ទទៅប្រាប់នាងឲ្យដឹងថា កាលពីម្សិលមិញ គាត់ត្រូវបានហៅឲ្យបម្រើជាសមាជិកម្នាក់ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។

ដំណឹងនេះមិនបានធ្វើឲ្យផ្លូរ៉ាភ្ញាក់ផ្អើលនោះទេ ។ នាង « មានអារម្មណ៍ដ៏មុតមាំមួយថា មានរឿងដ៏អស្ចារ្យមួយនឹងកើតមានឡើងក្នុងការធ្វើដំណើររបស់ស្វាមីនាងនោះ » ។[10] នាងបានបង្ហាញទំនុកចិត្តលើអ៊ែសរ៉ា ហើយពាក្យសម្ដីនាងបានធ្វើឲ្យគាត់មានភាពកក់ក្ដៅ ។ ក្រោយមក គាត់បាននៅចាំថា ៖ « វាជាការលើកទឹកចិត្ត ពេលបាននិយាយនឹងគាត់ ។ គាត់តែងបង្ហាញសេចក្ដីជំនឿយ៉ាងច្រើនមកលើខ្ញុំជាងខ្ញុំមានលើខ្លួនឯងទៅទៀត » ។[11]

ទោះជា ផ្លូរ៉ា មានភាពជឿជាក់លើស្វាមីនាងក្ដី នាងបានដឹងថា គាត់មិនអាចបំពេញការហៅរបស់គាត់តែម្នាក់ឯងបានឡើយ — គាត់ត្រូវការការជួយគាំទ្រពីគ្រួសារ និង កម្លាំងពីស្ថានសួគ៌ ។ នៅឯសន្និសីទទូទៅមួយ ពាក្យខ្សឹបប្រាប់មួយបានបង្ហាញពីសេចក្ដីស្រឡាញ់របស់ផ្លូរ៉ាចំពោះស្វាមីនាង និងការយល់ដឹងរបស់នាងពីការពឹងផ្អែករបស់គាត់លើព្រះអម្ចាស់ ( សូមមើល ទំព័រ 48–49 ) ។

ផ្លូរ៉ា បានទទួលទូរសព្ទមួយទៀតដែលបានផ្លាស់ប្ដូរជីវិតស្វាមីនាងនៅថ្ងៃទី 24 ខែ វិច្ឆិកា ឆ្នាំ 1952 ។ ពេលនេះគាត់កំពុងទៅទស្សនកិច្ចនៅតំបន់វ៉ាស៊ីងតោន ឌី.ស៊ី. ហើយនាងបានស្នាក់នៅផ្ទះនៅទីក្រុង សលត៍ លេក ។ ដ្វាយ ឌី អ៊ីសេនហូវើរ ដែលមិនយូរប៉ុន្មាននឹងចាប់ផ្ដើមធ្វើជាប្រធានាធិបតីសហរដ្ឋអាមេរិក ទើបតែបានសុំឲ្យអែលឌើរ បែនសឹន បម្រើជាលេខារបស់លោកខាងផ្នែកកសិកម្ម ជាតួនាទីខ្ពស់មួយដែលតម្រូវឲ្យមានការលះបង់ និង ការតាំង

ចិត្តដ៏អស្ចារ្យ ។ អែលឌើរ ប៉ែនសឹន បានទទួលយកមុខតំណែងនោះ ដោយបានប្រឹក្សាឲ្យធ្វើដូច្នោះដោយប្រធានសាសនាចក្រ ដេវីឌ អូ ម៉ាក់ឃេ ( 1873–1970 ) ។

កាលអែលឌើរ ប៉ែនសឹន បានប្រាប់ផ្លរ៉ា ថា ប្រធាន អ៉ីសេនហូវើរ ដែលបានជាប់ឆ្នោតបានឲ្យមុខតំណែងដល់គាត់ ហើយថាគាត់បានទទួលយក នាងបានតបថា « អូនដឹងថាលោកនឹងផ្ដល់តំណែងនោះដល់បង ។ ហើយអូនបានដឹងថា បងនឹងទទួលយក » ។ នាងបានទទួលស្គាល់ថា វាជារឿងដ៏ពិបាកសម្រាប់គ្រួសារ ប៉ុន្តែបានបន្ថែមថា « វាទំនងជាព្រះទ័យរបស់ព្រះ » ។[12]

អែលឌើរ ប៉ែនសឹន បានបម្រើជាលេខាផ្នែកកសិកម្មអស់រយៈពេលប្រាំបីឆ្នាំ ។ អំឡុងពេលនោះ គ្រួសារបានទ្រាំទ្រនៃការរស់នៅឆ្ងាយពីគ្នា ហើយអែលឌើរ ប៉ែនសឹន ត្រូវប្រឈមនឹងការរិះគន់ និង ការកោតសរសើរដែលជារឿយៗកើតមានជាមួយនឹងកិច្ចការសាធារណៈ ។ គ្រួសារប៉ែនសឹនបានទទួលឱកាសដ៏អស្ចារ្យ ។ ឧទាហរណ៍ មានគ្រាមួយ អែលឌើរ ប៉ែនសឹន បាននាំ ផ្លរ៉ានិង កូនស្រីៗពួកគាត់ ប៊េវើរលី និង បូនី ទៅធ្វើដំណើរកម្សាន្តប្រួនសប្ដាហ៍ ដែលគាត់បានធ្វើការដើម្បីស្ថាបនាទំនាក់ទំនងពាណិជ្ជកម្មជាមួយនឹងប្រទេសចំនួន 12 ផ្សេងគ្នា ( សូមមើល ទំព័រ 181–82 ) ។ ការអញ្ជើញមួយមកពីអ្នកសារព័ត៌មានម្នាក់ បាននាំទៅរកបទពិសោធន៍នៃការផ្សព្វផ្សាយសាសនាដ៏អស្ចារ្យសម្រាប់គ្រួសារ ( សូមមើល ទំព័រ 24 ) ។



**ឧបករណ៍ដ៏ស្មើភាពក្នុងព្រះហស្តរបស់ព្រះអម្ចាស់**

ដូចជាប្រធានសាសនាចក្រទាំងអស់ដែរ អ៊ែសរ៉ា ថាហ្វ ប៉ែនសឹន ត្រូវបានតែងតាំងពីមុនផែនដីសម្រាប់ការហៅរបស់លោក ។ ប៉ុន្តែលោកមិនអាចបំពេញការតែងតាំងពីមុន ឬបម្រើដោយមានកម្លាំងបែបនេះបានដោយម្នាក់ឯងបានឡើយ ។ ពិតណាស់ គ្មានមនុស្សណាផ្សេងទៀតដែលបានជះឥទ្ធិពលយ៉ាងច្រើនទៅលើលោកដូចជា ផ្លរ៉ា ទេ ។ ក្នុងសាសនាចក្រ និង ក្នុងគ្រួសារពួកគាត់ ពួកគាត់បានធ្វើការរួមគ្នាជាឧបករណ៍ដ៏មានឥទ្ធិពលនៅក្នុងព្រះហស្តរបស់ព្រះអម្ចាស់ ។

ដូចជាប្រធាន និង ស៊ិស្ទើរ ប៉ែនសឹន បានលុតជង្គង់ចុះរួមគ្នា កាលពួកគាត់បានដឹងថា លោកត្រូវធ្វើជាអធិបតីលើសាសនាចក្រ ពួកគាត់បានធ្វើការរួមគ្នាដើម្បី « ជម្រុញកិច្ចការនេះឲ្យឆ្ពោះទៅមុខនៅលើផែនដី » ។[13] កាលនាងធ្លាប់សង្ឃឹមកាលពីនៅក្មេងថា ពួកគាត់ទទួលបានអ្វីដែលពួកគេចង់បាន — រួមគ្នា ។[14]

ប្រធាន ប៉ែនសឹន បានទូន្មានដល់ពួកបរិសុទ្ធថ្ងៃចុងក្រោយពីលើវេទិកាមកឲ្យពន្លិចផែនដីនេះ និង ជីវិតរបស់ពួកគេជាមួយនឹងព្រះគម្ពីរមរមន ( សូមមើល ជំពូក 9–10 ) ។ នៅផ្ទះ ផ្លរ៉ា បានអានព្រះគម្ពីរមរមនឲ្យលោកស្ដាប់ជារៀងរាល់ថ្ងៃ រួចពួកគាត់បានពិភាក្សាគ្នាពីអ្វីដែលបានអាន ។[15] ប្រធាន ប៉ែនសឹន បានលើកទឹកចិត្តដល់ពួកបរិសុទ្ធចេញពីវេទិកាមក ឲ្យបម្រើ ហើយថ្វាយបង្គំជាទៀងទាត់ក្នុងព្រះវិហារបរិសុទ្ធ ( សូមមើល ជំពូក 13 ) ។ ផ្លរ៉ា និង អ៊ែសរ៉ា ប៉ែនសឹន បានចូលរួមក្នុងព្រះវិហារបរិសុទ្ធតែពីនាក់រៀងរាល់ថ្ងៃព្រឹកថ្ងៃសុក្រ ជាថ្ងៃដែលពួកគាត់អាចមានលទ្ធភាពធ្វើបែបនោះបាន ។[16] ប្រធាន ប៉ែនសឹន បានព្រមានចេញពីលើវេទិកាអំពីអំពើបាប នៃសេចក្ដីអំនួត និង « ការកោតសរសើររបស់លោកិយ » ។[17] ប៉ុន្តែទោះជា ផ្លរ៉ា មានជោគជ័យក្នុងការជួយ « ឲ្យពិភពលោកទាំងមូលបានស្គាល់លោក » ក្ដី[18] ពួកគាត់បានរីករាយរួមគ្នា ដោយមាន « ការកោតសរសើរពីស្ថានសួគ៌ » ដោយស្ងៀមស្ងាត់ ។[19]

ប្រធានអ៊ែសរ៉ា ថាហ្វ ប៉ែនសឹន បានធ្វើការបង្រៀនរាប់ពាន់ក្នុងនាមជាសាវក និង ជាប្រធាននៃសាសនាចក្រ ។ វាពិបាកដើម្បីស្រមើស្រមៃពីការបង្រៀនទាំងនោះដោយគ្មានឥទ្ធិពលនៃពាក្យបីម៉ាត់នោះ ដែលលោកបានថ្លែងនៅថ្ងៃទី 11 ខែ វិច្ឆិកា ឆ្នាំ 1985 ថា ៖ « ផ្លរ៉ា និង ខ្ញុំ » ។ ■

**កំណត់ចំណាំ**

1. Sheri L. Dew, *Ezra Taft Benson: A Biography* ( 1987 ) ទំព័រ 479 ។
2. អ៊ែសរ៉ា ថាហ្វ ប៉ែនសឹន ក្នុង Don L. Searle « President Ezra Taft Benson Ordained Thirteenth President of the Church » *Ensign,* ខែ ធ្នូ ឆ្នាំ 1985 ទំព័រ 5 ។
3. *Teachings of Presidents of the Church: Ezra Taft Benson* ( ឆ្នាំ 2014 ) ទំព័រ 7–8 ។
4. Dew, *Ezra Taft Benson* ទំព័រ 74–75 ។
5. *Teachings: Ezra Taft Benson* ទំព័រ 8 ។
6. *Teachings: Ezra Taft Benson* ទំព័រ 40 ។
7. *Teachings: Ezra Taft Benson* ទំព័រ 10 ។
8. *Teachings: Ezra Taft Benson* ទំព័រ 11–12 ។
9. *Teachings: Ezra Taft Benson* ទំព័រ 12 ។
10. Dew, *Ezra Taft Benson* ទំព័រ 176 ។
11. អ៊ែសរ៉ា ថាហ្វ ប៉ែនសឹន ក្នុង *Teachings: Ezra Taft Benson* ទំព័រ 16 ។
12. ផ្លរ៉ា អាំម៉ូសឹន ប៉ែនសឹន ក្នុង *Teachings: Ezra Taft Benson* ទំព័រ 23 ។
13. អ៊ែសរ៉ា ថាហ្វ ប៉ែនសឹន ក្នុង Don L. Searle « President Ezra Taft Benson Ordained Thirteenth President of the Church » *Ensign,* ខែ ធ្នូ ឆ្នាំ 1985 ទំព័រ 5 ។
14. សូមមើល ផ្លរ៉ា អាំម៉ូសឹន ប៉ែនសឹន ក្នុង *Teachings: Ezra Taft Benson* ទំព័រ 74–75 ។
15. សូមមើល Derin Head Rodriguez « Flora Amussen Benson: Handmaiden of the Lord, Helpmeet of a Prophet, Mother in Zion » *Ensign,* ខែ មិនា ឆ្នាំ 1987 ទំព័រ 20 ។
16. សូមមើល Dew, *Ezra Taft Benson* ទំព័រ 511 ។
17. *Teachings: Ezra Taft Benson* ទំព័រ 229 ។
18. *Teachings: Ezra Taft Benson* ទំព័រ 11–12 ។
19. *Teachings: Ezra Taft Benson* ទំព័រ 229 ។

# ការបម្រើដែលបានទទួលផលតបស្នងមកវិញ

កាលខ្ញុំរៀននៅឆ្នាំទីមួយក្នុងមហាវិទ្យាល័យ ខ្ញុំបានទៅជាមួយមិត្តរួមបន្ទប់ ទៅលេងនឹងអ៊ំប្រុសរបស់នាង ដែលមានវ័យ 98 ឆ្នាំ យើងតែងហៅគាត់ថា លោកអ៊ំ ចូ ។ គាត់រស់នៅតែម្នាក់ឯងហើយឯកោ ដូច្នេះយើងបានព្យាយាមទៅលេងគាត់ជារឿយៗតាមដែលអាចធ្វើទៅបាន ។ នៅពេលយើងទៅលេង គាត់បានប្រាប់យើងពីដំណើររឿងកាលពីគាត់រស់នៅប្រទេសម៉ិកស៊ិក និងនៅភូមិមួយចំនួនជាប់ព្រំប្រទល់នឹងរដ្ឋអារីហ្សូណា ព្រមទាំងណូហ្គាឡេស ផងដែរ ។

កាលមិត្តខ្ញុំបានផ្លាស់ត្រឡប់ទៅផ្ទះវិញជាបណ្ដោះអាសន្ន ខ្ញុំបានទទួលអារម្មណ៍បំផុសគំនិតឲ្យបន្តទៅលេងនឹងលោកអ៊ំអ៊ំ ចូ ។ គាត់បានក្លាយជាមិត្តដ៏ជិតស្និទ្ធម្នាក់របស់ខ្ញុំ ហើយខ្ញុំបានទៅលេងគាត់រហូតដល់គាត់បានចែកឋានទៅរយៈពេលមួយឆ្នាំកន្លះក្រោយមកហើយ ។ ខ្ញុំមានចិត្តសោកសៅដោយបាត់បង់មិត្តរបស់ខ្ញុំ ប៉ុន្តែខ្ញុំមានអំណរគុណចំពោះពេលវេលាដ៏មានតម្លៃដែលយើងបានមានជាមួយគ្នា ។

បន្ទាប់ពីលោកអ៊ំ ចូ បានចែកឋានទៅរយៈពេលដប់ឆ្នាំក្រោយមក ខ្ញុំបានអាននៅក្នុងសៀវភៅកំណត់ហេតុរបស់លោកយាយទួតខ្ញុំ ។ សៀវភៅនោះបានប្រាប់ពីការដែលស្វាមីគាត់បានចុះចោលគាត់ដោយគ្មានទុកប្រាក់ឲ្យគាត់សោះ ហើយគាត់ត្រូវបង់ថ្លៃជួលផ្ទះ 30 ដុល្លា និងចិញ្ចឹមកូនដល់ទៅប្រាំបួននាក់ ។

រួចគាត់បានសរសេរថា ៖ « នៅប៊ីស្ប៊ី [អារីហ្សូណា] មនុស្សនៅទីនេះមានចិត្តល្អចំពោះយើងណាស់ ។ សូម្បីតែពេលយើងបានរស់នៅភាគខាងត្បូងនៃប៊ីស្ប៊ីក្ដី ពួកគេបានដឹកយើង [ ពីព្រះវិហារ ] ត្រឡប់មកផ្ទះវិញ ។ បងប្រុស យ៉ូសែប ខ្លានម៉ិន ដែលរស់នៅប្រទេសម៉ិកស៊ិក បានជូនយើងមកផ្ទះជាច្រើនដង ហើយមិនតែប៉ុណ្ណោះ [ គ្រួសារគាត់ ] បាននាំយើងទាំងអស់គ្នាទៅហូបអាហារពេលល្ងាចជាមួយនឹងពួកគាត់ទៀតផង ។

លោកអ៊ំ ចូ បានរស់នៅម្នាក់ឯង ហើយឯកោ ។ ដូច្នេះមិត្តរួមបន្ទប់ខ្ញុំ និងខ្ញុំបានព្យាយាមទៅលេងគាត់ជារឿយៗតាមដែលអាចធ្វើទៅបាន ។



ពួកគាត់បានធ្វើទន្សាយបំពងដោយមានតុបតែរចនាលម្អរ ដែលធ្វើឲ្យយើងចូលចិត្តបំផុត ។ ពួកគាត់បានផ្លាស់ទៅ ណូហ្គាឡេស . . . ហើយពួកគាត់បានឲ្យសត្វទន្សាយពណ៌ — សស្អាតរបស់ពួកគាត់មកយើង ហើយយើងមានអាហារល្មមគ្រប់គ្រាន់ដើម្បីបរិភោគនៅពេលនោះ » ។

កាលខ្ញុំអានដំណើររឿងនេះ ខ្ញុំបានដឹងថា យ៉ូសែប ឃ្លីនមិន ដែលបានជួយលោកយាយទួតរបស់ខ្ញុំនោះគឺជាលោកអ៊ំ ចូ ! ខ្ញុំទទួលអារម្មណ៍ពីព្រះវិញ្ញាណខ្សឹបប្រាប់រហូតដល់ខ្ញុំបានបំផុសគំនិតឲ្យបន្តទៅលេងនឹងលោកអ៊ំ ចូ ទុកជាអំណរគុណដ៏តូចតាចមួយចំពោះសន្តានចិត្តល្អដែលគាត់បានមានចំពោះលោកយាយទួតខ្ញុំនិង គ្រួសារគាត់ ។

ខ្ញុំមានចិត្តរំភើបជាខ្លាំងដោយបានក្លាយជាផ្នែកមួយនៃដំណើររឿងអំពីសេចក្តីស្រឡាញ់ និង ការបម្រើមួយដែលបានទទួលផលតបស្នងមកវិញ ។ ខ្ញុំដឹងថា ព្រះអម្ចាស់ជ្រាបពីកូនចៅរបស់ទ្រង់ ។ ប្រសិនបើយើងស្តាប់តាមការបំផុសគំនិតរបស់ព្រះវិញ្ញាណបរិសុទ្ធ នោះយើងអាចប្រទានពរដល់ជីវិតអ្នកដទៃ ហើយក្រោយមកទទួលបានពរជ័យសម្រាប់ខ្លួនយើងវិញ ។ ■

គ្រីសី ឈើច សាំម៉ឺរ រដ្ឋយូថាហ៍ ស.រ.អា.

# តើខ្ញុំគួរសារភាពដែរឬទេ ?

កាលខ្ញុំអង្គុយនៅពីមុខសមាជិកមួយរូបនៃគណៈប្រធានស្តេក បេះដូងខ្ញុំចាប់ផ្តើមលោតខុសចង្វាក់ ។ ខ្ញុំមានអារម្មណ៍ភ័យខ្លាចចាប់តាំងពីពេលដែលស្មៀនស្តេកបានទូរសព្ទមកណាត់ជួប ។ *តើគាត់នឹងដឹងថាខ្ញុំមិនសក្តិសមដើម្បីបម្រើដែរឬទេ ?*

ខ្ញុំបានសម្រេចចិត្តថា អំពើបាបមួយចំនួនងាយស្រួលដើម្បីយកទៅឯវេទិកាកាត់សេចក្តីរបស់ព្រះជាងនៅលើផែនដីនេះ ដោយគិតថាវាគឺជារឿងដ៏អាត្មានិយមបំផុត ដើម្បីប្រាប់រឿងទាំងឡាយដែលនាំឲ្យភរិយាខ្ញុំឈឺចាប់ ឬអាម៉ាស់មុខនោះ ។ វាជាការល្អដើម្បីយកឈ្នះវាដោយខ្លួនឯង ហើយរស់នៅដោយមានបន្ទុកនោះ ។ បញ្ហាតែមួយគត់គឺថា ខ្ញុំមិនអាចយកឈ្នះវាដោយខ្លួនឯងបានឡើយ ។

ខ្ញុំបានអង្គុយនៅទីនោះ កាលទីប្រឹក្សាក្នុងគណៈប្រធានស្តេកបានផ្តល់ការហៅបម្រើមួយដល់ខ្ញុំ ។ គាត់បានសួរថា « ប្អូនប្រុស តើអ្នកព្រមទទួលយកការហៅនេះដែរឬទេ ? » ខ្ញុំចង់តែស្រែកថា « បាទ ! » ប៉ុន្តែផ្ទុយទៅវិញ ខ្ញុំបានឮខ្លួនឯងនិយាយរាងស្ទាក់ស្ទើរថា « ខ្ញុំមិនអាចទទួលយកបានទេ ខ្ញុំត្រូវដោះស្រាយអំពើបាបមួយចំនួនសិន » ។

ការភ័យបារម្ភ និង ភាពធូរស្រាលបានកើតមានចំពោះខ្ញុំក្នុងពេលតែមួយ កាលខ្ញុំបានសារភាពពីលក្ខណៈនៃអំពើបាបនោះ ។ គាត់បានសួរខ្ញុំថា ខ្ញុំបាននិយាយនឹងប៊ីស្សពខ្ញុំហើយឬនៅ ។ « ទេ » ។ ចុះភរិយាខ្ញុំវិញ ? « *ទេ* » ។ គាត់បានចាប់ដៃខ្ញុំ ហើយប្រាប់ខ្ញុំទាំងញញឹមថា គាត់មានមោទនភាពចំពោះខ្ញុំខ្លាំងណាស់ សម្រាប់ការសារភាពនេះ ហើយបានណែនាំខ្ញុំ និង ភរិយាខ្ញុំឲ្យជួបជាមួយនឹងប៊ីស្សព ។

ខ្ញុំបានគោរពតាម ដោយត្រូវប្រាប់ភរិយាខ្ញុំជាមុនសិន — ដូច្នេះវាបានដកយកការភ័យខ្លាចដ៏ធំបំផុតរបស់ខ្ញុំចេញ ។ នាងនៅតែស្រឡាញ់ខ្ញុំ ! ពិតណាស់ នាងបានអាក់អន់ចិត្ត ហើយយើងត្រូវដោះស្រាយរឿងមួយចំនួន ប៉ុន្តែនាងស្រឡាញ់ខ្ញុំ ហើយបានលើកទឹកចិត្តខ្ញុំឲ្យទៅជួបនឹងប៊ីស្សព ។

កាលខ្ញុំបានទៅជួបនឹងប៊ីស្សព រំពេចនោះគាត់បានស្វាគមន៍ខ្ញុំចូលទៅក្នុងការិយាល័យរបស់គាត់ ។ ខ្ញុំបានព្យាយាមបញ្ជាក់ពីហេតុផលដែលខ្ញុំមកជួបនឹងគាត់ទាំងពិបាកបំផុត ។ បន្ទាប់ពីលាក់បាំងអំពើបាបរបស់ខ្ញុំជាយូរមកហើយ ខ្ញុំមិនដឹងថាត្រូវចាប់ផ្តើមពីត្រង់ណានោះទេ ។ គាត់បានលើកទឹកចិត្តខ្ញុំដោយសេចក្តីស្រឡាញ់ឲ្យសម្អាតអំពើបាបនោះចេញ ។ ខ្ញុំបានពន្យល់ពីលក្ខណៈនៃអំពើបាបរបស់ខ្ញុំ ហើយបានសូមពេលដើម្បីផ្តល់នូវបញ្ជីដ៏ពេញលេញនៃទង្វើខុសឆ្គងរបស់ខ្ញុំ ។ គាត់បានយល់ព្រមដោយក្តីរីករាយ ។

ខ្ញុំនៅតែមិនទាន់បានសារភាពទាំងស្រុងនៅឡើយ ប៉ុន្តែខ្ញុំមានអារម្មណ៍ថា ទម្ងន់នៃពិភពលោកកំពុងតែលើកចេញពីស្មារបស់ខ្ញុំ ។ នៅទីបំផុត ខ្ញុំក៏មានអារម្មណ៍នូវសេចក្តីសង្ឃឹមថ្មីនៃសេរីភាពពីបន្ទុកនេះផងដែរ ។

ខ្ញុំបានចំណាយពេលជាច្រើនសប្តាហ៍ក្រោយមកអធិស្ឋាន អានព្រះគម្ពីរ ហើយបង្កើតបញ្ជីរបស់ខ្ញុំដើម្បីបង្ហាញទៅដល់ប៊ីស្សព និង ព្រះវរបិតាសួគ៌របស់ខ្ញុំ ។ ដំបូង ខ្ញុំបានយកបញ្ជីរបស់ខ្ញុំទូលប្រាប់ដល់ព្រះវរបិតាសួគ៌ ដោយចិត្តសង្រេង និង វិញ្ញាណទន់ទាប ដើម្បីឲ្យទ្រង់បានជ្រាបថា ខ្ញុំមានចិត្តសោកស្តាយ ហើយមានបំណងចង់កែប្រែដោយស្មោះ ។ ខ្ញុំបានណាត់ជួបនឹងប៊ីស្សពម្តងទៀត ហើយបានបង្ហាញបញ្ជីទាំងមូលរបស់ខ្ញុំទៅដល់គាត់ ។ គាត់មិនបានចងចិញ្ចើម ស្រែក ឬស្តីបន្ទោសដល់ខ្ញុំទេ ផ្ទុយទៅវិញ គាត់បានឱបខ្ញុំយ៉ាងណែន ។ គាត់បានប្រាប់ខ្ញុំឲ្យដឹងពីសេចក្តីស្រឡាញ់របស់គាត់ និង សេចក្តីស្រឡាញ់របស់ព្រះអម្ចាស់ ដោយប្រាប់ខ្ញុំថា ឥឡូវនេះខ្ញុំស្ថិតនៅលើផ្លូវនៃការប្រែចិត្តដ៏ពិតហើយ ។ ខ្ញុំបានដឹងថាវាគឺជាការពិត ។

ការសារភាពអំពើបាបរបស់ខ្ញុំ ដែលជាការភ័យខ្លាចដ៏ធំបំផុតរបស់ខ្ញុំកាលពីមុន បានក្លាយទៅជាបទពិសោធន៍មួយដ៏ល្អបំផុតនៅក្នុងជីវិតខ្ញុំ ។ វាគឺជាជំហានទីមួយសម្រាប់ខ្ញុំ ដើម្បីយល់ដឹងយ៉ាងច្បាស់ពីអំណោយទាន និង ព្រះចេស្តាដើម្បីព្យាបាលនៃដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។ ■

ឈ្មោះត្រូវត្រូវបានដកចេញ



# យើងបានដើរតាមផ្លូវនោះ

នៅតំបន់ចុងក្រោយក្នុងបេសកកម្មខ្ញុំ ដៃគូខ្ញុំ និង ខ្ញុំបានបម្រើនៅក្នុងភូមិចំនួនពីរដែលមានទីតាំងនៅក្នុងរដ្ឋសៅ ផាឡូ ប្រទេសប្រេស៊ីល ។ នៅចន្លោះភូមិទាំងពីរនោះមានផ្លូវវាងមួយកាត់តាមព្រៃ ដែលយើងពុំធ្លាប់ធ្វើដំណើរតាមផ្លូវនោះពីមុនមកឡើយ ដោយសារយើងមានអារម្មណ៍អាចមានភាពគ្រោះថ្នាក់ ហើយទំនងដូចជាគ្មាននរណាម្នាក់ធ្វើដំណើរតាមផ្លូវនោះឡើយ ។

នៅរសៀលមួយ កាលយើងហៀបនឹងទៅដល់ផ្លូវវាងនោះ ព្រះវិញ្ញាណបរិសុទ្ធបានប៉ះដួងចិត្តខ្ញុំដោយប្រាប់ខ្ញុំថា យើងគួរចូលទៅក្នុងព្រៃនោះ ។ ខ្ញុំមើលមុខអែលឌើរ អង់ឌ្រេដ ហើយប្រាប់គាត់ពីអារម្មណ៍ដែលខ្ញុំទើបតែទទួលបាន ។ គាត់បានប្រាប់ខ្ញុំថា គាត់ក៏មានអារម្មណ៍ដូចគ្នាដែរ ។

កាលយើងបានចាប់ផ្ដើមចុះតាមផ្លូវដែលមិនស្គាល់នោះមិនយូរប៉ុន្មាន យើងបានឃើញស្ត្រីម្នាក់កំពុងដើរមករកយើង ។ ផ្លូវនោះតូចណាស់ ហើយកាលយើងបានដើរកាត់គាត់ យើងបានឃើញថាគាត់កំពុងតែយំ ។

កាលគាត់បានងើយមុខឡើង គាត់បានអញ្ជើញយើងឲ្យមកតាមគាត់ទៅផ្ទះរបស់គាត់ ដើម្បីទៅជួបនឹងស្វាមីរបស់គាត់ ។ ភ្លាមនោះ យើងបានចាប់ផ្ដើមបង្រៀនដំណឹងល្អដល់ប្ដីប្រពន្ធមួយគូនេះ ។ បន្ទាប់ពីពីរបីសប្ដាហ៍មក យើងបានអញ្ជើញពួកគេឲ្យទទួលបុណ្យជ្រមុជទឹក ។ យើងបានរីករាយយ៉ាងខ្លាំង កាលពួកគាត់បានទទួលយកដោយក្ដីរីករាយ ដោយសារវួដពុំបានធ្វើបុណ្យជ្រមុជទឹកអស់រយៈពេលមួយឆ្នាំហើយ ។ យើងមានអំណរគុណដែលយើងបានធ្វើតាមការបំផុសគំនិតឲ្យចូលតាមផ្លូវនោះនៅថ្ងៃនោះ ។

ប៉ុន្តែពីមុនពិធីបុណ្យជ្រមុជទឹករបស់ពួកគាត់បន្តិច ស្ត្រីដែលជាភរិយាបានពោលថា គាត់ចង់និយាយនឹងពួកយើង ។ គាត់បានពោលថា អស់រយៈពេលជាច្រើនឆ្នាំហើយ គាត់ធ្លាប់មានសុបិនមួយម្ដងហើយម្ដងទៀត ។ នៅក្នុងសុបិនរបស់គាត់ គាត់បានឃើញថាគាត់កំពុងរង់ចាំនៅត្រង់ចំណុចកណ្ដាលនៃរដ្ឋសៅ ផាឡូ ។ មានបុរសចំណាស់ម្នាក់បានដើរមករកគាត់ ហើយប្រាប់ថា យុវជនពីរនាក់នឹងមកផ្លាស់ប្ដូរជីវិតគាត់ ។ រួចគាត់បានឃើញយុវជនពីរនាក់ដើរមក ប៉ុន្តែសុបិនរបស់គាត់តែងតែបញ្ចប់នៅត្រង់ចំណុចនេះ ។

មានថ្ងៃមួយកាលពីពីរបីសប្ដាហ៍មុន កាលគាត់កំពុងតែបោសសម្អាតផ្ទះ គាត់បានឮសំឡេងមួយប្រាប់គាត់ថា យុវជនពីរនាក់នោះកំពុងតែមកហើយ ហើយថាគាត់ត្រូវចេញទៅផ្លូវវាងនោះភ្លាម ជាកន្លែងដែលយើងបានជួបគាត់ដំបូង ។ ដោយមិនបានយល់ពីការបំផុសគំនិត ប៉ុន្តែចង់ដឹងពីចម្លើយចំពោះសុបិនរបស់គាត់ គាត់បានទម្លាក់អំបោសគាត់ចុះ ហើយដើរទៅផ្លូវនោះ ។

កាលដែលគាត់កំពុងដើរ រូបភាពនៃសុបិនរបស់គាត់បានផុសឡើងក្នុងគំនិតគាត់ ដូចជានៅក្នុងខ្សែភាពយន្តមួយដែលបញ្ចប់នៅត្រង់ឈុតឆាកដែលនៅទីបំផុតគាត់បានឃើញមុខរបស់យុវជនទាំងពីរនាក់នោះ ។ គាត់ក៏បានឃើញថា ពួកគេទាំងពីរនាក់មានពាក់ស្លាកឈ្មោះពណ៌ខ្មៅផងដែរ ។ មួយសន្ទុះក្រោយមក គាត់បានពោលថា អែលឌើរ អង់ឌ្រេដ និង ខ្ញុំបានលេចឡើងនៅចំពោះមុខគាត់នៅលើផ្លូវនោះ ។ គាត់មានអារម្មណ៍រំភើបជាខ្លាំង ហើយគាត់មិនអាចទប់ខ្លួនឯងមិនឲ្យយំបានឡើយ ។

នៅសព្វថ្ងៃនេះ ដោយចងចាំពីបទពិសោធន៍ដ៏ពិសិដ្ឋនោះ ខ្ញុំទទួលអារម្មណ៍ពីព្រះវិញ្ញាណ ហើយបានឃើញនៅក្នុងគំនិតខ្ញុំជាថ្មីម្ដងទៀតនូវទឹកមុខដែលពោរពេញដោយទឹកភ្នែករបស់បងស្រីនោះ ដែលបានឱបក្រសោបយកដំណឹងល្អ ។ វាគឺជាសំណាងល្អណាស់ ដែលដៃគូខ្ញុំ និង ខ្ញុំមានអារម្មណ៍ និង ភាពក្លាហានដើម្បីដើរតាមផ្លូវដែលព្រះអម្ចាស់បានប្រាប់ដល់យើងនៅថ្ងៃនោះ ។ ■

រុត ឌេ អូលីវីរ៉ា ម៉ាកូលីណូ វីយ៉ូ ហ្វ្រេដ ដូ ន័រតេ ប្រទេសប្រេស៊ីល

កាលយើងបានចាប់ផ្ដើមចុះតាមផ្លូវដែលមិនស្គាល់នោះ មិនយូរប៉ុន្មាន យើងបានឃើញស្ត្រីម្នាក់កំពុងដើរមករកយើង ។ យើងមិនអាចជួយអ្វីបានឡើយ ប៉ុន្តែបានសង្កេតឃើញថា គាត់កំពុងតែយំ ។



# តើអ្នកចង់បានផ្កាទេ ?

មានថ្ងៃមួយ ជាពិសេសនៅក្រោយពេលវេនធ្វើការដ៏សែនលំបាកក្នុងសាលមន្ទីរពេទ្យកុមារ ខ្ញុំបានអស់កម្លាំង ហើយមានចិត្តមួរម៉ៅ ។ កាលខ្ញុំដើរទៅតុសន្តិសុខ ខ្ញុំបានឃើញផ្កាដ៏ស្រស់ស្អាត ។ នៅពេលខ្ញុំបានប្រាប់ទៅអ្នកដែលអង្គុយនៅឯតុនោះ ថាផ្កាទាំងនេះស្រស់ស្អាត ហើយមានក្លិនក្រអូបថែមទៀតផង នោះនាងប្រាប់ខ្ញុំថា ខ្ញុំអាចយកវាបាន ។

ខ្ញុំមានចិត្តរីករាយជាខ្លាំង ! ខ្ញុំបានគិតថា ប្រាកដជាព្រះវរបិតាសួគ៌ចង់ឲ្យខ្ញុំបានផ្កាទាំងនេះ ដើម្បីធ្វើឲ្យខ្ញុំបានសប្បាយចិត្តហើយមើលទៅ ។

ពេលដើរចេញពីមន្ទីរពេទ្យ ខ្ញុំសង្កេតឃើញថាខ្ញុំបាននៅពីក្រោយស្ត្រីម្នាក់ ដែលអង្គុយនៅលើកៅអីរុញ ។ ខ្ញុំមានការតានតឹងចិត្តជាខ្លាំងជាមួយនឹងគាត់ ប៉ុន្តែនៅទីបំផុតខ្ញុំបានហួសគាត់ទៅ កាលយើងបានចេញពីអគារនោះ ។ កាលខ្ញុំបានដើរហួសគាត់ គាត់ងើបមុខឡើង ហើយពោលថា « អូ៎ ផ្កាទាំងនោះស្រស់ស្អាតណាស់ » ។ ខ្ញុំបានអរគុណគាត់ ហើយបានប្រញាប់ដើរទៅរកស្វាមីខ្ញុំដែលកំពុងរង់ចាំនៅឯឡាន ។ ខ្ញុំមានចិត្តរំភើបដើម្បីបង្ហាញផ្ការបស់ខ្ញុំដល់គាត់ ។

រំពេចនោះ ខ្ញុំបានទទួលអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធប្រាប់ខ្ញុំថា ស្ត្រីម្នាក់នោះត្រូវការផ្កាទាំងនោះជាងខ្ញុំទៅទៀត ។ ខ្ញុំមានការស្ទាក់ស្ទើរឲ្យវាទៅគាត់ ប៉ុន្តែខ្ញុំបានធ្វើតាមការបំផុសគំនិតនោះ ។ កាលខ្ញុំបានសួរថាតើគាត់ចង់បានផ្កាទេ ខ្ញុំបានសង្ឃឹមថាគាត់នឹងនិយាយថាទេ ។

« អូ៎ ជាការប្រពៃណាស់ ! » គាត់បានតប ។ « ខ្ញុំចូលចិត្តវាណាស់ ។ វាស្រស់ស្អាត » ។

ខ្ញុំបានជូនផ្កាទាំងនោះទៅគាត់ ប៉ុន្តែកាលខ្ញុំងាកដើរចេញ គាត់បានចាប់ផ្ដើមយំ ។ នៅពេលខ្ញុំបានសួរថាគាត់មានរឿងអី គាត់បានប្រាប់ខ្ញុំថា ស្វាមីគាត់បានស្លាប់កាលពីពីរបីឆ្នាំមុន ហើយថាវាអស់រយៈពេលជាងមួយឆ្នាំហើយ ដែលកូនចៅរបស់គាត់មិនបានមកសួរសុខទុក្ខនឹងគាត់ ។ គាត់បានពោលថា គាត់បានទូលអង្វរដល់ព្រះឲ្យបង្ហាញគាត់ពីទីសម្គាល់នៃសេចក្ដីស្រឡាញ់របស់ទ្រង់ ។

គាត់បានពោលថា « អ្នកគឺជាទេវតាដែលព្រះបានបញ្ជូនមកដើម្បីយកផ្កាដែលខ្ញុំចូលចិត្តមកឲ្យខ្ញុំ » ។ « ឥឡូវខ្ញុំដឹងថា ទ្រង់ស្រឡាញ់ខ្ញុំ » ។

ខ្ញុំមានចិត្តក្ដុកក្ដួលយ៉ាងខ្លាំង ។ ខ្ញុំជាមនុស្សអាត្មានិយមខ្លាំងណាស់ ។ ស្ត្រីម្នាក់នេះត្រូវការពាក្យល្អមួយម៉ាត់តែប៉ុណ្ណោះ ប៉ុន្តែខ្ញុំបែរជាមិនចង់និយាយនឹងគាត់ទៅវិញ ។ ខ្ញុំមិនមែនជាទេវតាទេ ។ កាលយើងបានលាគ្នា ខ្ញុំក៏បានចាប់ផ្ដើមយំផងដែរ ។

នៅពេលខ្ញុំបានដើរទៅដល់ឡាន ស្វាមីខ្ញុំបានសួរថាតើមានរឿងអី ហើយហេតុអ្វីក៏ខ្ញុំឲ្យផ្កានោះទៅគេ ។ គាត់ហាក់ដូចជាងឿងឆ្ងល់ ប៉ុន្តែក្រោយមកបានធូរចិត្តវិញ កាលខ្ញុំបានប្រាប់ពីដំណើររឿងនោះ ។

គាត់បានប្រាប់ថា « ថ្ងៃនេះ បងបានផ្ញើផ្កាមកឲ្យអូន ។ បងមានអារម្មណ៍ថា អូនត្រូវការវា » ។ « បងបារម្ភខ្លាចអូនឲ្យវាទៅអ្នកដទៃ ។ បើផ្កាទាំងនោះពុំមែនជាផ្កាដែលបងផ្ញើឲ្យអូន អញ្ចឹងតើវានៅឯណា ? »

តាមពិតទៅ ហាងផ្កាភ្លេចផ្ញើផ្កាកូលាបនោះ ដូច្នេះយើងបានបើកឡានទៅហាងនោះ ។ ស្វាមីខ្ញុំបានចូលទៅក្នុងហាង ហើយមិនយូរប៉ុន្មានបានចេញមកវិញដោយមានផ្កាមួយបាច់ដ៏ស្រស់ស្អាត ។

ខ្ញុំមិនអាចទប់ចិត្តខ្ញុំមិនឲ្យយំម្ដងទៀតបានឡើយ ។ ព្រះវរបិតាសួគ៌បានសុំឲ្យខ្ញុំលះបង់ផ្កាទាំងនោះ ដោយជ្រាបថាមានអ្វីមួយប្រសើរជាងនេះកំពុងរង់ចាំខ្ញុំ ហើយក៏បានជ្រាបផងដែរថា បុត្រីរបស់ទ្រង់ដែលឯកោត្រូវការការរំឭកពីសេចក្ដីស្រឡាញ់របស់ទ្រង់ ។ ■

ស៊ីនឌី អាលម៉ារ៉ាស្ស អាន់ធូនី រដ្ឋយូថាហ៍ ស.រ.អា.








# ប្រឹក្សារួមគ្នាជារឿយៗ ៖

## ក្រុមប្រឹក្សាគ្រួសារសម្រាប់ភរិយា និងស្វាមី

**ដោយ នីកូល អេក**

ក្រុមប្រឹក្សាក្នុងសាសនាចក្រធ្វើតាមគំរូដ៏ទេវភាពនៅគ្រប់កម្រិតចាប់តាំងពីក្រុមប្រឹក្សានៃគណៈប្រធានទីមួយ និងកូរ៉ុមនៃពួកសាវកដប់ពីរនាក់រហូតដល់ស្តេក វួដ សាខា កូរ៉ុម និង ក្រុមប្រឹក្សាថ្នាក់ដឹកនាំដទៃទៀតដែរ ។ ប្រធាន ស្ពែនស៊ើរ ដបុលយូ ឃីមបឹល ( 1895–1985 ) បានថ្លែងថា « ក្រុមប្រឹក្សាដ៏សំខាន់បំផុតរបស់សាសនាចក្រ » គឺជាក្រុមប្រឹក្សាគ្រួសារ ។[1]

> ក្រុមគ្រួសារទាំងឡាយជួបប្រទះនឹងបញ្ហា ហើយនិងការសម្រេចចិត្តជាច្រើន ។ គោលការណ៍ស្ដីពីក្រុមប្រឹក្សាគ្រួសារទាំងប្រាំមួយនេះអាចជួយអ្នកបាន ។

អែលឌើរ អិម រ័សុល បាឡឺដ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា « ក្រុមប្រឹក្សាគ្រួសារគឺការប្រជុំដ៏ល្អបំផុតដើម្បីធ្វើឲ្យទំនាក់ទំនងដ៏មានប្រសិទ្ធភាពកើតឡើង » ។[2] លោកបានពន្យល់ថា វាគឺជាឱកាសមួយដើម្បី « និយាយអំពីសេចក្ដីត្រូវការរបស់គ្រួសារ និងសេចក្ដីត្រូវការរបស់សមាជិកគ្រួសារម្នាក់ៗ . . . ដោះស្រាយបញ្ហា ធ្វើការសម្រេចចិត្តជាគ្រួសារ [ និង ] ដាក់ផែនការប្រចាំថ្ងៃ ព្រមទាំងសកម្មភាព និង គោលដៅរយៈពេលយូររបស់គ្រួសារផងដែរ » ។[3]

ប្រសិនបើអ្នកពុំទាន់មានក្រុមប្រឹក្សាគ្រួសារនៅឡើយ អ្នកអាចចាប់ផ្ដើមវានៅថ្ងៃនេះ ។ ប្រសិនបើអ្នកមានកូនរស់នៅជាមួយនឹងអ្នក អ្នកអាចរាប់បញ្ចូលពួកគេផងដែរ ។ ប៉ុន្តែ វាក៏ជាកត្តាដ៏សំខាន់ផងដែរ ដែលស្វាមី និង ភរិយាមានក្រុមប្រឹក្សាគ្រួសារដាច់ដោយឡែកមួយ ជាពេលដែលពួកគេអាចពិភាក្សាពីបញ្ហាគ្រួសារ និង បញ្ហាផ្ទាល់ខ្លួនតែពីរនាក់ ។

នេះគឺជាគោលការណ៍ និង សេចក្ដីណែនាំដ៏មានប្រយោជន៍មួយចំនួន ដែលអ្នកអាចអនុវត្តនៅក្នុងការប្រឹក្សាគ្រួសាររបស់អ្នករវាងស្វាមី និង ភរិយា ។

### ចាប់ផ្ដើមដោយការអធិស្ឋាន

« *នៅពេលទំនាក់ទំនងជាមួយនឹងព្រះវរបិតាសួគ៌ក្លាយទៅជាអសារឥតការ នោះទំនាក់ទំនងរវាងស្វាមី និងភរិយាក៏ឥតបានប្រយោជន៍ផងដែរ* » ។[4]

ព្រះអម្ចាស់អាចជាអ្នកចូលរួមដ៏សំខាន់នៅក្នុងអាពាហ៍ពិពាហ៍របស់អ្នក ។ នៅក្នុងការអធិស្ឋានរបស់អ្នក អ្នកអាចថ្លែងអំណរគុណដល់ព្រះវរបិតាសួគ៌សម្រាប់ពរជ័យជាច្រើនរបស់អ្នករួមទាំងស្វាមី ឬភរិយារបស់អ្នកផងដែរ ហើយទូលសូមឲ្យព្រះវិញ្ញាណទ្រង់បានគង់នៅក្នុងការសន្ទនារបស់អ្នក ។ ព្រះវិញ្ញាណទ្រង់អាចដឹកនាំការពិភាក្សារបស់អ្នក ហើយជួយបង្កើតនូវអារម្មណ៍ និង ទំនាក់ទំនងល្អៗ ។



## សម្រេចចិត្តរួមគ្នា

« *ការព្រមព្រៀងរបស់សមាជិកក្នុងការប្រឹក្សានេះត្រូវតែមាន តាមរយៈការអធិស្ឋាន និង ការពិភាក្សា ដើម្បីឲ្យមានសាមគ្គីភាពដែលជាតម្រូវការពីមុនទទួលបានជំនួយរបស់ព្រះអម្ចាស់* » ។[5]

អ្នក និង ស្វាមី ឬភរិយារបស់អ្នកត្រូវតែធ្វើការសម្រេចចិត្តដ៏សំខាន់ ដូចជាថាតើគួរទទួលយកការងារដែលបានផ្ដល់ឲ្យ ឬមិនគួរ ត្រូវចូលរៀនសាលាមួយណា ត្រូវមានកូននៅពេលណា ឬរបៀបបែងចែកការងារផ្ទះ ។ ស្វាមី និង ភរិយាអាចដាក់ស្នើនូវដំណោះស្រាយល្អៗសម្រាប់បញ្ហានានា ហើយពិភាក្សាវា ។ សូមស្ដាប់ដោយរាបសាចំពោះគំនិតរបស់ស្វាមី ឬភរិយារបស់អ្នក ។ ការណ៍នេះអាចជួយអ្នកឲ្យយល់ពីទស្សនៈរបស់អ្នកដទៃ ហើយនឹងរំឭកស្វាមី ឬភរិយារបស់អ្នកថា អ្នកឲ្យតម្លៃទៅលើទស្សនៈរបស់គាត់ ។

នៅក្នុងក្រុមប្រឹក្សាគ្រួសារ យើងត្រូវតែឈានទៅដល់ការសម្រេចចិត្តដ៏សំខាន់របស់យើង « ដោយការព្រមព្រៀងដ៏ទេវភាព ពុំមែនដោយការសម្រុះសម្រួលគ្នានោះទេ » ។[6] អ្នកប្រហែលជាមិនអាចទទួលបាននូវសាមគ្គីភាពនេះភ្លាមៗនៅគ្រប់បញ្ហាបានឡើយ ។ ការសម្រេចចិត្តអាចតម្រូវឲ្យមានក្រុមប្រឹក្សាជាច្រើនដង និង ការអធិស្ឋានដោយស្មោះ — ទាំងដោយរៀងៗខ្លួន និងជាមួយស្វាមី ឬភរិយា — ដើម្បីយល់ស្របចំពោះការសម្រេចចិត្តមួយ ។ ប៉ុន្តែ « ប្រសិនបើអ្នកនឹងពិភាក្សាក្នុងក្រុមប្រឹក្សាដូចដែលអ្នកត្រូវបានរំពឹងទុកឲ្យធ្វើ នោះព្រះនឹងប្រទានដំណោះស្រាយដល់អ្នកនៅរាល់បញ្ហាដែលរារាំងអ្នក » ។[7]

វាក៏ជាការល្អផងដែរ ដើម្បីសម្រេចចិត្តទុកជាមុនពីប្រធានបទសម្រាប់ក្រុមប្រឹក្សាគ្រួសារ ។ ការណ៍នេះនឹងផ្ដល់ពេលឲ្យអ្នករិះគិតពីប្រធានបទនោះ ដើម្បីអ្នក និង ស្វាមី ឬភរិយាអ្នកអាចត្រៀមអារម្មណ៍ដើម្បីបញ្ចេញគំនិតរបស់អ្នក ។

## វាយតម្លៃខ្លួនឯង

« *ហេតុអ្វីបានជាអ្នកមើលឃើញកំទេចដែលនៅក្នុងភ្នែករបស់បងប្អូនអ្នក តែមិនឃើញធ្នឹមដែលនៅក្នុងភ្នែករបស់ខ្លួនសោះដូច្នេះ ?* » ( *ម៉ាថាយ 7:3* ) ។

អ្នកមានអំណាចដើម្បីផ្លាស់ប្ដូរមនុស្សតែម្នាក់គត់ ៖ គឺខ្លួនឯង ។ អ្នកប្រហែលជាត្រូវបានល្បួងឲ្យប្រើក្រុមប្រឹក្សាគ្រួសារបង្ហាញនូវបញ្ជីនៃការរិះគន់ដល់ស្វាមី ឬភរិយារបស់អ្នក ។ ផ្ទុយទៅវិញ ចាប់ផ្ដើមក្រុមប្រឹក្សាទាំងដោយបំណងប្រាថ្នាចង់ធ្វើឲ្យខ្លួនឯងបានប្រសើរឡើង ។ សួរស្វាមី ឬភរិយាអ្នកថា តើមានអ្វីមួយដែលជាបញ្ហា ឬការព្រួយបារម្ភដែលគាត់បានសង្កេតឃើញនៅក្នុងពាក្យសម្ដី ឬឥរិយាបថរបស់អ្នកដែរឬទេ ។ ដាក់គោលដៅសម្រាប់ការកែលម្អផ្ទាល់ខ្លួន ហើយសុំការគាំទ្រពីស្វាមី ឬភរិយារបស់អ្នក កាលអ្នកខិតខំធ្វើការផ្លាស់ប្ដូរ ។ គាំទ្រដល់ស្វាមី



ឬភរិយារបស់អ្នកនៅរាល់គោលដៅផ្ទាល់ខ្លួនដែលគាត់ចង់ធ្វើ ។

**ពិភាក្សាពីរឿងពិបាក**

*« គ្រួសារគ្រប់រូបមានបញ្ហា និង ឧបសគ្គ ។ ប៉ុន្តែផ្ទុយទៅវិញក្រុមគ្រួសារដ៏មានជោគជ័យ ព្យាយាមធ្វើការរួមគ្នា ឆ្ពោះទៅរកដំណោះស្រាយនានាជាជាងការងាកទៅរកការរិះគន់ និង ការទាស់ទែងគ្នា »* ។[8]

អាពាហ៍ពិពាហ៍រឹងមាំត្រូវបានស្ថាបនាដោយការយកឈ្នះឧបសគ្គទាំងឡាយ ពុំមែនដោយការគេចវេស ឬជៀសវាងពីវានោះទេ ។ វានឹងកើតមានកាលដែលបញ្ហាធំៗបានកើតឡើង ដែលតម្រូវឲ្យមានការពិភាក្សាគ្នា ។ ឧទាហរណ៍ អ្នកប្រហែលជាមានការពិបាកដើម្បីយកឈ្នះលើបញ្ហាអំពើបាប និង ការប្រែចិត្ត ឬបន្ទុកផ្នែកហិរញ្ញវត្ថុ ប៉ុន្តែទំនាក់ទំនងដោយបើកទូលាយ និងដោយស្មោះត្រង់របស់ក្រុមប្រឹក្សាគ្រួសារអាចជួយបន្ធូរអារម្មណ៍ដ៏តានតឹងនោះបាន ។ ក្រុមប្រឹក្សាគ្រួសារអាចដើរតួជាការប្រជុំមួយដ៏ល្អដើម្បីលើកឡើងនូវកង្វល់ ឬ សុំជំនួយ ។

ផ្តោតគំនិតរបស់អ្នកទៅលើដំណោះស្រាយដែលអាចកើតមានចំពោះបញ្ហានោះ ហើយចៀសវាងពីការឈ្លោះប្រកែកគ្នា ឬការរិះគន់ ។ ចូរមានចិត្តរាបសា ។ ចែកចាយសេចក្តីស្រឡាញ់ដល់ស្វាមី ឬភរិយារបស់អ្នក ហើយរំឭកគ្នាទៅវិញទៅមកថា អ្នកទាំងពីរកំពុងធ្វើការរួមគ្នាដើម្បីបង្កើតអាពាហ៍ពិពាហ៍ និង គ្រួសារមួយដ៏រីករាយ និងដ៏នៅអស់កល្បជានិច្ច ។

**រក្សាបរិយាកាសល្អជានិច្ច**

ប្រសិនបើអ្នកគិតថា *ក្រុមប្រឹក្សាគ្រួសារគ្រាន់តែជា « ពេលដ៏តានតឹង . . . ហើយមិនដែលទទួលស្គាល់ . . . នូវជោគជ័យ ឬកោតសរសើរដល់ [ សមាជិកគ្រួសារអ្នក ] ហើយបង្ហាញសេចក្តីស្រឡាញ់របស់អ្នកដល់ពួកគេ នោះពួកគេនឹងភ័យខ្លាចចំពោះក្រុមប្រឹក្សាគ្រួសារ »* ។[9]

ពុំមែនរាល់ការប្រជុំក្រុមប្រឹក្សាគ្រួសារត្រូវតែផ្តោតទៅលើបញ្ហា ឬការសម្រេចចិត្តជានិច្ចនោះទេ ។ អ្នកអាចយកឱកាសនោះដើម្បីចែកចាយពីរឿងល្អៗអំពីភរិយា ឬស្វាមីរបស់អ្នក ឬ ចែកចាយពីពរជ័យនៅក្នុងជីវិតរបស់អ្នក ។ អ្នកអាចអបអរដល់ជោគជ័យផ្ទាល់ខ្លួន ពិភាក្សាពីរបៀបដើម្បីពង្រឹងខាងវិញ្ញាណ ដល់អាពាហ៍ពិពាហ៍ និង គ្រួសាររបស់អ្នក ដាក់គោលដៅរួមគ្នា ឬបង្ហាញអំណរគុណចំពោះភាពរឹងមាំ ឬទង្វើនៃការបម្រើរបស់ស្វាមី ឬភរិយាអ្នក ។ សូមប្រើក្រុមប្រឹក្សាគ្រួសារដើម្បី « បង្កើតទម្លាប់នៃទំនាក់ទំនង និង ការគោរពគ្នាទៅវិញទៅមកដែល . . . [អ្នក និង ស្វាមី ឬភរិយាអ្នក] អាចពឹងផ្អែក កាលបញ្ហាធំៗ ហើយពិបាកបានកើតឡើង » ។[10]

**តស៊ូ**

*« ចូរយើងធ្វើឲ្យអស់ពីលទ្ធភាព ហើយព្យាយាមធ្វើឲ្យប្រសើរឡើងជារៀងរាល់ថ្ងៃ ។ កាលភាពទន់ខ្សោយរបស់យើងបានលេចឡើង យើងអាចខំព្យាយាមកែតម្រូវវា ។ យើងអាចមានការអត់ទោសដល់កំហុសចំពោះខ្លួនឯង និងចំពោះមនុស្សដែលយើងស្រឡាញ់ឲ្យកាន់តែច្រើន »* ។[11]

ជាចុងក្រោយ សូមចងចាំថា ការដាក់ជំនួសទម្លាប់នៃទំនាក់ទំនងមិនល្អជាមួយនឹងគំរូវិជ្ជមានត្រូវការពេលវេលា និង ការអនុវត្ត ។ ក្រុមប្រឹក្សាគ្រួសារដំបូងរបស់អ្នកអាចទំនងជាមានភាពឆ្គាំឆ្គង ឬ គួរឲ្យខ្លាចញញើត ប៉ុន្តែនៅពេលអ្នកព្យាយាមទំនាក់ទំនងជាមួយគ្នាដោយរាបសា ហើយដាក់បញ្ចូលព្រះអម្ចាស់នៅក្នុងការសម្រេចចិត្តរបស់អ្នក អ្នកនឹងយល់ដឹងកាន់តែប្រសើរពីពរជ័យនៃក្រុមប្រឹក្សាគ្រួសារ ។

ព្រះអម្ចាស់មានព្រះទ័យចង់ឲ្យយើងមានសេចក្តីសុខសាន្តនៅ





ក្នុងផ្ទះ និង ក្នុងទំនាក់ទំនងរបស់យើង ។ ទ្រង់ជួយយើងកាលណាយើងមានកំហុស ហើយប្រទានពរដល់កិច្ចខិតខំរបស់យើង ។ ដោយមានជំនួយរបស់ទ្រង់ យើងអាចថែទាំ « បរិយាកាសនៃការគោរព ការយល់ចិត្ត និង ភាពសុខដុម »[12] ដែលនឹងធ្វើឲ្យផ្ទះរបស់យើងប្រៀបបាន « នឹងស្ថានសួគ៌នៅលើផែនដី » ដូចដែលប្រធាន ថូម៉ាស អេស ម៉នសុន បានសន្យា ។[13] ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា. ។*

**កំណត់ចំណាំ**


1. *Teachings of Presidents of the Church: Spencer W. Kimball* ( ឆ្នាំ 2006 ) ទំព័រ 211 ។
2. អិម រ័សុល បាឡឺដ *Counseling with Our Councils: Learning to Minister Together in the Church and in the Family* ( ឆ្នាំ 2012 ) ទំព័រ 165 ។
3. អិម រ័សុល បាឡឺដ « Family Councils: A Conversation with Elder and Sister Ballard » *Liahona,* ខែ មិថុនា ឆ្នាំ 2003 ទំព័រ 14 ។
4. អិម រ័សុល បាឡឺដ « Family Councils » *Liahona,* ទំព័រ 17 ។
5. រ៉ូណាល់ អ៊ី ផូលមែន « Priesthood Councils: Key to Meeting Temporal and Spiritual Needs » *Ensign,* ខែ ឧសភា 1980 ទំព័រ 91 ។
6. រ៉ូណាល់ អ៊ី ផូមែន « Priesthood Councils » ទំព័រ 91 ។
7. ស្ទេហ្វិន អិល រីឆាដ ក្នុង Conference Report ខែ តុលា ឆ្នាំ 1953 ទំព័រ 86 ។
8. អ៊ែសរ៉ា ថាហ្វ ប៊ែនសឹន « Counsel to the Saints » *Ensign,* ខែ ឧសភា ឆ្នាំ 1984 ទំព័រ 6 ។
9. *When Thou Art Converted, Strengthen Thy Brethren* ( Melchizedek Priesthood study guide ឆ្នាំ 1974 ) ទំព័រ 168 ។
10. « Family Councils: A Heavenly Pattern » *Follow Me: Relief Society Personal Study Guide* ( ឆ្នាំ 1989 ) ទំព័រ 171 ។
11. រ័សុល អិម ណិលសុន « Perfection Pending » *Ensign,* ខែ វិច្ឆិកា ឆ្នាំ 1995 ទំព័រ 88 ។
12. « Working Together in Family Councils » *Ensign,* ខែ កុម្ភៈ ឆ្នាំ 1985 ទំព័រ 31 ។
13. ថូម៉ាស អេស ម៉នសុន « Hallmarks of a Happy Home » *Ensign,* ខែ វិច្ឆិកា ឆ្នាំ 1988 ទំព័រ 69 ។


## តើយើងពិភាក្សាពីអ្វី ?

ប្រសិនបើអ្នកមិនដឹងពីអ្វីដែលត្រូវពិភាក្សានៅក្នុងក្រុមប្រឹក្សាគ្រួសារ សូមគិតពីសំណួរទាំងនេះ ៖

- តើយើងអាចបែងចែកការងារដើម្បីឲ្យសមាជិកម្នាក់ៗចែកចាយទំនួលខុសត្រូវក្នុងផ្ទះ ហើយមានអារម្មណ៍ល្អពីអ្វីដែលពួកគេកំពុងធ្វើដោយរបៀបណា ?
- តើប្រព័ន្ធផ្សព្វផ្សាយប្រភេទណាដែលយើងនឹងអនុញ្ញាតឲ្យមាននៅក្នុងផ្ទះ ?
- តើជំនាញថ្មីណាអ្វីខ្លះដែលយើងអាចរៀនជាគ្រួសារ ?
- តើយើងអាចធ្វើអ្វីខ្លះជាគ្រួសារដើម្បីលុបបំបាត់នូវការឈ្លោះប្រកែកគ្នា ?
- តើសកម្មភាពដែលនឹងលើកទឹកចិត្តយើងឲ្យរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធមានអ្វីខ្លះ ?
- តើយើងអាចរៀបចំខ្លួនសម្រាប់គ្រោះថ្នាក់ធម្មជាតិបានដោយរបៀបណា ?
- តើយើងចូលរួមនៅក្នុងសហគមន៍របស់យើងឲ្យបានច្រើនតាមរបៀបណា ?
- តើទំនៀមទម្លាប់ថ្មីអ្វីទៅដែលយើងអាចចាប់ផ្ដើមជាគ្រួសារ ?
- តើយើងអាចធ្វើឲ្យការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុរបស់យើងបានប្រសើរឡើងដោយរបៀបណា ?
- តើយើងអាចធ្វើអ្វីខ្លះដើម្បីពង្រឹងខាងវិញ្ញាណដល់អាពាហ៍ពិពាហ៍របស់យើង ?

# ភាពក្លាហាន

ដោយ គ្រីស្ទាន ហ័គក្លាន់

នៅពេលខ្ញុំបានបញ្ចប់បេសកកម្ម ហើយត្រឡប់ទៅប្រទេសកំណើតខ្ញុំនៅស៊ុយអែតវិញ ខ្ញុំមានចិត្តរសប់រសល់ស្អុគស្អាញអស់រយៈពេលយ៉ាងយូរជាមួយនឹងជំហានបន្ទាប់ទៀតក្នុងជីវិតខ្ញុំ — អាពាហ៍ពិពាហ៍ក្នុងព្រះវិហារបរិសុទ្ធ ។ ព្រះវិញ្ញាណបានបញ្ជាក់ប្រាប់ខ្ញុំថា ខ្ញុំត្រូវតែចាប់ផ្ដើមគ្រួសារខ្ញុំដើម្បីក្លាយទៅជាមនុស្សដែលខ្ញុំត្រូវប្រែក្លាយ ។ ខ្ញុំបានផ្ដោតយកចិត្តទុកដាក់យ៉ាងខ្លាំងថា តើរឿងនេះគឺជាការសម្រេចចិត្តដ៏សំខាន់បំផុតក្នុងជីវិតយ៉ាងដូចម្ដេចទៅ ទោះជាខ្ញុំមានអារម្មណ៍ថាខ្ញុំបានរកឃើញដៃគូដ៏អស់កល្ប ហើយថាព្រះអម្ចាស់បានអនុញ្ញាតចំពោះការជ្រើសរើសរបស់ខ្ញុំក៏ដោយ សេចក្ដីជំនឿរបស់ខ្ញុំនៅតែមានភាពស្ទាក់ស្ទើរ ។ មិត្តស្រីរបស់ខ្ញុំឈ្មោះ អេវីលីណា និងខ្ញុំបានរើសពេលសម្រាប់ការផ្សារភ្ជាប់របស់យើងនៅក្នុងព្រះវិហារបរិសុទ្ធ បានកក់កន្លែងសម្រាប់រាត្រីក្រេបទឹកឃ្មុំ ហើយបានទិញចិញ្ចៀនភ្ជាប់ពាក្យពីមុនយើងភ្ជាប់ពាក្យទៅទៀត — រឿងទាំងអស់នេះកើតឡើង ដោយសារខ្ញុំខ្លាចក្នុងការតាំងចិត្តដើម្បីរៀបការ ។ ខ្ញុំចង់ឲ្យព្រះវរបិតាសួគ៌បង្គាប់ដល់ខ្ញុំឲ្យរៀបការនឹងអេវីលីណា ដោយសារខ្ញុំខ្លាចក្នុងការទទួលខុសត្រូវចំពោះការសម្រេចចិត្តនោះ ក្នុងករណីដែលអាពាហ៍ពិពាហ៍របស់យើងអាចត្រូវបានបញ្ចប់ ។ ការភ័យខ្លាច និង ការអធិស្ឋានខុសបានធ្វើឲ្យខ្ញុំគាំងតក់ស្លុតចំពោះការសម្រេចចិត្តដ៏សំខាន់ដែលនៅតែគ្របបាំងលើខ្ញុំ ។



**ខ្ញុំបានរៀនប្រើសិទ្ធិជ្រើសរើសរបស់ខ្ញុំដើម្បីធ្វើសកម្មភាពជាជាងទទួលរងនូវអំពើ កាលខ្ញុំបានធ្វើការសម្រេចចិត្តដ៏សំខាន់បំផុតនៅក្នុងជីវិតខ្ញុំ ។**

## សិទ្ធិជ្រើសរើស — របៀបរបស់ព្រះអម្ចាស់

នៅទីបំផុត ការបំផុសគំនិតរបស់ព្រះវិញ្ញាណបរិសុទ្ធបានធ្វើឲ្យមានការផ្លាស់ប្ដូរគំនិត កាលខ្ញុំបើកអាននៅក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញា 58:26–29៖ « ត្បិតមើលចុះ មិនសមឲ្យយើងត្រូវបញ្ជានូវគ្រប់អ្វីៗទាំងអស់ទេ ត្បិតអ្នកណាដែលត្រូវគេបង្ខំនូវគ្រប់អ្វីៗទាំងអស់ អ្នកនោះមានឈ្មោះថា ជាបាវ [ខ្ជិលច្រអូស ] ។ . . .

« . . . មនុស្សលោកត្រូវឧស្សាហ៍ចូលរួមក្នុងប្រយោជន៍ល្អ ហើយប្រព្រឹត្តអ្វីៗជាច្រើនតាមបំណងចិត្ត ហើយនាំមកនូវសេចក្ដីសុចរិតដ៏ច្រើន

« ត្បិតអំណាចគឺមាននៅក្នុងខ្លួនគេ ម្ល៉ោះហើយពួកគេជាភ្នាក់ងារចំពោះខ្លួនផ្ទាល់ ។ . . .

« ប៉ុន្តែអ្នកណាដែលមិនប្រព្រឹត្តអ្វីសោះឡើយ ទាល់តែអ្នកនោះត្រូវបានបញ្ជា ហើយទទួលបញ្ញត្តិនោះដោយចិត្តសង្ស័យ ហើយកាន់តាមដោយចិត្តខ្ជិលច្រអូស អ្នកនោះឈ្មោះថាជាប់ទោសហើយ » ។

កាលខ្ញុំរិះគិតពីបទគម្ពីរទាំងនេះ ខ្ញុំទទួលបាននូវការយល់ដឹងពីតួនាទីនៃសិទ្ធិជ្រើសរើសនៅក្នុងផែនការនៃព្រះវរបិតាសួគ៌យើង ដែលបានផ្លាស់ប្ដូរការគិតរបស់ខ្ញុំ ហើយផ្ដល់ឲ្យខ្ញុំនូវភាពក្លាហានដើម្បីឆ្ពោះទៅមុខ ។ អែលឌើរ រីឆាដ ជី ស្កុត ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនថា ប្រសិនបើយើងទទួលបានការដឹកនាំដ៏បំផុសគំនិត

# ដើម្បីរៀបការ

ដោយគ្មានការខិតខំផ្ទាល់ខ្លួនរបស់យើងទេនោះ យើងនឹងបាត់បង់នូវ « ការរីកចម្រើនផ្ទាល់ខ្លួនដ៏ចាំបាច់ » ដែលកើតមាន « កាល [ យើង ] មានការពិបាកដើម្បីរៀនពីរបៀបទទួលបានការដឹកនាំពីព្រះវិញ្ញាណ » ។[1]



**អំណាចដើម្បីឆ្ពោះទៅមុខ**

ក្រោយមក ខ្ញុំបានតាំងចិត្តអនុវត្តសេចក្ដីជំនឿខ្ញុំ ហើយធ្វើការសម្រេចចិត្តមួយ ហើយព្រះអម្ចាស់បានប្រទានពរខ្ញុំជាមួយនឹងភាពជឿជាក់លើសមត្ថភាពខ្ញុំដើម្បីសម្រេចចិត្ត ។ ខ្ញុំបានដឹងថា ខ្ញុំគួរតែ « ធ្វើរឿងឲ្យបានច្រើន ។ . . . ហើយធ្វើអ្វីៗជាច្រើនតាមបំណងចិត្ត [ របស់ខ្ញុំ ] » — រួមបញ្ចូលទាំងការភ្ជាប់ពាក្យដែរ ។ ព្រះអម្ចាស់លើកទឹកចិត្តយើងឲ្យប្រើអំណាចរបស់យើងជាភ្នាក់ងារដើម្បីគ្រប់គ្រងខ្លួនយើង ។ ការប្រើអំណាចនេះគឺជាកត្តាដ៏សំខាន់មួយនៅក្នុងជីវិតរបស់យើង ។

ខ្ញុំជឿថា ព្រះអម្ចាស់មានព្រះទ័យចង់ឃើញយើងអនុវត្តសិទ្ធិជ្រើសរើសរបស់យើងជាងការឃើញយើងធ្វើការសម្រេចចិត្តដ៏ល្អឥតខ្ចោះជានិច្ចនោះ ។ ប៉ុន្តែទ្រង់បានប្រទានឲ្យយើងនូវមធ្យោបាយចាំបាច់ដើម្បីធ្វើការសម្រេចចិត្តត្រឹមត្រូវ ជាពិសេសនៅពេលត្រូវសម្រេចចិត្តរៀបការនឹងនរណាម្នាក់នោះ ។ ដូចប្រធាន ស្ពែនសើរ ដបុលយូ឵ ឃីមបឹល ( 1895–1985 ) បានបង្រៀនថា « អារម្មណ៍មិនត្រូវកំណត់នូវការសម្រេចចិត្តទាំងស្រុងនោះទេ ប៉ុន្តែគំនិត និង ដួងចិត្តវិញទេតើ ដែលបានពង្រឹងដោយការតមអាហារ ការអធិស្ឋាន និង ការគិតពិចារណាដ៏ហ្មត់ចត់ ដែលនឹងផ្ដល់ឱកាសមួយដ៏ល្អបំផុតសម្រាប់សុភមង្គលក្នុងអាពាហ៍ពិពាហ៍ ។ វានាំមកជាមួយនូវការលះបង់ ការចែករំលែក និង ទាមទារឲ្យមានការមិនខ្វាយខ្វល់ពីខ្លួនឯង » ។[2]

យើងក៏មាននូវការណែនាំក្នុងបទគម្ពីរអំពីរបៀបទទួលបានការបញ្ជាក់ខាងវិញ្ញាណផងដែរ ៖ « អ្នកត្រូវសិក្សាក្នុងគំនិតរបស់អ្នក រួចហើយ អ្នកត្រូវសូមដល់យើង បើសិនជាត្រឹមត្រូវ នោះយើងនឹងបណ្ដាលឲ្យទ្រូងរបស់អ្នកខ្ជួលខ្វាញ់ខាងក្នុង ហេតុដូច្នោះហើយ អ្នកនឹងមានអារម្មណ៍ថា ការណ៍នោះត្រឹមត្រូវ ។

« ប៉ុន្តែបើសិនជាការណ៍នោះមិនត្រឹមត្រូវវិញ នោះអ្នកនឹងពុំមានអារម្មណ៍យ៉ាងដូច្នោះឡើយ ប៉ុន្តែអ្នកនឹងអាប់គំនិត » ( គ. និង ស. 9:8–9 ) ។ ប៉ុន្តែ ពុំមែនយើងទាំងអស់គ្នាសុទ្ធតែទទួលបានភាពខ្ជួលខ្វាញ់នៅក្នុងទ្រូងរបស់យើងជាចម្លើយនៃការបញ្ជាក់ខាងវិញ្ញាណរបស់ព្រះអម្ចាស់នោះទេ ។ យើងម្នាក់ៗត្រូវតែរៀនស្គាល់ពីរបៀបជាក់លាក់របស់យើងនៃការទទួលបានការបញ្ជាក់ទាំងនេះ ។[3] ដោយការធ្វើតាមគំរូនេះ យើងនឹងទទួលបានសេចក្ដីជំនឿក្នុងសមត្ថភាពរបស់យើងដើម្បីធ្វើការជ្រើសរើស ។

ព្រះវរបិតាសួគ៌បានជ្រាបពីសេចក្ដីត្រូវការនៃដួងចិត្ត ព្រលឹង និង គំនិតរបស់ខ្ញុំ ។ ទ្រង់បានប្រទានសេចក្ដីពិតទាំងនេះ ដែលធ្វើឲ្យអាកប្បកិរិយាចិត្ត និង គំនិតរបស់ខ្ញុំផ្លាស់ប្ដូរទាំងស្រុង ។ អេលីវីណា និង ខ្ញុំបានរៀបការ ។ ឥឡូវនេះ រយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ យើងបានរីករាយនឹងជីវិតគ្រួសារដ៏មានសុភមង្គល ហើយយើងមានកូនបីនាក់ដ៏ស្រស់ស្អាត ។ ខ្ញុំមានអំណរគុណជាខ្លាំងចំពោះព្រះអម្ចាស់សម្រាប់ទីបន្ទាល់របស់ខ្ញុំអំពីសិទ្ធិជ្រើសរើស និង តួនាទីរបស់វាក្នុងការធ្វើការសម្រេចចិត្តដ៏សំខាន់បំផុតនៅក្នុងជីវិត ។ ■

*អ្នកនិពន្ធរស់នៅទីក្រុង ស្តុកខុល ប្រទេសស៊ុយអែត ។*

**កំណត់ចំណាំ**

1. អែលឌើរ រីឆាត ជី ស្កត « To Acquire Spiritual Guidance » *Liahona,* វិច្ឆិកា ឆ្នាំ 2009 ទំព័រ 7 ។
2. ស្ពែនសើរ ដបុលយូ ឃីមបឹល « Oneness in Marriage » *Liahona,* ខែ តុលា ឆ្នាំ 2002 ទំព័រ 36 ។
3. សូមមើលផងដែរ គោលលទ្ធិ និង សេចក្ដីសញ្ញា 8:2–3 ។

ខាងឆ្វេង ៖ រចនារូបថតដោយ ក្លូលីណា ប៉េស្ស៊ូក្គី ខាងស្ដាំ ៖ រចនារូបថតដោយ OLENA KYRIAN/ISTOCK/THINKSTOCK

# បាវចនាម៉្យូឆលឆ្នាំ 2015

*« ហេតុដូច្នេះហើយ ឱអ្នករាល់គ្នាដែលចាប់ផ្ដើមធ្វើការបម្រើព្រះអើយ សូមឲ្យឃើញថា អ្នករាល់គ្នាបម្រើទ្រង់ឲ្យអស់ពីចិត្ត អស់ពីពលំ អស់ពីគំនិត ហើយអស់ពីកម្លាំង ដើម្បីឲ្យអ្នករាល់គ្នាអាចបានឈរដោយឥតទោសនៅចំពោះព្រះនៅថ្ងៃចុងក្រោយបំផុត » ( គ. និង ស. 4:2 ) ។*



## ឱអ្នករាល់គ្នា

# ដែលចាប់ផ្ដើម

## ធ្វើការបម្រើព្រះអើយ

## ការបម្រើដោយអស់ពីព្រលឹងរបស់អ្នក

**ដោយគណៈប្រធានយុវនារីទូទៅ**

**នៅ**ពេលយើងរៀននៅក្នុងបាវចនាម៉្យូឆលឆ្នាំ 2015 វាគឺជាអភ័យឯកសិទ្ធិដ៏ពិសិដ្ឋមួយដើម្បីបម្រើដល់ព្រះ ។ យើងសង្ឃឹមថា នៅឆ្នាំនេះយើងម្នាក់ៗនឹងរៀនបម្រើដោយមានការតាំងចិត្តដ៏ខ្ពស់តាមរបៀប ដែលព្រះអង្គសង្គ្រោះបានបង្រៀន — ឲ្យអស់ពីចិត្ត អស់ពីពលំ អស់ពីគំនិត ហើយអស់ពីកម្លាំងរបស់យើង ។ តើយើងអាចធ្វើរឿងនោះបានដោយរបៀបណា ? ទាំងនេះគឺជាគំនិតមួយចំនួន ។

ទីមួយ យើងបម្រើឲ្យអស់ពី**ចិត្តរបស់យើង ។** យើងយល់ថាប្រយោគនេះមានន័យថា ការបម្រើរបស់អ្នកចំពោះព្រះ ត្រូវតែមានការបំផុសគំនិតដោយសេចក្ដីស្រឡាញ់របស់អ្នកចំពោះទ្រង់ និងកូនចៅទ្រង់ ។ « សេចក្ដីស្រឡាញ់របស់យើងចំពោះព្រះអម្ចាស់ត្រូវបានបង្ហាញដោយមនោសញ្ចេតនារបស់យើង ដោយរបៀបដែលយើងចំណាយពេលវេលារបស់យើង ចំណូលចិត្តដែលយើងតាមរក និងលំដាប់នៃអាទិភាពរបស់យើង » ។[1] អ្នកអាចបង្ហាញព្រះអម្ចាស់ពីសេចក្ដីស្រឡាញ់របស់អ្នក នៅពេលអ្នកគោរពតាមព្រះបញ្ញត្តិរបស់ទ្រង់ ( សូមមើល គ. និង ស. 42:29 ) ។ អ្នកបម្រើដល់មនុស្សក្នុងផ្ទះរបស់អ្នក ហើយពង្រឹងដល់គ្រួសារអ្នក ។ អ្នកលើកតម្កើងការហៅរបស់អ្នក ហើយឈោងដៃទៅជួយដល់ជនដែលត្រូវការមិត្តភក្ដិ ។ អ្នកស្វែងរកឈ្មោះគ្រួសារដើម្បីយកទៅព្រះវិហារបរិសុទ្ធ ។



*បូនី អិល អូស្កាសុន ប្រធាន (កណ្ដាល) ខារ៉ុល អេហ្វ ម៉ាក់ខន់ឃី ទីប្រឹក្សាទីមួយ (ខាងឆ្វេង) នៀល អេហ្វ ម៉ារីយ៉ូត ទីប្រឹក្សាទីពីរ (ខាងស្ដាំ)*

រូបភាពដោយ THE DESIGN FARM; រូបថតខាងក្រោមដោយ ISTOCK/THINKSTOCK

ទីពីរ យើងបម្រើព្រះឲ្យអស់ពី**ពលំរបស់យើង ។** ត្រូវមានកម្លាំងកាយ និង ការខំប្រឹងប្រែងដ៏ឧស្សាហ៍ព្យាយាម ។ កិច្ចការផ្សព្វផ្សាយសាសនាតម្រូវឲ្យមានកម្លាំងចិត្ត និង ការស៊ូទ្រាំ ។ អ្នកបម្រើឲ្យអស់ពីពលំ នៅពេលអ្នកយកចិត្តទុកដាក់នឹងសេចក្ដីត្រូវការអ្នកដទៃត្រូវការអ្នក « ដូចជាឲ្យអាហារដល់អ្នកអត់ឃ្លាន ឲ្យសំលៀកបំពាក់ដល់អ្នកអាក្រាត ទៅមើលអ្នកឈឺ ហើយជួយគាំទ្រដល់គេទាំងខាងវិញ្ញាណ និង ខាងសាច់ឈាម » ( ម៉ូសាយ 4:26 ) ។

បន្ទាប់មកទៀត យើងបម្រើឲ្យអស់**ពីគំនិតរបស់យើង ។** គំនិតរបស់អ្នកត្រូវតែមានភាពស្អាតស្អំ ហើយបរិសុទ្ធ ផ្ដោតទៅលើព្រះអង្គសង្គ្រោះ ។ អ្នកបានចុះសេចក្ដីសញ្ញាដើម្បីចងចាំទ្រង់ជានិច្ច ។ អ្នកស្វែងរកការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធតាមរយៈការសិក្សាព្រះគម្ពីរ និង ការអធិស្ឋាន ។ កាលណាអ្នកធ្វើឲ្យគំនិត ពាក្យសម្ដី និង ទង្វើរបស់អ្នកស្របទៅនឹងព្រះតំរិះ និង ព្រះទ័យរបស់ព្រះ អ្នកស្គាល់ពីសេចក្ដីត្រូវការរបស់អ្នក ហើយមានភាពសក្ដិសម ព្រមទាំងត្រៀមខ្លួនជាស្រេចដើម្បីបម្រើ ។

ចុងក្រោយបង្អស់ យើងបម្រើព្រះឲ្យអស់**ពីកម្លាំងរបស់យើង ។** វិធីមួយដើម្បីទទួលបានកម្លាំង គឺការអនុវត្តសេចក្ដីជំនឿទៅលើដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ ។ អ្នកប្រែចិត្ត ហើយញែកខ្លួនអ្នកឲ្យបរិសុទ្ធតាមរយៈការគោរពប្រតិបត្តិតាមព្រះបញ្ញត្តិរបស់ទ្រង់ ។ អ្នកទទួលអារម្មណ៍នូវព្រះចេស្ដាគាំទ្ររបស់ព្រះអង្គសង្គ្រោះ ហើយឃើញនូវអព្ភូតហេតុ កាលណាអ្នកបម្រើនៅក្នុងកម្លាំងរបស់ព្រះអម្ចាស់ ( សូមមើល អាលម៉ា 26:12 ) ។

នៅពេលអ្នកបម្រើព្រះឲ្យអស់ពីព្រលឹងរបស់អ្នក ទ្រង់សន្យាថា អ្នកនឹងត្រូវបានជ្រះស្អាតពីអំពើបាប ហើយរៀបចំខ្លួនឈរនៅចំពោះព្រះភក្ត្រទ្រង់ ហើយទទួលបាននូវសិរីល្អដ៏អស់កល្បរបស់ទ្រង់ ។ ■

**កំណត់ចំណាំ**

1. អ៊ែសរ៉ា ថាហ្វ ប៊ែនសឹន « The Great Commandment — Love the Lord » *Ensign* ខែ ឧសភា ឆ្នាំ 1988 ទំព័រ 4 ។

# កិច្ចការដ៏អស្ចារ្យនេះ

**ដោយគណៈប្រធានយុវជនទូទៅ**

**នៅ**ពេលអ្នកឮពាក្យថា *ចាប់ផ្ដើម*តើអ្នកគិតពីអ្វីខ្លះ ? ពីការរៀបចំបើកក្ដោងកប៉ាល់មួយមែនទេ ? ពីការចូលរួមក្នុងបុព្វហេតុដ៏ធំមួយមែនទេ ? ពីការចាប់ផ្ដើមនៃដំណើរមួយមែនទេ ?

នៅពេល « ចាប់ផ្ដើមធ្វើការបម្រើព្រះ » អ្នកកំពុងចូលរួមក្នុងដំណើរដ៏អស្ចារ្យមួយដែលពុំធ្លាប់មានពីមុនមក ។ អ្នកកំពុងជួយព្រះឲ្យពន្លឿនកិច្ចការរបស់ទ្រង់ ហើយវាគឺជាបទពិសោធន៍មួយដ៏ល្អ រីករាយ ហើយអស្ចារ្យ ។

ចូរកុំឆាប់ជឿលើសម្ដីរបស់ពួកយើងពេក ។ កាលពីឆ្នាំមុន នៅក្រុងតូចមួយក្នុងរដ្ឋយូថាហ៍ មានយុវជនជាច្រើនក្នុងកូរ៉ុមគ្រូបានចូលទៅកាន់វិបសាយសកម្មភាពសម្រាប់យុវវ័យ ( lds.org/youth/activities ) ដើម្បីស្វែងរកគំនិតធ្វើសកម្មភាពមួយ ។ មានគំនិតដ៏ជាក់លាក់មួយបានធ្វើឲ្យពួកគេជាប់ចិត្ត ដែលសរសេរថា ៖ « ការបម្រើរយៈពេលប្រាំពីថ្ងៃ » ។

យុវជនទាំងនេះបានសម្រេចចិត្តធ្វើរឿងមួយដ៏ធំ ៖ ពួកគេបានធ្វើការបម្រើជារៀងរាល់ថ្ងៃពេញមួយសប្ដាហ៍ដល់មនុស្សគ្រប់គ្នាក្នុងវួដដែលបានសុំឲ្យជួយ ។ នៅមានក្រុមគ្រួសារចំនួន 19 គ្រួសារបានចុះឈ្មោះ ពួកយុវជនទាំងនោះមានការភ្ញាក់ផ្អើល ហើយថែមទាំងគិតថានឹងមានរឿងដែលត្រូវធ្វើច្រើនផងដែរ ។ តើពួកគេអាចធ្វើការបម្រើដ៏ច្រើនបែបនេះនៅក្នុងរយៈពេលមួយដ៏ខ្លីបានដោយរបៀបណា ? ប៉ុន្តែពួកគេបានធ្វើការតាំងចិត្តមួយ ដូច្នេះពួកគេបាន



*ដេវីឌ អិល បេក ប្រធាន (កណ្ដាល) ឡារី អិម ហ្គីបសិន ទីប្រឹក្សាទីមួយ (ខាងឆ្វេង) រ៉ានឌល អិល រិដ ទីប្រឹក្សាទីពីរ (ខាងស្ដាំ)*

សម្រេចចិត្តបម្រើក្រុមគ្រួសារទាំងអស់នោះ ។

តែមួយសប្ដាហ៍ប៉ុណ្ណោះ ពួកគេបានចំណាយពេលច្រើនជាង 250 ម៉ោង ធ្វើការបម្រើរួមគ្នា ដោយធ្វើការជាច្រើនដូចជាការលើកថ្មមួយគំនរធំ ច្រកខ្សាច់ដាក់បាវ សម្អាតប្រឡាយ និង រៀបអូស ។ ហើយកិច្ចការនេះក៏បានផ្លាស់ប្ដូរយុវជនទាំងនោះផងដែរ ។

ពួកគេមានអារម្មណ៍ភ្ញាក់ផ្អើលដោយសារកម្លាំងដែលពួកគេមាន និង ពរជ័យដែលពួកគេបានទទួល ។ ពួកគេបានរៀបរាប់ពីអារម្មណ៍នៃសាមគ្គីភាពជាកូរ៉ុម និង ការទទួលបានជំនួយពីព្រះដើម្បីធ្វើកិច្ចការសាលា និង ទំនួលខុសត្រូវផ្សេងទៀត ។ ឥឡូវនេះ នៅវួដរបស់ពួកគេត្រូវការការបម្រើកូរ៉ុមគ្រូនេះបានឆ្លើយតបដោយសាទរ ។ ពួកគេមិនគ្រាន់តែចង់បម្រើសម្រាប់រយៈពេលមួយសប្ដាហ៍ប៉ុណ្ណោះទេ — ពួកគេព្យាយាមបម្រើជារៀងរាល់ថ្ងៃ ។

ការបម្រើ និង ការស្ដាបនានគរព្រះពិតជាកិច្ចការមួយដ៏អស្ចារ្យមែន ។ វាបាននាំមកនូវសេចក្ដីអំណរដល់យុវជនទាំងនេះ ហើយវានឹងនាំសេចក្ដីអំណរដល់អ្នក កាលណាអ្នកជួយលើកអ្នកដទៃឡើង ហើយមើលឃើញជីវិតពួកគេផ្លាស់ប្ដូរដោយកិច្ចខិតខំដ៏បរិសុទ្ធ ហើយស្មោះត្រង់ ។ ដូចដែលគណៈប្រធានយុវនារីទូទៅបានបញ្ជាក់នៅទំព័រទី 48 ដែរ វាគឺជាអភ័យឯកសិទ្ធមួយដើម្បីបម្រើដល់ព្រះ ។

សូមចាប់ផ្ដើមឥឡូវនេះក្នុងការបម្រើរបស់អ្នកចំពោះព្រះ « ឲ្យអស់ពីចិត្ត ឲ្យអស់ពីពលំ ឲ្យអស់ពីគំនិត និង ឲ្យអស់ពីកម្លាំងរបស់អ្នក » ( គ. និង ស. 4:2 ) ។ យើងចង់ដឹងពីបទពិសោធន៍ការបម្រើរបស់អ្នក ! សូមថតជាវីដេអូ ហើយថតរូបអំពីការបម្រើរបស់អ្នក រួចដាក់វានៅក្នុងវិបសាយប្រព័ន្ធផ្សព្វផ្សាយសង្គមនានា ចែកចាយវាជាមួយនឹងគ្រួសារ និង មិត្តភក្ដិរបស់អ្នក និងអ៊ីម៉ែលវាទៅកាន់ liahona@ldschurch.org ។ អ្នកក៏អាចប្រាប់អ្នកដទៃពីរឿងរ៉ាវទាំងនេះនៅលើវិបសាយសកម្មភាពសម្រាប់យុវវ័យផងដែរ ។ សូមអញ្ជើញអ្នកដទៃឲ្យចូលរួមនឹងអ្នកនៅក្នុងកិច្ចការដ៏អស្ចារ្យនេះ ហើយចាំមើលថាតើយើងអាចផ្លាស់ប្ដូរពិភពលោកនេះបានដល់កម្រិតណា ។ ■



# មួយជំហាន ម្តងៗ

*យុវវ័យក្នុងប្រទេសអ៊ីតាលី បានចែកចាយពីរបៀបដែលពួកគេបម្រើដល់ព្រះដោយអស់ពីចិត្ត គំនិត កម្លាំង និង ពលំរបស់ពួកគេ ។*

**ដោយ ហិល្លារី អុលសិន**

ឥឡូវនេះ ដោយសារអ្នកដឹងថាបាវចនាម៉ូឆលសម្រាប់ឆ្នាំនេះគឺអំពីការបម្រើ តើអ្នកនឹងធ្វើអ្វីខ្លះ ? ព្រះអម្ចាស់បានសុំឲ្យអ្នកបម្រើទ្រង់ឲ្យ*អស់*ពីចិត្ត អស់ពីពលំ អស់ពីគំនិត និង អស់ពីកម្លាំងរបស់អ្នក ( សូមមើល គ. និង ស. 4:2 ) ។ កិច្ចការនោះគឺច្រើនណាស់ ហើយវាអាចមានអារម្មណ៍ថាលើសលុប ។ ប៉ុន្តែមិនចាំបាច់មានអារម្មណ៍បែបនេះឡើយ ។

ម៉ាកូ ឌី មកពី តារ៉ង់តូ ប្រទេសអ៊ីតាលី បាននិយាយថា « វាដូចជាការឡើងលើភ្នំមួយដូច្នោះដែរ » ។ « ការគិតពីការឡើងភ្នំទាំងមូលក្នុងពេលតែមួយ វាគឺជារឿងដ៏លំបាក ប៉ុន្តែប្រសិនបើអ្នកធ្វើវាមួយជំហានម្តងៗ វានឹងមានភាពងាយស្រួលជាង ។ សូមបោះមួយជំហានម្តងៗ ហើយនៅពេលអ្នកដើរបានមួយជំហាន សូមគិតថា ‹ ខ្ញុំបានធ្វើវាហើយ ! › រួចដើរមួយជំហានទៀត » ។

នៅក្នុងចំណោមជីវិតនៃប្រជាជនអ៊ីតាលី យុវវ័យអ៊ីតាលីភាគខាងត្បូងបានរកឃើញនូវជំហានដ៏មានអត្ថប្រយោជន៍មួយចំនួន ដើម្បីផ្តោតយកចិត្តទុកដាក់ នៅពេលពួកគេព្យាយាមបម្រើឲ្យ*អស់*ពីចិត្ត ពីពលំ ពីគំនិត និងពីកម្លាំងរបស់ពួកគេ ។

រចនារូបភាពដោយ ក្លេតុន ថមសុន

## ស្វែងរកការដឹកនាំខាងវិញ្ញាណ

ការទទួលការដឹកនាំខាងវិញ្ញាណគឺជាជំហានមួយដ៏សំខាន់ដល់ការបម្រើដល់ព្រះអម្ចាស់ ហើយ ដាវីឌ ស៊ី អាយុ 15 ឆ្នាំ បានដឹងថា វានឹងមិនកើតឡើងដោយគ្មានការខិតខំរបស់គាត់នោះឡើយ ។ គាត់បាននិយាយថា « ខ្ញុំត្រូវធ្វើជាឧបករណ៍នៅក្នុងព្រះហស្តរបស់ព្រះ » ។ « ខ្ញុំត្រូវត្រៀមខ្លួនជាស្រេចដើម្បីទទួល ហើយធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណ ។ ដើម្បីធ្វើបែបនោះបាន ខ្ញុំត្រូវធ្វើឲ្យខ្លួនខ្ញុំហ៊ុមព័ទ្ធទៅដោយកិច្ចការរបស់ព្រះអម្ចាស់ជានិច្ច » ។

ដាវីដ និង គ្រួសារគាត់គឺជាពួកអ្នកប្រែចិត្តជឿចំពោះសាសនាចក្រ ។ គាត់បានដឹងពីសារៈសំខាន់នៃការសិក្សាព្រះគម្ពីរពីមុនគាត់បានទទួលបុណ្យជ្រមុជទឹកទៅទៀត ។ បងប្រុសគាត់គឺជាមនុស្សដំបូងដែលបានទទួលបុណ្យជ្រមុជទឹក ហើយក្រោយមកទៀតមិនយូរប៉ុន្មាន ឪពុកម្ដាយគាត់ក៏បានជ្រមុជទឹកដែរ ។ ដាវីឌ បានដឹងថា គាត់ត្រូវការទីបន្ទាល់ផ្ទាល់ខ្លួនរបស់គាត់ ។ ក្នុងអំឡុងពេលគាត់សិក្សាព្រះគម្ពីរមរមន គាត់បានទទួលអារម្មណ៍ពីព្រះវិញ្ញាណ ។ អារម្មណ៍ល្អដែលគាត់មានក្នុងដួងចិត្តគាត់ បានជួយគាត់ឲ្យសម្រេចចិត្តចូលរួមនឹងសាសនាចក្រ ។

បួនឆ្នាំក្រោយមក ដាវីឌ នៅតែពឹងផ្អែកលើការដឹកនាំពីព្រះវិញ្ញាណ ។ គាត់និយាយថា « យើងធ្វើឲ្យបានទៀងទាត់ ។ យើងមិនអាចព្រងើយកន្តើយចំពោះការសិក្សាព្រះគម្ពីរ និង ការអធិស្ឋានរបស់យើងឡើយ » ។

## បន្តមានភាពបរិសុទ្ធ

ម៉ាកូ ឌី អាយុ 17 ឆ្នាំ បានចង្អុលបង្ហាញពីសារៈសំខាន់នៃការគោរពប្រតិបត្តិដល់ព្រះបញ្ញត្តិជាពិសេសច្បាប់ព្រហ្មចារីភាព ។ ម៉ាកូ និយាយថា « មារសត្រូវល្បួងយើងតាមគ្រប់វិធី ដោយព្យាយាមឲ្យយើងធ្វើខុស » ។ « មិត្តភក្តិក៏អាចជាឥទ្ធិពលអាក្រក់មួយផងដែរ » ។ ប៉ុន្មានឆ្នាំមុន ម៉ាកូ ត្រូវផ្លាស់ប្តូរការសេពគប់មិត្តភក្តិ ដោយសារគាត់បានដឹងពីឥទ្ធិពលអវិជ្ជមាន ដែលពួកគេកំពុងតែធ្វើឲ្យប៉ះពាល់ដល់ការជ្រើសរើសរបស់គាត់ ។ « ខ្ញុំត្រូវរកមិត្តភក្តិដែលទទួលយកភាពពិតរបស់ខ្ញុំ ហើយពុំមែនជាមនុស្សដែលពិភពលោកនេះរំពឹងទុកឲ្យខ្ញុំប្រែក្លាយនោះទេ » ។

ពេលខ្លះ នៅក្នុងការឡើងទៅលើភ្នំរបស់យើង យើងនឹងជំពប់ជើងដួល ។ នៅពេលរឿងនេះកើតឡើង ម៉ាកូ បន្លឺពាក្យលើកទឹកចិត្តថា « សូមទៅជួបប៊ីស្សព ហើយនិយាយជាមួយនឹងគាត់ដោយឥតលាក់លាម » ។ « ប៊ីស្សពគឺជាបងប្រុសរបស់យើង ។ យើងអាចទុកចិត្តគាត់បាន » ។

ការខិតខំរបស់គាត់ដើម្បីមានការគោរពប្រតិបត្តិ ហើយបន្តមានភាពបរិសុទ្ធ ផ្តល់ឱកាសដល់ ម៉ាកូ ដើម្បីបម្រើដល់ព្រះនៅពេលនេះ ហើយវាក៏កំពុងរៀបចំខ្លួនគាត់ ឲ្យមានភាពសក្តិសមដើម្បីបម្រើបេសកកម្មពេញម៉ោងនៅថ្ងៃណាមួយផងដែរ ។

## ឈ្លាតពេល

ម៉ាញ៉ូអែល អិម អាយុ 17 ឆ្នាំ បានដឹងថា ការបម្រើព្រះពុំមែនងាយស្រួលជានិច្ចនោះទេ ។ ម៉ាញ៉ូអែល និយាយថា « ជារឿយៗយើងត្រូវបានសាកល្បង » ។ « ពេលខ្លះ យើងបែរជាសុខចិត្តធ្វើទង្វើផ្សេងទៅវិញ ។ ពេលខ្លះ ខ្ញុំសុខចិត្តដេក ទៅមើលការប្រកួតបាល់ទាត់ ឬដើរលេងនឹងមិត្តភក្តិ ។ ប៉ុន្តែម្ដាយខ្ញុំតែងតែបង្រៀនខ្ញុំថា យើងត្រូវតែជ្រើសដើម្បីបម្រើព្រះជានិច្ច ។ ការធ្វើទង្វើអ្វីៗផ្សេងទៀតគឺគ្មានបញ្ហាអ្វីទេ ប៉ុន្តែការបម្រើព្រះអម្ចាស់ត្រូវតែជាអាទិភាពចម្បងរបស់យើង » ។

មែរៀម ឌី អាយុ 14 ឆ្នាំ បានដឹងថា ចំពោះនាងវិធីតែមួយគត់ដើម្បីធ្វើឲ្យប្រាកដថា ការសិក្សាព្រះគម្ពីរ និង ការអធិស្ឋានកើតឡើងរៀងរាល់ថ្ងៃ គឺត្រូវញែកពេលវេលាដ៏ជាក់លាក់ចេញដើម្បីកិច្ចការនេះ ។ មែរៀម បាននិយាយថា « ខ្ញុំមានអារម្មណ៍ដូចជាខ្ញុំអាចសម្រេចបានកិច្ចការយ៉ាងច្រើន នៅពេលខ្ញុំញែកពេលវេលា » ។ « លើសពីនេះទៀត នៅពេលយើងលះបង់ពេលវេលាកាន់តែច្រើនថ្វាយដល់ព្រះអម្ចាស់ យើងមិនមានការល្បួងច្រើននោះទេ — ប៉ុន្តែវាធ្វើឲ្យយើងកាន់តែរឹងមាំទៅវិញ » ។





## បម្រើដោយមានឆន្ទៈ

ចំពោះ សាប្រ៊ីណា ឌី អាយុ 15 ឆ្នាំ ការបម្រើដោយអស់ពីចិត្ត ពីពលំ ពីគំនិត និង ពីកម្លាំងរបស់នាងមានន័យថា ជាការបម្រើឲ្យអស់*ប៊ូអូណា វ៉ូឡុនតា* ។ នោះមានន័យថា ការធ្វើកិច្ចការនានាដោយមានអាកប្បកិរិយាត្រៀមខ្លួនជាស្រេច ហើយពោរពេញដោយភាពរីករាយ ។

អាឡេស្ស៊ូ អ៊ី អាយុ 12 ឆ្នាំ បានយល់ស្របថា ៖ « ការធ្វើកិច្ចការនេះដោយសារប៊ីស្សព ឬឪពុកម្ដាយរបស់អ្នកប្រាប់ឲ្យអ្នកធ្វើនោះ វាពុំមែនជារឿងត្រឹមត្រូវទេ ។ អ្នកមិនគួរមានអារម្មណ៍ថា អ្នកត្រូវតែធ្វើកិច្ចការនេះនោះទេ ។ ព្រះអម្ចាស់សព្វព្រះទ័យឲ្យយើងបម្រើដោយមានហេតុផលត្រឹមត្រូវ » ។

តើយើងអាចមាន*ប៊ូអូណា វ៉ូឡុនតា*កាន់តែច្រើន នៅពេលយើងបម្រើបានដោយរបៀបណា ? សាប្រ៊ីណា និយាយថា « ការអានព្រះគម្ពីរបានជួយខ្ញុំ ដោយសាព្រះគម្ពីរបង្រៀនយើងថា ការបម្រើគឺជារឿងត្រឹមត្រូវដែលត្រូវធ្វើ » ។

ការសិក្សា និង ការយល់ដឹងពីដង្វាយធួនឲ្យបានកាន់តែប្រសើរ ក៏អាចជួយយើងឲ្យបម្រើដោយត្រៀមខ្លួនជាស្រេច ហើយពោរពេញដោយភាពរីករាយផងដែរ ។ អេលវីសា ឌី អាយុ 17 ឆ្នាំ

និយាយថា « ដូចជាព្រះវរបិតាសួគ៌បានបញ្ជូនព្រះរាជបុត្រាទ្រង់ដែលបានលះបង់អ្វីៗគ្រប់យ៉ាងសម្រាប់យើងដែរ យើងត្រូវតែត្រៀមខ្លួនជាស្រេចដើម្បីលះបង់នូវអ្វីៗទាំងអស់ដែលយើងអាចធ្វើទៅបាន ដើម្បីបម្រើដល់ព្រះអម្ចាស់ » ។

## យកចិត្តទុកដាក់លើអ្នកដទៃ

បងប្អូនស្រី គ្វីលលីយ៉ា អាយុ 16 ឆ្នាំ និង វើរ៉ូនីកា ឌី អាយុ 14 ឆ្នាំ បានដឹងថា វាគឺជាការសំខាន់ដើម្បីផ្តោតយកចិត្តទុកដាក់ទៅលើអ្នកដទៃ ។ « ការបម្រើជួយយើងឲ្យមើលឃើញមនុស្សដទៃក្នុងទិដ្ឋភាពផ្សេងៗគ្នា ។ នៅពេលអ្នកបម្រើដល់នរណាម្នាក់ អ្នកទាំងពីរនឹងមានពរ » គ្វីលលីយ៉ា បាននិយាយ ។



វើរ៉ូនីកា និយាយថា « នៅពេលមួយខ្ញុំពិតជាចង់ចែកចាយដំណឹងល្អ ប៉ុន្តែខ្ញុំមានអារម្មណ៍ថាមិនទាន់ត្រៀមខ្លួននៅឡើយ ។ ខ្ញុំមានការភ័យខ្លាច ។ ប៉ុន្តែនៅពេលខ្ញុំផ្តោតយកចិត្តទុកដាក់លើមនុស្សដែលខ្ញុំបម្រើ ខ្ញុំមានអារម្មណ៍កាន់តែជឿជាក់ ដោយសារខ្ញុំបានដឹងថា ព្រះអម្ចាស់បានជួយដល់ខ្ញុំ » ។

គ្វីលលីយ៉ា និង វើរ៉ូនីកា អាចបម្រើមិត្តម្នាក់របស់ពួកគេឈ្មោះ វើរជីញ៉ា តាមវិធីមួយដែលបានធ្វើឲ្យមានការផ្លាស់ប្តូរជីវិត ។ ពួកគេបានចាប់ផ្តើមអញ្ជើញនាងឲ្យមកចូលរួមក្នុងសកម្មភាពរបស់សាសនាចក្រជាមួយនឹងពួកគេ ។ ពួកគេក៏បានអញ្ជើញគ្រួសាររបស់វើរជីញ៉ាឲ្យធ្វើរឿងនានាជាមួយនឹងគ្រួសារពួកគេផងដែរ ។ មិនយូរប៉ុន្មាន គ្រួសារវើរជីញ៉ាបានចាប់ផ្តើមជួបនឹងពួកអ្នកផ្សព្វផ្សាយសាសនា ។ មួយឆ្នាំក្រោយមក វើរជីញ៉ា និង ប្អូនស្រីនាងបានទទួលបុណ្យជ្រមុជទឹក ។

ឥឡូវនេះដោយសារនាងគឺជាសមាជិកនៃសាសនាចក្រ វើរជីញ៉ា បានស្វែងរកវិធីដើម្បីបម្រើដល់អ្នកដទៃទៀតដែលនៅជុំវិញនាង ។ នាងពិតជាចង់ចែកចាយដំណឹងល្អជាមួយនឹងអ្នកដទៃ ។ ពេលខ្លះ មិត្តនាងនៅឯសាលាបានសើចចំអកឲ្យនាងចំពោះជំនឿថ្មីរបស់នាង ដូច្នេះនាងបានអធិស្ឋានដើម្បីដឹងថាតើនរណាទៅដែលនាងគួរនិយាយជាមួយ ។ មានថ្ងៃមួយ ព្រះវិញ្ញាណបានបំផុសគំនិតនាងឲ្យនិយាយនឹងក្មេងស្រីម្នាក់ដែលនាងធ្លាប់បានស្គាល់ ។ « ខ្ញុំបានឲ្យព្រះគម្ពីរមរមនមួយក្បាលទៅនាង ហើយបានអញ្ជើញនាងឲ្យមកព្រះវិហារជាមួយនឹងខ្ញុំ ។ នាងបានមកមែន ! ហើយឥឡូវនេះនាងកំពុងអានព្រះគម្ពីរមរមន » ។

សាំញ៉ូអែល ឌី អាយុ 14 ឆ្នាំ ស្វែងរកឱកាសដើម្បីពង្រឹងដល់សមាជិកកូរ៉ុមរបស់ខ្លួន ៖ « ខ្ញុំព្យាយាមជួយក្មេងប្រុសដទៃទៀតនៅក្នុងកូរ៉ុមខ្ញុំដោយការលើកទឹកចិត្តពួកគេនៅក្នុងថ្នាក់រៀន ។ ពេលខ្លះ ពួកគេមានអារម្មណ៍អៀនខ្មាស់ ឬភ័យខ្លាចដើម្បីចូលរួម » ។ សាំញ៉ូអែលនិយាយថា ការជួយអ្នកដទៃឲ្យមានអារម្មណ៍ជឿជាក់គឺជាវិធីមួយដែលគាត់អាចបម្រើដល់ព្រះ ហើយរៀបចំខ្លួនសម្រាប់ទំនួលខុសត្រូវនាពេលអនាគត ។

## ចាប់ផ្តើមឥឡូវនេះ

ដូច្នេះ តើអ្នកនឹងធ្វើអ្វីខ្លះ ? អាឡេស្ស៊ូ អ៊ី និយាយថា « ខ្ញុំមិនត្រូវរង់ចាំរហូតដល់ខ្ញុំធំឡើងដើម្បីធ្វើនូវរឿងមួយដែលសំខាន់នោះទេ ។ ខ្ញុំត្រូវតែធ្វើនៅពេលនេះ » ។

ជំហានទាំងនេះក៏នឹងជួយអ្នកផងដែរ នៅពេលអ្នកបានយល់ដឹងថា អ្នកគឺជាចំណែកមួយដ៏សំខាន់នៃកិច្ចការរបស់ព្រះអម្ចាស់ ។ ធ្វើវាមួយជំហានម្តងៗ ។ អ្នកនឹងធ្វើឲ្យមានភាពខុសប្លែកមួយដ៏សំខាន់ នៅពេលអ្នករៀនថ្វាយនូវអ្វីៗទាំងអស់ដែលអ្នកមានដល់ការបម្រើរបស់ព្រះអម្ចាស់ ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា. ។*





បម្រើព្រះឲ្យអស់ពី

# ចិត្តអ្នក

បម្រើព្រះឲ្យអស់ពី

# គំនិតអ្នក





បម្រើព្រះឲ្យអស់ពី

# ពលំអ្នក

បម្រើព្រះឲ្យអស់ពី

# កម្លាំងអ្នក



## បម្រើព្រះឲ្យអស់ពីគំនិតអ្នក

« អំណាចដើម្បីគិតគឺជាអំណោយទានមួយមកពីព្រះ ។ . . . របៀបដែលយើងគិត ជះឥទ្ធិពលយ៉ាងខ្លាំងទៅលើអាកប្បកិរិយា និង ឥរិយាបថ រួមទាំងជំហររបស់យើងបន្ទាប់ពីជីវិតនេះដែរ » ( សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ « គំនិត » scriptures.lds.org ) ។ គំនិតរបស់យើងជួយយើងរៀន ហើយផ្លាស់ប្ដូរទៅរកភាពប្រសើរឡើង — ប្រសិនបើយើងបន្តស្វែងរករឿងល្អៗ ។ នេះគឺជាគំនិតមួយចំនួនសម្រាប់ការបម្រើព្រះឲ្យអស់ពីគំនិតអ្នក ៖

- សិក្សាព្រះគម្ពីរ និងប្រសាសន៍របស់ពួកព្យាការី ។
- មានគំនិតវិជ្ជមានអំពីអ្នកដទៃ និង ខ្លួនឯង ។
- ស្វែងរកតម្រិះ ជាពិសេសរឿងដែលមានប្រយោជន៍ ។
- ជ្រើសការកម្សាន្តល្អៗ ហើយលើកតម្កើង ។
- ស្រាវជ្រាវអ្វីមួយដែលសំខាន់ចំពោះអ្នក — ឧទាហរណ៍ ព្រឹត្តិការណ៍មួយនៅក្នុងប្រវត្តិសាសនាចក្រ ឬដូនតាម្នាក់ ។
- ផ្ដោតគំនិតរបស់អ្នកទៅលើព្រះអង្គសង្គ្រោះនៅក្នុងម៉ោងពិធីសាក្រាម៉ង់ ។
- សរសេរសៀវភៅកំណត់ហេតុមួយ ហើយមើលវាឡើងវិញម្ដងម្កាល ។

## បម្រើព្រះឲ្យអស់ពីចិត្តអ្នក

បេះដូងជាសរីរាង្គមួយទ្រទ្រង់ដល់ជីវិត ។ ជារឿយៗ « បេះដូង » មានន័យថា ជាស្នូលកណ្ដាល ឬជាផ្នែកដែលបំណងប្រាថ្នា និង អារម្មណ៍ផ្ដួចផ្ដើមឡើង ។ ដើម្បីបម្រើព្រះឲ្យអស់ពីដួងចិត្តអ្នក គឺត្រូវថ្វាយដល់ទ្រង់នូវរាល់បំណងប្រាថ្នា ឆន្ទៈ និង សេចក្ដីស្រឡាញ់របស់យើង ។ ទ្រង់សុំឲ្យយើងស្រឡាញ់ទ្រង់ដោយការគោរពតាមព្រះបញ្ញត្តិរបស់ទ្រង់ និង ការស្រឡាញ់អ្នកដទៃ ។ នេះគឺជាគំនិតមួយចំនួនសម្រាប់ធ្វើកិច្ចការនេះ ៖

- ចូរយកការអធិស្ឋាន ការសិក្សាព្រះគម្ពីរ និង ការចូលរួមក្នុងសាសនាចក្រមកដាក់ឲ្យខ្ពស់ជាងបំណងប្រាថ្នាផ្ទាល់ខ្លួនរបស់យើង ។
- បង្ហាញសេចក្ដីមេត្តាករុណា និង សេចក្ដីសប្បុរសដល់មនុស្សណាម្នាក់នៅក្នុងគ្រួសារអ្នក ឬនៅឯសាលារៀន ។
- ចំណាយពេលធ្វើអ្វីដែលនរណាម្នាក់ទៀតចង់ធ្វើ ។
- ព្យាយាមយល់ពីអារម្មណ៍របស់មនុស្សម្នាក់ទៀត ។
- ផ្ដល់ការសរសើរដល់នរណាម្នាក់ ដោយស្មោះពីចិត្ត ។
- និយាយ ឬអង្គុយក្បែរនរណាម្នាក់ដែលឯកោ ។

## បម្រើព្រះឲ្យអស់ពីកម្លាំងអ្នក

ថាមពលដែលយើងបម្រើព្រះ គឺជាផ្នែកមួយនៃការថ្វាយដល់ទ្រង់នូវកម្លាំងទាំងអស់ដែលយើងមាន ។ កម្លាំងក៏ជាអំណាចខាងវិញ្ញាណ ការតាំងចិត្ត ភាពអត់ធន់ និង ភាពឧស្សាហ៍នៅក្នុងការប្រព្រឹត្តល្អដែរ ។ យើងអាចបង្ហាញកម្លាំងយើង នៅពេលយើងរស់នៅតាមគោលការណ៍ដែលព្រះអង្គសង្គ្រោះផ្ទាល់បានរស់នៅតាម ។ រួចយើងអាចទទួលបាននូវអំណាចខាងវិញ្ញាណដ៏ទេវភាព ។ នេះគឺជាគំនិតមួយចំនួនសម្រាប់ការបម្រើព្រះឲ្យអស់ពីកម្លាំងអ្នក ៖

- ផ្ដោតការយកចិត្តទុកដាក់របស់អ្នកទាំងស្រុងទៅការសិក្សាព្រះគម្ពីរ ។
- ធ្វើការក្នុងសាមគ្គីភាពជាមួយនឹងសមាជិកក្នុងវួដ ឬសាខារបស់អ្នក ។
- ឈរយ៉ាងរឹងមាំការពារបទដ្ឋានខាងសីលធម៌ ។
- ធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធដើម្បីប្រទានពរដល់អ្នកដទៃ ។
- តាំងចិត្តរស់នៅដោយសុចរិត ហើយពង្រឹងការតាំងចិត្តរបស់អ្នក នៅពេលការល្បួងកើតឡើង ។
- ថែទាំរូបកាយរបស់អ្នកតាមរយៈអាហាររូបត្ថម្ភ និងការធ្វើលំហាត់ប្រាណ ។
- រក្សាសេចក្ដីសញ្ញាអ្នកដើម្បីទទួលបានអំណាចខាងវិញ្ញាណដែលធំជាងមុន ។

## បម្រើព្រះឲ្យអស់ពីពលំអ្នក

ការបម្រើព្រះឲ្យអស់ពីពលំយើងអាចមានន័យយ៉ាងសាមញ្ញថា គឺជាការធ្វើអ្វីដែលយើងអាចធ្វើទៅបាន ទាំងខាងវិញ្ញាណ និង សាច់ឈាម ហើយត្រូវបានផ្ដោតទៅលើផ្នែកខាងក្រៅ ។ មិនថាយើងម្នាក់ៗមានទេពកោសល្យអ្វីនោះទេ ( ចាប់តាំងពីការលើកសាឡុងមួយដ៏ធ្ងន់រហូតដល់ការបន្តមានទស្សនៈវិជ្ជមាននៅក្នុងស្ថានភាពពិបាកៗ ) យើងអាចប្រើប្រាស់វាដើម្បីពង្រឹងអ្នកដទៃបាន ។ នេះគឺជាគំនិតមួយចំនួនសម្រាប់ការបម្រើឲ្យអស់ពីពលំរបស់អ្នក ៖

- សួរខ្លួនឯងថា « តើនរណាខ្លះត្រូវការជំនួយពីខ្ញុំថ្ងៃនេះ ? » — ហើយធ្វើនូវកិច្ចការ ។
- ធ្វើកិច្ចការមួយសម្រាប់នរណាម្នាក់ ដូចជាការបោសសម្អាតរានហាល ការសម្អាតបន្ទប់ ឬការលាងចាន ។
- ប្រើទេពកោសល្យរបស់អ្នក ៖ ជួសជុលរថយន្ត ឬកុំព្យូទ័រ តុបតែងបន្ទប់ ធ្វើអំណោយដោយខ្លួនឯង សរសេរកំណាព្យ ។
- ងាកចេញពីទម្លាប់ប្រចាំថ្ងៃរបស់អ្នកដើម្បីធ្វើជាមិត្តម្នាក់ និង ធ្វើជាគំរូដ៏ល្អមួយ ។
- បង្រៀននរណាម្នាក់ពីជំនាញដែលអ្នកបានរៀន ។

រចនារូបថតដោយ ដាវីឌ ស្ទូឃី

# ចាប់ផ្ដើម

« ហេតុដូច្នេះហើយ ឱអ្នករាល់គ្នាដែលចាប់ផ្ដើមធ្វើការបម្រើព្រះអើយ សូមឲ្យឃើញថា អ្នករាល់គ្នាបម្រើទ្រង់ឲ្យអស់ពីចិត្ត អស់ពីពលំ អស់ពីគំនិត ហើយអស់ពីកម្លាំង ដើម្បីឲ្យអ្នករាល់គ្នាអាចបានឈរដោយឥតទោសនៅចំពោះព្រះនៅថ្ងៃចុងក្រោយបំផុត » ។

( គ. និង ស. 4:2 )



# ហេតុអ្វីបានជា ព្រះយេស៊ូវគ្រីស្ទ មានសារៈសំខាន់ ចំពោះជីវិតខ្ញុំ ?

*នៅពេលយើងយល់ពីអ្វីៗទាំងអស់ដែលព្រះអង្គសង្គ្រោះធ្វើសម្រាប់យើង ទ្រង់ក្លាយជាតួអង្គដ៏សំខាន់បំផុតនៅក្នុងជីវិតយើង ។*



**មេរៀនថ្ងៃអាទិត្យ**

ប្រធានបទសម្រាប់ខែនេះ ៖ ក្រុមព្រះ

**ដោយ ម៉ែគល អរ ម៉ូរីស**
ទស្សនាវដ្ដីសាសនាចក្រ

ថ្មីៗនេះ ខ្ញុំបានអានការចុះផ្សាយមួយនៅលើកំណត់ហេតុបណ្ដាញ ដែលអ្នកនិពន្ធបានលើកឡើងពីរបៀបដែលព្រះអង្គសង្គ្រោះដើរតួយ៉ាងសំខាន់នៅក្នុងជីវិតប្រចាំថ្ងៃរបស់នាង ។ ខ្ញុំមានចិត្តរីករាយដែលនាងព្រមចែកចាយអារម្មណ៍របស់នាង ប៉ុន្តែខ្ញុំមានចិត្តសោកសៅចំពោះមតិរបស់អ្នកអានម្នាក់ គាត់បាននិយាយថា ៖ « ទ្រង់ពុំមែនជាតួអង្គដ៏សំខាន់នៅក្នុងជីវិតរបស់ខ្ញុំទេ — ខ្ញុំពុំធ្លាប់គិត ហើយនឹងមិនគិតជារឿងរហូត » ។

អ្នកអានម្នាក់នោះបានគិតខុសហើយ ។ នៅពេលណាមួយ យើងទាំងអស់គ្នានឹងត្រូវការព្រះអង្គសង្គ្រោះ ។ យើងទាំងអស់គ្នាធ្វើកំហុសដែលយើងមិនអាចធ្វើឲ្យដូចដើមវិញបាន ហើយជួបប្រទះនឹងការបាត់បង់ដែលយើងមិនអាចយកមកវិញបាន ហើយជួបនឹងការឈឺចាប់ ការបៀតបៀន សោកនាដកម្ម បន្ទុក និង ការខកបំណង ដែលយើងមិនអាចទ្រាំទ្រតែម្នាក់ឯងបាន ។

អ្វីដែលល្អនោះគឺថា យើងមិន*ចាំបាច់*ទ្រាំទ្រវាតែម្នាក់ឯងនោះទេ ។

« នៅក្នុងគ្រានៃភាពទន់ខ្សោយមួយដែលយើងអាចនឹងស្រែកឡើងថា ‹ គ្មាននរណាម្នាក់យល់ពីអារម្មណ៍នេះទេ ។ គ្មាននរណាម្នាក់យល់ទេ ›។ ប៉ុន្តែព្រះរាជបុត្រានៃព្រះជ្រាប ហើយយល់យ៉ាងឥតខ្ចោះ ពីព្រោះទ្រង់ធ្លាប់ទទួល ហើយទូលបន្ទុករបស់យើងម្នាក់ៗ » បានថ្លែងដោយ អែលឌើរ ដេវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ « ហើយដោយសារការលះបង់ដ៏គ្មានទីបញ្ចប់ និង អស់កល្បជានិច្ចរបស់ទ្រង់ ( សូមមើល អាលម៉ា 34:14 ) ទ្រង់មានការយល់ចិត្តយ៉ាងឥតខ្ចោះ ហើយអាចលាតសន្ធឹងព្រះហស្តនៃសេចក្ដីមេត្តាករុណារបស់ទ្រង់មកកាន់យើង » ។[1]

ព្រះយេស៊ូវគឺជាអង្គដ៏សំខាន់សម្រាប់យើង ដោយសារតាមរយៈដង្វាយធួន ការបង្រៀន សេចក្ដីសង្ឃឹម សេចក្ដីសុខសាន្ត និង គំរូរបស់ទ្រង់ ទ្រង់ជួយយើងផ្លាស់ប្ដូរជីវិតយើង ប្រឈមមុខនឹងការសាកល្បងរបស់យើង ហើយដើរឆ្ពោះទៅមុខដោយសេចក្ដីជំនឿ នៅពេលយើងធ្វើដំណើរត្រឡប់ទៅរកទ្រង់ និង ព្រះវរបិតាទ្រង់វិញ ។

## ព្រះយេស៊ូវធ្វើឲ្យការប្រែចិត្តកើតមាន

ហេតុផលមួយដែលព្រះយេស៊ូវគឺជាអង្គដ៏សំខាន់បំផុតចំពោះអ្នក ដែលព្យាយាមដើរតាមទ្រង់ដោយស្មោះ គឺថា យើងទាំងអស់គ្នាធ្វើកំហុស ហើយត្រូវការអំណោយទាននៃការប្រែចិត្តដែលបានផ្ដល់ឲ្យតាមរយៈដង្វាយធួន ។

នៅពេលយើងជំពប់ជើងដួល សាតាំងចង់ឲ្យយើងគិតថា យើងមិនល្អគ្រប់គ្រាន់ដើម្បីក្រោកឈរឡើង ហើយត្រឡប់ទៅផ្លូវត្រូវវិញទេ ។ វាក៏ចង់ឲ្យយើងបំភ្លេចផងដែរថា ដំណឹងល្អគឺជា « ដំណឹងល្អនៃ*ការប្រែចិត្ត* » ( គ. និង ស. 13:1 ការគូសបញ្ជាក់បានបន្ថែម ) ។ ប៉ុន្តែយើងដឹងថា « ព្រះគុណរបស់ព្រះគ្រីស្ទមានពិតមែន ដោយផ្ដល់ឲ្យទាំងការអត់ទោស និង ការលាងសម្អាតទៅដល់អ្នកធ្វើបាបដែលបានប្រែចិត្ត » ។[2]

អំណាចនៃដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទគឺមានសម្រាប់យើងម្នាក់ៗ ប៉ុន្តែយើងត្រូវតែជ្រើសធ្វើឲ្យវាមានដំណើរការនៅក្នុងជីវិតយើង ។ សូមនឹកស្រមៃពីការផ្ដល់អំណោយដ៏ពិសេសមួយដល់មិត្តម្នាក់ — ជាអ្វីមួយដែលមិត្តរបស់អ្នកពិតជាត្រូវការ និងជាអ្វីមួយដែលអ្នកបានរៀបចំតាមរយៈការលះបង់ផ្ទាល់ខ្លួន ។ រួចនឹកស្រមៃថាមិត្តរបស់អ្នកបានពោលថា « អរគុណ ប៉ុន្តែខ្ញុំពិតជាមិនចង់បានអំណោយរបស់ឯងទេ » ។ តើអ្នកមានអារម្មណ៍យ៉ាងណាដែរ ?



នៅពេលយើងមិនបានអញ្ជើញព្រះយេស៊ូវឲ្យជួយយើងដើម្បីមានភាពស្អាតស្អំតាមរយៈការប្រែចិត្តនោះទេ វាប្រៀបដូចជាយើងកំពុងតែបដិសេធអំណោយរបស់ទ្រង់ដូច្នោះដែរ ។

## ព្រះយេស៊ូវបង្រៀនពីសេចក្ដីពិត

មានគ្រាមួយ បន្ទាប់ពីមនុស្សជាច្រើនបានបដិសេធឈប់ដើរតាមទ្រង់ទៀត ព្រះយេស៊ូវបានសួរ



ទៅពួកសាវកដប់ពីរនាក់ថា « អ្នករាល់គ្នាចង់ថយទៅដែរឬ ? » ពេត្រុស ឆ្លើយថា « ព្រះអម្ចាស់អើយ តើយើងខ្ញុំនឹងទៅឯអ្នកណាវិញ ? គឺទ្រង់ហើយដែលមានព្រះបន្ទូលនៃជីវិតដ៏នៅអស់កល្បជានិច្ច » ( យ៉ូហាន 6:67–68 ) ។

អ្នកអាចស្វែងរក « ព្រះបន្ទូលនៃជីវិតដ៏នៅអស់កល្បជានិច្ច » របស់ព្រះអង្គសង្គ្រោះនៅក្នុងព្រះគម្ពីរ ការបង្រៀនរបស់ពួកព្យាការីនៅរស់ និង ការខ្សឹបប្រាប់នៃព្រះវិញ្ញាណបរិសុទ្ធ ។ ធនធានទាំងនេះផ្ដល់នូវគ្រឹះមួយសម្រាប់ « សុភមង្គលនៅក្នុងជីវិតនេះ និង ជីវិតដ៏នៅអស់កល្បជានិច្ចនៅក្នុងជីវិតខាងមុខ »[3] ហើយវាដឹកនាំយើងដោយសុវត្ថិភាពត្រឡប់ទៅរកព្រះវរបិតាសួគ៌ និង ព្រះអង្គសង្គ្រោះរបស់យើងវិញ ។

តើសេចក្ដីពិតដ៏អស្ចារ្យមួយចំនួនដែលព្រះអង្គសង្គ្រោះបានបង្រៀនមានអ្វីខ្លះ ? ប្រធាន ឌីថើរ អេហ្វ អុជដុហ្វ ទីប្រឹក្សាទីពីរក្នុងគណៈប្រធានទីមួយ បានលើកឡើងនូវចំណុចបួននៅក្នុងសុន្ទរកថាមួយនៅឯសន្និសីទទូទៅថ្មីៗនេះថា ៖

- « ព្រះវរបិតាយើងបានប្រទានដល់កូនចៅទ្រង់នូវផែនការនៃសុភមង្គលដ៏មហិមា » ។
- « តាមរយៈដង្វាយធួន . . . យើងអាចរស់នៅជារៀងរហូតជាមួយនឹងមនុស្សជាទីស្រឡាញ់របស់យើង » ។
- « យើងនឹងមានរូបកាយដ៏រុងរឿង ល្អឥតខ្ចោះ ហើយអមតៈ ដោយមិនមានជំងឺ ឬអសមត្ថភាពអ្វីឡើយ » ។
- « ទឹកភ្នែកនៃភាពសោកសៅ និង ការបាត់បង់របស់យើងនឹងត្រូវបានជំនួសដោយសុភមង្គល និង សេចក្ដីអំណរដ៏បរិបូរណ៍ » ។[4]

## ព្រះយេស៊ូវប្រទានសេចក្ដីសង្ឃឹម

នៅពេលយើងជួបប្រទះនឹងឧបសគ្គដ៏ធ្ងន់ធ្ងរ ពេលខ្លួនយើងឃើញថា វាមានភាពលំបាកណាស់ដើម្បីទុកចិត្តលើព្រះអម្ចាស់ ។ ប៉ុន្តែការទុកចិត្តលើទ្រង់ង់នាំមកឲ្យយើងនូវសេចក្ដីសង្ឃឹមដែលយើងត្រូវការដើម្បីប្រឈមមុខនឹងឧបសគ្គរបស់យើង ។

នោះគឺជាអ្វីដែលបានកើតឡើងជាមួយនឹងសមាជិកគ្រួសារហ្គាត្រល ដែលរស់នៅក្នុងវួដរបស់ស៊ិស្ទើរ ជីន អេ ស្ទីវិនសិន ។ ស៊ិស្ទើរ ស្ទីវិនសិន ជាទីប្រឹក្សាទីមួយក្នុងគណៈប្រធានអង្គការបឋមសិក្សាទូទៅ បានថ្លែងថា គ្រួសារនោះបានតោងខ្ជាប់ទៅនឹងដំណឹងល្អ និង សេចក្ដីសញ្ញានៃព្រះវិហារបរិសុទ្ធរបស់ពួកគេ បន្ទាប់ពីបងប្រុសហ្គាតរ៉េល កើតជំងឺមហារីក ។ ការធ្វើបែបនេះ បានផ្ដល់សេចក្ដីសង្ឃឹមដល់ពួកគេនៅក្នុងការសន្យារបស់ព្រះថា ពួកគេនឹងរួមរស់ជាមួយគ្នាម្ដងទៀតបន្ទាប់ពីជីវិតនេះ ។

តាមរយៈគ្រាដ៏លំបាកទាំងនោះពីមុនស្វាមីគាត់បានចែកឋានទៅ បងស្រីហ្គាតរ៉េល បានពោលថា « ខ្ញុំបានដឹងថា ព្រះអម្ចាស់បានឃុំគ្រងយើង ។ ប្រសិនបើអ្នកទុកចិត្តលើព្រះអម្ចាស់ អ្នកពិតជាអាចយកឈ្នះលើឧបសគ្គទាំងអស់នៅក្នុងជីវិតបាន » ។[5]

អំណោយទាននៃដង្វាយធួន ផ្ដល់ឲ្យយើងនូវសេចក្ដីសង្ឃឹមនៃជីវិតអស់កល្បជានិច្ច — ជាអ្វីមួយដែលយើងត្រូវការ នៅពេលយើងរងទុក្ខដោយការសាកល្បង ឬសេចក្ដីស្លាប់នៃមនុស្សជាទីស្រឡាញ់ ។

ប្រធាន ហិនរី ប៊ី អាវរិង ជាទីប្រឹក្សាទីមួយក្នុងគណៈប្រធានទីមួយ បានថ្លែងថា « ព្រះវរបិតាសួគ៌ជាទីស្រឡាញ់របស់យើងបានប្រទានឲ្យយើងនូវអំណោយនៃបុត្រាដ៏ជាទីស្រលាញ់របស់ទ្រង់ គឺ ព្រះយេស៊ូវគ្រីស្ទ ដែលជាព្រះអង្គសង្គ្រោះរបស់យើង » ។ អំណោយដ៏អស្ចារ្យនោះ និង ពរជ័យនៃដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ នាំមកនូវកេរដំណែលជាសាកលមួយគឺ ៖ ការសន្យានៃការរស់ឡើងវិញ និង លទ្ធភាពនៃជីវិតដ៏អស់កល្បជានិច្ចដល់មនុស្សទាំងអស់ដែលបានកើតមក » ។[6]

## ព្រះយេស៊ូវប្រទានសេចក្ដីសុខសាន្ត

ប្រសិនបើអ្នកធ្លាប់ជួបនឹងគ្រោះធម្មជាតិ ធ្លាប់ត្រូវបានគេនិយាយ មួលបង្កាច់ ធ្លាប់ជួបឧបសគ្គដែលបានផ្លាស់ប្ដូរជីវិត ធ្លាប់បាត់បង់មិត្តភាព ឬធ្លាប់ក្រោកឈរឡើងការពារអ្វីដែលត្រឹមត្រូវ នោះអ្នកដឹងថា អ្នកត្រូវការសេចក្ដីសុខសាន្តរបស់ព្រះអម្ចាស់ ។ អែលឌើរ នែល អិល អាន់ឌើរសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានថ្លែងថា « សេចក្ដីសុខសាន្ត







របស់ព្រះអង្គសង្គ្រោះធ្វើឲ្យល់កួចនៃលោកិយនេះស្ងប់ » ។[7]

នៅក្នុងសន្និសីទថ្មីៗនេះ អែលឌើរ អាន់ឌើរសិន បានចែកចាយពីដំណើររឿងមួយអំពីក្មេងស្រីថ្នាក់ឡូរ៉ែលម្នាក់ដែលត្រូវបានគេសើចចំអក ហើយប្រមាថដោយសារគោលជំហរការពារអាពាហ៍ពិពាហ៍តាមទំនៀមទម្លាប់ ។ នាងបានរៀនថា ពេលខ្លះ ការសើចចំអកគឺជាតម្លៃនៃ « ការស្មោះចំពោះព្រះ និង ចំពោះការបង្រៀននៃព្យាការីដែលកំពុងរស់នៅរបស់ទ្រង់ » ។[8]

ប៉ុន្តែការក្រោកឈរឡើងពុំមែនមានន័យថា ជាការឈរតែម្នាក់ឯងនោះទេ ។ យើងអាចងាកទៅរកព្រះអម្ចាស់នៃមេត្រីភាពបានជានិច្ច នៅពេលយើងមានអារម្មណ៍ឯកោ ឬថប់បារម្ភ សោកសៅ ឬព្រួយចិត្ត ភ័យខ្លាច ឬគ្មានតម្លៃនោះ ។ យើងធ្វើកិច្ចការទាំងនេះបានតាមរយៈ ៖

- ការអធិស្ឋានទៅព្រះវរបិតាសួគ៌ទូលសូមព្រះវិញ្ញាណឲ្យគង់ជាមួយយើង ។
- ការអានបន្ទូលរបស់ព្រះអម្ចាស់នៅក្នុងព្រះគម្ពីរ និងដែលបានបើកសម្ដែងតាមរយៈពួកព្យាការីដែលកំពុងរស់នៅ ។
- ការចូលព្រះវិហារបរិសុទ្ធ ។
- ការសិក្សាពីឆាកជីវិតរបស់ព្រះអង្គសង្គ្រោះនៅឯព្រះវិហារ និង ក្នុងថ្នាក់សិក្ខាសាលា ។
- ការអនុវត្តដង្វាយធួនទ្រង់តាមរយៈការប្រែចិត្តពីអំពើបាបរបស់យើង ។
- ការចែកចាយទីបន្ទាល់របស់យើងអំពីទ្រង់ ។

នៅពេលយើងទទួលបានអារម្មណ៍នៃសេចក្ដីសុខសាន្តរបស់ព្រះអង្គសង្គ្រោះ ដួងចិត្តយើងមិនត្រូវបារម្ភ ឬភ័យខ្លាចនោះទេ ( សូមមើល យ៉ូហាន 14:26–27 ) ។

ប្រធាន ថូម៉ាស អេស ម៉នសុន បានថ្លែងថា « មានតែលោកចៅហ្វាយប៉ុណ្ណោះ ដែលទ្រង់ជ្រាបពីជម្រៅនៃការសាកល្បង ការឈឺចាប់ និង ការរងទុក្ខរបស់យើង » ។ « មានតែទ្រង់ទេ ដែលប្រទានភាពសុខសាន្តអស់កល្បនៅគ្រារងទុក្ខ ។ មានតែទ្រង់ទេដែលមានអានុភាពលើព្រលឹងជាប់បាបកម្ម ដោយបន្ទូលលួងលោមរបស់ទ្រង់ » ។[9]

## ព្រះយេស៊ូវបានធ្វើជាគំរូ

នៅក្នុងការបម្រើរបស់ទ្រង់ ព្រះយេស៊ូវមិនមែនគ្រាន់តែចង្អុលបង្ហាញផ្លូវទៅកាន់សុភមង្គលប៉ុណ្ណោះទេ — ទ្រង់ក៏បានដឹកនាំផ្លូវផងដែរ ។ តាមរយៈដង្វាយធួនរបស់ទ្រង់ ទ្រង់បានដឹកនាំយើងឲ្យចេះស្រឡាញ់ ។ តាមរយៈការបង្រៀនរបស់ទ្រង់ ទ្រង់ដឹកនាំទៅរកសេចក្ដីពិតអស់កល្បជានិច្ច ។ តាមរយៈព្រះជន្មដ៏ល្អឥតខ្ចោះរបស់ទ្រង់ ទ្រង់ដឹកនាំយើងទៅរកផ្លូវនៃការគោរពប្រតិបត្តិ ។

អែលឌើរ រីឆាដ ជី ស្កត ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានថ្លែងថា « បុគ្គលដែលបានបង្ហាញគំរូដ៏អស្ចារ្យបំផុតនៅលើផែនដីគឺជាព្រះអង្គសង្គ្រោះរបស់យើង ព្រះយេស៊ូវគ្រីស្ទ ។ ការបម្រើក្នុងជីវិតរមែងស្លាប់របស់ទ្រង់ត្រូវបានបំពេញដោយការបង្រៀន ការបម្រើ និង ការស្រឡាញ់ដល់អ្នកដទៃ » ។ លោកបានបន្ថែមទៀតថា ព្រះអង្គសង្គ្រោះ « អញ្ជើញយើងឲ្យធ្វើតាមគំរូដ៏ល្អឥតខ្ចោះរបស់ទ្រង់ » ។[10]

នៅពេលយើងយល់ដឹងថា ព្រះអង្គសង្គ្រោះបានធ្វើឲ្យកើតមានការប្រែចិត្ត និង ការរស់ឡើងវិញ ទ្រង់បានបង្រៀនពីសេចក្ដីពិតដ៏សំខាន់ ប្រទានសេចក្ដីសង្ឃឹម និង សេចក្ដីសុខសាន្ត ហើយបានធ្វើជាគំរូដ៏ល្អឥតខ្ចោះ នោះទ្រង់ក្លាយទៅជាអង្គសំខាន់នៅក្នុងជីវិតរបស់យើង ។ ហើយដោយមានទ្រង់ជាមិត្តរបស់យើង យើងមានភាពក្លាហានដើម្បីបណ្ដេញភាពភ័យខ្លាច ហើយដើរឆ្ពោះទៅដោយសេចក្ដីជំនឿ ។ ■

**កំណត់ចំណាំ**

1. ដេវីឌ អេ បែដណា « Bear Up Their Burdens with Ease » *Liahona,* ខែ ឧសភា ឆ្នាំ 2014 ទំព័រ 90 ។
2. ឌី ថត គ្រីស្តូហ្វឺសិន « The Resurrection of Jesus Christ » *Liahona,* ខែ ឧសភា ឆ្នាំ 2014 ទំព័រ 113 ។
3. « The Living Christ: The Testimony of the Apostles » *Liahona,* ខែ មេសា ឆ្នាំ 2000 ទំព័រ 3 ។
4. ឌីថើរ អេហ្វ អុជដុហ្វ « Grateful in Any Circumstances » *Liahona,* ខែ ឧសភា ឆ្នាំ 2014 ទំព័រ 76 ។
5. ជីន អេ ស្ទីវិនសិន « Fear Not; I Am with Thee » *Liahona,* ខែ ឧសភា ឆ្នាំ 2014 ទំព័រ 83 ។
6. ហិនរី ប៊ី អាវរិង « A Priceless Heritage of Hope » *Liahona,* ខែ ឧសភា ឆ្នាំ 2014 ទំព័រ 24 ។
7. នៀល អិល អាន់ឌើរសិន « Spiritual Whirlwinds » *Liahona,* ខែ ឧសភា ឆ្នាំ 2014 ទំព័រ 18 ។
8. សូមមើល នៃល អិល អាន់ឌើរសិន « Spiritual Whirlwinds » ទំព័រ 19–20 ។
9. ថូម៉ាស អេស ម៉នសុន « I Will Not Fail Thee, nor Forsake Thee » *Liahona,* ខែ វិច្ឆិកា ឆ្នាំ 2013 ទំព័រ 87 ។
10. រីឆាដ ជី ស្កត « I Have Given You an Example » *Liahona,* ខែ ឧសភា ឆ្នាំ 2014 ទំព័រ 35 ។

## សូមចូលរួមការសន្ទនានេះ

### រឿងដើម្បីពិចារណាសម្រាប់ថ្ងៃអាទិត្យ

- តើដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទបានប្រទានពរដល់ជីវិតអ្នកយ៉ាងដូចម្ដេចខ្លះ ?
- តើបន្ទូលអ្វីខ្លះរបស់ព្រះយេស៊ូវដែលអ្នកបានងាកទៅរកដើម្បីទទួលការលួងលោមចិត្ត ?
- តើអ្នកអាចនឹកឃើញពីគ្រាមួយ ដែលអ្នកទទួលបានអារម្មណ៍នៃសេចក្ដីសុខសាន្តរបស់ព្រះអង្គសង្គ្រោះតាមរយៈព្រះវិញ្ញាណបរិសុទ្ធដែរឬទេ ?

### រឿងទាំងឡាយដែលអ្នកអាចធ្វើ

- កត់ត្រានៅក្នុងសៀវភៅកំណត់ហេតុរបស់អ្នក ពេលដែលគំរូ ឬការបង្រៀនរបស់ព្រះអង្គសង្គ្រោះជួយអ្នកឲ្យរើសផ្លូវត្រូវនៅពេលក្រោយទៀត ។
- សិក្សាពីដង្វាយធួនដើម្បីរៀបចំខ្លួនទទួលទានសាក្រាម៉ង់ ។
- ចែកចាយអារម្មណ៍របស់អ្នកអំពីព្រះយេស៊ូវគ្រីស្ទជាមួយនឹងគ្រួសារអ្នក នៅឯព្រះវិហារ ឬនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម ។



**ដោយ អែលឌើរ រ៉ូប៊ឺត ឌី ហែល**
ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់

# របៀប សម្រេចគោលដៅអស់កល្បជានិច្ច

ខ្ញុំសូមណែនាំនូវគោលដៅដ៏សំខាន់បំផុតមួយចំនួននៅក្នុងជីវិតដែលនឹងផ្ដល់សេចក្ដីអំណរដល់អ្នក នៅពេលអ្នកបំពេញបេសកកម្មរបស់អ្នកនៅលើផែនដីនេះ — ជាគោលដៅអស់កល្បដែលនឹងជួយអ្នកឲ្យត្រឡប់ទៅរកព្រះវរបិតាគង់នៅស្ថានសួគ៌របស់អ្នកវិញដោយមានកិត្តិយស ។ គោលដៅទាំងនោះរួមមាន ៖

1. រៀបការនៅក្នុងព្រះវិហារបរិសុទ្ធ ហើយពង្រឹង ទំនាក់ទំនងគ្រួសារដ៏អស់កល្បតាមរយៈ ការធ្វើឲ្យកត្តាជាច្រើននៅក្នុងជីវិតមានតុល្យភាពប្រកបដោយការអធិស្ឋាន ដូចជា គ្រួសារ កាងារ ការបន្តការអប់រំ ចំណង់ចំណូលចិត្ត និង ការកម្សាន្ត ។
2. រស់នៅតាមសាសនារបស់អ្នកដោយស្មោះត្រង់ និង ដោយគោរពប្រតិបត្តិ ហើយស្មោះត្រង់ចំពោះសេចក្ដីសញ្ញានៃបុណ្យជ្រមុជទឹក និង ព្រះវិហារបរិសុទ្ធរបស់អ្នក ដោយស្វែងរករឿងល្អៗនៅក្នុងជីវិតជានិច្ច ។
3. ប្រកាន់ខ្ជាប់ទៅលើទស្សនៈដ៏អស់កល្បដោយចងចាំថា រឿងទាំងឡាយនៃនគររបស់ព្រះ គឺជារឿងអស់កល្ប ហើយរឿងនៃលោកិយគឺជារឿងខាងសាច់ឈាម ឬជារឿងបណ្ដោះអាសន្ន ។
4. ចូរចងចាំដើម្បីផ្ដល់ការបម្រើដែលមានការលះបង់ខ្ពស់នៅក្នុងជីវិតអ្នក ហើយមើលថែដល់ជនខ្វះខាតដែលអាចត្រូវការជានិច្ចនូវសេចក្ដីស្រឡាញ់ និង ការគាំទ្រផ្សេងទៀតរបស់អ្នក ។

ទាំងនេះគឺជាគោលដៅសម្រាប់ជីវិតដែលតម្រូវនូវការផ្ដោតចិត្តទុកដាក់ និង ពេលវេលាដើម្បីសម្រេចបាន ។ ការដាក់គោលដៅទាំងនេះគឺមិនគ្រប់គ្រាន់នោះទេ យើងត្រូវតែដាក់ផែនការដើម្បីអនុវត្តវា ។

នៅយប់នេះ ឬថ្ងៃស្អែកសូមសញ្ជឹងគិតពីអ្វីដែលអ្នកចង់សម្រេចនៅក្នុងជីវិត*របស់អ្នក* និង អ្វីទៅដែលជាគោលដៅ*របស់អ្នក*នោះ ។ ចំណាយពេលសរសេរវាទុក ហើយមើលវាឡើងវិញនៅឆ្នាំក្រោយៗទៀត ។ រួចចំណាយពេលពីរបីម៉ោងសួរខ្លួនឯងពីអ្វីដែលអ្នកអាចធ្វើដើម្បីសម្រេចគោលដៅទាំងនេះនៅថ្ងៃនេះ ថ្ងៃស្អែក សប្ដាហ៍ក្រោយ និង នៅខែខាងមុខទៀត ។

តើអ្នកជ្រើស ហើយកំណត់គោលដៅអស់កល្បដ៏សំខាន់ទាំងនេះដោយរបៀបណា ? ហើយថា តើអ្នកដាក់ផែនការដើម្បីសម្រេចវាដោយរបៀបណាក៏សំខាន់ផងដែរ ? ចូរចងចាំថា ៖ ពេលវេលាគឺជាកត្តាដ៏ចាំបាច់ — ហើយក៏សំខាន់ផងដែរ — នៅក្នុងការគណនារបស់អ្នក ។ ពីកន្លែងដែលអ្នកឈរនៅពេលនេះ វាហាក់បីដូចជាអ្នកមាននូវពេលវេលាដែលគ្មានកំណត់មួយ ដើម្បីសម្រេចបានរឿងអស់កល្បទាំងឡាយ ។

ពិតណាស់ មនុស្សគ្រប់គ្នាមានពេលវេលា ។ ប៉ុន្តែដោយព្រោះពេលវេលាចេះតែកន្លងទៅ វាពុំមែនមានន័យថាយើងកំពុងតែរីកចម្រើននោះទេ ។

« ជីវិតនេះគឺជាពេលវេលាសម្រាប់ឲ្យមនុស្សប្រុងប្រៀបខ្លួនទៅជួបនឹងព្រះ មែនហើយមើលចុះ ពេលវេលានៃជីវិតនេះគឺជាពេលវេលាសម្រាប់ឲ្យមនុស្សប្រព្រឹត្តការងារទាំងឡាយរបស់ខ្លួន » ( អាលម៉ា 34:32 ) ។

រឿងដ៏សំខាន់នោះគឺការ ជ្រើសសកម្មភាពទាំងនោះដោយឈ្លាសវៃដែលនឹងជួយយើងឲ្យសម្រេចបាននូវគោលដៅរបស់យើងដែលបានបំផុសគំនិតមកពីព្រះ រួចមានចរិតលក្ខណៈ និង ជំនឿរឹងមាំដើម្បីបដិសេធនូវអ្វីដែលនឹងអូសទាញ ឬបង្អាក់យើងពីទិសដៅអស់កល្បរបស់យើង ។

ខ្ញុំសូមថ្លែងទីបន្ទាល់ថា ពេលវេលារបស់យើងនៅលើផែនដីនេះនឹងល្មមគ្រប់គ្រាន់ដើម្បីសម្រេចបាននូវការរៀបចំខ្លួនរបស់អ្នក ហើយធ្វើការងារនៅក្នុងបេសកម្មរបស់អ្នកក្នុងជីវិតនេះ — ប្រសិនបើអ្នកប្រើវាដោយឈ្លាសវៃ ។ ហើយគ្មានពេលវេលាណាល្អជាងពេលនេះឡើយដើម្បីធ្វើរឿងនោះ ក្នុងយុវវ័យរបស់អ្នក ( សូមមើលអាលម៉ា 37:35 ) ។ ■

*ដកស្រង់ចេញពីសុន្ទរកថាចាប់ផ្ដើមមួយ ដែលបានធ្វើឡើងនៅសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់ អៃដាហូ នៅថ្ងៃទី 11 ខែ ធ្នូ ឆ្នាំ 2004 ។*





# គ្រឹះនៃជីវិតខ្ញុំ

*ខ្ញុំបានដឹងពីការបម្រើរបស់ព្រះគ្រីស្ទនៅក្នុងព្រះគម្ពីរប៊ីប ប៉ុន្តែតើទ្រង់ពិតជាបានយាងទៅទ្វីបអាមេរិកមែនឬ ?*

**ដោយ រ៉ូប៊ើរតូ ប៉ាឆេកូ ព្រេតេល**

កាលខ្ញុំឈានចូលវ័យ 18 ឆ្នាំ ឪពុកខ្ញុំបានអនុញ្ញាតឲ្យខ្ញុំទទួលបុណ្យជ្រមុជទឹកនៅក្នុងព្រះវិហារណាក៏បាន តាមចិត្តរបស់ខ្ញុំ ។ ខ្ញុំចង់ចូលរួមនឹងព្រះវិហារគ្រីស្ទានមួយ ដោយសារខ្ញុំបានសិក្សាព្រះគម្ពីរប៊ីបនៅក្នុងក្រុមជំនុំមួយចំនួន ហើយបានជឿលើព្រះយេស៊ូវគ្រីស្ទ ។

មានថ្ងៃមួយពូរបស់ខ្ញុំបានអញ្ជើញអ្នកផ្សព្វផ្សាយសាសនាស្រីពីរនាក់មកផ្ទះរបស់យើង ។ ពួកគេបាននិយាយដោយមានភាពជឿជាក់យ៉ាងខ្លាំង អំពីជំនឿរបស់ពួកគេលើព្រះគម្ពីរមរមនដែលជាសក្ខីបទមួយទៀតនៃព្រះយេស៊ូវគ្រីស្ទ ដោយថ្លែងថា ទ្រង់បានយាងទៅទ្វីបអាមេរិក ។

នៅត្រង់ចំណុចនោះ ខ្ញុំបានសម្ដែងនូវទស្សនៈខ្ញុំថា ប្រហែលជាពួកគេយល់ខុសហើយ ដោយសារនៅក្នុងជីវិតខ្ញុំ ខ្ញុំពុំធ្លាប់បានសិក្សាពីរឿងដូចនោះសោះ ។ អ្នកផ្សព្វផ្សាយសាសនាស្រីម្នាក់បាននិយាយមកកាន់ខ្ញុំទាំងទឹកភ្នែក និងដោយទន់ភ្លន់ថា « បងប្រុស រ៉ូប៊ើរតូ កាលដែលបងប្រុសមិនបានដឹងថាព្រះគម្ពីរមរមនគឺជាព្រះគម្ពីរពិត នោះមិនមែនមានន័យថាយើងយល់ខុសនោះទេ ។ ខ្ញុំដឹងថា ព្រះយេស៊ូវគ្រីស្ទស្រឡាញ់យើង ហើយថាទ្រង់បានយាងទៅដែនដីនោះ ហើយថាទ្រង់បានបង្រៀនដំណឹងល្អទ្រង់ ដូចដែលទ្រង់បានធ្វើនៅក្នុងដែនដីបរិសុទ្ធដែរ » ។

ពួកគេបានព្យាយាមជួយខ្ញុំជាមួយនឹងកង្វល់ និង ការសង្ស័យជាច្រើនរបស់ខ្ញុំនៅក្នុងការពិភាក្សាដំបូង ដោយយល់ស្របថា ពួកគេនឹងមកជួបខ្ញុំនៅសប្ដាហ៍ក្រោយទៀត ។

នៅយប់នោះខ្ញុំបានចាប់ផ្ដើមបើកព្រះគម្ពីរមរមនអាន ។ កាលខ្ញុំអានទំព័រចំណងជើង មានពាក្យមួយឃ្លាបានធ្វើឲ្យខ្ញុំចាប់អារម្មណ៍ ៖ « ព្រះយេស៊ូវ គឺជាព្រះគ្រីស្ទ ជាព្រះដ៏នៅអស់កល្បជានិច្ច ដែលបានសម្ដែងរូបអង្គទ្រង់ដល់គ្រប់ទាំងសាសន៍ » ។ ខ្ញុំក៏បានអាននៅក្នុងនីហ្វៃទី 3 11 អំពីការយាងទៅទ្វីបអាមេរិករបស់ព្រះអង្គសង្គ្រោះផងដែរ ហើយខ្ញុំបានមានភាពរីករាយនៅក្នុងចិត្តខ្ញុំ ។ ដូច្នេះខ្ញុំបានធ្វើនូវអ្វីដែលពួកអ្នកផ្សព្វផ្សាយសាសនាបានប្រាប់ឲ្យខ្ញុំធ្វើ ៖ ខ្ញុំបានលុតជង្គង់ ហើយទូលសួរព្រះវរបិតាសួគ៌ខ្ញុំថាតើព្រះគម្ពីរនេះពិតដែរឬទេ ។

កាលខ្ញុំបានបញ្ចប់ការអធិស្ឋាន ខ្ញុំទទួលអារម្មណ៍នូវសេចក្ដីសុខសាន្ត និង ការបញ្ជាក់អះអាងថា ព្រះគម្ពីរនេះគឺជាព្រះគម្ពីរពិតមែន ។ ខ្ញុំបានគិតមួយសន្ទុះថា ទឹកភ្នែករបស់ស៊ិស្ទើរទាំងពីរនាក់នោះបានធ្វើឲ្យខ្ញុំមានចិត្តរំភើប ហើយបានបណ្ដាលឲ្យខ្ញុំជឿលើទីបន្ទាល់របស់ពួកគេ ។ ដូច្នេះខ្ញុំបានបន្តអានព្រះគម្ពីរមរមនរហូតដល់ម៉ោង 4:00 ជាងនៅពេលព្រឹក ។ រាល់ពេលដែលខ្ញុំបានអធិស្ឋាន ខ្ញុំបានទទួលអារម្មណ៍កាន់តែខ្លាំងឡើងៗនូវការបញ្ជាក់ថា ព្រះគ្រីស្ទបានយាងទៅទ្វីបអាមេរិក ហើយថាទ្រង់សព្វព្រះទ័យឲ្យខ្ញុំរៀនពីដំណឹងល្អដ៏ពិតរបស់ទ្រង់ ។

ក្នុងរយៈពេលតែប៉ុន្មានសប្ដាហ៍ ខ្ញុំបានអានព្រះគម្ពីរមរមនចប់ទាំងស្រុង ហើយខ្ញុំមានអារម្មណ៍ថាត្រូវជ្រមុជទឹកចូលទៅក្នុងសាសនាចក្រដ៏ពិតនេះ ។

ការអានព្រះគម្ពីរមរមនបានជួយខ្ញុំឲ្យខិតកាន់តែជិតទៅនឹងព្រះយេស៊ូវគ្រីស្ទ ហើយធ្វើឲ្យទ្រង់ក្លាយទៅជាគ្រឹះនៃជីវិតរបស់ខ្ញុំ ។ ខ្ញុំមានអំណរជាខ្លាំងណាស់ ដែលព្រះអង្គសង្គ្រោះបានបញ្ជូនពួកអ្នកផ្សព្វផ្សាយសាសនាទាំងពីរនាក់នោះ និងសាសនាចក្ររបស់ទ្រង់ចូលមកក្នុងជីវិតខ្ញុំ ។ ■

*អ្នកនិពន្ធរស់នៅទីក្រុង អ៊ីរឃ្វីប៉ា ប្រទេសប៉េរូ ។*

ព្រះយេស៊ូវគ្រីស្ទយាងទៅទ្វីបអាមេរិក ដោយ ចន ស្កុត; ការតុបតែងដោយ ISTOCK/THINKSTOCK

# ទៅកាន់គោលដៅ



## ខ្ញុំធ្លាប់ជាមនុស្សកាច ប៉ុន្តែខ្ញុំបានផ្លាស់ប្ដូរ ហើយខ្ញុំចង់ចែកចាយដំណឹងល្អ ។ តើខ្ញុំអាចយកឈ្នះលើនិស្ស័យរបស់ខ្ញុំបានដោយរបៀបណា ?

ដំបូង សូមកុំឲ្យភាពភ័យខ្លាចបញ្ឈប់អ្នកឡើយ ។ ប្រសិនបើអ្នកត្រូវបានប៉ះដោយព្រះវិញ្ញាណ ហើយកំពុងព្យាយាមប្រែចិត្ត ហើយផ្លាស់ប្ដូរ នោះគឺជារឿងមួយដ៏អស្ចារ្យ ។ ចូរចងចាំថា ការផ្លាស់ប្ដូរនេះកើតឡើងតាមរយៈព្រះចេស្ដាគាំទ្រនៃព្រះគុណរបស់ព្រះយេស៊ូវគ្រីស្ទ ។ ដោយមានជំនួយរបស់ទ្រង់ អ្នកអាចក្លាយជាមនុស្សថ្មីម្នាក់ ហើយចាប់ផ្ដើមផ្លាស់ប្ដូរនិស្ស័យរបស់អ្នក ។ ទ្រង់ក៏នឹងជួយអ្នកឲ្យចែកចាយដំណឹងល្អផងដែរ ។ ទោះជាការផ្លាស់ប្ដូរនិស្ស័យរបស់អ្នកតម្រូវនូវពេលវេលាជាច្រើនក្ដី វានឹងក្លាយជារឿងល្អ ។ ទាំងនេះជារឿងមួយចំនួនដែលអ្នកអាចធ្វើនៅក្នុងដំណើរការនោះ ៖

- សុំទោសមនុស្សដែលអ្នកដឹងថា អ្នកបានធ្វើឲ្យអាក់អន់ចិត្ត ។
- សូមបង្ហាញសេចក្ដីសប្បុរស ដល់នរណាដែលអ្នកមិនបានបង្ហាញសេចក្ដីសប្បុរសពីមុនមក ។
- ចូរមានចិត្តស្មោះត្រង់ ហើយទៀងត្រង់ជានិច្ច ។
- ប្រសិនបើមនុស្សដែលអ្នកសេពគប់ធ្វើរឿងមិនល្អដាក់មនុស្សដទៃទៀត អ្នកអាចប្រាប់ឲ្យគេបញ្ឈប់វា ឬឈប់សេពគប់នឹងពួកគេ ។ បើមិនដូច្នេះទេ មនុស្សទូទៅនឹងរាប់បញ្ចូលអ្នកជាមួយនឹងពួកគេដែរ ។
- ពិចារណាសិក្សា មរ៉ូណៃ 7 ហើយអធិស្ឋានទូលសូមឲ្យមានសេចក្ដីសប្បុរស ។ ■

## ព្រះអង្គសង្គ្រោះបានមានបន្ទូលថា វិញ្ញាណនៃការទាស់ទែងគ្នាគឺជារបស់ផងអារក្ស ( សូមមើលនីហ្វៃទី 3 11:29 ) ។ តើការមិនចុះសម្រុងនឹងមនុស្សទូទៅ និង ការឈ្លោះប្រកែកនឹងពួកគេខុសគ្នាដូចម្ដេច ?

វាគឺជារឿងធម្មតាទេ ដែលមនុស្សទូទៅមានទស្សនៈខុសៗពីគ្នា ហើយមានពេលខ្លះ ដែលពួកសិស្សនៃព្រះយេស៊ូវគ្រីស្ទត្រូវក្រោកឈរឡើងប្រឈមមុខនឹងការជំទាស់ចំពោះអ្វីដែលយើងជឿ ។ ប៉ុន្តែយើងត្រូវតែប្រាប់ពីទស្សនៈរបស់យើងតាមរបៀបវិជ្ជមាន ហើយពិត ដោយគ្មានការខឹងសម្បារ គ្មានភាពជូរចត់ ឬការជេរប្រមាថនោះទេ ។ ដូច្នេះតើយើងជៀសវាងការទាស់ទែងគ្នាបានដោយរបៀបណា ?

អ្នកប្រហែលជាធ្លាប់ឮថា យើងអាច « បដិសេធដោយគ្មានការខ្វែងគំនិតគ្នា » ។ ការជៀសវាងពីការទាស់ទែងគ្នា ចាប់ផ្ដើមឡើងជាមួយនឹងហេតុផល និង បំណងប្រាថ្នារបស់អ្នក ។ ព្រះគម្ពីរចែងថា « ផលនៃសេចក្ដីឆ្មើងឆ្មៃ នោះមានតែការទាស់ទែងគ្នាប៉ុណ្ណោះ » ( សុភាសិត 13:10 ) ។ ប្រសិនបើអ្នកខ្វល់ខ្វាយច្រើនពី « ការចង់ឈ្នះការប្រកែកគ្នាមួយ » ឬ « ចង់ឲ្យខ្លួនត្រូវ » នោះវិញ្ញាណនៃការទាស់ទែងគ្នាគឺពិតជានឹងកើតឡើង ។

អែលឌើរ រ័សុល អិម ណិលសុន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនពីរបៀបមួយចំនួនដើម្បីចៀសវាងពីការទាស់ទែងគ្នាថា ៖ (1) « បង្ហាញចិត្តមេត្តាដល់អ្នកដទៃ » (2) « បញ្ឈប់ការចង់និយាយ ឬសរសេរជាបន្តបន្ទាប់បង្កើនមុខមាត់ ឬភាពរុងរឿងផ្ទាល់ខ្លួន » និង (3) « ក្នុងការចេះស្ដាប់បង្គាប់ដោយរាបសា [ ស្រឡាញ់ ] ព្រះដោយពិតប្រាកដ » ។[1] នោះយើងនឹងអាចមានព្រះវិញ្ញាណនៃព្រះអម្ចាស់គង់នៅជាមួយយើង ពុំមែនជាវិញ្ញាណនៃការទាស់ទែងគ្នានោះទេ ។ ■

**កំណត់ចំណាំ**

1. រ័សុល អិម ណិលសុន « The Canker of Contention » *Ensign,* ខែ ឧសភា ឆ្នាំ 1989 ទំព័រ 70–71 ។

# ការផ្ដល់អំណោយដ៏ល្អបំផុត

*ខ្ញុំបានឲ្យមិត្តខ្ញុំនូវអំណោយខួបកំណើតមួយដ៏ល្អបំផុត ដែលនាងពុំធ្លាប់បានទទួលពីមុនមក ។*

**ដោយ ម៉ារីឡា រ៉ូឌ្រីហ្គេស្ស**

កាលខ្ញុំមានអាយុ 13 ឆ្នាំ ព្យាការីបានសូមឲ្យសមាជិកសាសនាចក្រអានបញ្ចប់ព្រះគម្ពីរមរមននៅក្នុងរយៈពេលប្រាំខែ គឺនៅត្រឹមចុងឆ្នាំនោះ ហើយបានសន្យាពីពរជ័យចំពោះការធ្វើបែបនេះ ។ មានថ្ងៃមួយកាលខ្ញុំកំពុងអានព្រះគម្ពីរនៅលើរថយន្តក្រុង មានក្មេងស្រីម្នាក់ឈ្មោះ ស៊ីនទីយ៉ា ដែលអង្គុយនៅក្បែរខ្ញុំបានសួរថាតើសៀវភៅនោះជាសៀវភៅអ្វីទៅ ។ ខ្ញុំបានតបថា វាគឺជាព្រះគម្ពីរមរមន ហើយថាវាគឺជាសៀវភៅមួយដ៏ពិសេស ។ ខ្ញុំបាននិយាយថា ខ្ញុំចង់អានវាឲ្យចប់ពីមុនចុងឆ្នាំ ដើម្បីខ្ញុំអាចទទួលបានពរជ័យ ។

នាងបានចាប់ផ្ដើមសួរសំណួរបន្ថែមទៀត ហើយខ្ញុំបានប្រាប់នាងថា នាងអាចមកផ្ទះខ្ញុំដើម្បីយើងអាចពិភាក្សាគ្នាបន្ថែមទៀតពីសៀវភៅនេះ ។ នាងបានទទួលយកការអញ្ជើញរបស់ខ្ញុំ ហើយយើងបានចំណាយពេលពីរទៅបីម៉ោងនៅថ្ងៃបន្ទាប់ពិភាក្សាពីព្រះគម្ពីរមរមន និង សាសនាចក្រ ។

លុះថ្ងៃច័ន្ទសប្ដាហ៍ក្រោយ ខ្ញុំបានអញ្ជើញនាងមករាត្រីជួបជុំក្រុមគ្រួសារ ជាពេលដែលខ្ញុំបានណែនាំនាងឲ្យស្គាល់ពួកអ្នកផ្សព្វផ្សាយសាសនា ។ ពួកគេបានចាប់ផ្ដើមបង្រៀននាងពីមេរៀននានា ហើយនាងបានចាប់ផ្ដើមមកព្រះវិហារ ហើយមកចូលរួមរាល់សកម្មភាពសម្រាប់យុវវ័យ និង ការប្រជុំផ្សេងទៀតរបស់សាសនាចក្រ ។

នាងបានសម្រេចចិត្តថា នាងចង់ទទួលពិធីបុណ្យជ្រមុជទឹក ហើយដោយមានការអនុញ្ញាតពីឪពុកម្ដាយនាង នាងបានជ្រមុជទឹកនៅចំថ្ងៃកំណើតរបស់នាងក្នុងឆ្នាំនោះ ។ នាងបាននិយាយថា វាគឺជាអំណោយដ៏ល្អបំផុតដែលនាងធ្លាប់បានទទួល ។ ម្ដាយ និង បងប្អូននាងបានមកចូលរួមក្នុងពិធីបុណជ្រមុជទឹកនោះ ។ នាងបានសុំឲ្យខ្ញុំច្រៀងបទ « ព្រះវិញ្ញាណនៃព្រះ » ( *ទំនុកដំកើងព្រះ និងចំរៀងកុមារាកុមារី* ទំព័រ 28 ) ហើយបានសុំឲ្យឪពុកខ្ញុំធ្វើពិធីបុណ្យជ្រមុជទឹកឲ្យនាង ។ បន្ទាប់ពីនាងបានងើបចេញពីទឹកមកវិញ យើងបានយំឱបគ្នា ។ ខ្ញុំមិនអាចបំភ្លេចថ្ងៃនោះបានឡើយ ដោយសារខ្ញុំមានអារម្មណ៍នូវសុភមង្គលដ៏លើសលប់ ។

មួយឆ្នាំក្រោយមក គ្រួសារខ្ញុំបានផ្លាស់ទីលំនៅ ។ វាគឺជារឿងដ៏ពិបាកណាស់ ដោយសារស៊ីនទីយ៉ា និង ខ្ញុំបានក្លាយជាមិត្តដ៏ល្អ និង បងប្អូនស្រីនៅក្នុងដំណឹងល្អ ។

ទោះជាយើងមិនបានរស់នៅជិតគ្នាទៀតក៏ដោយ យើងនៅតែជាមិត្តសម្លាញ់នឹងគ្នា ។ ជារឿយៗខ្ញុំបានទូរសព្ទទៅរកគ្នា ហើយថ្មីៗនេះ នាងបានទូរសព្ទមកប្រាប់ខ្ញុំថា ម្ដាយនាងកំពុងរៀនជាមួយនឹងពួកអ្នកផ្សព្វផ្សាយសាសនា ។ ដំណឹងនេះបានធ្វើឲ្យខ្ញុំមានចិត្តរីករាយ ដោយសារពីមុនមកម្ដាយរបស់នាងមិនចង់ស្ដាប់មេរៀនទាំងនោះទេ ។ ស៊ីនទីយ៉ា បានប្រាប់ខ្ញុំថា នៅថ្ងៃមួយ នាងសង្ឃឹមថា គ្រួសារនាងទាំងមូលនឹងទៅព្រះវិហារជាមួយនឹងនាង ។ នាងបានអរគុណខ្ញុំដែលបានណែនាំនាងឲ្យស្គាល់សាសនាចក្រ ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋតិចសាស ស.រ.អា. ។*



រូបគំនូរដោយ ចាហ្វ ម៉ិនី

# សូមហុចដៃជួយយើងផង!

រៀងរាល់ថ្ងៃ កុមារនៅជុំវិញពិភពលោកបង្ហាញថា ពួកគេមានចិត្តខ្វល់ខ្វាយតាមរយៈការស្វែងរកវិធីជួយដល់អ្នកដទៃ !



**នំឃុកឃី និង រូបតុក្កតា**

*គ្រួសារយើងមាន « ការបម្រើដ៏ច្រើន » ។ បងប្អូនប្រុសខ្ញុំ និង ខ្ញុំបានធ្វើរូបតុក្កតាសម្រាប់កុមារនៅមណ្ឌលកុមារកំព្រា ។ យើងក៏បានយកនំឃុកឃីស៊ុកកូឡាទៅឲ្យពួកអ្នកពន្លត់អគ្គីភ័យមួយចំនួន ហើយបានសម្អាតបឹងមួយ ។ ខ្ញុំរីករាយដែលយើងមានការបម្រើ !*

តូបឺន ភី អាយុ ៩ ឆ្នាំ រដ្ឋអៃដាហូ ស.រ.អា.



**ចម្រៀងដ៏រីករាយ**

*នៅថ្ងៃនៃការបម្រើដ៏ពិសេសរបស់យើង យើងបានទៅលេងនៅមជ្ឈមណ្ឌលមនុស្សចាស់ជរា ។ កាលយើងបានចាប់ផ្ដើមច្រៀងចម្រៀងកុមារ និង ចម្រៀងផ្សេងទៀត មនុស្សម្នាបានចាប់ផ្ដើមទះដៃ ហើយច្រៀងជាមួយយើង ។ មានពួកគេមួយចំនួនបានឡើងរាំទៀតផង ! យើងឱប ហើយទុកកាតដែលបានធ្វើឡើងសម្រាប់ពួកគេ ។*

មណ្ឌល លីរីយ៉ា ប្រទេសព័រទុយហ្គាល



**លើសពីបុណ្យគ្រីស្ទម៉ាស់ទៅទៀត**

*ឪពុកម្ដាយខ្ញុំបាននឿយហត់យ៉ាងខ្លាំងដោយសារធ្វើការងារជាច្រើន ។ ខ្ញុំបានលាងចាន ហើយរៀបរាទុក ហើយបានបោសសម្អាតកម្រាល ជូតតុ និង កន្លែងចម្អិនអាហារ ។ រួចខ្ញុំបានសម្អាតបន្ទប់ទទួលភ្ញៀវ និង បន្ទប់សម្រាប់លេង ។ កាលឪពុកម្ដាយខ្ញុំក្រោកឡើង ពួកគាត់និយាយថា វាលើសពីបុណ្យគ្រីស្ទម៉ាស់ទៅទៀត !*

ខាំប្រី ជី អាយុ ១១ ឆ្នាំ រដ្ឋ ចចចា ស.រ.អា.






## សូមផ្ញើស្នាមបាតដៃអ្នកមកឲ្យយើង

តើត្រូវការដៃដែលចាំជួយចំនួនប៉ុន្មាននាក់ ដើម្បីអាចជួយបានពាសពេញពិភពលោក ? ចូរធ្វើទង្វើល្អ ហើយជួយយើងស្វែងយល់ពីបញ្ហានេះ !

1. សូមគូសដានដៃរបស់អ្នកនៅលើក្រដាសមួយសន្លឹក រួចកាត់វាចេញ ។
2. សូមសរសេរពីទង្វើនៃការបម្រើមួយដែលអ្នកបានធ្វើសម្រាប់នរណាម្នាក់ — ឬទង្វើនៃការបម្រើដែលនរណាម្នាក់បានធ្វើដល់អ្នក ។ វាអាចជាទង្វើមួយធំ ឬតូច ។
3. សូមដាក់រូបថតរបស់អ្នក ។
4. សុំឲ្យឪពុកម្ដាយអ្នក ឬមនុស្សធំម្នាក់ជួយអ្នកធ្វើការដាក់ស្នើរបស់អ្នកទៅកាន់ liahona@ldschurch.org ឬ ទៅកាន់អាសយដ្ឋាននៅទំព័រ 3 ។

យើងនឹងប្រមូលដៃដែលចាំជួយចាប់ពីពេលនេះរហូតដល់ខែ តុលា ឆ្នាំ 2015 ។



**គម្រោងរៀបចំស្រោមជើងដាក់ជាប្រអប់**

*មនុស្សដែលគ្មានផ្ទះសម្បែងនឹងមានភាពត្រជាក់ខ្លាំងណាស់នៅរដូវរងា ! យើងបានសម្រេចចិត្តប្រមូលស្រោមជើងក្រាស់ៗសម្រាប់ឲ្យទៅមនុស្សដែលគ្មានផ្ទះសម្បែងក្នុងស្រុករបស់យើង ។ យុវជន និង យុវនារីបានជួយ ហើយមិនយូរប៉ុន្មានប្រអប់ស្រោមជើងរបស់យើងបានពេញទៅដោយស្រោមជើងរាប់រយសម្រាប់អ្នកដែលគ្មានផ្ទះសម្បែងទាំងនោះ !*

អាល់បើរតា ប្រទេសកាណាដា



# ការសាកល្បងតម្រិះព្រះគម្ពីរក្នុងព្រះគម្ពីរសញ្ញាថ្មី

ព្រះយេស៊ូវបាននិទានប្រាប់ពីដំណើររឿងស្ដីពីអ្នកគង្វាលម្នាក់ដែលស្រឡាញ់ចៀមរបស់ខ្លួន ហើយបានស្វែងរកចៀមមួយក្បាលដែលបានបាត់ ។ នៅឆ្នាំនេះ អ្នកអាចរៀនបន្ថែមទៀតអំពីការបង្រៀនរបស់ព្រះយេស៊ូវនៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។ រាល់ពេលដែលអ្នកអានបទគម្ពីរមួយនៅទំព័រ 68 សូមផាត់ពណ៌លើលេខក្បែរនោះ ។ ប្រសិនបើអ្នកអានរាល់សប្ដាហ៍ អ្នកនឹងបញ្ចប់វាត្រឹមចុងឆ្នាំ !

សូមឲ្យមនុស្សពេញវ័យម្នាក់ជួយអ្នកកាត់យកតារាងនេះ ឬបោះពុម្ពវាចេញពី liahona.lds.org ។ ■








រចនាដោយ ផល មេន និង យ៉ាប៉េត បើក ស្រ្តួន

សេចក្តីណែនាំសម្រាប់ការអានប្រចាំសប្តាហ៍នៅក្នុងការសាកល្បងតម្រិះព្រះគម្ពីរក្នុងព្រះគម្ពីរសញ្ញាថ្មី ( សូមមើល ទំព័រ 66-67 ) ។

| សប្តាហ៍ | ការអាន |
|---|---|
| 1 | **យ៉ូហាន បាទីស្ទបានរៀបចំផ្លូវសម្រាប់ព្រះយេស៊ូវគ្រីស្ទ**<br>ម៉ាថាយ 3:1–6, លូកា 1:5–25, 57–80 |
| 2 | **ការប្រសូតរបស់ព្រះយេស៊ូវគ្រីស្ទ**<br>ម៉ាថាយ 1:18–25, លូកា 1:26–38, 2:1–20 |
| 3 | **កុមារភាពរបស់ព្រះយេស៊ូវគ្រីស្ទ**<br>ម៉ាថាយ 2, លូកា 2:21–52 |
| 4 | **ពិធីបុណ្យជ្រមុជទឹករបស់ព្រះយេស៊ូវគ្រីស្ទ**<br>ម៉ាថាយ 3:13–17, យ៉ូហាន 3:5 |
| 5 | **សាតាំងបានល្បួងព្រះយេស៊ូវគ្រីស្ទ**<br>ម៉ាថាយ 4:1–11, ម៉ាកុស 1:12–13, លូកា 4:1–13 |
| 6 | **ព្រះយេស៊ូវគ្រីស្ទសម្អាតព្រះវិហារបរិសុទ្ធ**<br>ម៉ាថាយ 21:12–14, លូកា 19:45–48, យ៉ហាន 2:13–16 |
| 7 | **ព្រះយេស៊ូវគ្រីស្ទហៅពួកសាវកទ្រង់**<br>ម៉ាថាយ 4:18–22, 16:13–19, ម៉ាកុស 3:13–19, 16:15, លូកា 5:1–11, 6:12–16 |
| 8 | **ការបង្រៀននៅលើភ្នំ**<br>ម៉ាថាយ 5:1–6:4, 7:12, លូកា 6:17–36 |
| 9 | **ព្រះយេស៊ូវគ្រីស្ទបង្រៀនអំពីការអធិស្ឋាន**<br>ម៉ាថាយ 6:5–13, 7:7–11, 26:36–46, លូកា 9:28–29, 11:2–4, 9–13, យ៉ាកុប 1:5–6 |
| 10 | **ព្រះយេស៊ូវគ្រីស្ទព្យាបាលអ្នកឈឺ**<br>ម៉ាថាយ 8:5–10, 13, 25:34–40, ម៉ាកុស 1:40–45,<br>លូកា 4:38–40, 7:11–17, យ៉ូហាន 4:46–54, 13:34–35 |
| 11 | **ព្រះយេស៊ូវគ្រីស្ទ និង ថ្ងៃឈប់សម្រាក**<br>ម៉ាថាយ 12:1–13, ម៉ាកុស 2:23–28, 3:1–6, លូកា 13:11–17, 14:1–6, យ៉ូហាន 5:2–16 |
| 12 | **ព្រះយេស៊ូវគ្រីស្ទបានប្រើអំណាចបព្វជិតភាពរបស់ទ្រង់ប្រទានពរដល់មនុស្សរាល់គ្នា**<br>ម៉ាថាយ 14:23–33, ម៉ាកុស 4:35–41, 6:33–44, លូកា 9:37–43, កិច្ចការ 10:38 |
| 13 | **ព្រះយេស៊ូវគ្រីស្ទបានធ្វើអព្ភូតហេតុ**<br>ម៉ាកុស 2:1–12, 5:21–43 |
| 14 | **អ្នកសាបព្រួស និងស្រូវ និង ស្រងែ**<br>ម៉ាថាយ 13:1–9, 18–30, 37–43, ម៉ាកុស 4:14–20, លូកា 8:11–15 |
| 15 | **ចៀមវង្វេងផ្លូវ កាក់ដែលបាត់ និង កូនប្រុសដែលខ្ជះខ្ជាយ**<br>ម៉ាថាយ 18:12–14, លូកា 15 |
| 16 | **សាសន៍សាម៉ារីចិត្តល្អ និង ផ្ទះដែលបានសង់នៅលើថ្ម**<br>ម៉ាថាយ 7:24–27, 22:34–40, លូកា 6:47–49, 10:25–37 |
| 17 | **ព្រះយេស៊ូវគ្រីស្ទព្យាបាលមនុស្សឃ្លង់ 10 នាក់ និង មនុស្សខ្វាក់ម្នាក់**<br>លូកា 17:12–19, យ៉ូហាន 9 |
| 18 | **អ្នកគង្វាលល្អ**<br>ម៉ាថាយ 19:13–15, ម៉ាកុស 10:13–16, យ៉ូហាន 10:1–18 |
| 19 | **អ្នកបម្រើដែលគ្មានក្តីមេត្តា**<br>ម៉ាថាយ 6:12, 14–15, 18:21–35 |
| 20 | **ស្ត្រីព្រហ្មចារីដប់នាក់ ទេពកោសល្យ និង ប្រាក់របស់ស្ត្រីមេម៉ាយ**<br>ម៉ាថាយ 25:1–13, 14–46, ម៉ាកុស 12:41–44, លូកា 21:1–4 |
| 21 | **ព្រះយេស៊ូវគ្រីស្ទបានប្រោសឡាសារឲ្យរស់ពីស្លាប់**<br>យ៉ូហាន 11:1–46 |
| 22 | **ការយាងចូលដ៏ជោគជ័យរបស់ព្រះយេស៊ូវគ្រីស្ទ និង អាហារថ្ងៃចុងក្រោយ**<br>ម៉ាថាយ 21:1–11, ម៉ាកុស 14:12–26, លូកា 19:29–38, 22:15–20 |
| 23 | **ព្រះយេស៊ូវគ្រីស្ទនៅក្នុងសួនច្បារគែតសាម៉ានី**<br>ម៉ាថាយ 26:36–46, លូកា 22:40–46, យ៉ូហាន 3:16, 15:12–13 |
| 24 | **ព្រះយេស៊ូវគ្រីស្ទត្រូវបានគេក្បត់ ចាប់ហើយចង**<br>ម៉ាថាយ 26:14–16, 47–27:31, លូកា 22:47–23:25 |
| 25 | **ការឆ្កាង និង ការបញ្ចុះព្រះសពរបស់ព្រះយេស៊ូវគ្រីស្ទ**<br>ម៉ាថាយ 27:32–66, លូកា 23:26–56, យ៉ូហាន 10:17–18, 15:13, 19:13–42 |
| 26 | **ការរស់ឡើងវិញនៃព្រះយេស៊ូវគ្រីស្ទ**<br>ម៉ាថាយ 27:52–53, 28:1–20, លូកា 24, យ៉ូហាន 20,<br>កិច្ចការ 1:3, 9–11, កូរិនថូសទី 1 15:5–6, 22 |
| 27 | **ចូរឲ្យចំណីដល់ហ្វូងចៀមខ្ញុំសឹងផង**<br>ម៉ាកុស 16:15, យ៉ូហាន 21:1–17 |
| 28 | **បុណ្យថ្ងៃ 50**<br>យ៉ូហាន 14:25–27, កិច្ចការ 2:1–24, 32–33, 36–47 |
| 29 | **ពេត្រុស ជាសាវក**<br>ម៉ាថាយ 4:18–19, 14:22–33, 16:13–17, 17:1–9,<br>លូកា 22:31–34, 54–62, កិច្ចការ 3:1–9, 19–21, 4:6–20, 5:12–42 |
| 30 | **បាណាបាស, អាន៉ានាស និង សាភីរ៉ា, ស្ទេផាន ជាស្មរបន្ទាល់**<br>កិច្ចការ 4:32–5:10, 6, 7:54–60 |
| 31 | **ពេត្រុស និង កូនេលាស**<br>កិច្ចការ 10:1–11:18 |
| 32 | **ការប្រែចិត្តជឿរបស់សូល**<br>កិច្ចការ 7:57–60, 8:1–3, 9:1–30, 26:9–23 |
| 33 | **បេសកកម្មដំបូងរបស់ប៉ុល**<br>កិច្ចការ 13:4–11, 14–43, 14:5–10 |
| 34 | **បេសកកម្មទីពីររបស់ប៉ុល**<br>កិច្ចការ 15:36 –41, 16:16–34 |
| 35 | **បេសកកម្មទីបីរបស់ប៉ុល**<br>កិច្ចការ 18:23, 19:1–7, 11–12, 20 |
| 36 | **ព្រះយេស៊ូវគ្រីស្ទនឹងយាងមកម្តងទៀត**<br>កិច្ចការ 1:9–11, យ៉ូសែប ស្ម៊ីធ — ម៉ាថាយ 1:1–4, 21–55 |
| 37 | **សំបុត្ររបស់ប៉ុលដល់ពួករ៉ូម**<br>រ៉ូម 1:16, 8:13–18, 31–39, 12:3–21 |
| 38 | **សំបុត្រទីមួយរបស់ប៉ុលដល់ពួកកូរិនថូស**<br>កូរិនថូសទី 1 6:19–20, 12:4–27, 13, 15:20–22, 40–42 |
| 39 | **សំបុត្រទីពីររបស់ប៉ុលដល់ពួកកូរិនថូស**<br>កូរិនថូសទី 2 4:5–18, 9:6–8, 12:6–10 |
| 40 | **សំបុត្ររបស់ប៉ុលដល់ពួកកាឡាទី**<br>កាឡាទី 2:16–21, 5:22–23, 6:7–10 |
| 41 | **សំបុត្ររបស់ប៉ុលដល់ពួកអេភេសូរ**<br>អេភេសូរ 1:3–12, 4:11–16, 6:10–18 |
| 42 | **សំបុត្ររបស់ប៉ុលដល់ពួកភីលីព**<br>ភីលីព 1:2–11, 2:12–13, 4:4–13 |
| 43 | **សំបុត្ររបស់ប៉ុលដល់ពួកកូល៉ុស**<br>កូល៉ុស 1:9–20, 3:1–16 |
| 44 | **សំបុត្ររបស់ប៉ុលដល់ពួកថែស្សាឡូនីច**<br>ថែស្សាឡូនីចទី 1 2:1–12, 4:1–7, ថែស្សាឡូនីចទី 2 2:1–4, 3:10–13 |
| 45 | **សំបុត្ររបស់ប៉ុលដល់ធីម៉ូថេ**<br>ធីម៉ូថេទី 1 1:12–17, 5:1–3, ធីម៉ូថេទី 2 3:1– 5, 14–17 |
| 46 | **សំបុត្ររបស់ប៉ុលដល់ទីតុស និង ភីលេម៉ូន**<br>ទីតុស 1:1–4, 2, ភីលេម៉ូន 1:3–9 |
| 47 | **សំបុត្ររបស់ប៉ុលដល់ហេព្រើរ**<br>ហេព្រើរ 1:1–6, 5:1–4, 11:1–11, 12:1–2 |
| 48 | **ការបង្រៀនរបស់យ៉ាកុប**<br>យ៉ាកុប 1:5–6, 2:17–18, 3:2–13, 5:12 |
| 49 | **ការបង្រៀនរបស់ពេត្រុស**<br>ពេត្រុសទី 1 1:3–11, 3:18–20, 4:6, ពេត្រុសទី 2 1:2–8 |
| 50 | **ការបង្រៀនរបស់យ៉ូហាន និង យូដា**<br>យ៉ូហានទី 1 2:1–6, 3:10–18, 23, 4:7–10, 5:1–3,<br>យ៉ូហានទី 2 1:4, យ៉ូហានទី 3 1:4, យូដា 1:20–22 |
| 51 | **វិវរណៈរបស់យ៉ូហាន**<br>វិវរណៈ 1:1–3, 2:7,4, 12:7–9, 20:12 |
| 52 | **ចូរមករកព្រះយេស៊ូវគ្រីស្ទ — ទ្រង់គឺជាពន្លឺ និង ជីវិតនៃលោកិយ**<br>ម៉ាថាយ 11:28–30, យ៉ូហាន 4:3–14, 6:35–51, 8:12,14:6,15 |

# ការធ្វើអ្វីមួយដែលល្អ សក្តិសមនឹងពេលវេលាខ្ញុំ

ក្លេតុន ដឺបុលយូ អាយុ 10 ឆ្នាំ រដ្ឋមិសសួរី ស.រ.អា.

ពេលខ្លះ អាកាសធាតុពិតជាត្រជាក់ ហើយមានព្រិលច្រើនណាស់នៅទីកន្លែងដែលយើងរស់នៅ ។ ពេលខ្លះ យើងត្រូវបានឈប់សម្រាកពីសាលា ហើយជិះគារទឹកកករបស់យើងចុះពីលើទួលដ៏ធំមួយនៅក្បែរផ្ទះរបស់យើងទៀតផង ។ មានថ្ងៃមួយ កាលយើងកំពុងរៀបចំខ្លួនពាក់អាវរងារ មួក និង ស្រោមដៃរបស់យើង ស្រាប់តែម្ដាយខ្ញុំបានពោលថា កុំចេញទៅខាងក្រៅអី វាត្រជាក់ ហើយមានខ្យល់បក់ខ្លាំងណាស់ ។ ខ្ញុំបានរអ៊ូរទាំ ដោយសារយើងត្រូវនៅតែក្នុងផ្ទះ ។ ខ្ញុំបានចាប់ផ្ដើមត្អូញត្អែរ ហើយម្ដាយខ្ញុំបានពោលថា « កូនត្រូវឡើងទៅបន្ទប់កូន ហើយរកអ្វីមួយធ្វើដែលល្អសក្តិសមនឹងពេលវេលាកូន » ។

កាលខ្ញុំឡើងទៅដល់បន្ទប់ខ្ញុំ ខ្ញុំបានគិតពីអ្វីដែលព្រះអង្គសង្គ្រោះសព្វព្រះទ័យឲ្យខ្ញុំធ្វើ ។ ខ្ញុំបានសម្រេចចិត្តដើម្បីទន្ទេញមាត្រានៃសេចក្ដីជំនឿ ។ ពីរបីម៉ោងក្រោយមក កាលខ្ញុំចុះមកវិញ ខ្ញុំបានប្រាប់ម្ដាយខ្ញុំ បងប្រុស និង បងប្អូនស្រីខ្ញុំថា ខ្ញុំសុំទោសដែលបានរអ៊ូរទាំ ហើយថាខ្ញុំបានទន្ទេញចាំមាត្រានៃសេចក្ដីជំនឿគ្រប់មាត្រាទាំងអស់ ។ ពួកគេមានការភ្ញាក់ផ្អើលជាខ្លាំង ! ខ្ញុំបានសូត្រមាត្រានីមួយៗឲ្យពួកគេស្ដាប់ ហើយខ្ញុំមានអារម្មណ៍ល្អដែលបានចំណាយពេលរបស់ខ្ញុំដោយមានប្រយោជន៍ ។

ខ្ញុំគិតថា ព្រះអង្គសង្គ្រោះមានព្រះទ័យរីករាយដោយសារខ្ញុំបានសម្រេចចិត្តរៀនបន្ថែមទៀតពីទ្រង់នៅពេលទំនេរដែលខ្ញុំមាននៅពេលព្រឹក ។ ខ្ញុំមានអំណរគុណដែលទ្រង់បានប្រទានគ្រួសារ និង ព្រះគម្ពីរមកដល់ខ្ញុំ ដើម្បីជួយយើងរៀនបន្ថែមទៀតពីព្រះវរបិតាសួគ៌យើង និង ព្រះរាជបុត្រាទ្រង់ ព្រះយេស៊ូវគ្រីស្ទ ។ ■



រចនារូបភាព ដោយ ស្ទីវិនខល វ៉ៃវ៉ះគាម

# ទំព័ររបស់យើង



*ឪពុកខ្ញុំគឺជាប៊ីស្សពក្នុងវួដរបស់យើង ហើយគាត់បានសម្ភាសន៍ខ្ញុំពីមុនគាត់ជ្រមុជទឹកឲ្យខ្ញុំ ។ ខ្ញុំរីករាយខ្លាំងណាស់ ។ ខ្ញុំបានសម្រេចចិត្តអញ្ជើញមិត្តសម្លាញ់ខ្ញុំនៅឯសាលារៀន និង គ្រួសារគាត់មកពិធីបុណ្យជ្រមុជទឹករបស់ខ្ញុំ ។ ពួកគេបានមកមែន ! ខ្ញុំមិនដែលភ្លេចពីថ្ងៃពិសេសនោះឡើយ ។*

អ៊ីហ្វ្រេន ដឹបុលយូ អាយុ 8 ឆ្នាំ ប្រទេសអេស្ប៉ាញ



*ខ្ញុំដឹងពីរបៀបចូលទៅកាន់គេហទំព័ររបស់ពង្សប្រវត្តិ ហើយរកឈ្មោះរបស់ជីដូនជីតា ។ ខ្ញុំសិក្សាស្វែងយល់ថាតើជីដូនជីតារូបនោះត្រូវការកិច្ចការព្រះវិហារបរិសុទ្ធដែរឬទេ ។ នេះគឺជាចំណែករបស់ខ្ញុំក្នុងការធ្វើកិច្ចការរបស់ព្រះអម្ចាស់ ។*

ស្ទេហ្វិន អេស អាយុ 6 ឆ្នាំ ប្រទេសហ្វីលីពីន



ឡូរ៉ា ឌី អាយុ 8 ប្រទេសប្រេស៊ីល



**សាក្សីពិសេស**



# តើព្រះគម្ពីរអាចជួយខ្ញុំបានតាមរបៀបណា ?

**ដោយ ប្រធាន**
**ប៊យដ៏ ឃេ ផាកកឺ**

ប្រធានកូរ៉ុមនៃពួកសាវកដប់ពីរនាក់

*សមាជិកនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ គឺជាសាក្សីពិសេសរបស់ព្រះយេស៊ូវគ្រីស្ទ ។*



## ព្រះគម្ពីរ . . .

- បង្រៀនយើងថាត្រូវទៅកន្លែងណា និងត្រូវធ្វើអ្វី ខ្លះ។
- ផ្តល់សេចក្តីសង្ឃឹម និង ចំណេះដឹងដល់យើង ។
- ជួយយើងទទួលបានទីបន្ទាល់មួយអំពីព្រះយេស៊ូវគ្រីស្ទ ។
- ផ្តល់ការការពារខាងវិញ្ញាណដល់យើង ។

សូមធ្វើឲ្យការអានគម្ពីរជាផ្នែកមួយនៃទម្លាប់ទៀងទាត់របស់អ្នក នោះពរជ័យនឹងមកតាមក្រោយ

ប្រសិនបើអ្នករៀននៅក្នុងព្រះគម្ពីរតាំងពីក្មេង អ្នកនឹងដឹងពីផ្លូវដែលអ្នកគួរដើរ ។ ■

*ដកស្រង់ចេញពី « The Key to Spiritual Protection »* Liahona *ខែ វិច្ឆិកា ឆ្នាំ 2013 ទំព័រ 26–28 ។*

# គ្រឿងសឹកសម្ងាត់



**ដោយ ជេស្ស៊ីកា ឡាសិន**
ផ្អែកទៅលើដំណើររឿងពិតមួយ

« *ឲ្យនូវអ្វីដែលយើងអាចផ្ដល់ឲ្យ* » ( សៀវភៅចម្រៀងកុមារ *ទំព័រ 116* ) ។

« ពុំមែនជាអាយវីនោះទេ ! នាងជា*ក្មេងស្រី* ម្នាក់ » ប្រេឌិន បានខ្សឹបប្រាប់ពីក្រោយខ្នង អ័ដាម ។

តែ អ័ដាម គឺជាប្រធានក្រុមកីឡាបាល់គប់សម្រាប់ថ្ងៃនោះ ហើយគាត់បានធ្វើការជ្រើសរើសរបស់គាត់ ។ គាត់បាននិយាយឮៗម្ដងហើយម្ដងទៀតថា « ខ្ញុំរើសយកអាយវី » ។ ថៃលើ ជាប្រធានក្រុមម្ខាងទៀត បានញញឹមបែបចំអក ។ សូម្បីតែគ្រូបង្វឹកឈ្មោះ ហ្គាសៀយ៉ា ក៏ភ្ញាក់ផ្អើលនឹងការរើសមនុស្សទីពីររបស់អ័ដាមដែរ ។

អាយវី ក៏មានទឹកមុខភ្ញាក់ផ្អើលដែររួចដើរចេញទាំងអៀន ។ ប្រេឌិន បានត្អូញត្អែរ ។

អាយវី មិនដូចជាក្មេងស្រីដទៃទៀតទេ ។ នាងគឺជាក្មេងស្រីមានមាឌល្អិតជាងគេនៅក្នុងថ្នាក់ ។ នាងមើលទៅដូចមិនសូវរហ័សរហួនសោះ ហើយបាល់នោះហាក់ដូចជាធំជាងខ្លួននាងទៅទៀត ។ កាល អាយវី បានដើរមក នោះ ប្រេឌិន បានពោលថា « នាងប្រហែលជាលើកបាល់មិនរួចផងតាមមើលទៅ » ។

ដោយព្យាយាមធ្វើឲ្យភាពជឿជាក់ អ័ដាម បានពោលថា « ប្រហែលជានាងអាចក្លាយគ្រឿងសឹកសម្ងាត់របស់យើងបាន » ។ ប៉ុន្តែនោះពុំមែនជាហេតុផលដែលគាត់បានរើសនាងនោះទេ ។ មានគ្រាមួយ អាយវី ធ្លាប់ប្រាប់ អ័ដាម ថានាងមិនចូលចិត្តលេងកីឡាទេ ដោយសារនាងតែងតែរើសឲ្យលេងក្រោយគេជានិច្ច ។ ពួកក្មេងប្រុសដទៃទៀតបានចំអន់អាយវី ប៉ុន្តែឪពុកម្ដាយរបស់អ័ដាមបានប្រាប់គាត់ថា ក្មេងប្រុសគួរបង្ហាញការគោរពដល់ក្មេងស្រី ។ ដូច្នេះទើបគាត់រើស អាយវី ។ នៅពេលគាត់ឃើញ ថៃលើ រើសក្មេងប្រុសមាឌធំជាងគេក្នុងថ្នាក់ អ័ដាម បានសង្ឃឹមថា គាត់បានធ្វើការសម្រេចចិត្តដ៏ត្រឹមត្រូវ ។

បន្ទាប់ពីមនុស្សគ្រប់គ្នាមានក្រុមរបស់ខ្លួនមក គ្រូបង្វឹក ហ្គាសៀយ៉ាបានផ្លុំកញ្ចែ ហើយក្រុមទាំងពីរបានរត់បែកគ្នាទៅចុងម្ខាងៗនៃទីលានប្រកួត ។ គ្រូបង្វឹក ហ្គាសៀយ៉ា បានហុចបាល់ឲ្យទៅថៃលើ ហើយថៃលើបានសម្លឹងមកមើលក្រុមអ័ដាមពីមុនគាត់សម្លឹងភ្នែកដាក់លើអាយវី ។ គាត់បានយាដៃមកក្រោយ ហើយចោលបាល់ ។

*វ៉ំពេចនោះ !* បាល់នោះបានត្រូវនឹងដី ហើយលោតគ្មានប៉ះនរណាម្នាក់ឡើយ ។ អ័ដាម បានព្រិចភ្នែក ។ អាយវី បានគេចខ្លួនផុតទាន់ពេល ។

រចនារូបភាពដោយ ម៉ាត ស្មីធ



*មនុស្សគ្រប់គ្នាបានមើលស្រាលនូវអ្វីដែល អាយវី អាចធ្វើ ។*

មនុស្សគ្រប់គ្នាជុំវិញគាត់ហាក់ដូចជាភ្ញាក់ផ្អើល ប៉ុន្តែអ័ដាមបានញញឹម ។ ប្រហែលជាការរើសយក អាយវី ពិតជាគំនិតមួយដ៏ល្អ ។

ការប្រកួតនោះបានបន្ត ។ ថៃលើ បានព្យាយាមគប់បាល់ឲ្យចំអាយវី ប៉ុន្តែនាងចេះតែគេចរួចខ្លួនផុតជានិច្ច ។ គ្មាននរណាម្នាក់ចោលបាល់ចំនាងឡើយ ។ ដោយថៃលើ និង មិត្តរួមក្រុមគាត់មួយចំនួនរវល់តែព្យាយាមធ្វើឲ្យអាយវីចេញ នោះពួកគេមិនបានផ្ដោតទៅលើអ្នកផ្សេងទៀតទេ ។ អ័ដាមបានញញឹម — តាមពិតទៅ មាឌរបស់អាយវីបានធ្វើឲ្យការលេងកីឡាបាល់គប់របស់នាងកាន់តែមានភាព *ប្រសើរ* ដោយសារនាងមានមាឌតូច ហើយលឿន នោះពួកគេពិបាកនឹងចោលត្រូវនាងណាស់ ។

នៅទីបំផុត ក្រុមអ័ដាមបានឈ្នះការប្រកួតនោះ ។ ប្រេឌិន បានពោលថា « ពិតជាគ្រឿងសឹកសម្ងាត់មែន » ។ « អាយវីលេងបានល្អណាស់ » ។

ថៃលើ បានពោលថា « មែនហើយ » ។ « លើកក្រោយ នាងនៅក្នុងក្រុម*របស់ខ្ញុំ* ។ យើងនឹងឈ្នះជាពុំខានឡើយ ! » ។ អាយវីបានញញឹមកាលនាងដើរត្រឡប់ទៅថ្នាក់វិញ ដោយមានមិត្តរួមក្រុមទ័ព្ទជុំវិញ ។

អ័ដាមញញឹមមិនឈប់ កាលគាត់បានដើរពីក្រោយក្រុម។ គាត់បានធ្វើល្អចំពោះអាយវី ហើយគាត់បានជួយក្មេងប្រុសដទៃទៀតឲ្យគោរពដល់ក្មេងស្រីបន្ថែមទៀត ។ គ្រឿងសឹកសម្ងាត់ដ៏អស្ចារ្យបំផុតគឺពុំមានអ្វីដែលអស្ចារ្យនោះទេ — វាគ្រាន់តែជាការមានសណ្ដានចិត្តល្អប៉ុណ្ណោះ ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ អារីស្សូណា ស.រ.អា. ។*



**គ្មាននរណាម្នាក់ត្រូវបានកំណត់មកឲ្យបរាជ័យនោះទេ ។**

« មនុស្សគ្រប់រូបមានលក្ខណៈខុសគ្នា ហើយមានការរួមចំណែកដែលត្រូវធ្វើផ្សេងៗពីគ្នា ។ គ្មាននរណាម្នាក់ត្រូវបានកំណត់មកឲ្យបរាជ័យនោះទេ » ។

**ប្រធាន ហិនរី ប៊ី អាវរិង ទីប្រឹក្សាទីមួយក្នុងគណៈប្រធានទីមួយ « Help Them Aim High » *Liahona* ខែ វិច្ឆិកា ឆ្នាំ 2012 ទំព័រ 60**

# ការធ្វើដំណើរមួយដើម្បី រៀនពីព្រះយេស៊ូវគ្រីស្ទ



នៅក្នុងថ្នាក់កុមារឆ្នាំនេះ អ្នកនឹងមានការធ្វើដំណើរមួយយ៉ាងអស្ចារ្យ ដោយដើរតាមដានព្រះបាទារបស់ព្រះយេស៊ូវ ហើយរៀនពីឆាកជីវិតរបស់ទ្រង់នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។ ឪពុកម្ដាយអ្នកនឹងសិក្សាបទគម្ពីរដូចគ្នានៅក្នុងថ្នាក់រៀនរបស់ពួកគាត់ផងដែរ ។

នេះគឺជាសកម្មភាពមួយចំនួនដើម្បីជួយអ្នក និង គ្រួសារអ្នកឲ្យរៀនរួមគ្នាបន្ថែមទៀតពីព្រះគម្ពីរសញ្ញាថ្មី ។

## គំនិតយោបល់សម្រាប់ការពិភាក្សាក្នុងគ្រួសារ

ហេតុអ្វីបានជាវាមានសារៈសំខាន់ ហើយមានចិត្តរំភើបអ្វីម្ល៉េះដើម្បីសិក្សាពីព្រះគម្ពីរសញ្ញាថ្មី ? តើការរៀនបន្ថែមទៀតពីព្រះអង្គសង្គ្រោះនឹងជួយយើងឲ្យកាន់តែមានភាពរឹងមាំបានដោយរបៀបណា ? សូមធ្វើឲ្យប្រាកដថា មនុស្សម្នាក់ៗមានឱកាសដើម្បីចែកចាយ ។ បន្ទាប់មកទៀតអ្នកអាចច្រៀងបទ « សូមប្រាប់ខ្ញុំពីរឿងព្រះយេស៊ូវ » ( *សៀវភៅចម្រៀងកុមារ* ទំព័រ 36 ) ។ អ្នកក៏អាចធ្វើជាប័ណ្ណ ហើយសរសេរឈ្មោះគម្ពីរទាំងឡាយ រួចរៀបវាតាមលំដាប់លំដោយ ។

## ចម្រៀង និង បទព្រះគម្ពីរ

- « សូមប្រាប់ខ្ញុំពីរឿង ព្រះយេស៊ូវ » ( *សៀវភៅចម្រៀងកុមារ* ទំព័រ 36 )
- ម៉ាថាយ 11:29

## ព័ត៌មានជំនួយសម្រាប់ព្រះគម្ពីរ

ការគូសចំណាំក្នុងព្រះគម្ពីររបស់អ្នក អាចជួយអ្នកឲ្យរកឃើញនូវបទគម្ពីរដែលអ្នកចូលចិត្តនៅពេលក្រោយ !

អ្នកអាចប្រើខ្មៅដៃ ប៊ិច ឬខ្មៅដៃផាត់ពណ៌ ។

គូសបន្ទាត់ក្រោមបទគម្ពីរដែលព្រះយេស៊ូវមានបន្ទូល — ឬគ្រាន់តែគូសជារង្វង់នៅត្រង់លេខនៃបទគម្ពីរនោះ ។

រចនារូបភាពដោយ ជេរ៉េដ ម៉ាឡុន

*ឪពុកម្ដាយអ្នកអាចទិញព្រះគម្ពីរប៊ីបមួយក្បាលសម្រាប់អ្នកបាន ។ store.lds.org*

រៀនបន្ថែមទៀត

ម៉ារា និង យ៉ូសែប បានមកទីនេះដើម្បីត្រូវបានរាប់បញ្ចូលដោយរដ្ឋាភិបាល ។

រៀនបន្ថែមទៀត

ស្ដេចហេរ៉ូឌ មានចិត្តច្រណែននឹងព្រះយេស៊ូ ដូច្នេះយ៉ូសែប និង ម៉ារាបាននាំព្រះយេស៊ូមកទីនេះ ដើម្បីឲ្យមានសុវត្ថិភាព ។

រៀនបន្ថែមទៀត

ម៉ាថាយ 2:23

រៀនបន្ថែមទៀត

បន្ទាប់ពីព្រះយេស៊ូវបានប្រសូត ពួកអ្នកគង្វាល និង ពួកហោរា បានមកទីនេះថ្វាយបង្គំទ្រង់ ។

រៀនបន្ថែមទៀត

ម៉ាថាយ 2:14

រៀនបន្ថែមទៀត

យ៉ូសែប និង ម៉ារាបាននាំព្រះយេស៊ូវមកទីនេះកាលពីទ្រង់នៅតូច ហើយបានមកម្ដងទៀតកាលទ្រង់មានវ័យ 12 ឆ្នាំ ។ ទ្រង់បាននៅទីនេះ ហើយបានបង្រៀនដល់មនុស្សជាច្រើននៅក្នុងព្រះវិហារបរិសុទ្ធ ។

រៀនបន្ថែមទៀត

ម៉ាថាយ 2:1

រៀនបន្ថែមទៀត

ម៉ារាបានរស់នៅទីនេះ កាលទេវតាកាព្រីយ៉ែលបានលេចមកប្រាប់នាងថា ព្រះយេស៊ូវនឹងប្រសូតមក ។

រៀនបន្ថែមទៀត

ព្រះវិហារបរិសុទ្ធដែលបានសាងសង់ដោយស្ដេចហេរ៉ូឌ មានទីតាំងនៅក្នុងទីក្រុងធំនេះ ដែលមានរបងព័ទ្ធជុំវិញ ។

រៀនបន្ថែមទៀត

ប្រទេសនេះនៅក្បែរប្រទេសអ៊ីស្រាអែល ។

រៀនបន្ថែមទៀត

កាលព្រះយេស៊ូវនៅក្មេង ទ្រង់បានរស់នៅទីនេះជាមួយម៉ារា និង យ៉ូសែប ។

រៀនបន្ថែមទៀត

លូកា 2:42–49

# ទីកន្លែងដែលព្រះយេស៊ូវបានយាងទៅ

សូមប្ដូរវេនគ្នាជ្រើសយកប័ណ្ណមួយដែលមានពាក្យថា « រៀនបន្ថែមទៀត » ។ សូមអានដំណើររឿងពិត ឬស្វែងរក ហើយអានបទគម្ពីរនោះ ។ រួចដាក់ប័ណ្ណនោះឲ្យត្រូវនឹងទីតាំងនៅលើផែនទី ។




រចនារូបភាពដោយ ស្កត ហ្គ្រា



# រឿងដ៏សំខាន់បំផុតទាំង 10 យ៉ាង របស់អាប់ប៊ី

**ដោយ រ៉ូសម៉ារី អិម វិកសុម**
ប្រធានអង្គការបឋមសិក្សាទូទៅ

« *នេះហើយជាផែនការនៃសេចក្ដីសង្គ្រោះដល់មនុស្សទាំងអស់* » ( *ម៉ូសេ* 6:62 ) ។

មានគ្រាមួយ កាលខ្ញុំបានទៅលេងថ្នាក់យុវនារី គ្រូបង្រៀនបានសុំសិស្សក្នុងថ្នាក់ឲ្យសរសេរពីគោលដដ៏សំខាន់បំផុតទាំង 10 ក្នុងជីវិតរបស់ពួកគេ ។ រួចគាត់បានសុំឲ្យពួកគេចែកចាយពីអ្វីដែលពួកគេបានសរសេរ ។ អ៊ែប៊ី ដែលទើបតែមានអាយុ 12 ឆ្នាំ បានអង្គុយនៅជិតខ្ញុំ ។ នេះគឺជាបញ្ជីរបស់អាប់ប៊ី ៖




អាប់ប៊ី មាននូវទស្សនៈអំពីផែនការដែលព្រះវរបិតាសួគ៌បានរៀបចំសម្រាប់យើងគ្រប់គ្នា ។ នៅពេលអ្នកផ្ដោតទៅលើគោលដៅដ៏សំខាន់បំផុតនៃការត្រឡប់ទៅព្រះវរបិតាសួគ៌វិញ នោះអ្នកនឹងអាចទៅដល់ទីនោះបាន ! ■

*ដកស្រង់ពី « Taking Time to Talk and Listen »* Liahona *ខែ មេសា ឆ្នាំ 2012 ទំព័រ 37 ។*

**បញ្ជីអំពីរឿងដ៏សំខាន់បំផុតទាំង 10 របស់អ្នក**

សូមសរសេរគោលដៅទាំង 10 សម្រាប់ជីវិត*របស់អ្នក* ។ រួចដាក់វានៅក្នុងសៀវភៅកំណត់ហេតុរបស់អ្នក បិទវាលើជញ្ជាំង ឬនៅកន្លែងណាដែលអ្នកមើលឃើញវាជារឿយៗ ។

រចនារូបភាពដោយ ហេថាន អាន់ឌើរសិន

# ព្រះយេស៊ូវកំពុងបង្រៀន នៅក្នុងព្រះវិហារបរិសុទ្ធ លូកា 2:42-47

សូមបិទទំព័រនេះនឹងក្រដាសរឹង ឬក្រដាសការតុង រួចកាត់រូបនោះចេញ ហើយបិទវាទៅនឹងបន្ទះឈើ ឬថង់ក្រដាស ។ ដាក់វានៅក្នុងស្រោមសំបុត្រមួយដោយមានសរសេរសេចក្ដីយោងបទគម្ពីរនៅផ្នែកខាងមុខនៃស្រោមសំបុត្រ ។ ■

*អ្នកអាចបោះពុម្ពវាច្រើនច្បាប់បន្ថែមទៀតនៅ liahona.lds.org ។*




រចនារូបភាព ដោយ បេស អិម វាយថេកឃើរ

# ការអធិស្ឋាននៅលើ

ដោយ មិតស្សី ដីមេណេស្ស រ៉ាមិរេស្ស
ផ្អែកទៅលើដំណើររឿងពិតមួយ

សូហ្វីយ៉ា មានអាយុជិតប្រាំបីឆ្នាំហើយ ។ នាងកំពុងតែរៀបចំខ្លួនទទួលពិធីបុណ្យជ្រមុជទឹក ។ នាងកំពុងរៀនពីរឿងសំខាន់ៗជាច្រើន ។ រឿងមួយដែលនាងបានរៀនគឺអំពីការអធិស្ឋាន ។ នាងបានដឹងថា នាងអាចអធិស្ឋានទៅព្រះវរបិតាសួគ៌គ្រប់ពេល ។ នាងបានដឹងថា នាងអាចអធិស្ឋាននៅគ្រប់ទីកន្លែង ។

ថ្ងៃមួយ សូហ្វីយ៉ា និង ម្ដាយនាងបានសម្រេចចិត្តទៅលេងឪពុកនាងនៅឯកន្លែងធ្វើការរបស់គាត់ ។ វាតម្រូវឲ្យមានការធ្វើដំណើរមួយយ៉ាងវែង ។ ឪពុកនាងបានធ្វើការនៅក្រុងមួយទៀត ។ ពួកគេត្រូវជិះរថយន្តក្រុង រួចជិះរថយន្តដឹកទំនិញ បន្ទាប់មកទៀតជិះរថយន្តតាក់ស៊ី ។

ពេលកំពុងជិះក្នុងរថយន្តក្រុង សូហ្វីយ៉ា បានដេកលក់ ។ ពេលនាងបានឮសំឡេងកូនង៉ែតយំ នាងក៏ភ្ញាក់ឡើង ។ មានស្វាមីភរិយាមួយគូដែលមានកូនតូចជិះក្នុងរថយន្តក្រុងនោះដែរ ។ កូនតូចនោះឈឺហើយស្រែកយំយ៉ាងខ្លាំង ។ ឪពុកម្ដាយរបស់កូនតូចនោះមានទឹកមុខព្រួយបារម្ភ ។

សូហ្វីយ៉ា មានចិត្តអាណិតអាសូរដល់កូនតូចនោះ ។ នាងក៏មានចិត្តអាណិតអាសូរដល់ឪពុកម្ដាយរបស់កូនតូចនោះផងដែរ ។ រួចនាងបាននឹកឃើញគំនិតមួយ ។ នាង

រូបភាពគូរដោយ ដានី ម៉ាគី



# រថយន្តក្រុង

បានខ្សឹបដាក់ត្រចៀកម្ដាយនាង ។ នាងបានខ្សឹបថា « តើកូនអាចធ្វើការអធិស្ឋានសូមឲ្យព្រះវរបិតាសួគ៌ប្រទានពរដល់កូនតូចនោះបានដែរឬទេ ? »

ម្ដាយបានតបទាំងញញឹមថា « ពិតជាបាន » ។

សូហ្វីយ៉ា ឱនក្បាលធ្វើការអធិស្ឋានដោយស្ងៀមស្ងាត់ ។ នាងបានខិតខំអធិស្ឋាន ។ នាងបានសូមព្រះវរបិតាសួគ៌ឲ្យប្រទានពរដល់កូនតូចនោះ ។ នាងបានសូមទ្រង់ជួយឲ្យកូនតូចធូរស្បើយ ហើយឈប់យំ ។

សូហ្វីយ៉ា បានដឹងថា យើងមិនអាចទទួលបានអ្វីដែលយើងបានអធិស្ឋានសូមជានិច្ចនោះទេ ។ នាងក៏បានដឹងផងដែរថា ការអធិស្ឋានរបស់យើងនឹងទទួលបានចម្លើយភ្លាមៗជានិច្ចនោះទេ ។ ប៉ុន្តែក្នុងរយៈពេលដ៏ខ្លី កូនតូចនោះបានស្រួលអារម្មណ៍បន្តិច ។ រួចកូនតូចនោះបានឈប់យំ ។ នាងហាក់ដូចជាបានធូរស្បើយ ។ ឪពុកម្ដាយនាងមានទឹកមុខមិនសូវបារម្ភខ្លាំងទេ ។

សូហ្វីយ៉ា មានចិត្តកក់ក្ដៅ ហើយរីករាយ ។ នាងមានចិត្តរីករាយចំពោះកូនតូចនោះ — និងឪពុកម្ដាយរបស់វា ។ នាងបានដឹងថា ព្រះវរបិតាសួគ៌បានឮការអធិស្ឋាននាង ។ ■

*អ្នកនិពន្ធរស់នៅប្រទេសម៉ិកស៊ិក ។*





ដោយប្រធាន
ហារ៉ូល ប៊ី លី
( 1899–1973 )

# តើខ្ញុំអាចដឹងថា ព្រះអម្ចាស់បានអត់ទោសឲ្យខ្ញុំតាមរបៀបណា ?

*តើអ្នកនឹងឆ្លើយតបចំពោះមនុស្សម្នាក់ដែលមកសួរអ្នកនៅសំណួរនោះតាមរបៀបណា ?*

ជាយូរយារមកហើយ ប្រធាន [ ម៉ារុន ជី ] រ៉ូមនី [ 1897–1988 ] និង ខ្ញុំបានអង្គុយនៅក្នុងការិយាល័យរបស់ខ្ញុំ ។ ទ្វារបានបើកឡើង ហើយមានយុវជនដ៏ប្រពៃម្នាក់បានដើរចូលមកដោយមានទឹកមុខសោកសៅ ហើយគាត់បាននិយាយថា « បងប្អូនប្រុស ខ្ញុំនឹងទៅព្រះវិហារបរិសុទ្ធជាលើកដំបូងនៅថ្ងៃស្អែក ។ ខ្ញុំបានធ្វើកំហុសមួយចំនួនកាលពីអតីតកាល ហើយខ្ញុំបានធ្លាប់ទៅជួបនឹងប៊ីស្សព និង ប្រធានស្តេករបស់ខ្ញុំ ហើយខ្ញុំបានសារភាពវាទាំងអស់ ហើយក្រោយពីការប្រែចិត្ត និងការបញ្ជាក់មួយរយៈពេលមក ដើម្បីប្រាកដថាខ្ញុំមិនត្រឡប់ទៅធ្វើកំហុសទាំងនោះម្តងទៀត ឥឡូវនេះពួកគាត់បានប្រកាសថា ខ្ញុំអាចទៅព្រះវិហារបរិសុទ្ធបានហើយ ។ ប៉ុន្តែ បងប្អូនប្រុស ការណ៍នោះវាមិនទាន់គ្រប់គ្រាន់នៅឡើយទេ ។ ខ្ញុំចង់ដឹង ហើយថា តើខ្ញុំអាចដឹងតាមរបៀបណាបានថា ព្រះអម្ចាស់ក៏បានអត់ទោសឲ្យខ្ញុំហើយផងដែរ » ។

តើអ្នកនឹងឆ្លើយចំពោះជនម្នាក់ដែលមកសួរអ្នកនូវសំណួរនោះតាមរបៀបណា ? កាលយើងបានសញ្ជឹងគិតមួយភ្លែត យើងបាននឹកចាំពីសុន្ទរកថារបស់ស្តេចបេនយ៉ាមីននៅក្នុងព្រះគម្ពីរម៉ូសាយ ។ ឥឡូវនេះ នេះគឺជាមនុស្សមួយក្រុមដែលចង់បាន



ពិធីបុណ្យជ្រមុជទឹក ហើយពួកគេបាននិយាយថា ពួកគេបានមើលឃើញខ្លួនឯងនៅក្នុងស្ថានភាពខាងរូបកាយរបស់ពួកគេ ៖

« ហើយពួកគេទាំងអស់គ្នាបានស្រែកព្រមគ្នាដោយសំឡេងតែមួយថា ៖ ឱសូមមេត្តាផង ហើយសូមប្រទាននូវព្រះលោហិតដ៏ធួននៃព្រះគ្រីស្ទ ដើម្បីឲ្យយើងអាចបានទទួលនូវការអភ័យទោសចំពោះអំពើបាបទាំងឡាយរបស់យើង ហើយដើម្បីឲ្យចិត្តយើងអាចបានជ្រះបរិសុទ្ធផងចុះ ។ . . .

« . . . បន្ទាប់ពីពួកគេបានពោលពាក្យទាំងនេះហើយ នោះព្រះវិញ្ញាណនៃព្រះអម្ចាស់ក៏បានចុះមកសណ្ឋិតលើពួកគេ ហើយពួកគេក៏ពោរពេញទៅដោយសេចក្តីអំណរ ដោយបានទទួលការផ្តាច់បាបទាំងឡាយរបស់គេ ហើយដោយមានសេចក្តីសុខសាន្តក្នុងសតិសម្បជញ្ញៈ » ( ម៉ូសាយ 4:2–3 ) ។

មាននូវចម្លើយ ។

ប្រសិនបើពេលនោះមកដល់ នៅពេលអ្នកបានធ្វើនូវអ្វីៗទាំងអស់ដែលអ្នកអាចធ្វើដើម្បីប្រែចិត្តចេញពីអំពើបាបរបស់អ្នក មិនថាអ្នកជានរណា អ្នកនៅកន្លែងណា ហើយបានធ្វើការសងថ្លៃ និង ការផ្តុំសងវិញអស់ពីសមត្ថភាពរបស់អ្នក ប្រសិនបើវាជាអ្វីមួយដែលប៉ះពាល់ដល់សមាជិកភាពរបស់អ្នកនៅក្នុងសាសនាចក្រ ហើយអ្នកបានទៅរកអ្នកមានសិទ្ធិអំណាចត្រឹមត្រូវ បន្ទាប់មកអ្នកនឹងចង់បានចម្លើយនៃការបញ្ជាក់នោះ ថាតើព្រះអម្ចាស់បានទទួលយកអ្នកហើយឬនៅ ។ នៅក្នុងការស្វែងរកវិញ្ញាណរបស់អ្នក ប្រសិនបើអ្នកស្វែងរក ហើយអ្នករកឃើញសេចក្តីសុខសាន្តក្នុងសតិសម្បជញ្ញៈនោះ តាមរបៀបនោះហើយដែលអាចដឹងថាព្រះអម្ចាស់បានទទួលយកការប្រែចិត្តរបស់អ្នកហើយ ។ សាតាំងនឹងធ្វើឲ្យអ្នកបែរចិត្តគំនិតផ្សេងពីនោះ ហើយពេលខ្លះវាញុះញង់ឲ្យអ្នកគិតថាឥឡូវនេះដោយសារអ្នកធ្វើបានធ្វើកំហុសមួយហើយនោះអ្នកអាចនឹងធ្វើបន្ត ធ្វើម្តងហើយម្តងទៀតដោយគ្មានការត្រឡប់មកវិញបានទេ ។ នេះគឺជាការកុហកដ៏ធំមួយ ។ អព្ភូតហេតុនៃការអត់ទោសគឺមានចំពោះមនុស្សគ្រប់គ្នាដែលងាកចេញពីការធ្វើអាក្រក់ហើយមិនត្រឡប់ទៅធ្វើវាទៀតឡើយ ។ ■

*ដកស្រង់ពី « Stand Ye in Holy Places » Ensign ខែកក្កដា ឆ្នាំ 1973 ទំព័រ 122 ។*

# ការយល់ដឹង




**តើខ្ញុំអាចរកឃើញសេចក្ដីអំណរ កាលជីវិតខ្ញុំជួបនឹងគ្រាដ៏លំបាកបានដោយរបៀបណា ?**

« មានអ្វីៗជាច្រើននៅក្នុងជីវិតនេះគឺពឹងផ្អែកទៅលើឥរិយាបថរបស់យើង ។ របៀបដែលយើងជ្រើសរើសដើម្បីមើលអ្វីៗ និង ឆ្លើយតបចំពោះអ្នកដទៃ ធ្វើឲ្យកើតមានការផ្លាស់ប្ដូរទាំងអស់នោះ ។ ការធ្វើឲ្យអស់ពីសមត្ថភាពរបស់យើង ហើយបន្ទាប់មកជ្រើសរើសមានភាពសប្បាយរីករាយចំពោះកាលៈទេសៈទាំងឡាយរបស់យើង មិនថាវាជាអ្វីក៏ដោយ នោះវាអាចនាំមកនូវសន្តិភាព និង ការសប្បាយចិត្ត » ។

**ប្រធានថូម៉ាស អេស ម៉នសុន** « Living the Abundant Life » *Liahona* ខែ មករា ឆ្នាំ 2012 ទំព័រ 4 ។

# កំមាននៅក្នុងច្បាប់នេះផងដែរ

## សម្រាប់យុវមជ្ឈិមវ័យ

### ប្រឹក្សា រួមគ្នាជារឿយៗ

សូមប្រើគោលការណ៍ទាំងប្រាំមួយដើម្បីមានក្រុមប្រឹក្សាគ្រួសារដ៏មានជោគជ័យ ។



ទំព័រ 42

## សម្រាប់យុវវ័យ

ទំព័រ 48



### បាវចនាម្ចាស់ឆ្នាំ 2015

គណៈប្រធានយុវនារី និង យុវជនទូទៅបានបង្រៀនពី គោលលទ្ធិ និង សេចក្ដីសញ្ញា 4:2 ។

## សម្រាប់កុមារ

### ការសាកល្បងតម្រិះក្នុងព្រះគម្ពីរ សម្រាប់ព្រះគម្ពីរសញ្ញាថ្មី

សូមប្រើសកម្មភាពផាត់ពណ៌នេះ នៅពេលអ្នកអានបទគម្ពីរទាំងនេះនៅក្នុងព្រះគម្ពីរសញ្ញាថ្មីសម្រាប់ឆ្នាំនេះ ។



ទំព័រ 66

4 02125 61258 6
CAMBODIAN

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ